ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

# និន្នាការអប់រំ និងពលរដ្ឋសកល




បណ្ឌិត គួយ សុគាន

ឆ្នាំសិក្សា២០២៣-២០២៤

# អារម្ភកថា

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១(២០២៣-២០២៨) បានកំណត់នូវមុំទី១ ស្តីអំពីការអភិវឌ្ឍមូលធនមនុស្សជាចំណុចអាទិភាពក្នុងនោះរួមមាន (១)ពង្រឹងគុណវិស័យអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(២)បណ្តុះបណ្តាលជំនាញបច្ចេកទេស(៣)លើកកម្ពស់សុខភាព និងសុខុមាលភាព(៤) ពង្រឹងប្រព័ន្ធគាំពារសង្គម និង(៥)ពង្រឹងភាពជាពលរដ្ឋសកលក្នុងសង្គម ដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍ២០៥០។

ក្រសួងអប់រំយុវជន និងកីឡាបានកំណត់នូវចក្ខុវិស័យប្រព័ន្ធអប់រំកម្ពុជា២០៣០ គឺកសាងប្រព័ន្ធអប់រំមួយមានភាពធន់ រឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងសង្គមពុទ្ធិ និងបានកំណត់គោលដៅអប់រំជាតិដូចជាបណ្តុះមនសិកាស្នេហាជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិតាមរយៈការលើកកម្ពស់គំនិតហេតុផល គុណតម្លៃ និងការគិតស៊ីជម្រៅប្រកបដោយគំនិតច្នៃប្រឌិត បង្កើតនូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សាស្រាវជ្រាវឱ្យទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី ផលិតធនធានមនុស្សឱ្យមានចំណេះដឹង បំណិន ជំនាញ សមត្ថភាព និងសីលធម៌ ចរិយាធម៌ស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយពិពិធភាពអាចប្រកួតប្រជែងក្នុងតំបន់ និងសកលលោកព្រមទាំងរៀបចំយន្តការសិក្សាពេញមួយជីវិត ដើម្បីឱ្យមនុស្សមានទំនាក់ទំនងជាប្រចាំជាមួយគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមកព្រមទាំងអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់នៅក្នុងសហគមន៍ សង្គមជាតិ និងបណ្តុះបណ្តាលបានភាពជាពលរដ្ឋសកលកសាងនូវពិភពលោកមួយឱ្យប្រកាន់ភ្ជាប់សុខសន្តិភាព និងអភិវឌ្ឍប្រកបដោយចីរភាព។

ដូចនេះវិស័យអប់រំបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍមូលធនមនុស្សឱ្យមានចំណេះដឹង និងភាពច្នៃប្រឌិត ការស្រាវជ្រាវ ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ជួយបង្កើនកំណើនសេដ្ឋកិច្ច និងបរិយាបន្នតាមរយៈការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ក្នុងន័យនេះ មុខវិជ្ជានិន្នាការអប់រំ និងពលរដ្ឋសកលបានរួមចំណែកបណ្តុះបណ្តាលគរុនិស្សិតបរិញ្ញាបត្រ+២ ទទួលបាននូវការអប់រំមួយប្រកបដោយគុណភាព សមធម៌ បរិយាបន្ន បំណិនឌីជីថល និងការអប់រំពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព បង្កើនការងារស្របតាមយុគសម័យបច្ចេកវិទ្យា និងរួមចំណែកអនុវត្តស្តង់ដាសាលារៀនគំរូ ។

ថ្ងៃអង្គារ១២កើត ខែពិសាខ ឆ្នាំខាល បញ្ចស័កព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣

បណ្ឌិត គួយ សូគាន

# មាតិកា


អារម្ភកថា ........................................................................................................២
មាតិកា ...............................................................................................................៣

## មេរៀនទី១៖ ការអប់រំពលរដ្ឋសកល និងការអប់រំពលរដ្ឋពេញលេញ

១-១-វត្ថុបំណងមេរៀន ...........................................................................................៧
១-២-សេចក្តីផ្តើម .................................................................................................៧
១-៣-ការអប់រំពលរដ្ឋសកល ......................................................................................៩
ក-បញ្ញត្តិការអប់រំពលរដ្ឋសកល ...............................................................................៩
ខ-ប្រវត្តិនៃការអប់រំពលរដ្ឋសកល .............................................................................១១
គ-បញ្ហាសមធម៌យែនឌ័រ និងសិទ្ធិមនុស្ស .................................................................១២
ឃ-ការស្វែងយល់អំពីសហគមន៍សង្គមវប្បធម៌អាស៊ាន ..................................................១៤
ង-ការស្វែងយល់អំពីសុខដុមនីយកម្មសាសនាក្នុងប្រទេសកម្ពុជា ....................................១៦
ច-ក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ..............................................................១៨
១.៤.ការអប់រំពលរដ្ឋពេញលេញ ................................................................................២០
ក-បញ្ញត្តិពលរដ្ឋពេញលេញ ...................................................................................២០
ខ-បរិបទនៃអប់រំពលរដ្ឋពេញលេញក្នុងសង្គមកម្ពុជា ..................................................២២
គ-ក្របខណ្ឌកម្មសិក្សាឆ្នាំ២០១៦ .............................................................................២៣
ឃ-គោលបំណងនៃកម្មវិធីសិក្សា ...............................................................................២៤
១.៥.ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន .....................................................................២៦
១.៦.កិច្ចតែងការបង្រៀនបញ្ជ្រាបខ្លឹមសារពលរដ្ឋសកល .................................................២៧

## មេរៀនទី២៖ ផែនទីបង្ហាញផ្លូវនៃការអប់រំកម្ពុជានៅឆ្នាំ២០៣០

២-១-វត្ថុបំណងមេរៀន...........................................................................................៣២
២-២-សេចក្តីផ្តើម .................................................................................................៣២
២.៣.សសរស្តម្ភទាំង៥នៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ..............៣៤
២-៣-១-សសរស្តម្ភទី១ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តជាតិ .............................៣៦
២-៣-២-សសរស្តម្ភទី២ ការអប់រំ ដើម្បីកសាងមូលធនបញ្ញាផ្នែកធនធានមនុស្ស..................៣៦
២-៣-៣-សសរស្តម្ភទី៣ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាព ................................៤០
២-៣-៤-សសរស្តម្ភទី៤ បង្កើនកិច្ចសហការ និងបណ្តាញក្នុងចំណោមតួអង្គពាក់ព័ន្ធ.............៤១

២-៣-៥-សសរស្តម្ភទី៥ ការជំរុញប្រព័ន្ធអេកូឡូស៊ី បង្កបរិយាកាសដល់ការកសាងសមត្ថភាព ........៤២
២-៤-បង្កើតទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍........................................៤៣
២.៥.ផែនទីបង្ហាញផ្លូវវិស័យអប់រំនៅមធ្យមសិក្សាសម្រាប់ឆ្នាំ២០៣០ ..........................៤៣
ក-សាវតារនៃការរៀបចំឯកសារផែនទីបង្ហាញផ្លូវ ..................................................៤៤
ខ-ការរៀបចំផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ .........................៤៦
គ-ផែនការសកម្មភាពនៃផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ ..............៤៧
២-៥-១-បង្កើនការចូលរៀន និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ................៤៨
២-៥-២-បន្តយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ ..............៥០
២-៥-៣.រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃឱ្យស្របតាមការអប់រំ ................៥២
២-៥-៤.បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា...........................៥៣
២-៥-៥-អនុវត្តគោលនយោបាយគ្រូបង្រៀនមានលក្ខណៈគ្រប់ជ្រុងជ្រោយ.......................៥៥
២-៥-៦.បន្តយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធបណ្តុះបណ្តាល ...........................៥៦
២-៦-៧.ធ្វើពិពិធកម្ម ពង្រីកលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេស .....................៥៧
២-៥-៨.បង្កើនការសហការនៃការអប់រំកម្រិតមធ្យមសិក្សា ......................................៥៨

## មេរៀនទី៣៖ កំណែទម្រង់វិស័យអប់រំនៅប្រទេសកម្ពុជា

៣-១-វត្ថុបំណងមេរៀន.........................................................................៦០
៣-២-សេចក្តីផ្តើម ..............................................................................៦០
៣.៣.ការអនុវត្តគោលនយោបាយអប់រំស្តីពីគ្រូបង្រៀន ..........................................៦១
៣-៤-កំណែទម្រង់ស៊ីជម្រៅវិស័យអប់រំចាប់ពីឆ្នាំ២០១៣ .......................................៦៤
៣-៤-១-កំណែទម្រង់ថ្នាក់ជាតិ(២០១៣) ............................................................៦៤
៣-៤-២-កំណែទម្រង់កម្រិតសាលារៀន(២០១៥-២០១៨)..........................................៦៦
៣-៤-៣-កំណែទម្រង់ដំណាក់កាលទី៣(២០១៨-២០២៣) ..........................................៧០
៣-៤-៤-កំណែទម្រង់ដំណាក់កាលទី៤(២០២៣តទៅ) ...............................................៧២

## មេរៀនទី៤៖ និន្នាការរំលើបកម្មនៃការបង្រៀន និងរៀន

៤-១-វត្ថុបំណងមេរៀន ...........................................................................៨០
៤-២-សេចក្តីផ្តើម ..................................................................................៨០
៤.៣-រចនាសម្ព័ន្ធ និងដំណើរការនៃចំណេះដឹង .................................................៨១
៤-៣-១-រចនាសម្ព័ន្ធចំណេះដឹង ..................................................................៨១

៤-៣-២-កម្រិតចំណេះដឹងតាមទ្រឹស្តីប្លូម ……………………………………………….៨៤
៤.៤.ការស្ថាបនាចំណេះដឹង និងការផ្ទេរចំណេះដឹង ……………………………….៨៥
៤-៤-១-ការស្ថាបនាចំណេះដឹង ……………………………………………………….៨៥
៤-៤-២-ការផ្ទេរចំណេះដឹង ……………………………………………………………..៩០

## មេរៀនទី៥៖ ការអប់រំបំណិនឌីជីថល

៥-១-វត្ថុបំណងមេរៀន ……………………………………………………………..៩២
៥-២-សេចក្តីផ្តើម ……………………………………………………………………..៩២
៥.៣.ការអប់រំនៅសតវត្សរ៍ទី២១ ……………………………………………………..៩២
៥-៣-១-ការគិតត្រិះរិះពិចារណា ……………………………………………………..៩៥
៥-៣-២-គំនិតច្នៃប្រឌិត និងនវានុវត្តន៍ …………………………………………….៩៨
៥-៣-៣-បំណិនទំនាក់ទំនង ………………………………………………………..១០១
៥-៣-៤-កិច្ចសហប្រតិបត្តិការ ……………………………………………………..១០៩
៥.៤.ភាពចម្រុះនៃការរៀន និងបង្រៀន ……………………………………………..១១២
៥-៤-១-បញ្ញត្តិភាពចម្រុះនៃការរៀន និងបង្រៀន …………………………………..១១២
៥-៤-២-ការរៀនពីចម្ងាយក្នុងបរិបទកូវីដ-១៩ ……………………………………..១១៤
៤-៤-៣-ប្រភេទនៃការរៀនបែបចម្រុះ………………………………………………..១១៥
៤-៤-៤-គោលបំណងនៃការរៀនតាមបែបចម្រុះ ……………………………………..១១៦
៤-៤-៥-យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំតាមបែបឌីជីថល ………………………..១១៧
៥.៥.ភាពច្នៃប្រឌិតនៃយុទ្ធសាស្ត្រក្នុងការរៀន និងបង្រៀន …………………………..១១៨
៥.៦-ទំនើបកម្មនៃការផ្ទេរចំណេះដឹងក្នុងយុគសម័យបច្ចេកវិទ្យា…………………….១២១

## មេរៀនទី៦៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

៦-១-វត្ថុបំណងមេរៀន…………………………………………………………….១៣០
៦-២-សេចក្តីផ្តើម ……………………………………………………………………..១៣០
៦.៣.ការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ………………………………………………..១៣១
៦-៣.១.ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ ……………………………………………..១៣៣
៦.៣.២ ប្រព័ន្ធគាំទ្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ……………………………………..១៣៤
៦.៤.សហគមន៍សិក្សាវិជ្ជាជីវៈគ្រូមធ្យមសិក្សា ……………………………………..១៣៦
៦.៥.សកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈ ……………………………………………..១៣៨

៦.៦.សហគមន៍សិក្សាវិជាជីវៈសម្រាប់គ្រូវិទ្យាល័យ និងអនុវិទ្យាល័យ ..........................១៤១
៦-៧-ប្រព័ន្ធគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ ..........................................................១៤៤
**មេរៀនទី៧៖ កិច្ចសហប្រតិបត្តិការរវាងសាលារៀន គ្រួសារ និងសហគមន៍**
៧-១-វត្ថុបំណងមេរៀន ..........................................................................១៥១
៧-២-សេចក្តីផ្តើម ..........................................................................................១៥១
៧.៣.ទំនាក់ទំនងរវាងសាលារៀន គ្រួសារ និងសហគមន៍ ......................................១៥២
៧.៤.តួនាទីគ្រូបង្រៀន និងកិច្ចគាំទ្រការសិក្សាក្នុងសហគមន៍ ..................................១៥៤
៧.៥.ការអប់រំតាមផ្ទះក្នុងយុគសម័យឌីជីថល....................................................១៥៨
៧.៦.ការសិក្សាតាមអនឡាញ និងអំណានតាមឌីជីថល ..........................................១៥៩
ទស្សនៈសំខាន់ៗស្តីពីការអប់រំ ....................................................................១៦០
ឯកសារយោង ..........................................................................................១៦៤

## មេរៀនទី១៖ ការអប់រំពលរដ្ឋសកល និងការអប់រំពលរដ្ឋពេញលេញ

### ១-១-វត្ថុបំណងមេរៀន

### ក-វិជ្ជាសម្បទា

- ប្រាប់បានពីអត្ថន័យនៃការអប់រំពលរដ្ឋសកល និងលក្ខណសម្បត្តិនៃពលរដ្ឋសកល និងពលរដ្ឋពេញលេញ និងសារៈសំខាន់នៃការអប់រំពលរដ្ឋសកល និងការអប់រំពលរដ្ឋពេញលេញបានច្បាស់លាស់តាមរយៈអានអត្ថបទមេរៀន

**ខ-បំណិនសម្បទា**

- វិភាគបានពីសារប្រយោជន៍នៃការអប់រំពលរដ្ឋសកល និងការអប់រំពលរដ្ឋពេញលេញតាមរយៈការពិភាក្សាក្រុម

**គ-ចរិយាសម្បទា**

- ចូលរួមក្នុងការអប់រំពលរដ្ឋសកល និងពលរដ្ឋពេញលេញនៅតាមសាលារៀនចំណោះទូទៅក៏ដូចជាក្នុងសហគមន៍។

**១-២-សេចក្ដីផ្ដើម**

បន្ទាប់ពីសង្គ្រាមត្រជាក់បានដួលរលំការប្រែប្រួលដ៏ជ្រាលជ្រៅនៃតុល្យការកម្លាំងពហុប៉ូល[1] និងការលេចឡើងនូវតួអង្គថ្មីៗ ដែលបណ្ដាលឱ្យមានបញ្ហាប្រឈម និងសមរភូមិភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អន្តោប្រវេសន៍ខុសច្បាប់ គ្រោះមហន្តរាយ ការប្រែប្រួលធាតុអាកាស ជំងឺឆ្លងផ្សេងៗ និងបានជំរុញឱ្យស្ថានភាពពិភពលោកមានភាពច្របូកច្របល់ និងបង្កើតជាទំនាស់ជំនឿសាសនា ការរើសអើងពូជសាសន៍ ពណ៌សម្បុរ នយោបាយ អំពើហិង្សាក្នុងសង្គម ព្រមទាំងទំនាស់ភូមិសាស្ត្រនយោបាយ។ ស្ថានការណ៍ពិភពលោកមានការប្រែប្រួលលូតលាស់ផ្នែកបច្ចេកវិទ្យាព័ត៌មាន មានលក្ខណៈសម្បូរបែបព័ត៌មានក្នុងពិភពលោក ទើបតម្រូវឱ្យប្រជាជាតិនីមួយៗមានទំនួលខុសត្រូវខ្ពស់ដោយផ្អែកលើការយល់ដឹងអំពីអត្តសញ្ញាណជាតិ វប្បធម៌ ភូមិសាស្ត្រ និងអំបូរជាតិសាសន៍ឱ្យកាន់តែរឹងមាំ និងបង្កើនភាពប្រាស័យទាក់ទងគ្នាកាន់តែល្អប្រសើរក្នុងដំណាក់កាលនៃសកលភាវូបនីយកម្មវប្បធម៌ សេដ្ឋកិច្ច នយោបាយតាមរយៈការអប់រំភាពពលរដ្ឋសកល។

ការអប់រំក្នុងពិភពសកលភាវូបនីយកម្មកំពុងតែមានឥទ្ធិពលយ៉ាងខ្លាំងលើគុណតម្លៃ អាកប្បកិរិយា ជំនាញទំនាក់ទំនង ដើម្បីបំពេញបន្ថែមលើចំណេះដឹង និងជំនាញនៃការត្រិះរិះពិចារណា។ សហគមន៍អប់រំ

---

[1] សង្គ្រាមត្រជាក់មានប៉ូល២គឺសហភាពសូវៀត និងសហរដ្ឋអាមេរិករហូតដល់សវត្សរ៍ទី២១គឺមានប៉ូលសាធារណរដ្ឋប្រជាមានិត(រស់ ចន្ទ្រាបុត្រ,កម្ពុជាក្នុងយុទ្ធសាស្ត្រមហាអំណាច ឆ្នាំ២៩២៣,ទំ.៦)។

កំពុងបង្កើនការយកចិត្តទុកដាក់លើការអប់រំនៃការយល់ដឹង និងដំណោះស្រាយបញ្ហាសង្គម នយោបាយ និងអប់រំគាំទ្រសន្តិភាព សិទ្ធិមនុស្ស សមធម៌ ការទទួលយកភាពចម្រុះវប្បធម៌ និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងពិភពលោក[2]។ ដូចនេះ ការអប់រំភាពជាពលរដ្ឋសកល និងពលរដ្ឋពេញលេញពិតជាមានសារៈសំខាន់ជួយបណ្តុះបណ្តាលធនធានមនុស្សឱ្យទទួលបាននូវចំណេះដឹង(Knowledge) បំណិនវិជ្ជាជីវៈ(Skills) គុណតម្លៃ(Values) ឥរិយាបថ(Attitudes)ដល់ពលរដ្ឋគ្រប់រូបប្រកបដោយសមធម៌ ដើម្បីបង្កើននូវនិរន្តរភាពសម្រាប់ការរស់នៅក្នុងពេលអនាគត ហើយរួមគ្នាកសាងពិភពលោកមួយប្រកបដោយសន្តិភាព គ្មានអំពើហិង្សា។ ការអប់រំអំពីភាពជាពលរដ្ឋសកល បានជួយឱ្យអ្នកសិក្សាយល់ច្បាស់ពីបញ្ហានានា និងការលើកទឹកចិត្តឱ្យអ្នកសិក្សាចូលរួមស្វែងរកឫសគល់នៃបញ្ហាទាំងនោះ ដើម្បីឈានទៅរកការអភិវឌ្ឍជាវិជ្ជមាននៅក្នុងសង្គម។ ការអប់រំអំពីភាពជាពលរដ្ឋសកល មានគោលបំណងជំរុញអ្នកសិក្សាឱ្យក្លាយជាភ្នាក់ងារនៃការអភិវឌ្ឍសង្គម ដោយការលើកកម្ពស់ចំណេះដឹង ជំនាញ និងបទពិសោធ ព្រមទាំងការផ្លាស់ប្តូរជាវិជ្ជមាននូវអាកប្បកិរិយា ឬទម្លាប់មិនល្អនាពេលកន្លងមក។

ជាមួយគ្នានេះ ទស្សនវិទូល្បីៗមួយចំនួនដូចជា សូក្រាត ប្លាតុង អារីស្តូត ខុងជឺ បានឱ្យតម្លៃទៅលើការអប់រំមនុស្សសំខាន់ជាងអ្វីផ្សេងទៀត ដើម្បីប្រែក្លាយមនុស្សអំពីភាពអវិជ្ជា ល្ងង់ខ្លៅទៅជាពលរដ្ឋដ៏ល្អម្នាក់ក្នុងសង្គម។ ការអប់រំគឺជាកត្តាសំខាន់មួយសម្រាប់ភាពជាពលរដ្ឋសកល ដើម្បីផលប្រយោជន៍មនុស្សជាតិ ប្រព្រឹត្តតែអ្វីជាតម្លៃពលរដ្ឋដោយមិនគិតអំពីការរើសអើងពូជសាសន៍ សាសនាក្នុងសង្គម។ ការអប់រំមនុស្សគឺជាជំហានដ៏សំខាន់ផ្តោតអំពីលក្ខណសម្បត្តិរបស់មនុស្ស និងជំរុញឱ្យមនុស្សមានតម្លៃសីលធម៌ថ្លៃថ្នូរ ឧត្តមគតិស្នេហាជាតិ ជាមនុស្សមានមនោគតិបរិសុទ្ធ និងជួយអ្នកដទៃក្នុងសង្គម។ ជាមួយគ្នានេះ ការអប់រំបានធ្វើសង្គមមានសោភណភាព សេចក្តីថ្លៃថ្នូរ សីលធម៌ យុត្តិធម៌ ប្រជាធិបតេយ្យសេរីភាព និងជាសង្គមស៊ីវិល័យ[3]។ លោក **ថេអូដរ រូស្វែលត៍** (Theodore Roosevelt)លើកឡើងថា គ្រប់សង្គមទាំងអស់បានខិតខំអប់រំយុវជនរបស់ខ្លួនឱ្យក្លាយជាពលរដ្ឋល្អ ហើយជាលទ្ធផលទ្រឹស្តីជាច្រើនបានប្រែក្លាយមនុស្សជាចរិតល្អ។ភាពជាពលរដ្ឋល្អទាមទារនូវសមិទ្ធផលបញ្ញា ដើម្បីការយល់ដឹងរួមលើបញ្ហានយោបាយ តុល្យភាពនៃសេរីភាព សមភាព និងការប្រព្រឹត្តចំពោះអ្នកដទៃដោយភាពថ្លៃថ្នូរ។

សេចក្តីថ្លែងការណ៍រួមនៃអង្គការសហប្រជាជាតិ(UN)ស្តីពីគោលដៅនៃការអភិវឌ្ឍប្រចាំសហស្សវត្សរ៍សម្រាប់ពិភពលោកចាប់ពីឆ្នាំ២០០០-២០១៥ គឺសំដៅលើគោលការណ៍ដូចជា៖

- កាត់បន្ថយភាពក្រីក្រ និងលុបបំបាត់ភាពអត់ឃ្លាន
- ជំរុញឱ្យកុមារបានចូលរៀននៅកម្រិតបឋមសិក្សា

[2] UNESCO, Global Citizenship Education: An Emerging Perspective, 2013. P.1.

[3] សង្គមស៊ីវិល័យ គឺជាសង្គមមនុស្សដែលមានការរីកចម្រើន ជឿនលឿន អភិវឌ្ឍផ្នែកវប្បធម៌ សង្គមធម៌ បច្ចេកវិទ្យា វិទ្យាសាស្ត្រសម្រាប់ការរស់នៅរបស់មនុស្សក្នុងសង្គម។

- លើកកម្ពស់សមភាពយេនឌ័រ
- កាត់បន្ថយអត្រាមរណភាពកុមារ
- ប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍
- លើកកម្ពស់សុខភាពមាតា
- ធានាបរិស្ថានប្រកបនិរន្តរភាព និង
- ការអភិវឌ្ឍភាពជាដៃគូក្នុងយុគសម័យភាវូបនីយកម្ម

### ១-៣-ការអប់រំពលរដ្ឋសកល (Universal Citizen)

### ក-បញ្ញត្តិការអប់រំពលរដ្ឋសកល

- ពលរដ្ឋសកល គឺជាពលរដ្ឋដែលជាសមាជិកនៃសកលជាតិទាំងមូល ដោយមិនមានការរើសអើង ហើយប្រកាន់ខ្ជាប់នូវការចែករំលែកវប្បធម៌ ទទួលស្គាល់ និងឱ្យតម្លៃវប្បធម៌ចម្រុះនៃជាតិសាសន៍ដទៃ និងមានការទទួលខុសត្រូវ ខ្វាយខ្វល់ទៅលើបញ្ហានយោបាយ សេដ្ឋកិច្ច បរិស្ថាន និងសង្គមទូទាំងសកលលោក[4]។ ភាពជាពលរដ្ឋសកល គឺជាគំនិតដ៏ស្មុគស្មាញ និងមានការជជែកគ្នាយ៉ាងទូលំទូលាយអំពីភាពខុសគ្នានៃវប្បធម៌ និងប្រវត្តិសាស្ត្រ ទស្សនវិទ្យា និងការប្រើប្រាស់ភាសា ដែលតម្រូវឱ្យមនុស្សមានការយល់ដឹងទាំងអស់គ្នា។
- ពលរដ្ឋសកល គឺជាពលរដ្ឋដែលជាសមាជិកនៃសកលលោកទាំងមូលដោយមិនមានការរើសអើង និងជាពលរដ្ឋ ដែលប្រកាន់ខ្ជាប់នូវការចែករំលែកវប្បធម៌ ការទទួលស្គាល់ និងការឱ្យតម្លៃវប្បធម៌ចម្រុះនៃជាតិសាសន៍ដទៃ ព្រមទាំងមានការទទួលខុសត្រូវ ខ្វាយខ្វល់ទៅលើបញ្ហានយោបាយ បញ្ហាសេដ្ឋកិច្ច បញ្ហាបរិស្ថាន និងបញ្ហាសង្គម[5]។
- ការអប់រំជាពលរដ្ឋសកល គឺជាមុខវិជ្ជាបែបយុទ្ធសាស្ត្រនៃកម្មវិធីវិស័យអប់រំរបស់អង្គការយូណេស្កូ (UNESCO) ដែលបង្កើតឡើងដើម្បីការងារនៃការអប់រំសន្តិភាព និងសិទ្ធិមនុស្ស។ គោលបំណងនៃការអប់រំពលរដ្ឋសកល ដើម្បីបណ្តុះដល់អ្នកសិក្សានូវតម្លៃ បំណិនទន់ និងអាកប្បកិរិយា ដែលគាំទ្រដល់ភាពជាពលរដ្ឋសកល ដែលមានទំនួលខុសត្រូវ ការច្នៃប្រឌិត ការបង្កើតថ្មី ការប្តេជ្ញាចិត្តខ្ពស់ចំពោះសន្តិភាព សិទ្ធិមនុស្ស និងការអភិវឌ្ឍប្រកបដោយចីរភាព[6]។ ការអប់រំពលរដ្ឋសកលក៏មានគោលបំណងផ្តល់សិទ្ធិអំណាចដល់សិស្ស និស្សិតឱ្យចូលរួម និងបំពេញតួនាទីយ៉ាងសកម្ម ដើម្បីរួមចំណែកដោះស្រាយបញ្ហាប្រឈមជាសកល និងគាំទ្រសកម្មភាពសមធម៌ សន្តិភាព ការអត់ឱន សុវត្ថិភាព និងនិរន្តរភាព។
- ការអប់រំភាពជាពលរដ្ឋសកល (Global Citizenship Education, GCED) មានគោលបំណង

---

[4] https://www.postkhmer.com/national

[5] វិទ្យាស្ថានជាតិអប់រំ, ការអប់រំភាពជាពលរដ្ឋសកល, ឆ្នាំ២០២៣ ,ទំព័រ១។

[6] https://www.unescouclachair.gseis.ucla.edu/about/

ពង្រឹងអ្នកសិក្សាគ្រប់វ័យដើម្បីបំពេញតួនាទីសកម្មទាំងក្នុងស្រុក និងសកល ក្នុងការកសាងបន្ថែមទៀត សន្តិភាព ភាពអត់ធ្មត់ បរិយាបន្ន និងសុវត្ថិភាព[7]។

- ការអប់រំភាពជាពលរដ្ឋសកលមានគោលបំណងដើម្បីសម្រេចឱ្យបាននូវការកែទម្រង់ ដើម្បីកសាងចំណេះដឹង ជំនាញ តម្លៃ និងឥរិយាបថ ដែលអ្នកសិក្សាត្រូវការ ដើម្បីអាចចូលរួមនៅក្នុងការបង្កើតពិភពលោកមួយ ដែលប្រកបដោយការរួមបញ្ចូលគ្នា យុត្តិធម៌ និងសន្តិភាព។ ការអប់រំភាពជាពលរដ្ឋសកលជ្រើសរើសយកពហុវិធីសាស្ត្រដោយប្រើប្រាស់ទស្សនាទាន និងវិធីសាស្ត្របង្រៀន ដែលត្រូវបានអនុវត្តរួច ហើយនៅក្នុងមុខវិជ្ជាផ្សេងៗទៀតរួមមានការអប់រំពីសិទ្ធិមនុស្ស ការអប់រំពីសន្តិភាព ការអប់រំពីការអភិវឌ្ឍជានិរន្ត និងការអប់រំដើម្បីការយល់ដឹងជាអន្តរជាតិ និងមានបំណងធ្វើឱ្យកាន់តែជឿនលឿននូវគោលបំណងរួមនៃការអប់រំទាំងនេះ។ ការអប់រំភាពជាពលរដ្ឋសកល អនុវត្តនូវគោលគំនិតនៃការរៀនមួយជីវិតដោយចាប់ផ្តើមពីដំណាក់កាលដំបូងនៃកុមារភាព និងបន្តទៅគ្រប់កម្រិតនៃការអប់រំរហូតដល់វ័យជំទង់ ដោយត្រូវការវិធីសាស្ត្រ កម្មវិធីសិក្សា និងអន្តរាគមន៍ពីកម្មវិធីសិក្សាបន្ថែម ទាំងផ្លូវការនិងក្រៅផ្លូវការ និងត្រូវការទាំងវិធីសាស្ត្រចូលរួមបែបប្រពៃណី និងបែបទំនើប[8]។

- ការអប់រំភាពជាពលរដ្ឋសកលគឺជាផ្តល់ឱ្យយើងនូវការយល់ដឹងជ្រៅជ្រះមួយ ដែលផ្សាភ្ជាប់ ជាមួយគ្នាក្នុងនាមជាពលរដ្ឋនៃសហគមន៍សកល និងការប្រឈមរបស់យើងទាំងអស់គ្នាមានទំនាក់ទំនង[9]។

- ការអប់រំពលរដ្ឋសកលរួមមាន (១)ការអប់រំចំណេះដឹង ការយល់ដឹងអំពីបញ្ហាសកល និន្នាការពិភពលោក និងការគោរពតម្លៃសកលសំខាន់ៗដូចជាសន្តិភាព និងសិទ្ធិមនុស្ស ភាពចម្រុះវប្បធម៌ យុត្តិធម៌ ប្រជាធិបតេយ្យ ការមិនរើសអើង ការសន្តោសប្រណី។ (២) ជំនាញនៃការយល់ដឹងសម្រាប់ការត្រិះរិះពិចារណាប្រកបដោយភាពច្នៃប្រឌិត ការដោះស្រាយបញ្ហា និងការសម្រេចចិត្ត។ (៣)ជំនាញទន់ដូចជាការយល់ចិត្ត ការបើកចំហនៃការដកបទពិសោធន៍ និងទស្សនៈផ្សេងៗ ជំនាញអន្តរបុគ្គល ការប្រាស្រ័យទាក់ទង និងជំនាញទាក់ទងបណ្តាញ និងការទំនាក់ទំនងជាមួយមនុស្សមានប្រវត្តិ និងប្រភពដើមផ្សេងៗគ្នា និង(៤)ការចូលរួមក្នុងសកម្មភាពសង្គម។

- ភាពពលរដ្ឋសកលប្រកបដោយគុណភាពគឺយល់អំពី(១)ផ្នែកសេដ្ឋកិច្ច(ក) ការដឹងពីសកលក (ខ) ការគោរពចំពោះភាពខុសគ្នា និងតម្លៃមនុស្ស (២) ផ្នែកសង្គមនយោបាយ (ក) ការធ្វើឱ្យពិភពលោកប្រសើរជាងមុន (ខ) ការទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន។

- ភាពជាពលរដ្ឋកម្ពុជាប្រកបដោយគុណភាពត្រូវយល់ដឹង(១)ផ្នែកសេដ្ឋកិច្ច (ក) ចំណេះដឹង និង

---

[7] Prof. Serafin, Implementing in the Philippine Context, (workshop at Khemra hotel 2-4/9/2023).

[8] អង្គការយូនីស្កូ,ការអប់រំភាពជាពលរដ្ឋសាកល,ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមនៅក្នុងសតវត្សរ៍ទី២១,២០២៤, ទំ១៦។

[9] បាន គីម៉ូន អគ្គលេខាធិការអង្គការសហប្រជាជាតិ។

ជំនាញរឹង (ខ) ជំនាញ ទន់ និងបំណិនជីវិត(២) សង្គមនយោបាយ (ក) ការគោរពច្បាប់ និងសណ្តាប់-ធ្នាប់សង្គម (ខ) ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍប្រកបដោយចីរភាព (គ) ការចូលរួមក្នុងសកម្មភាពនយោបាយ។

## ១-ប្រវត្តិនៃការអប់រំពលរដ្ឋសកល

អង្គការយូណេស្កូ បានលើកកម្ពស់ការអប់រំភាពជាពលរដ្ឋសកលចាប់តាំងពីការដាក់ចេញនូវគម្រោងផែនការ «ការផ្តួចផ្តើមដំបូងនៃការអប់រំសកល» របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅក្នុងឆ្នាំ២០១២ បានធ្វើឱ្យមានការជំរុញភាពជាពលរដ្ឋសកលទៅជាអាទិភាពនៃការអប់រំមួយនៅក្នុងចំណោមអាទិភាពនៃការអប់រំ។ ការអប់រំភាពជាពលរដ្ឋសកលអំពីប្រធានបទ និងវត្ថុបំណងនៃការសិក្សា គឺជាការណែនាំបែបគរុកោសល្យដំបូងបង្អស់របស់អង្គការយូណេស្កូ ស្តីអំពីការអប់រំភាពជាពលរដ្ឋសកល។ សៀវភៅណែនាំមួយត្រូវបានដកចេញស្រង់ពីសៀវភៅរបស់អង្គការយូណេស្កូមានចំណងជើងថា «ការអប់រំភាពជាពលរដ្ឋសកល ការរៀបចំអ្នកសិក្សាសម្រាប់បញ្ហាប្រឈមទាំងឡាយនៃសតវត្សរ៍ទី២១»។ សៀវភៅណែនាំនេះក៏ដកស្រង់ចេញពីលទ្ធផលនៃកិច្ចប្រជុំចម្បងៗរបស់អង្គការយូណេស្កូ ស្តីអំពីការអប់រំភាពជាពលរដ្ឋសាកលរួមមាន កិច្ចពិគ្រោះយោបល់បច្ចេកទេសស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានធ្វើឡើងនៅខែកញ្ញា ឆ្នាំ២០១៣ និងវេទិកាអង្គការយូណេស្កូលើកទី១ ស្តីអំពីការអប់រំភាពជាពលរដ្ឋសកល ដែលត្រូវបានប្រារព្ធធ្វើឡើងនៅខែធ្នូ ឆ្នាំ២០១៣ និងវេទិកាលើកទី២ ដែលត្រូវបានប្រារព្ធធ្វើឡើងនៅខែមករា ឆ្នាំ២០១៥។

ដើម្បីបញ្ជាក់អំពីភាពច្បាស់លាស់ផ្នែកទស្សនៃការអប់រំភាពជាពលរដ្ឋសកល និងដាក់ចេញជាគោលនយោបាយ និងទិសដៅផ្នែកកម្មវិធីសៀវភៅនេះត្រូវបានអភិវឌ្ឍឡើងជាការឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋជាសមាជិកសម្រាប់ជាសេចក្តីណែនាំរួមមួយនៅក្នុងការបញ្ចូលការអប់រំភាពជាពលរដ្ឋសកលទៅក្នុងប្រព័ន្ធអប់រំរបស់ពួកគេ ហើយក៏ជាការណែនាំមួយសម្រាប់ការពន្យល់អំពីទស្សនាទាននៃការអប់រំភាពជាពលរដ្ឋសកលឱ្យទៅជាប្រធានបទ ដែលអាចអនុវត្តបាន និងសមស្របទៅតាមភាពជាក់ស្តែងរួមទាំងវត្ថុបំណងនៃការសិក្សាក្នុងរបៀបមួយ ដែលអនុញ្ញាតដល់ការសម្របសម្រួលក្នុងបរិបទមូលដ្ឋាន។ ឯកសារនេះ គឺជាប្រភពធនធានមួយសម្រាប់អ្នកអប់រំ អ្នកអភិវឌ្ឍកម្មវិធីសិក្សា អ្នកបណ្តុះបណ្តាលក៏ដូចជាអ្នកធ្វើគោលនយោបាយអប់រំ។ នៅក្នុងពេលវេលាមួយ ដែលសហគមន៍អន្តរជាតិត្រូវបានជំរុញឱ្យកំណត់នូវសកម្មភាព ដើម្បីលើកកម្ពស់សន្តិភាព សុខុមាលភាព វិបុលភាព និងនិរន្តរភាពក្នុងការធានាដល់ អ្នកសិក្សាគ្រប់វ័យអាចអភិវឌ្ឍខ្លួនឱ្យទៅជាពលរដ្ឋសកលប្រកបដោយចំណេះដឹង ការត្រិះរិះពិចារណា ទំនាក់ទំនងល្អក្នុងសង្គមសីលធម៌ និងការចូលរួម។

គោលបំណងនៃការអប់រំភាពជាពលរដ្ឋសកលគឺ ៖

- អភិវឌ្ឍនូវការយល់ដឹងមួយស្តីអំពីរចនាសម្ព័ន្ធអភិបាលកិច្ចសកល សិទ្ធិមនុស្ស និងការទទួលខុសត្រូវបញ្ហាសកល និងទំនាក់ទំនងរវាងប្រព័ន្ធ និងដំណើរការនៅថ្នាក់មូលដ្ឋាន ជាតិ និងសកល។
- ទទួលស្គាល់ និងលើកសរសើរភាពខុសគ្នា និងពហុអត្តសញ្ញាណដូចជាវប្បធម៌ ភាសា សាសនា ភេទ និងមនុស្សជាតិទូទៅ និងអភិវឌ្ឍជំនាញសម្រាប់ការរស់នៅនៅក្នុងពិភពលោកមួយដែលកាន់តែមានពិពិធភាព។
- អភិវឌ្ឍ និងអនុវត្តជំនាញក្នុងការត្រិះរិះពិចារណា ដើម្បីក្លាយទៅជាអក្ខរកម្មពលរដ្ឋ។ ជំនាញទាំងនោះរួមមានការសួរដេញដោលប្រកបដោយការត្រិះរិះពិចារណា បច្ចេកវិទ្យាព័ត៌មាន អក្ខរកម្មសារព័ត៌មាន ការត្រិះរិះពិចារណា ការធ្វើសេចក្តីសម្រេចចិត្ត ការដោះស្រាយបញ្ហា ការចរចារ ការកសាងសន្តិភាព និងការទទួលខុសត្រូវជាលក្ខណៈបុគ្គល និងសង្គម។
- ទទួលស្គាល់ និងពិនិត្យមើលទៅលើជំនឿ និងតម្លៃ និងរបៀប ដែលពួកវាមានឥទ្ធិពលទៅលើទស្សននិងការធ្វើសេចក្តីសម្រេចចិត្តផ្នែកសង្គម និងនយោបាយស្តីអំពីយុត្តិធម៌សង្គម និងការចូលរួមរបស់ពលរដ្ឋ។
- អភិវឌ្ឍឥរិយាបថយកចិត្តទុកដាក់ និងសេចក្តីអាណិតអាសូរសម្រាប់អ្នកដទៃ និងបរិស្ថាន និងការគោរពចំពោះពិពិធភាព។
- អភិវឌ្ឍតម្លៃនៃភាពត្រឹមត្រូវ និងយុត្តិធម៌សង្គម និងជំនាញក្នុងការវិភាគប្រកបដោយការត្រិះរិះពិចារណាអំពីវិសមភាពផ្អែកលើភេទ ឋានៈសង្គមសេដ្ឋកិច្ច វប្បធម៌ សាសនា វ័យ និងបញ្ហាផ្សេងៗទៀត។
- ចូលរួម និងរួមចំណែកនៅក្នុងបញ្ហាសកលនាសហសម័យនៅក្នុងកម្រិតមូលដ្ឋាន ជាតិ និងសកលក្នុងនាមជាពលរដ្ឋសកល ដែលប្រកបដោយចំណេះដឹង ការចូលរួម ការទទួលខុសត្រូវ និងការឆ្លើយតប។

## គ-បញ្ហាសមធម៌យេនឌ័រ និងសិទ្ធិមនុស្ស

គោលការណ៍ជាមូលដ្ឋាននៃធម្មនុញ្ញអង្គការសហប្រជាជាតិដែលបានអនុម័តដោយមេដឹកនាំពិភពលោកក្នុងឆ្នាំ១៩៤៥ គឺសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី ហើយកិច្ចការពារ និងការលើកកម្ពស់សិទ្ធិស្ត្រី គឺជាទំនួលខុសត្រូវរបស់រដ្ឋទាំងអស់[10]។ ឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស កាលពីពេលថ្មីៗនេះបានសន្យាថានឹងប្រែក្លាយជាជើងឯកយេនឌ័រនៅហ្ស៊ីណែវ ដោយធ្វើការប្តេជ្ញាចិត្តជំរុញសមភាពយេនឌ័រនៅការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងក្នុងវេទិកាអន្តរជាតិ។ ស្ត្រីរាប់លាននាក់នៅជុំវិញពិភពលោកបានបន្តជួបប្រទះការរើសអើងនៅឡើយដោយៈ

- ច្បាប់ និងគោលនយោបាយនានាបានហាមឃាត់ស្ត្រីពីការទទួលបានស្មើភាពនូវដីធ្លី ទ្រព្យសម្បត្តិ និងលំនៅឋាន

[10] https://cambodia.ohchr.org/kh/issues/gender-equality-and-human-rights

- ការរើសអើងផ្នែកសេដ្ឋកិច្ច និងសង្គមបណ្ដាលឱ្យមានជម្រើសជីវិតសម្រាប់ស្ត្រីកាន់តែតិចទៅតិចទៅ និងក្រីក្រទៅក្រីក្រទៅធ្វើឱ្យស្ត្រីទាំងនោះងាយរងគ្រោះនឹងការជួញ
- អំពើហិង្សាកើតចេញពីយេនឌ័រប៉ះពាល់យ៉ាងហោចណាស់៣០% នៃស្ត្រីនៅទូទាំងពិភពលោក
- អ្នកការពារសិទ្ធិមនុស្សជាស្ត្រីត្រូវបានបដិសេធពុំទទួលយកដោយសហគមន៍ និងបានមើលឃើញថា ជាការគំរាមកំហែងដល់សាសនា កិត្តិយស ឬវប្បធម៌
- ស្ត្រីមួយចំនួនប្រឈមនឹងទម្រង់នៃការរើសអើងនានា ដែលកាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ ដោយសារតែកត្តានានា ដូចជាអាយុ ជាតិពន្ធ ពិការភាព ឬស្ថានភាពសេដ្ឋកិច្ចសង្គម ដែលបន្ថែមលើការរើសអើងយេនឌ័រ។ ដើម្បីធានាឱ្យមានប្រសិទ្ធភាពនូវសិទ្ធិមនុស្សរបស់ស្ត្រី ជាបឋមតម្រូវឱ្យមានការយល់ដឹងទូលំទូលាយនូវរចនាសម្ព័ន្ធសង្គម និងទំនាក់ទំនងអំណាច នយោបាយ សេដ្ឋកិច្ច សក្ដានុពលសង្គម និងគ្រួសារព្រមទាំងជីវិតសហគមន៍។
- អសមភាពក្នុងវិស័យការងារ បើយោងតាមតួលេខរបស់អង្គការពលកម្មអន្តរជាតិចេញផ្សាយថ្ងៃទី៦មីនាឆ្នាំ២០២៣ បញ្ជាក់ថា ស្ត្រីនៅតែជួបឧបសគ្គច្រើនជាងបុរសនៅពេលណាពួកគេចង់ស្វែងរកការងារធ្វើដើម្បីចិញ្ចឹមជីវិត។ ឧបសគ្គបានដាក់បន្ទុកឱ្យស្ត្រីត្រូវតែបង្ខំចិត្តបោះបង់ចោលចំណេះជំនាញ ហើយងាកទៅធ្វើការងារផ្ទះ និងការរស់នៅរំពឹងប្រាក់ចំណូលរបស់បុរស ដែលធ្វើឱ្យស្ត្រីកាន់តែស្ថិតនៅក្នុងគំនាបកៀបសង្កត់ពីសំណាក់មនុស្សប្រុស។ ជាទូទៅប្រាក់កម្រៃការងារសម្រាប់ការងារដូចគ្នា មនុស្សស្រីទទួលបានប្រាក់កម្រៃទាបជាងបុរស ដែលជាមធ្យមបើមនុស្សប្រុសបានប្រាក់កម្រៃ១ដុល្លារ មនុស្សស្រីបានត្រឹមតែ៥១សេនតែប៉ុណ្ណោះ[11]។

ស្ត្រីអាហ្វហ្កានីស្ថានស្ថិតក្រោមអាណាព្យាបាលទាំងស្រុងរបស់បុរស ក្រុមតាលីបង់ត្រឡប់មកកាន់អំណាចវិញកាលពីខែសីហាឆ្នាំ២០២១ ធ្វើឱ្យការរីកចម្រើននៃសិទ្ធិស្ត្រីអាហ្វហ្កានីស្ថានប្រមាណ២០ឆ្នាំមកនេះត្រូវរលាយដូចអំបិលត្រូវទឹក។ របបតាលីបង់បានដកហូតសិទ្ធិសឹងទាំងស្រុងរបស់ស្ត្រីអាហ្វហ្កានីស្ថាន ស្ត្រីមានសិទ្ធិអាហ្វហ្កានីស្ថាន លែងមានសិទ្ធិធ្វើដំណើរផ្លូវឆ្ងាយតែម្នាក់ឯង ដោយគ្មានមនុស្សប្រុសសមាជិកគ្រួសារទៅជាមួយ ពោលគឺស្ត្រីត្រូវស្ថិតនៅក្រោមអាណាព្យាបាលរបស់បុរសទាំងស្រុងតែម្ដង។ រដ្ឋាភិបាលក្រុមតាលីបង់បានបិទសាលារៀនសិស្សស្រីទូទាំងប្រទេស ប៉ុន្តែសកលវិទ្យាល័យត្រូវបានបើកទ្វារវិញនៅអាហ្វហ្កានីស្ថានតែអនុញ្ញាតឱ្យតែមនុស្សប្រុសចូលរៀនតែប៉ុណ្ណោះ។ ចំពោះស្ថានភាពនៅអ៊ីរ៉ង់ក៏ជាការព្រួយបារម្ភមួយដែរបន្ទាប់ពីប្រជាជនអ៊ីរ៉ង់បានធ្វើបាតុកម្មជាច្រើនខែ ដើម្បីប្រឆាំងនឹងការបំបិទសេរីភាព ហើយបាតុកម្មបានចាប់ផ្ដើមឡើងក្រោយមរណភាពរបស់ស្ត្រី ឈ្មោះអាហ្សា អាមីនី (Ahsa Amini) ដែលនគរបាលចាប់ខ្លួនដោយចោទថា ទទួលក្បាលមិនជិតសក់។ ប៉ុន្មានខែមកនេះ នៅអ៊ីរ៉ង់មានករណីដាក់ថ្នាំបំពុលតាមសាលារៀនសិស្សស្រីបានធ្វើឱ្យកុមារីជាច្រើនរយនាក់ត្រូវគេបញ្ជូនទៅមន្ទីរពេទ្យ។

[11] https://www.rfi.fr/km/

ឧទាហរណ៍៖ កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២២នេះ មេដឹកនាំតាលីបង់អាហ្វហ្គានីស្ថាន បានចេញការហាមឃាត់និស្សិតស្រីមិនឱ្យចូលរៀននៅសកលវិទ្យាល័យក្នុងបទបញ្ជាចុងក្រោយបង្អស់លើការរឹតត្បិតសិទ្ធិ និងសេរីភាពរបស់ស្ត្រី ដែលចូលជាធរមានភ្លាមៗ។ការហាមឃាត់ ដែលអនុវត្តតាមច្បាប់ឥស្លាមដ៏តឹងរ៉ឹងបានបិទសិទ្ធិក្មេងស្រីមិនឱ្យចូលរៀនក្នុងសាលាអនុវិទ្យាល័យ និងវិទ្យាល័យ ហើយហាមឃាត់ស្ត្រីមិនឱ្យធ្វើការងារជាច្រើនជាមួយគ្នានឹងបទបញ្ជាឱ្យស្លៀកពាក់ បិទជិតតាំងពីក្បាលដល់ចុងជើងនៅទីសាធារណៈ ហើយស្ត្រីក៏ត្រូវបានហាមឃាត់មិនឱ្យចូលទីសួនច្បារ កន្លែងហាត់ប្រាណ ទិញកាតទូរសព្ទ ធ្វើដំណើរផ្លូវឆ្ងាយតែម្នាក់ឯងដោយគ្មានសមាជិកគ្រួសារជាភេទប្រុសធ្វើដំណើរជាមួយជាដើម។ និស្សិតស្រីម្នាក់ឈ្មោះម៉ាឌីណា( Madina )បានថ្លែងប្រាប់អ្នកយកព័ត៌មានបារាំងថា ក្រុមតាលីបង់បានជាន់ពន្លិចសេចក្តីសង្ឃឹម និងបានកាយដីកប់សេចក្តីស្រម៉ៃរបស់ស្ត្រីអាហ្វហ្គានីស្ថានថា អាចបានរៀនសូត្រជ្រៅជ្រះ។ និស្សិតស្រីម្នាក់ទៀតបានថ្លែងទាំងទឹកភ្នែកថា ពីមួយថ្ងៃទៅមួយថ្ងៃ ក្រុមតាលីបង់បានដាក់ទណ្ឌកម្មមកលើស្ត្រីអាហ្វហ្គានីស្ថានឱ្យរស់នៅក្រៅសង្គម។



រូបភាពទី១៖ បង្ហាញស្ត្រីគ្រូបង្រៀនអាហ្វហ្គានីស្ថានអាយុ៤០ឆ្នាំ ឈ្មោះ Arefeh ចេញពីថ្នាក់រៀនស្ថិតនៅក្រោមដីមួយកន្លែងក្នុងក្រុងកាប៊ូល។ ដោយសារការហាមឃាត់សិស្សស្រីមិនឱ្យចូលរៀន។ សិស្សស្រីខ្លះបានបន្តការរៀនសូត្រនៅក្រៅក្របខណ្ឌសាលាដោយមានការបង្រៀនលួចលាក់នៅតាមផ្ទះ និងតាមបន្ទប់ក្រោមដី( ប្រភព៖ កាប៊ូល ថ្ងៃទី ២០ កក្កដា ២០២២ AP - Ebrahim Noroozi )។

## ឃ-ការស្វែងយល់អំពីសហគមន៍សង្គមវប្បធម៌អាស៊ាន

ប្រទេសជាសមាជិកសមាគមអាស៊ានបានខិតខំធ្វើការរួមគ្នាឆ្ពោះទៅការបង្កើតនូវសហគមន៍អាស៊ានមួយនៅបំណាច់ឆ្នាំ២០១៥ ដោយឈរលើមូលដ្ឋានសំខាន់ៗ៣គឺសហគមន៍សេដ្ឋកិច្ច( Economic Community ) សហគមន៍សន្តិសុខនយោបាយ ( Political-Security Community ) និងសហគមន៍សង្គមវប្បធម៌( Socio-Cultural Community )។ សហគមន៍សង្គមវប្បធម៌ត្រូវបានគេដាក់ចេញនូវគោល

ដៅ(២០០៩-២០១៥)ដើម្បីចូលរួមចំណែកទទួលស្គាល់នូវលក្ខណៈសង្គមមនុស្ស និងលក្ខណៈវប្បធម៌របស់បណ្តាប្រទេសនីមួយៗជាសមាជិករបស់សហគមន៍ដោយធានាបាននូវការឯកភាព សាមគ្គីភាពរវាងមនុស្ស និងមនុស្ស សង្គមវប្បធម៌ និងសង្គមវប្បធម៌ឈរលើមូលដ្ឋានអត្តសញ្ញាណជាតិ និងអត្តសញ្ញាណវប្បធម៌ ដើម្បីឆ្ពោះទៅរកសុខដុមនីយកម្ម និងសុខុមាលភាពសង្គម[12]។ ការកសាងសហគមន៍ សង្គមវប្បធម៌នេះ គឺត្រូវផ្អែកលើការអភិវឌ្ឍធនធានមនុស្សមានចំណេះដឹងទូលំទូលាយស្តីពីវប្បធម៌ បេតិកភណ្ឌជាតិ ប្រវត្តិសាស្ត្រ បច្ចេកទេសវិជ្ជាជីវៈ និងបំណិនជីវិត លក្ខណៈសង្គមកិច្ច សេដ្ឋកិច្ច និងការអប់រំប្រកបដោយនិរន្តរភាព Education for Sustainable Development (ESD) របស់ប្រជាជាតិនីមួយៗក្នុងតំបន់។

សហគមន៍សង្គម-វប្បធម៌អាស៊ាន គឺសំដៅលើសក្តានុពលពេញលេញរបស់ពលរដ្ឋអាស៊ានក្នុងនោះផ្តោតវប្បធម៌ សិល្បៈ ព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយ ការអប់រំ យុវជន កីឡា សុខុមាលភាពសង្គម និងការអភិវឌ្ឍយេនឌ័រ សិទ្ធិស្ត្រី និងកុមារ ការអភិវឌ្ឍន៍ជនបទ ការលុបបំបាត់ភាពក្រីក្រ មុខងារស៊ីវិល បរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌។ សហគមន៍សង្គម-វប្បធម៌អាស៊ាន គឺជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបីនៃសហគមន៍អាស៊ាន ដែលអាស៊ានបានប្តេជ្ញាលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជនប្រកបដោយសុខុមាលភាពរបស់ប្រជាជនក្នុងអាស៊ាន[13]។ ប្រជាជនដែលកំពុងរស់នៅក្នុងសហគមន៍នេះមានចំនួនប្រមាណជាង៦០០លាននាក់មានទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ភាសា សាសនា សង្គម និងសេដ្ឋកិច្ចនយោបាយពុំដូចគ្នាឡើយ។ ប្រទេសមួយចំនួនគោរពព្រះពុទ្ធសាសនាដូចជាកម្ពុជា ថៃ ឡាវ ភូមា និងវៀតណាម និងប្រទេសមួយចំនួនទៀតគោរពសាសនាឥស្លាម និងគ្រីស្តស្ទៀន។

តើសហគមន៍សង្គម-វប្បធម៌បង្កើតគោលការណ៍យ៉ាងដូចម្តេច ដើម្បីសម្រេចបាននូវចក្ខុវិស័យមួយអត្តសញ្ញាណមួយ និងសហគមន៍មួយ?

យោងទៅតាមសង្គមវិទ្យា ឬនរវិទ្យាវប្បធម៌ ពហុវប្បធម៌ គឺបញ្ជាក់ថា វប្បធម៌មួយចំនួនរួមគ្នានៅក្នុងភូមិសាស្ត្រ ឬចន្លោះសង្គមដូចគ្នា ប៉ុន្តែពុំចាំបាច់បញ្ជាក់ថាមានឥទ្ធិពល ឬផ្លាស់ប្តូរគ្នារវាងពួកគេទេ។ នៅពេលដែលសហគមន៍គ្រប់គ្រង ដើម្បីរក្សាការផ្លាស់ប្តូរនៅក្នុងការគោរព និងការអត់អោនឱ្យគ្នាអ្នកជំនាញហៅ ពហុវប្បធម៌។ លក្ខណៈពិសេសនៃពហុវប្បធម៌គឺ៖

- លើកកម្ពស់ការគោរពនិងការអធ្យាស្រ័យចំពោះភាពខុសគ្នា។
- ហាមរើសអើងការប្រកាន់ពូជសាសន៍និងគោលគំនិតពាក់ព័ន្ធ។
- បង្កើតការរួមរស់ជាមួយគ្នាប្រកបដោយការចុះសម្រុងគ្នា។
- បង្កើតការផ្លាស់ប្តូររវាងក្រុមផ្សេងៗគ្នា។

[12] គួយ សូគាន, អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច, ឆ្នាំ២០១៥ ទំ១។

[13] https://www.google.com/search?q=asean+socio-cultural+community

ជាមួយគ្នានេះសហគមន៍សង្គម-វប្បធម៌អាស៊ាន ពិតជាមានតួនាទីកាន់តែសំខាន់នៅក្នុងការលើកកម្ពស់ស្មារតី និងកិច្ចខិតខំប្រឹងប្រែងរួម ដើម្បីបន្តការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ការពង្រឹងសន្តិសុខស្ថិរភាពនយោបាយក្នុងតំបន់ព្រមទាំងការពង្រឹងសាមគ្គីភាពអាស៊ានតាមរយៈការផ្តោតសំខាន់លើអាទិភាពចំនួន៤ គឺ(១)ពង្រឹងគុណតម្លៃ ការយល់ដឹង និងអត្តសញ្ញាណអាស៊ាន (២)លើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស និងការផ្តល់អំណាចទៅឱ្យស្ត្រី (៣)ពង្រឹងសុខភាព សុខុមាលភាព និងការគាំពារសង្គម និង(៤). ពង្រឹងសមត្ថភាព និងប្រសិទ្ធភាពស្ថាប័នរបស់សហគមន៍សង្គម-វប្បធម៌អាស៊ាន។ ដើម្បីស្តារកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ចតំបន់ប្រកបដោយភាពធន់ និងចីរភាព អាស៊ានចាំបាច់ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនការយកចិត្តទុកដាក់លើការគាំពារ និងអភិវឌ្ឍមូលធនមនុស្សតាមរយៈ(១) ការធ្វើឌីជីថលូបនីយកម្ម(Digitalization) ការផ្តល់អាទិភាពដល់ការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលឱ្យបានទូលំទូលាយ (២),ការអភិវឌ្ឍប្រព័ន្ធសុខភាពសាធារណៈ និងប្រព័ន្ធគាំពារសង្គម ដើម្បីត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងវិបត្តិនានា (៣)ការពង្រឹងវិស័យអប់រំ និងការអភិវឌ្ឍជំនាញ។

ដូចនេះ ពលរដ្ឋគ្រប់រូបក្នុងសហគមន៍អាស៊ានត្រូវចេះរួមសាមគ្គីគ្នា កំណត់អត្តសញ្ញាណជាតិ ការលើកកម្ពស់ការពារសិទ្ធិប្រជាពលរដ្ឋ ក្នុងសហគមន៍អាស៊ានឱ្យបានទូលំទូលាយជាពិសេសបង្កើនការយកចិត្តទុក ដាក់បង្កើតនូវសុខដុមនីយកម្មសេដ្ឋកិច្ច សាសនា នយោបាយឱ្យកាន់តែល្អប្រសើរឡើង។

## ង-ការស្វែងយល់អំពីសុខដុមនីយកម្មសាសនាក្នុងប្រទេសកម្ពុជា

សាសនា គឺជាមនោគមវិជ្ជាផ្លូវចិត្តមួយ ដែលបានបង្កើតឡើងតាមទស្សនៈផ្សេងៗរបស់មនុស្សក្នុងពិភពលោក។ មនោគមវិជ្ជានេះ បានរួមចំណែកកសាងសង្គមមនុស្សប្រកបដោយសុខសន្តិភាពនិងវឌ្ឍនភាពក្នុងពិភពលោកដោយផ្តោតលើការជំនឿ និងការប្រតិបត្តិ។

ការកសាង និងរក្សាបាននូវសុខដុមនីយកម្មសាសនាក្នុងសង្គមកម្ពុជាបច្ចុប្បន្ន គឺជាគោលនយោបាយមួយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាបាននូវសុខសន្តិភាព ឯកភាពជាតិ សាមគ្គីភាព វឌ្ឍនភាព វិបុលភាព និងនិរន្តរភាពរបស់ប្រជាជាតិកម្ពុជាក្នុងស្ថានភាព ដែលពិភពលោកទាំងមូលកំពុងប្រឈមទៅនឹងបញ្ហាសាសនា និងសកលភាវូបនីកម្ម។ ការកសាងសុខដុមនីយកម្មខាងសាសនានេះបានដាក់ចេញជាគោលនយោបាយក៏ដូចជាសកម្មភាពនានា ដែលពាក់ព័ន្ធជាមួយការរួមរស់ជាមួយគ្នាប្រកបដោយសិទ្ធិសេរីភាព និងជំនឿក្នុងប្រទេសនីតិរដ្ឋ។

គោលនយោបាយ និងសកម្មភាពទាក់ទងជាមួយសុខដុមនីយកម្មខាងសាសនាមានដូចជាៈ

យោងតាមបាវចនាជាតិ(ជាតិ សាសនា ព្រះមហាក្សត្រ)និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣(សេរីភាពនៃជំនឿ) និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា(២៩កញ្ញា ២០១៣)ស្តីពីវប្បធម៌ ជំនឿ សាសនាបានបញ្ជាក់ថា បង្កើនការអប់រំដល់ស្រទាប់យុវជន និងកុមារឱ្យយល់ដឹងច្បាស់ពីតម្លៃវិសេសវិសាលនៃវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ខ្មែរ ដែលជាអត្តសញ្ញាណរបស់ជាតិ ហើយ

កាត់បន្ថយវប្បធម៌អវិជ្ជមានពីបរទេស។ ជាមួយគ្នានេះ ជំរុញការគោរពជំនឿសាសនាលើកស្ទួយព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋជាពិសេសពង្រឹងពង្រីកពុទ្ធិកសិក្សាគ្រប់កម្រិតបោះពុម្ពផ្សាយគម្ពីរជីការក្បួនច្បាប់នានា និងគាំទ្រសកម្មភាពសាសនាផ្សេងៗ ក្នុងសង្គមរួមជាមួយការពង្រីកសុខដុមនីយកម្មរវាងសាសនិកនៃគ្រប់សាសនាប្រឆាំងការរើសអើង បែងចែកក្រុម និកាយប្រែក្លាយទៅជាទំនាស់។ផ្ទុយទៅវិញសំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់នោះទៅជាការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ពង្រីកសន្តិភាពសាមគ្គីភាព លើកកម្ពស់តម្លៃសីលធម៌ គុណធម៌ ចរិយាធម៌ ចូលរួមថែរក្សាប្រពៃណីជាតិ និងធានាបាននូវសុខដុមនីយកម្មសាសនាក្នុងសង្គមខ្មែរ។ ប្រទេសកម្ពុជាបច្ចុប្បន្នបានអនុវត្តនូវគោលនយោបាយសុខដុមនីយកម្មសាសនាបានល្អបំផុតមិនថាសាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រិស្តនោះទេគឺបានរួមរស់ជាមួយគ្នាក្នុងសង្គមខ្មែរពោរពេញទៅដោយសេចក្តីសុខ និងមានសិទ្ធិសេរីភាពពេញលេញក្នុងការប្រតិបត្តិតាមគន្លងធម៌សាសនារបស់ខ្លួននីមួយៗដោយពុំមានការរើសអើង គ្មានការមើលស្រាល និងមានការប៉ះទង្គិចគ្នាឡើយ។សាសនាទាំងអស់សុទ្ធសឹងតែដឹកនាំមនុស្សលោកឱ្យប្រព្រឹត្តតែអំពើល្អ សាងកុសលផលបុណ្យ ជួយទុក្ខធុរៈគ្នា ជួយយកអាសារគ្នា គឺរួមគ្នាអប់រំមនុស្សឱ្យធ្វើល្អតែប៉ុណ្ណោះ។



រូបភាព២៖ បង្ហាញពីពិធីមង្គលការរបស់ខ្មែរ-ឥស្លាមនៅស្រុកកោះសូទិន និមន្តព្រះសង្ឃមកសូត្រមន្ត និងប្រោះព្រំសុំសិរីសួស្តី( ថ្ងៃទី៤ មីនា ២០២១ )។

ឧទាហរណ៍៖ កាលពីថ្ងៃទី០៣-០៤ ខែមីនា ឆ្នាំ២០២១ ពិធីមង្គលការរបស់ខ្មែរ-ឥស្លាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម គឺជាសក្ខីភាពមួយបង្ហាញឱ្យនូវសុខដុមនីយកម្មផ្នែកសាសនា និងការរួមរស់ដោយសុខសាន្តរវាងអ្នកប្រណិប័តន៍សាសនាផ្សេងគ្នា ដែលបាននិមន្តព្រះសង្ឃមកឆាន់ចង្ហាន់ និងសូត្រមន្តប្រោសព្រំប្រសិទ្ធពរជ័យថ្ងៃរៀបអាពាហ៍ពិពាហ៍ក្នុងគ្រួសារខ្មែរ-ឥស្លាមមិនធ្លាប់កើតមាននោះឡើយក្នុងឃុំកោះសូទិន ស្រុកកោះសូទិន[14]។

[14] https://freshnewsasia.com/index.php/en/localnews



រូបភាព៣៖គណៈសាសនាគ្រីស្ដចូលបង្គំគាល់សម្ដេចអគ្គមហាសង្ឃរាជ ទេព វង្ស(មីនា ២០២៣)

## ច-ក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា(ការអប់រំពលរដ្ឋសកល)

ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពតាមកម្មវិធីសិក្សាមួយចំនួនដើម្បីផ្ដល់ជាពុទ្ធិដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សឱ្យយល់កាន់តែច្បាស់ពីភាពជាពលរដ្ឋសកលមានកំណត់ក្របខណ្ឌកម្មវិធីសិក្សា។ ដើម្បីយល់ច្បាស់ពីភាពជាពលរដ្ឋសកល គ្រូបង្រៀន និងសិស្សានុសិស្សត្រូវស្វែងយល់ពីសូចនាករគោលដៅដូចជា (១) ការទទួលខុសត្រូវក្នុងសង្គម (២) សមត្ថភាពសកល និង (៣) ការចូលរួមរបស់ពលរដ្ឋសកល និងតួនាទីមួយចំនួនរបស់ភាពជាពលរដ្ឋសកល ការទទួលខុសត្រូវក្នុងការស្វែងយល់ពីទស្សនៈផ្ទាល់ខ្លួន និងទស្សនៈអ្នកដទៃលើបញ្ហាសកល ការគោរពគោលការណ៍នៃវប្បធម៌ចម្រុះ បង្កើតទំនាក់ទំនងជាមួយមនុស្សមកពីប្រទេសនិងវប្បធម៌ផ្សេងៗស្វែងយល់ពីបញ្ហាសកលលោក និងចូលរួមបញ្ចេញមតិសម្រាប់ការអភិវឌ្ឍសហគមន៍ពិភពលោក។

កាលពីថ្ងៃទី១៨-១៩ ខែកក្កដា ឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយនឹងមជ្ឈមណ្ឌលអប់រំសម្រាប់ការយោគយល់អន្តរជាតិ(UNESCO APCEIU) បានប្រារព្ធសិក្ខាសាលាស្ដីពី ការកសាងសមត្ថភាពសម្រាប់ការអភិវឌ្ឍ និងការបញ្ជ្រាបការអប់រំពលរដ្ឋសកលក្នុងកម្មវិធីសិក្សា។ សិក្ខាសាលានេះប្រារព្ធឡើងក្នុងគោលបំណងធំៗចំនួន៣ដូចជា (១) លើកកម្ពស់ការយល់ដឹង និងសញ្ញាណនៃការអប់រំពលរដ្ឋសកល និងលើកទឹកចិត្តអ្នកចូលរួម ដើម្បីគាំទ្រភាពជាពលរដ្ឋសកលក្នុងការអភិវឌ្ឍកម្មវិធី និងសម្របសម្រួល (២) ចូលរួម និងបង្ហាញពីស្ថានភាពបច្ចុប្បន្ន សំណូមពរ ការខ្វះខាត និងសក្ដានុពលនៃការចូលរួមតាមកម្រិតនៃការអភិវឌ្ឍកម្មវិធីការអប់រំពលរដ្ឋសកល និង(៣) ផ្ដល់ទិន្នន័យសម្រាប់ការវិភាគស្ថានភាពជាតិ និងការអភិវឌ្ឍកម្មវិធីសិក្សា។ ទន្ទឹមនឹងនេះក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចូល

ខ្លឹមសារសីលធម៌ពលរដ្ឋចូលគ្រប់កម្មវិធីសិក្សាគ្រប់កម្រិតថ្នាក់«ការពង្រឹងសីលធម៌សិស្សដើម្បីលើកកម្ពស់គុណភាពអប់រំ» ដើម្បីពង្រឹងសមត្ថភាពសិស្សានុសិស្សគ្រប់កម្រិតថ្នាក់ឱ្យក្លាយជាពលរដ្ឋសកលដែលមានចរិយាសម្បទា វិជ្ជាសម្បទា បំណិនសម្បទា និងគុណតម្លៃឆ្លើយតបនឹងបរិបទជាតិ តំបន់ និងពិភពលោក។ នេះសបញ្ជាក់ឱ្យឃើញថា ភាពជាពលរដ្ឋសកលបានបញ្ជ្រាបចូលទៅក្នុងកម្មវិធីសិក្សា ដើម្បីជួយឱ្យលោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សស្វែងយល់បន្ថែមនូវភាពជាពលរដ្ឋសកលឱ្យកាន់តែទូលំទូលាយ។

ជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡាបានសម្របសម្រួល និងរៀបចំគោលនយោបាយជាតិស្តីពី «ការសិក្សាពេញមួយជីវិត» ដោយទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៧ ខែមិថុនា ឆ្នាំ ២០១៩ សម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងភាពថ្កើងថ្កាន។ គោលនយោបាយជាតិស្តីពី «ការសិក្សាពេញមួយជីវិត» មានគោលបំណងផ្តល់ឱកាស និងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបានដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូលស្របតាមយុគសម័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងសង្គមពុទ្ធិ។ ដើម្បីសម្រេចនូវគោលបំណងនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនដោយនៅក្នុងនោះយុទ្ធសាស្ត្រទី៨ត្រូវបានផ្តោតលើការលើកកម្ពស់វប្បធម៌រស់នៅជាពលរដ្ឋសកល។

ខ្លឹមសារនៃយុទ្ធសាស្ត្រទី៨សំដៅលើ (១) ការលើកកម្ពស់ចលនាពលរដ្ឋគ្រប់រូបជាពិសេសយុវជនឱ្យចូលរួមក្នុងការងារស្ម័គ្រចិត្តតាមគ្រប់រូបភាព (២) បណ្តុះវប្បធម៌ចែករំលែកចំណេះដឹង បទពិសោធដោយស្ម័គ្រចិត្តពីក្រសួងស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងសង្គមស៊ីវិល (៣) បង្កើនការទាក់ទាញ ជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកស្ថាប័នរដ្ឋ និងឯកជនឱ្យអនុវត្តការសិក្សាពេញមួយជីវិត (៤) លើកទឹកចិត្តឱ្យពលរដ្ឋគ្រប់រូបជាពិសេសក្រុមជនបាត់បង់ឱកាសបានចូលរួម និងបានទទួលផលប្រយោជន៍ពីកម្មវិធីសិក្សាពេញមួយជីវិត(៥)បង្កើនឱកាសទទួលបានការងារធ្វើសម្រាប់អ្នក ដែលបានឆ្លងកាត់ប្រព័ន្ធបណ្តុះបណ្តាលច្បាស់លាស់ ដោយលើកទឹកចិត្ត និងផ្តល់អាទិភាពដល់អ្នកធ្វើការងារស្ម័គ្រចិត្ត និង(៦) លើកទឹកចិត្តដល់គ្រួសារ សហគមន៍ឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិតលុបបំបាត់ការរើសអើងគ្រប់រូបភាព និងរស់នៅប្រកបដោយសុខដុមក្នុងសង្គម។

ជារួមអត្ថន័យ និងខ្លឹមសារនៃភាពជាពលរដ្ឋសកលត្រូវបានបន្តបញ្ជ្រាបឱ្យរឹតតែមានលក្ខណៈ ទូលំទូលាយនៅក្នុងប្រព័ន្ធអប់រំ និងសង្គមកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងខិតខំប្រឹងប្រែងលើកកម្ពស់ និងផ្សព្វផ្សាយឱ្យកាន់តែមានភាពទូលំទូលាយ ដើម្បីបញ្ជ្រាបចូលក្នុងផ្នត់គំនិតអ្នកសិក្សាស្រាវជ្រាវតាមរយៈការអប់រំគ្រប់រូបភាព និងការដាក់ចេញនូវគោលនយោបាយជាតិស្តីពី «ការសិក្សាពេញមួយជីវិត» និង «យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៨-២០២៣» ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងរៀបចំកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្គោល និងបង្ហាត់បង្រៀនដល់

សិស្ស និស្សិត គរុនិស្សិតនៅតាមគ្រឹះស្ថានសិក្សាជាពិសេសគ្រឹស្ថានបណ្ដុះបណ្ដាលគ្រូ។ ដូចនេះ ការសិក្សាពីពលរដ្ឋសកលពិតជាមានសារៈសំខាន់ ដើម្បីយល់ដឹងអំពីតួនាទីនៃការអប់រំចំពោះសិទ្ធិមនុស្ស សេរីភាពជំនឿសាសនា យល់ដឹងពីតម្លៃពហុវប្បធម៌ លុបបំបាត់ការរើសអើងពូជសាសន៍ ពណ៌សម្បុរ វណ្ណៈ ក្នុងគោលបំណងកសាងសហគមន៍ជាតិ និងពិភពលោកមួយឱ្យមានសុខសន្តិភាព វិបុលភាព បរិយាបន្ន និងការអភិវឌ្ឍដោយចីរភាព។

## ១.៤.ការអប់រំពលរដ្ឋពេញលេញ

លោកអារីស្តូតជាទស្សនវិទូក្រិកបុរាណលើកឡើងថា មនុស្សមិនអាចរស់នៅតែឯងបានទេ។ ផ្ទុយទៅវិញមនុស្សគ្រប់រូបសុទ្ធតែត្រូវការពឹងពាក់គ្នាទៅវិញទៅមក ដែលចាំបាច់ត្រូវតែរស់នៅក្នុងទម្រង់ជាសមូហភាព ឬសហគមន៍ ពោលគឺទម្រង់ជាគ្រួសារ។ គ្រួសារប្រមូលផ្តុំគ្នាបង្កើតទៅជាភូមិ ហើយភូមិប្រមូលផ្តុំគ្នាបង្កើតទៅជាបុរី ឬរដ្ឋ។ ការប្រមូលផ្តុំរបស់មនុស្សក្នុងទម្រង់ជាគ្រួសារមានលក្ខណៈជាធម្មជាតិយ៉ាងណានោះអាស្រ័យលើការប្រមូលផ្តុំគ្នារបស់មនុស្សក្នុងទម្រង់ជាបុរី ឬរដ្ឋ ។ ដូចនេះ ការរៀបចំរចនាសម្ព័ន្ធជារដ្ឋ ដែលមានប្រព័ន្ធគ្រប់គ្រងនយោបាយ ច្បាប់ រដ្ឋាភិបាល និងមានមេដឹកនាំជាដើម។ អារីស្តូតយល់ថា ចំណេះដឹងសំខាន់ជាងគេ អាចប្រែក្លាយមនុស្សឱ្យទៅជាពលរដ្ឋ ឬជាសមាជិកក្នុងសង្គមជាតិបានល្អ[15]។ ជាទូទៅរដ្ឋាភិបាលនៃប្រជាជាតិនីមួយៗ តែងតែដាក់ចេញនូវគោលការណ៍អប់រំបណ្ដុះបណ្ដាលយុវជនឱ្យក្លាយជាពលរដ្ឋល្អ ឬពលរដ្ឋពេញលេញទៅតាមតម្រូវការនៃបរិបទតំបន់ ពិភពលោក និងស្ថានភាពជាក់ស្តែងរបស់សង្គមនីមួយៗ ដើម្បីរួមចំណែកកសាងសង្គមជាតិ។ អារីស្តូតក៏យល់ឃើញថា មនុស្ស គឺជាសត្វលោកសម្រាប់សង្គមដែលមានន័យថា តាមធម្មតាមនុស្សមិនអាចរស់នៅឯកោតែឯងបានទេនៅក្នុងទំនាក់ទំនងសង្គម ប៉ុន្តែមានកាតព្វកិច្ចចំពោះសង្គមជាតិក្នុងឋានៈជាពលរដ្ឋពុំត្រឹមតែក្នុងឋានៈជាមនុស្សទេ[16]។

## ក-បញ្ញត្តិពលរដ្ឋពេញលេញ

ការអប់រំពលរដ្ឋពេញលេញ គឺជាមុខវិជ្ជាមួយ ដែលសាលារៀនរបស់ប្រទេសនីមួយៗត្រូវអភិវឌ្ឍចំណេះដឹង ជំនាញ និងការយល់ដឹងដែលសិស្សត្រូវដើរតួយ៉ាងពេញលេញនៅក្នុងសង្គមប្រជាធិបតេយ្យក្នុងនាមជាពលរដ្ឋសកម្ម និងការទទួលខុសត្រូវ ហើយការអប់រំមានភារកិច្ចធានានូវតម្លៃ និងឧត្តមគតិនៃវប្បធម៌សន្តិភាពដោយការប្រមូលផ្តុំនូវសហគមន៍បញ្ញវន្ត(Intellectual community)ដើម្បីធ្វើឱ្យសម្រេចគោលបំណង។ ការបណ្ដុះបណ្ដាលសិស្ស និស្សិតត្រូវឱ្យមានសមត្ថភាពខ្ពស់ និងជាពលរដ្ឋមានការទទួល

---

[15] https://www.rfi.fr/km

[16] ស៊ន សំណាង, ការធ្វើខ្លួនជាពលរដ្ឋខ្មែរពិបាកជាងការធ្វើខ្លួនត្រឹមតែជាមនុស្សខ្មែរ,ថ្ងៃទី១៦, ខែសីហា, ២០១៨។

ខុសត្រូវគឺអរិយពលរដ្ឋ(Civilized Citizen)[17] ពិតជារួមចំណែកក្នុងការអភិវឌ្ឍប្រទេសប្រកបដោយនិរន្តរភាព។ ការបង្កើត និងផ្សព្វផ្សាយចំណេះដឹងតាមរយៈការស្រាវជ្រាវ និងផ្តល់នូវភាពជំនាញសមស្រប ដើម្បីជួយសង្គមឱ្យមានការអភិវឌ្ឍវប្បធម៌ និងសេដ្ឋកិច្ចសង្គម គឺត្រូវជំរុញឱ្យមានការស្រាវជ្រាវបែបវិទ្យាសាស្ត្របច្ចេកវិទ្យាក៏ដូចជាការស្រាវជ្រាវខាងវិទ្យាសាស្ត្រសង្គម មនុស្សសាស្ត្រ និងសិល្បៈ ដែលអាចជួយពន្យល់បកស្រាយ និងផ្សព្វផ្សាយវប្បធម៌ជាតិ តំបន់ អន្តរជាតិ និងប្រវត្តិសាស្ត្រក្នុងបរិបទនៃពហុនិយម និងពិពិធភាព(In a context of cultural pluralism and diversity)។

លោកអារីស្តូតលើកថា គោលបំណងនៃការអប់រំសម្រាប់រយៈយូរគឺអប់រំមនុស្សក្លាយជាពលរដ្ឋល្អ ហើយជោគជ័យរបស់រដ្ឋាភិបាល គឺផ្អែកលើគុណភាពនៃការអប់រំដល់យុវជនក្មេងៗ។ លោកថមមើសជេហ្វើសិន(Thomas Jefferson)[18]បញ្ជាក់ថា សេចក្តីរំពឹងរបស់ប្រជាជាតិមួយដែលសំបូរទៅដោយភាពល្ងង់ខ្លៅនិងភាពទំនេរគ្មានការងារក្នុងរដ្ឋស៊ីវិល័យ នោះសេចក្តីរំពឹងពុំអាចកើតឡើងបានឡើយ។ ប្រវត្តិវិទូសហរដ្ឋអាមេរិក គឺលោកហង់រីស្ទីល កុមែនជើ(Henry Steel Commager)សន្និដ្ឋានថា ថ្ងៃដំបូងនៃជាតិសាសន៍ថ្មីសហរដ្ឋអាមេរិកគឺបង្កើតសាលារៀនដែលជាអ្នកទទួលខុសត្រូវនៃការផ្តល់ចំណេះដឹង ដើម្បីក្លាយជាពលរដ្ឋអាមេរិក ហើយគោលដៅទី២នៃការអប់រំក្នុងសាលាគឺច្នៃប្រឌិត និងការពង្រីកសហគមន៍ជាតិជាពិសេសចំពោះអ្នកដែលទើបធ្វើអន្តោប្រវេសន៍ចូលទឹកដីអាមេរិក ហើយគេក៏ទទួលបានភាសា និងវប្បធម៌ រួមមានន័យថា សាលារៀនបានដើរតួនាទីជួយលើកកម្ពស់បញ្ញាញាណរបស់សហគមន៍ និងឯកភាពជាតិ (Nation Unity)[19]។

ចំពោះទ្រឹស្តីព្រះពុទ្ធសាសនា បានអប់រំមនុស្សលោកឱ្យប្រព្រឹត្តអំពើល្អ វៀចាកអំពើអាក្រក់ដូចជាការអប់រំកសាងខ្លួនក្នុងផ្លូវល្អ ការតាំងចិត្តស្ងប់ និងប្រកបការងារក្នុងផ្លូវត្រូវ សេចក្តីសុខជាមង្គល ការប្រតិបត្តិបានល្អតាមព្រហ្មវិហារធម៌ ដែលនាំមកនូវសន្តិភាព សុវត្ថិភាព ភាពសុខសាន្តរីករាយជានិរន្តន៍។ ការស្គាល់ខុសត្រូវ គុណទោសចំពោះអ្នកជុំវិញ និងរៀនចំខ្លួនក្លាយជាពលរដ្ឋល្អរស់នៅចុះសម្រុងជាមួយអ្នកដទៃក្នុងសង្គម កសាងសុខសន្តិភាពក្នុងសហគមន៍ និងសង្គមជាតិ។ សង្ឃដីកាសម្តេចព្រះព្រហ្មរតនមុនី ពិន សែមលើកឡើងថា «ព្រះពុទ្ធសាសនា គឺជាសាសនាសន្តិភាព សាសនាសីលធម៌ ពោលគឺអប់រំមនុស្សឱ្យមានសីលធម៌ ប្រកាន់ធម៌អហិង្សា ស្រឡាញ់សន្តិភាព ហើយមនុស្សជាធាតុដ៏សំខាន់សម្រាប់សង្គម និងពិភពលោកឱ្យមានសន្តិភាពបានសេចក្តីថា មនុស្សមានសន្តិភាព សង្គម និងពិភពលោកទើប

---

[17] ស៊ន សំណាង, «ការធ្វើខ្លួនជាពលរដ្ឋខ្មែរពិបាកជាងការធ្វើខ្លួនត្រឹមតែជាមនុស្សខ្មែរ,ថ្ងៃទី១៦, ខែសីហា, ឆ្នាំ ២០១៨(សិក្ខាសាលា)

[18] Thomas Jefferson ជាប្រធានាធិបតីទី៣របស់សហរដ្ឋអាមេរិកពីឆ្នាំ១៨០០-១៨០៤។

[19] គួយ សូគាន ប្រវត្តិអប់រំសកលលោក ឆ្នាំ២០០៨ ទំ១៣។

មានសន្តិភាព»[20]។ មួយវិញទៀតធម៌វិន័យជាមូលដ្ឋានគ្រឹះរបស់ព្រះពុទ្ធសាសនាសម្រាប់អប់រំមនុស្សគឺសីល៥ ឬនិច្ចសីល បុគ្គលគ្រប់រូបគួររក្សាជាប្រចាំក្នុងជីវិតរាល់ថ្ងៃ ដែលនាំមកនូវសេចក្តីសុខក្សេមក្សាន្តជានិរន្តរ៍ដល់ខ្លួន និងអ្នកដទៃ ដែលសីលទាំងនោះរួមមាន(១)ការមិនសម្លាប់សត្វ ឬសម្លាប់អ្នកដទៃ (២)ការលួច ឬប្លន់នូវវត្ថុដែលគេមិនបានឱ្យ(៣)វាចាកិរិយាប្រព្រឹត្តខុសក្នុងកាមតណ្ហាទាំងឡាយ (៤)ការពោលនូវពាក្យកុហក និង(៥)ការមិនផឹកនូវទឹកស្រវឹងឡាំងឡាយ[21]។ រីឯព្រហ្មវិហារធម៌ប្រែថា គោលនៃការប្រព្រឹត្ត ដែលប្រសើរបរិសុទ្ធ ឬប្រែថា ធម៌ជាទីអាស្រ័យរបស់ព្រហ្ម។ ព្រហ្មវិហារធម៌ពោរពេញដោយការសន្ដោសប្រោសប្រណីចំពោះមនុស្សគ្រប់រូបដោយគ្មានការរើសអើង ការគុំកួន សងសឹក ព្យាបាទ ដែលនាំឱ្យវិនាសអន្តរាយ។ ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈត្រូវប្រតិបត្តិនូវសាមគ្គីភាព ភាពសុខក្សេមក្សាន្ត សុខដុមនីយកម្ម និងសុភមង្គលក្នុងគ្រួសារ និងសង្គមជាតិ។

ព្រហ្មវិហារធម៌មាន៤គឺៈ

- មេត្តា សេចក្តីរាប់អាន សេចក្តីប្រណី បំណងចង់ឱ្យអ្នកដទៃបានសុខ
- ករុណា សេចក្តីអាណិត អាសូរ
- មុទិតា ដំណើរមានចិត្តរីករាយទៅរកសេចក្តីសុខរបស់អ្នកដទៃពុំរើសមុខ គឺដំណើរដែលដឹងថាអ្នកដទៃតាមតែ អ្នកក៏ដោយគេមានទ្រព្យសម្បត្តិធនធាន បុណ្យសក្តិបានប្រកបដោយសេចក្តីសុខ ការមានចិត្តជួយអរគេ មិនច្រណែនឈ្នានីស។
- ឧបេក្ខា ឬឧបេក្សា ការតាំងចិត្តកណ្តាល ដំណើរមិនលម្អៀងទៅណា។

ដូចនេះពលរដ្ឋពេញលេញក្នុងទ្រឹស្តីព្រះពុទ្ធសាសនាសំដៅដល់បុគ្គលណាប្រកាន់ភ្ជាប់នូវសន្តិភាពផ្លូវចិត្ត ផ្លូវកាយ វាចា និងប្រព្រឹត្តនូវគុណធម៌ជាប្រយោជន៍ដល់សង្គម និងរួមគ្នាកសាងសហគមន៍មួយឱ្យមានសុខដុមនីយកម្ម។

## ១-បរិបទនៃអប់រំពលរដ្ឋពេញលេញក្នុងសង្គមកម្ពុជា

ការអប់រំសតវត្សរ៍២១ សំដៅដល់ការអប់រំឆ្លើយតបទៅនឹងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច បច្ចេកវិទ្យា និងសង្គមដែលមានបម្រែបម្រួលជាប្រចាំ។ ការអប់រំបានជំរុញដល់សិស្សានុសិស្ស ឬយុវជនអាចទទួលបានជោគជ័យក្នុងពិភពលោក ដែលការងាមួយចំនួនមិនទាន់បានលេចជារូបរាងនៅឡើយ។ បច្ចេកវិទ្យាបានដើរតួនាទីកាន់តែសំខាន់ក្នុងការបង្កើនផលិតភាព ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតការងារសំដៅជំរុញវឌ្ឍនភាពសង្គម សេដ្ឋកិច្ចឱ្យកាន់តែរីកចម្រើនព្រមទាំងបានផ្លាស់ប្តូរទម្លាប់រស់នៅ និងជីវិតប្រចាំថ្ងៃ

[20] សម្តេចព្រះព្រហ្មរតនមុនី ពិន សែម (សំដែងធម៌ទេសនានៅប្រទេសអូស្ត្រាលី)

[21] ព្រះមហា ចារ សំសារ៉ុន សន្តិបាលភិក្ខុ, ព្រះរតនត្រ័យសម្រាប់បណ្តុះបណ្តាលនិស្សិតនៅពុទ្ធិកសកលវិទ្យាល័យព្រះសីហនុរាជ ខេត្តបាត់ដំបង ឆ្នាំ២០២៣, ទំ.៧៩។

របស់មនុស្សក្នុងសង្គម។ បញ្ហាជាមូលដ្ឋាននៃអក្ខរកម្មឌីជីថល គឺជាប្រធានបទដ៏សំខាន់សម្រាប់ធនធានមនុស្សត្រូវបានផលិតចេញពីវិស័យអប់រំឱ្យក្លាយជាពលរដ្ឋឌីជីថលពេញលេញ។ សិស្សានុសិស្ស និងគ្រូបង្រៀនត្រូវភ្ជាប់ខ្លួនទៅកាន់នវានុវត្តន៍នៃការអប់រំថ្មីៗ ឌីជីថល និងកម្មវិធីសិក្សាដែលសម្បូរបែប និងមានគុណភាពជាឱកាសសម្រាប់អភិវឌ្ឍបំណិនសតវត្សរ៍ទី២១បានកាន់តែប្រសើរ និងការផ្សារភ្ជាប់ការសិក្សាទៅកាន់តម្រូវការនៅលើទីផ្សារការងារ ដែលតម្រូវឱ្យមានសមត្ថភាព និងជំនាញឌីជីថលកាន់តែខ្ពស់។

ក្រសួងអប់រំ យុវជន និងកីឡាមានចក្ខុវិស័យធានាអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញប្រកបដោយការរីកចម្រើនគ្រប់ផ្នែកមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទាមនសិការស្នេហាជាតិ មនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក។

## ក-ក្របខណ្ឌកម្មសិក្សាឆ្នាំ២០១៦(ការអប់រំពលរដ្ឋពេញលេញ)

ជាងពីរទសវត្សរ៍កន្លងទៅនេះ សកលភាវូបនីយកម្មលើគ្រប់វិស័យជាពិសេសវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស និងនយោបាយបានធ្វើឱ្យពិភពលោកកាន់តែមានការប្រកួតប្រជែង និងសហការគ្នាដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សរ៍ និងការអភិវឌ្ឍប្រកបដោយចីរភាព។កំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាជាកត្តាកំណត់ភាពជោគជ័យនៃការអភិវឌ្ឍវិស័យនានារបស់ជាតិ[22]។

ប្រទេសកម្ពុជាបានឆ្លងកាត់ពីឋានៈនៃប្រទេសមានចំណូលទាបទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប ហើយកំពុងប្រែក្លាយខ្លួនឱ្យទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេស មានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវធ្វើកំណែទម្រង់លើគ្រប់វិស័យជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ជាដើម។ ចំពោះក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនេះត្រូវបានរៀបចំឡើងដើម្បីអប់រំសិស្ស និស្សិតកម្ពុជាឱ្យក្លាយជាពលរដ្ឋពេញលេញ[23]តាមរយៈការធ្វើឱ្យកម្មវិធីសិក្សាជាតិមានលក្ខណៈស្តង់ដាលើខ្លឹមសារមេរៀន វិធីសាស្ត្ររៀន-បង្រៀន និងវិធីវាយតម្លៃលទ្ធផលសិក្សារបស់

---

[22] ជាតិមានន័យថា កំណើត កើតមកជារូបរាងកាយ។ ជាតិធម៌មានន័យថា កំណើតដែលជាធម្មតារបស់សព្វសត្វ, ដែលមានជីវិតជាតិជាធម្មតា។ ជាតិភូមិមានន័យថា ភូមិកំណើត ស្រុកកំណើត។ អលង្ការរបស់ជាតិមាន៥គឺ(១)-ពន្លឺរស្មីជាតិដូចចំណេះវិជ្ជាក្នុងលោកអក្សរសាស្ត្រ គណិត រូបគីមី (២)-ជីវិតរបស់ជាតិ ទឹក ដី ព្រៃឈើ បឹង ទន្លេ សមុទ្រ មាស ពេជ្រ(៣)-របងជាតិ នគរបាល ទាហាន ប្រជាជន(៤)វឌ្ឍនធម៌របស់ជាតិភាពរីកចម្រើនរបស់ជាតិទាំងវប្បធម៌ការរស់នៅ(៥)-ចរិយាធម៌របស់ជាតិសីលធម៌ភាពថ្លៃថ្នូររបស់សង្គមជាដើម។

[23] ក្រសួងអប់រំ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស ឆ្នាំ២០១៦, ទំ១។

សិស្សក្នុងគោលបំណងធ្វើឱ្យសមត្ថភាពសិស្សឆ្លើយតបនឹងតម្រូវការទីផ្សារការងារនៅកម្រិតតំបន់ និង ពិភពលោក។




រូបភាពទី៤៖ រូបភាពបង្ហាញលក្ខណសម្បត្តិជាពលរដ្ឋពេញលេញ។

## ឃ-គោលបំណងនៃកម្មវិធីសិក្សា

ចក្ខុវិស័យរបស់ក្របខណ្ឌកម្មវិធីសិក្សានេះ ជានាអប់រំពលរដ្ឋឱ្យមានលក្ខណសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែកដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិនិងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិនិងការធ្វើសមាហរណកម្ម កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ គោលបំណងនៃក្របខណ្ឌសកម្មវិធីសិក្សាចំណេះទូទៅនិងអប់បច្ចេកទេស ដើម្បីបណ្តុះបណ្តាលសិស្សក្លាយជាពលរដ្ឋពេញលេញរួមមាន៖

- សមត្ថភាពភាសាខ្មែរ និងភាសាបរទេសលើសមត្ថភាពទាំង៤(ការស្តាប់ ការនិយាយ ការអាន និង ការសរសេរ)ឱ្យបានច្បាស់លាស់សម្រាប់ប្រើប្រាស់ ក្នុងការសិក្សាស្រាវជ្រាវនិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។
- ចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្របច្ចេកទេសនិងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍សម្រាប់ជាមូលដ្ឋានដល់ការបន្តការសិក្សានិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។
- បំណិនសិល្បៈ សុខភាព កីឡា សោភ័ណភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជាសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងនាមជាបុគ្គល និងសមាជិកគ្រួសារ សហគមន៍ និងសង្គម។ បំណិនស្វ័យសិក្សាស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាក្នុង បរិបទផ្សេងៗ ដោយប្រើប្រាស់ចំណេះដឹងទូលំទូលាយនិងស៊ីជម្រៅ។

- សមត្ថភាពក្នុងការវាយតម្លៃនិងធ្វើសេចក្តីសម្រេចចិត្តដោយសុភវិនិច្ឆ័យនិងការទទួលខុស ត្រូវប្រកបដោយសេចក្តីថ្លៃថ្នូរ ចិត្តមេត្តាករុណានូវរាល់សកម្មភាពរបស់ខ្លួនក្នុងនាមជាបុគ្គល និងសមាជិក គ្រួសារ សហគមន៍ និងសង្គម។
- ការយល់ដឹងក្នុងការបំពេញកាតព្វកិច្ច និងការប្រើប្រាស់សិទ្ធិពលរដ្ឋដោយមានការទទួល ខុសត្រូវក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ សង្គម តំបន់ និងពិភពលោក។
- បំណិនសិក្សាពេញមួយជីវិតជួយលើកកម្ពស់គុណតម្លៃជាមូលដ្ឋាននឹងបង្កើនចំណេះដឹងឱ្យទូលំទូលាយស្តីពីសេដ្ឋកិច្ច នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា ជាតិសាសន៍ អត្តសញ្ញាណជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន ប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីលើកកម្ពស់ការអប់រំជាពលរដ្ឋសកម្ម និងពលរដ្ឋសកលប្រកបដោយចីរភាព និងសន្តិសហវិជ្ជមានជាមនុស្សជាតិ។
- ស្មារតីស្រឡាញ់ ការពារ និងកសាងជាតិ មាតុភូមិ និងពូជសាសន៍របស់ខ្លួនដោយអនុវត្ត គោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្សនឹងការគោរពសិទ្ធិមនុស្សដោយឈរលើច្បាប់ជាតិ និងអន្តរជាតិ។

ក្របខណ្ឌកម្មវិធីសិក្សាចំណេះដឹងទូទៅ និងអប់រំបច្ចេកទេសនេះបានរំលេចនូវបំណិនមួយចំនួនដែលចូលរួមក្នុងការលើកកម្ពស់ក្រមសីលធម៌របស់សិស្សានុសិស្សដូចជា បំណិនប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម បំណិនពិចារណានិងការបង្កើតថ្មីបំណិនអនុវត្តចំណេះដឹងនិងជំនាញ និងបំណិនអភិវឌ្ឍបុគ្គលគ្រួសារ និងសង្គមជាដើម។ បំណិនទាំងអស់នេះបានអប់រំសិស្សានុសិស្សឱ្យ(១) ណែនាំសិស្សានុសិស្សឱ្យចេះប្រាស្រ័យទាក់ទង និងធ្វើការងារជាក្រុម (២)ផ្សព្វផ្សាយគំនិតចំណេះដឹងបំណិន ជំនាញ អារម្មណ៍ និងទស្សនៈ (៣) ធ្វើសុភវិនិច្ឆ័យចំពោះព័ត៌មានដែលត្រូវទទួល ឬមិនត្រូវទទួលដោយឈរលើគោលការណ៍វិភាគហេតុផល(៤) ចរចាស្វែងរកយន្តការនិងវិធីសាស្ត្រដោះស្រាយបញ្ហាប្រកប ដោយប្រសិទ្ធភាពបំផុតទៅតាមកាលៈទេសៈ ដើម្បីបានជាប្រយោជន៍វិជ្ជមានទាំងអស់គ្នា (៥)ជំរុញចំណង់សិក្សាដោយឯករាជ្យ និងឱ្យតម្លៃការសិក្សាពេញមួយជីវិត (៦) ធ្វើនវានុវត្តន៍បង្កើតលទ្ធភាពថ្មីគំនិតថ្មី និងពិចារណាលើបញ្ហាប្រកប ដោយការវិភាគសមហេតុផល និងគ្រប់ជ្រុងជ្រោយ (៧) ទទួលខុសត្រូវក្នុងការបំពេញភារកិច្ចចំពោះខ្លួនឯងគ្រួសារ និងសង្គមដោយការយល់ដឹងការស្រឡាញ់ការដឹងគុណ និងការប្តេជ្ញាចិត្ត (៨) សីលធម៌រស់នៅការស្គាល់ខុស ស្គាល់ត្រូវ ការការពារ និងការពង្រីកសុចរិតធម៌ជាប្រចាំនិង(៩) ភាតរភាពក្នុងការបំពេញសកម្មភាពនានាឬមានទំនាក់ទំនងជាមួយគ្នាប្រកបដោយចិត្តមេត្តា ករុណាចំពោះគ្នាទៅវិញទៅ មកដើម្បីលើកកម្ពស់សេចក្តីសុខ និងសុភមង្គលផ្ទាល់ខ្លួនគ្រួសារ និងសង្គម។

ទន្ទឹមនឹងនេះ នៅតាមគ្រឹះស្ថានសិក្សាចំណេះដឹងទូទៅទាំងសាធារណៈ និងឯកជនបានបញ្ជ្រាប និងបង្រៀននៅក្នុងមុខវិជ្ជាសិក្សាសង្គមគ្រប់កម្រិតថ្នាក់សិក្សា ដើម្បីប្រែក្លាយសិស្សានុសិស្សជាពលរដ្ឋពេញលេញ។ មុខវិជ្ជាសិក្សាសង្គមរួមមាន ប្រវត្តិវិទ្យា ភូមិវិទ្យា គេហវិជ្ជា សេដ្ឋកិច្ចវិទ្យា សីលធម៌ ពលរដ្ឋវិជ្ជា និងទស្សនវិជ្ជាបានពង្រីកសមត្ថភាពសិស្សជាពលរដ្ឋពេញលេញដោយការសិក្សាអំពីទ្រឹស្តី និងការអនុវត្ត

ជាក់ស្តែងពាក់ព័ន្ធនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិស្រាស្ត ច្បាប់ និងនយោបាយជាដើម។ ការសិក្សាមុខវិជ្ជាសិក្សាសង្គមគឺជានាឱ្យសិស្ស(១) ទទួលបានចំណេះដឹង និង បំណិនទាក់ទងទៅនឹងអត្តសញ្ញាណវប្បធម៌ ប្រពៃណីទំនៀមទម្លាប់ បរិស្ថាន ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ ច្បាប់ និងនយោបាយរបស់កម្ពុជា និងបណ្តាប្រទេសក្នុងតំបន់ (២) អភិវឌ្ឍបំណិនពលរដ្ឋពាក់ព័ន្ធទៅនឹង តួនាទី និងការទទួលខុសត្រូវក្នុងនាមជាសិស្ស និងជាពលរដ្ឋទាំងនៅក្នុងសាលារៀនគ្រួសារ សហគមន៍ សង្គមជាតិ និងអន្តរជាតិ (៣) ប្រើប្រាស់ចំណេះដឹង និងបំណិន ដែលបានមកពីការសិក្សាមុខវិជ្ជានានា នៅក្នុងមុខវិជ្ជាសិក្សាសង្គមសម្រាប់ការរៀនសូត្រ និងការរស់នៅប្រចាំថ្ងៃ និង(៤) ស្រឡាញ់ជាតិធម្មជាតិ សាសនា និងព្រះមហាក្សត្រក្នុងនាមជាពលរដ្ឋ ដែលមានការចេះដឹង និងការទទួលខុស ត្រូវមានមោទន ភាពចំពោះជាតិរបស់ខ្លួន និងគោរពជាតិសាសន៍ដទៃ។

## ១.៤.ការអនុវត្តស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ជាឧបករណ៍សម្រាប់លើកកម្ពស់គុណតម្លៃរបស់គ្រូបង្រៀនក្នុងវិជ្ជាជីវៈ ជាអ្នកអប់រំ និងជីវភាពរស់នៅជាប្រចាំក្នុងសហគមន៍។ មិនតែប៉ុណ្ណោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនបានប្រែ ក្លាយអាកប្បកិរិយារបស់សិស្សានុសិស្ស និស្សិតជាពលរដ្ឋគំរូក្នុងសង្គមទៀតផង។ ជាទូទៅស្តង់ដាវិជ្ជាជីវៈ គ្រូបង្រៀនរួមមាន៖

(ក)ចំណេះដឹងវិជ្ជាជីវៈ គឺសំដៅចំណេះដឹងទូទៅ និងចំណេះដឹងឯកទេស។ គ្រូបង្រៀនត្រូវដឹង អំពីតម្រូវការសិក្សា ប្រវត្តិសិក្សា សមត្ថភាព និងឥរិយាបថសិក្សារបស់សិស្សថែមទៀត ព្រមទាំងដឹងអំពី ស្ថានភាពគ្រួសារ បញ្ហាយេនឌ័រ បញ្ហាសេដ្ឋកិច្ច ក្រុមជនជាតិ និងរបៀបរៀនរបស់សិស្ស។ ការស្គាល់ ព័ត៌មានទាំងអស់នេះ គឺជាកត្តាសំខាន់របស់គ្រូក្នុងការបង្ហាត់បង្រៀនប្រកបដោយបរិយាបន្ន និងគុណភាព ក្នុងសង្គមទាំងអស់គ្នា។

(ខ)ការប្រតិបត្តិវិជ្ជាជីវៈ គឺសំដៅលើការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ និងសម្បូរបែបជំរុញការចូល រួមរបស់សិស្សានុសិស្សប្រកបដោយភាពរស់រវើក និងការសាទរពីមាតាបិតារបស់សិស្សទៀតផង ព្រមទាំង មានការស្វែងយល់អំពីបរិស្ថានសិក្សារបស់សិស្ស និងចូលរួមដោះស្រាយនូវបញ្ហាទាំងឡាយដែលបានកើត ឡើងចំពោះសិស្សប្រកបគំនិតច្នៃប្រឌិត។

(គ)ការសិក្សាវិជ្ជាជីវៈសំដៅលើការសិក្សាស្វ័យវាយតម្លៃ និងសិក្សាស្រាវជ្រាវបន្តលើចំណេះដឹង បច្ចេកវិជ្ជាវិទ្យាសាស្ត្រថ្មីៗ និងភាសាបរទេសតាមគ្រប់រូបភាព ដើម្បីរួមចំណែកជំរុញការសិក្សារបស់សិស្ស ឱ្យកាន់តែជោគជ័យប្រសើរថែមទៀត។

(ឃ)សីលធម៌វិជ្ជាជីវៈ គឺជាការអនុវត្តវិជ្ជាជីវៈប្រកបដោយភាពទទួលខុសត្រូវខ្ពស់ និងមានអាកប្ប កិរិយាល្អៗ និងមានយុត្តិធម៌ តម្លាភាពជាគំរូដ៏ល្អដល់សិស្សគ្រប់កម្រិតសិក្សា។

## ១.៦.កិច្ចតែងការបង្រៀនបញ្ញាបន្ទឹមសារពលរដ្ឋសកល

### មេរៀនទី១៖ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

### ប្រធានបទ៖ **ទម្រង់រដ្ឋាភិបាល**

១.វត្ថុបំណងនៃមេរៀន

ក្រោយពីបញ្ចប់ការសិក្សាមេរៀននេះ បញ្ញាបន្ទឹមសារពលរដ្ឋសកលដល់អ្នកសិក្សាអំពី៖

ក-វិជ្ជាសម្បទា៖

-រៀបរាប់ពីគុណសម្បត្តិ និងគុណវិបត្តិរដ្ឋបាលកណ្តាល, គោលដៅនៃកំណែទម្រង់, និងតួនាទីរដ្ឋាភិបាលបានច្បាស់លាស់តាមរយៈការអានអត្ថបទ

ខ-បំណិនសម្បទា៖

-កំណត់បានអំពីទំនួលខុសត្រូវរបស់រដ្ឋបាលកណ្តាល, គោលដៅនៃកំណែទម្រង់ និងតួនាទីរដ្ឋាភិបាលតាមការពិភាក្សាក្រុម

គ-ចរិយាសម្បទា៖

-បណ្តុះស្មារតីសាមគ្គីភាពក្នុងការចូលរួមអភិវឌ្ឍន៍សង្គម រវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋប្រកបដោយសុខដុមនីយកម្មក្នុងសង្គមជាតិ។

២-សម្ភារៈបង្រៀន

- មេរៀនស្តីពី៖ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំដោយក្រុមការងារGCED នៃវិទ្យាស្ថានជាតិអប់រំ ទំព័រ ?
- វិធីសាស្រ្តបង្រៀន៖ សិស្សមជ្ឈមណ្ឌល(ស្ថាបនានិយម)
- កិច្ចតែងការបង្រៀន
- រូបភាពមួយចំនួន

៣.ដំណើរការបង្រៀន និងរៀន

| សកម្មភាពគ្រូ | ខ្លឹមសារ | សកម្មភាពសិស្ស |
|---|---|---|
| រដ្ឋបាលថ្នាក់រៀន<br>ពិនិត្យវត្តមាន | **ជំហានទី១**<br>ពង្រឹងថ្នាក់ *(៣ នាទី)* | ក្រោកឈរ ស្ងៀមស្ងាត់<br>ប្រធានថ្នាក់រាយការណ៍ |
| សួរសំណួរអំពីមេរៀនចាស់<br>បង្ហាញរូបភាព ថ្នាក់ដឹកនាំ<br>បង្ហាញវីដេអូស្តីពីការប្រជុំគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | **ជំហានទី២**<br>រម្លឹកមេរៀនចាស់*(៧ នាទី)* | សិស្សឆ្លើយជាលក្ខណៈបុគ្គល |

| | | |
|---|---|---|
| គ្រូបែងចែកសិស្សជាក្រុម ពិភាក្សា និងឆ្លើយសំណួរ | **ជំហានទី៣**<br>**មេរៀនថ្មី***(៣០ នាទី)*<br>**រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** | សិស្សស្ដាប់ការណែនាំរបស់គ្រូ |
| គ្រូបំផុសសិស្សឱ្យឆ្លើយសំណួរ<br><br>ចែកសិស្សជា៤ក្រុមគឺៈ<br>ក-ក្រុមទី១ | **១.រដ្ឋបាលកណ្ដាល**<br>ដើម្បីបានដឹងពីដំណើរការរបស់រាជរដ្ឋាភិបាលកម្ពុជាទទួលជោគជ័យក្នុងអាណត្តិនីមួយៗនោះ<br><br>ប្រភព៖https://www.google.com/search<br>**តើគេត្រូវសិក្សាលើកិច្ចការអ្វីខ្លះ?**<br>-សិក្សាពីភារកិច្ចរបស់រាជរដ្ឋាភិបាល<br>-សិក្សាគុណសម្បត្តិរបស់រាជរដ្ឋាភិបាល<br>-សិក្សាពីគុណវិបត្តិរបស់រាជរដ្ឋាភិបាល<br>-សិក្សាពីកំណែទម្រង់របស់រាជរដ្ឋាភិបាល<br>**ក-ភារកិច្ចរបស់រាជរដ្ឋាភិបាល**<br>-រដ្ឋបាលកណ្ដាលមានភាពខ្លាំងធ្វើឱ្យមានការឯកភាពគ្នាក្នុងការអនុវត្តការងារ ដោយគ្មានករណីពិសេស ឬដោយឡែកសម្រាប់មូលដ្ឋានណាមួយ | សិស្សឆ្លើយ<br><br>ក-សិស្សពិភាក្សា |

| | | |
|---|---|---|
| | ឡើយ។ ប្រជាពលរដ្ឋមានសិទ្ធិស្មើគ្នាក្នុងការរួមវិភាគទានអនុវត្តការងារដែលតម្រូវឱ្យធ្វើ ។<br>-ការប្រមូលផ្តុំអំណាចរដ្ឋបាលឱ្យនៅតែមួយកន្លែង និងធ្វើឱ្យដំណើការរដ្ឋបាលកណ្តាលមានបន្ទុកធ្ងន់ធ្ងរ។ ប្រធានស្ថាប័នរដ្ឋបាលកណ្តាលមិនត្រឹមតែរវល់នឹងការងារទាំងនោះទេ តែពេលខ្លះថែមទាំងមិនអាចទាំងក្រសោមការងារទាំងនោះបានដែរ។ | |
| ខ.ក្រុមទី២ | **១-គុណសម្បត្តិរបស់រាជរដ្ឋាភិបាល**<br>-ដើម្បីលើកស្ទួយសុខុមាលភាពប្រជាជន រដ្ឋាភិបាលអនុវត្ត និងពង្រឹងច្បាប់ផ្សេងៗព្រម ទាំងផ្តល់សេវាកម្មដល់ប្រជាជន និងអប់រំថែទាំសុខភាព។<br>-ដើម្បីថែរក្សាទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងអត្តសញ្ញាណជាតិ។ រដ្ឋាភិបាល ត្រូវតែលើកស្ទួយទស្សនជាតិនិយម និងធ្វើឱ្យប្រជាជនចេះគោរពស្រឡាញ់ និងការពារប្រពៃណីទំនៀមទម្លាប់ និងវប្បធម៌ជាតិ និងសហគមន៍ខ្លួន។<br>-រដ្ឋាភិបាលជាអង្គការនីតិប្រតិបត្តិមានភារកិច្ចការពាររដ្ឋធម្មនុញ្ញ អនុវត្តតាមច្បាប់ផ្សេងៗដែលបានអនុម័តដោយអង្គការនីតិបញ្ញត្តិ និងអនុវត្តកម្មវិធីនយោបាយរបស់រដ្ឋស្របតាមរដ្ឋធម្មនុញ្ញ។<br>-រដ្ឋាភិបាលទទួលស្គាល់នូវសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។<br>-រដ្ឋាភិបាលមានសិទ្ធិអំណាចចរចាធ្វើទំនាក់ទំនងពាណិជ្ជកម្មនិងសហប្រតិបត្តិការសេដ្ឋកិច្ចវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេសជាមួយបរទេស។<br>-រដ្ឋាភិបាល ត្រូវការពារនីត្យានុកូលភាពជាតិធានាសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ យកចិត្តទុកដាក់ចំពោះ ជីវភាពប្រជាជន។ | ខ-សិស្សពិភាក្សាក្រុម |

| | | |
|---|---|---|
| | -រាជរដ្ឋាភិបាល ត្រូវការពារឯករាជ្យអធិបតេយ្យ បូរណភាពទឹកដី រក្សាការពារទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ។ | |
| គ-ក្រុមទី៣ | -ការប្រមូលផ្ដុំអំណាច នៅតែថ្នាក់កណ្ដាលធ្វើឱ្យដំណើរការរដ្ឋបាលកណ្ដាល មានបន្ទុកដ៏ធ្ងន់ធ្ងរ ប្រធានរដ្ឋាបាលកណ្ដាលមកការរវល់ខ្លាំង ហើយពេលខ្លះមិនក្រសោបការងារឱ្យល្អបានទេ<br>-ពុំទាន់អនុវត្តវិមជ្ឈការបានល្អ គឺរៀបចំផែនការរដ្ឋបាលកណ្ដាលរៀបចំតែម្នាក់ឯងធ្វើឱ្យមានការលំបាកក្នុងការអនុវត្តនៅថ្នាក់ក្រោម ព្រោះថ្នាក់ក្រោមមិនបានយល់ ដែលនាំឱ្យផែនការបរាជ័យ។<br>-ការបំពេញការងារបម្រើសេវាដល់ប្រជាពលរដ្ឋ ពុំទាន់បានល្អដូចមានកំណត់នៅ ក្នុងកម្មវិធីគោលនយោបាយរបស់រដ្ឋាភិបាល។<br>-ធនធាននានាពុំទាន់មានគ្រប់គ្រាន់ឆ្លើយតបនឹងតម្រូវការជាក់ស្ដែងតាមតម្រូវការសង្គម។ | គ-សិស្សពិភាក្សា |
| ឃ-ក្រុមទី៤ | **ឃ-កំណែទម្រង់របស់រាជរដ្ឋាភិបាល**<br>-ការកែទម្រង់រដ្ឋបាលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កើតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយសង្ឃឹមថា នឹងទទួលបានផលប្រយោជន៍សំខាន់ៗដូចជា៖<br>- ផ្ដល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាព<br>- បង្កើននូវលទ្ធភាពនៃការរកប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្ដល់សេវា និងការអភិវឌ្ឍ។<br>ទិសដៅកំណែទម្រង់រដ្ឋបាល ដើម្បីលើកកម្ពស់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋធ្វើសេចក្ដីសម្រេចទាក់ទងនឹងតម្រូវការចាំបាច់នានានៅមូលដ្ឋាន។<br>-ដូចនេះរាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិនីមួយៗ | ឃ-សិស្សពិភាក្សាក្រុម |

| | | |
|---|---|---|
| | មានទាំងគុណសម្បត្តិ គុណវិបត្តិ និងកំណែទម្រង់ជាបន្តបន្ទាប់ ទើបបំពេញការងារឆ្លើយតបនឹងសំណូមពររបស់ប្រជាជនរស់នៅ ក្នុងរបបសង្គមប្រជាធិបតេយ្យ។ | |
| -តើរាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៦ កន្លងផុតបានកែទម្រង់លើវិស័យណាខ្លះ?<br>-ចូរប្អូនៗរៀបរាប់។ | **ជំហានទី៤**<br>**៣ត្រិះរិះពុទ្ធិ**(៧នាទី) | -សិស្សឆ្លើយ |
| ចូរប្អូនៗរៀបរាប់ពីគុណសម្បត្តិរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៧នេះ។ | **ជំហានទី៥**<br>បណ្តាំផ្ញើ(៣នាទី) | កត់ត្រាកិច្ចការផ្ទះ |

ដូច្នេះ ការសិក្សាពីពលរដ្ឋសកល និងពលរដ្ឋពេញលេញពិតជាមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ ដើម្បីប្រែក្លាយមនុស្សទៅជាពលរដ្ឋមានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាដើម្បីរួមចំណែកកសាង និងអភិវឌ្ឍសហគមន៍ និងសង្គមប្រកបដោយការរីកចម្រើន និងសុខសន្តិភាពពិសេសរួមគ្នាកសាងពិភពលោកគ្មានអំពើហិង្សា និងសហគមន៍ប្រកបដោយសន្តិភាពដោយផ្តើមចេញពីពលរដ្ឋម្នាក់ៗទាំងអស់គ្នា។

## សំណួរពិភាក្សា

១-តើកត្តាអ្វីខ្លះតម្រូវឱ្យវិស័យអប់រំក្នុងប្រទេសនីមួយៗបណ្តុះបណ្តាលអប់រំសិស្សនិស្សិតក្លាយជាពលរដ្ឋសកល ហើយត្រូវរៀបចំសកម្មភាពបណ្តុះបណ្តាលយ៉ាងដូចម្តេច?

២-តើការបណ្តុះបណ្តាលពលរដ្ឋពេញលេញក្នុងសង្គមខ្មែរមានសារៈសំខាន់យ៉ាងណាខ្លះក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិខ្មែរពេលបច្ចុប្បន្ន?

៣-តើក្រសួងអប់រំ យុវជន និងកីឡាបានធ្វើសកម្មភាពអ្វីខ្លះក្នុងការបណ្តុះបណ្តាលសិស្ស និស្សិតឱ្យក្លាយជាពលរដ្ឋពេញលេញក្នុងប្រព័ន្ធអប់រំកម្ពុជា?

៤-ចូរលោកគ្រូ អ្នកគ្រូរៀបចំកិច្ចតែងការបង្រៀនដោយបញ្ជ្រាបនូវខ្លឹមសារពលរដ្ឋសកលតាមមុខវិជ្ជាឯកទេសនីមួយៗដល់គរុនិស្សិត។

## មេរៀនទី២៖ ផែនទីបង្ហាញផ្លូវនៃការអប់រំកម្ពុជានៅឆ្នាំ២០៣០

### ២-១-វត្ថុបំណងមេរៀន

**ក-វិជ្ជាសម្បទា**

- រៀបរាប់បានពីគោលនយោបាយ និងសកម្មភាពអនុវត្តក្នុងសសរស្តម្ភទាំង៥ឆ្ពោះទៅឆ្នាំ២០៣០ បានច្បាស់លាស់តាមរយៈការអានមេរៀន
- រៀបរាប់បានពីកត្តាសំខាន់ៗសម្រាប់ការអប់រំនៅមធ្យមសិក្សា និងអប់រំបច្ចេកទេស
- ពិពណ៌នាពីកត្តាខាងក្រៅ ដែលជះឥទ្ធិពលលើការសិក្សារបស់សិស្សនៅមធ្យមសិក្សា
- បង្ហាញពីបញ្ហាប្រឈមនៃការអប់រំនៅមធ្យមសិក្សា និងការអប់រំបច្ចេកទេស

**ខ-បំណិនសម្បទា**

- វិភាគបានពីគោលនយោបាយ និងសកម្មភាពអនុវត្តក្នុងសសរស្តម្ភទាំង៥ ឆ្ពោះទៅឆ្នាំ២០៣០បានច្បាស់លាស់តាមរយៈការពិភាក្សាក្រុម
- វាយតម្លៃបានពីកត្តាសំខាន់ៗដែលពាក់ព័ន្ធនឹងការបង្រៀន និងរៀននៅមធ្យមសិក្សា និងការអប់រំបច្ចេកទេស
- វាយតម្លៃបានពីបញ្ហាប្រឈម និងការផ្លាស់ប្តូរនៃការអប់រំនៅមធ្យមសិក្សាឆ្ពោះទៅឆ្នាំ២០៣០

**គ-ចរិយាសម្បទា**

- មានឆន្ទៈចូលរួមសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមនានា ដើម្បីរកដំណោះស្រាយធ្វើឱ្យការអប់រំនៅមធ្យមសិក្សា និងការអប់រំបច្ចេកទេសមានភាពប្រសើរឡើង។

### ២-២-សេចក្តីផ្តើម

អង្គការសហប្រជាជាតិ(UN)បានកំណត់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ដែលបានអនុម័តក្នុងខែកញ្ញាឆ្នាំ២០១៥ ដោយមេដឹកនាំពិភពលោកចំនួន១៩៣ នៅក្នុងកិច្ចប្រជុំកំពូលនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិនៅទីក្រុងញូវយ៉ក។ របៀបវារៈមាន១៧គោលដៅ និង១៦៩ចំណុចដៅបានចូលជាធរមាននៅថ្ងៃទី១មករាឆ្នាំ២០១៦។ គោលដៅ១៧រួមមាន(១)លុបបំបាត់ភាពក្រីក្រ (២)គ្រោះឥតឃ្លានស្មើសូន្យ (៣)សុខភាព និងសុខុមាលភាពមាំមួន (៤)គុណភាពអប់រំ (៥)សមភាពយេនឌ័រ (៦)ទឹកស្អាត និងអនាម័យ (៧)ថាមពល ដែលមានតម្លៃសមរម្យ (៨)ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច (៩)ឧស្សាហកម្ម នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ (១០)កាត់បន្ថយវិសមភាព(១១)ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព (១២)ការប្រើប្រាស់ និងការផលិតប្រកបដោយទំនួលខុសត្រូវ (១៣)សកម្មភាពបរិស្ថាន(១៤)ជីវិតក្រោមទឹក (១៥)ជីវិតលើផែនដី(១៦)សន្តិភាព យុត្តិធម៌ និងស្ថាប័នរឹងមាំ និង(១៧) ភាពជាដៃគូដើម្បីសម្រេចគោលដៅខាងលើ[24]។

---

[24] https://cambodia.un.org/km/sdgs

ចក្ខុវិស័យរបស់របស់អង្គការសហប្រជាជាតិ គឺមានគោលដៅផ្លាស់ប្តូរជីវិតឱ្យល្អប្រសើរឡើងតាមរយៈការអប់រំ[25] និងការទទួលស្គាល់សារៈសំខាន់តួនាទីនៃការអប់រំដែលជាកត្តាជំរុញដ៏សំខាន់ក្នុងអភិវឌ្ឍន៍ និងសម្រេចបាននូវសមិទ្ធផលធំៗ។ ចក្ខុវិស័យថ្មីនេះត្រូវបានធានាថា ជារួមបញ្ចូលនូវការអប់រំប្រកបដោយគុណភាព សមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ទស្សនៈថ្មីនេះត្រូវផ្អែកលើសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរ សង្គមយុត្តិធម៌ ការការពារវប្បធម៌ចម្រុះនៃភាសា និងជនជាតិភាគតិច និងចែករំលែកទំនួលខុសត្រូវ ដើម្បីឈានទៅលុបបំបាត់ភាពក្រីក្រ។ រដ្ឋាភិបាលនីមួយៗបានប្តេជ្ញាចំពោះការអប់រំប្រកបដោយគុណភាព ដើម្បីកែលម្អលទ្ធផលសិក្សា ដែលទាមទារនូវការពង្រឹងធាតុចូល ដំណើរការ និងការវាយតម្លៃលទ្ធផល និងយន្តការវាស់វែងវឌ្ឍនភាព។ យើងនឹងធានាថា គ្រូបង្រៀន និងអ្នកអប់រំទាំងឡាយមានផ្តល់សិទ្ធិអំណាច ទទួលបានគ្រប់គ្រាន់បណ្តុះបណ្តាលបានល្អ មានសមត្ថភាពវិជ្ជាជីវៈ ការលើកទឹកចិត្ត និងប្រព័ន្ធគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព។

ការអប់រំប្រកបដោយគុណភាព ជំរុញការច្នៃប្រឌិត និងចំណេះដឹង និងធានាការទទួលបាននៃជំនាញមូលដ្ឋាននៃអក្ខរកម្ម និងលេខនព្វន្តក៏ដូចជាការវិភាគ ការដោះស្រាយបញ្ហា និងការយល់ដឹងកម្រិតខ្ពស់ផ្សេងទៀតជំនាញអន្តរបុគ្គល និងសង្គម។ អភិវឌ្ឍជំនាញ តម្លៃ និងអាកប្បកិរិយាដែលអាចឱ្យប្រជាពលរដ្ឋមានសុខភាពល្អ និងបំពេញជីវិតធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹងនិងឆ្លើយតបទៅនឹងមូលដ្ឋាន និងសកលបញ្ហាប្រឈមតាមរយៈការអប់រំសម្រាប់ការអភិវឌ្ឍនប្រកបដោយនិរន្តរភាព(ESD) និងការអប់រំពលរដ្ឋសកល(GCED)។

អង្គការសហប្រជាជាតិប្តេជ្ញាលើកកម្ពស់គុណភាពអប់រំពេញមួយជីវិត ផ្តល់ឱកាសសិក្សាសម្រាប់ទាំងអស់គ្នារួមបញ្ចូលសមធម៌ បរិយាបន្ន និងបង្កើនសិទ្ធិចូលរៀន គុណភាពអប់រំបច្ចេកទេស ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងឧត្តមសិក្សា និងការស្រាវជ្រាវផ្តោតលើគុណភាពអប់រំជាអាទិភាព។ លើសពីនេះទៀតត្រូវផ្តល់នូវផែនទីអប់រំមួយអាចបត់បែនបានក៏ដូចជា ការទទួលស្គាល់នៃចំណេះដឹង ជំនាញ និងសមត្ថភាពតាមរយៈការអប់រំមិនផ្លូវការ(Informal Education) និងការអប់រំក្រៅប្រព័ន្ធ(Non-formal Education) មានសារៈសំខាន់ណាស់ ដើម្បីធានាថា យុវជនទាំងអស់និងមនុស្សពេញវ័យជាពិសេសក្មេងស្រី និងស្ត្រីទទួលបាននូវកម្រិតជំនាញផ្នែកលេខនព្វន្ត អក្ខរកម្ម(ICTs) និងជំនាញវិជ្ជាជីវៈសម្រាប់ជីវិត ហើយប្តេជ្ញាពង្រឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការច្នៃប្រឌិត ព័ត៌មាននិងបច្ចេកវិទ្យាទំនាក់ទំនង(ICTs) ដើម្បីពង្រឹងប្រព័ន្ធអប់រំ ចំណេះដឹង ការផ្សព្វផ្សាយ ការទទួលបានព័ត៌មាន ការរៀនសូត្រប្រកបដោយគុណភាព និងប្រសិទ្ធភាព និងការផ្តល់សេវាកាន់តែមានប្រសិទ្ធភាព។

ការអប់រំ គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ដើម្បីបំពេញសិទ្ធិនេះបានប្រទេសនានាត្រូវតែធានាឱ្យមានសមភាពជាសកលលទ្ធភាពទទួលបានគុណភាព និងសមធម៌ ការអប់រំ និងការរៀនសូត្រ ដែលឥតគិតថ្លៃ

[25] https://uis.unesco.org/sites/default/files/documents/education-2030

និងជាកំហិតដោយមិនទុកនរណាម្នាក់ឡើយពុំទទួលបានការអប់រំឡើយ។ ការអប់រំត្រូវមានគោលបំណងពេញលេញគឺអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់មនុស្ស និងលើកកម្ពស់ការយល់ដឹងគ្នាទៅវិញទៅមក ការអត់ឱន មិត្តភាព និងសន្តិភាពប្រកបដោយសុខដុមនីយកម្ម។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើទំនើបកម្មប្រព័ន្ធអប់រំ ដើម្បីអភិវឌ្ឍនូវរបៀបវារៈប្រកបដោយចីរភាព បរិយាបន្ន និងសមធម៌តាមរយៈការខិតខំពង្រឹងសាមគ្គីភាពជាតិពីគ្រប់ស្រទាប់វណ្ណៈនិន្នាការនយោបាយ និងគ្រប់ជាតិសាសន៍ ដើម្បីរក្សាបាននូវសន្តិភាព និងសុខដុមនីយកម្មធានាបាននូវការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជាឆ្នាំ២០៣០ ដើម្បីជំរុញការធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅប្រទេសកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥[26]។ ក្នុងនោះត្រូវទទួលស្គាល់ពីភាពចាំបាច់នៃការកសាងកម្មករជំនាញ បច្ចេកទេសវិស្វករអ្នកវិទ្យាសាស្ត្រ ដើម្បីឈានទៅសម្រេចរបៀបវារៈនៃការអភិវឌ្ឍវិស័យកម្មន្តសាល។ ជាមួយគ្នានេះវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានដើរតួនាទីជាកម្លាំងចលករដែលពុំអាចខ្វះបានក្នុងការផ្លាស់ប្តូរបែបផែននៃកំណើនសេដ្ឋកិច្ចបែបប្រពៃណីទៅជាកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាព ព្រមទាំងជួយលើកកម្ពស់វិបុលភាព សន្តិសុខ សុវត្ថិភាព សេដ្ឋកិច្ចសង្គម និងគុណភាពជីវិតឱ្យកាន់តែប្រសើរឡើងសម្រាប់ជាតិមាតុភូមិ។

ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជាឆ្នាំ២០៣០ ផ្តោតលើសសរស្តម្ភសំខាន់ចំនួន៥គឺ១-អភិបាលកិច្ច ២-ការអប់រំ ៣-ការស្រាវជ្រាវ និងអភិវឌ្ឍ ៤-កិច្ចសហការ និងបណ្តាញ និង ៥-ប្រព័ន្ធអេកូឡូស៊ីសមស្រប។ សសរស្តម្ភទាំងនេះស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិផ្សេងៗរួមមានយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ២០១៩-២០២៣ គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០២០-២០៣០ និងផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥ជាដើម។

**២.៣.សសរស្តម្ភទាំង៥នៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

មុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤(២០១៨-២០២៣) បានកំណត់ពីការអភិវឌ្ឍធនធានមនុស្សរួមមាន(១)ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(២)ការបណ្តុះបណ្តាលជំនាញបច្ចេកទេស(៣)ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ និង(៤)ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។ សម្តេចតេជោហ៊ុន សែននាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជាបានលើកឡើងថា «ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០ គឺជាសម្បត្តិដ៏មានសារៈសំខាន់ និងទាន់សភាពការណ៍ក្នុងការតម្រង់ទិសមិនត្រឹមតែទៅរកការស្តារសេដ្ឋកិច្ច

[26]អ.យ.ក, ផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ២០៣០,ទំ.៩។

ឡើងវិញប៉ុណ្ណោះទេ តែថែមទាំងការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនផលិតភាពទៀតផង។ ក្នុងន័យនេះ ផែនទីបង្ហាញផ្លូវនឹងក្លាយជាកាតាលីករ ក្នុងការធ្វើបរិវត្តកម្មសេដ្ឋកិច្ចពីសេដ្ឋកិច្ចអតិពលកម្មទៅជាសេដ្ឋកិច្ចផ្អែកលើជំនាញ ហើយប្រែក្លាយជាប្រជាជាតិមួយដែលយកនវានុវត្តន៍ជាមូលដ្ឋានក្នុងការអភិវឌ្ឍ»[27]។ផែនទីនេះជាការពង្រឹងសមត្ថភាពខាងផ្នែកបច្ចេកវិទ្យា និងការលើកកម្ពស់សមិទ្ធកម្មនវានុវត្តន៍ និងជាកត្តាគន្លឹះកំណត់ការសម្រេចឱ្យបាននូវទស្សនវិស័យប្រកបដោយមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

ចំពោះយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១នៃរាជរដ្ឋាភិបាលកម្ពុជា(២០២៣-២០២៨) ដែលក្នុងនោះផ្តោតអភិវឌ្ឍមូលធនមនុស្ស(ទី១-ពង្រឹងគុណភាពវិស័យអប់រំកីឡា វិទ្យាសាស្ត្រ និងបច្ចេកទេស ទី២-បណ្តុះបណ្តាលជំនាញបច្ចេកទេស ទី៣-លើកកម្ពស់សុខភាព និងសុខុមាលភាព ទី៤-ពង្រឹងប្រព័ន្ធគាំពារសង្គម និងស្បៀង និងទី៥-ពង្រឹងភាពជាពលរក្នុងសង្គម)។ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានលើកឡើង៤ចំណុចសំខាន់ៗ ក្នុងគោលដៅពង្រឹងគុណភាពគ្រឹះស្ថានសិក្សារដ្ឋចាប់ពីថ្នាក់មត្តេយ្យសិក្សាដល់មធ្យមសិក្សារួមមាន(ទី១).ការពង្រឹងអភិបាលកិច្ចសាលារៀន,(ទី២).ការពិនិត្យ កែសម្រួល និងរៀបចំកម្មវិធីសិក្សា, និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង, វិន័យ, សីលធម៌ និងឥរិយាបថរបស់សិស្ស,(ទី៣).ការយកចិត្តទុកដាក់លើសុខភាពរបស់សិស្សតាមរយៈកម្មវិធី អាហារូបត្ថម្ភដល់កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន និង(ទី៤). ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់មាតាបិតាអ្នកអាណាព្យាបាល និងសហគមន៍ក្នុងការអប់រំស្របតាមពាក្យស្លោក «ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ[28]»។

ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានថ្លែងថា វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាឆ្អឹងខ្នង ដែលនាំឱ្យមានជោគជ័យនៅក្នុងដំណើរការអភិវឌ្ឍប្រទេស និងមានគោលដៅទាក់ទាញការវិនិយោគនៅក្នុងវិស័យឧស្សាហកម្ម។ រដ្ឋាភិបាលកម្ពុជាបានចាប់យកវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាការសម្រេចចិត្តដ៏សំខាន់មួយដែលនឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាឈានជើងចូលទៅក្នុងសករាជថ្មីនៃអារ្យធម៌ដ៏រស់រវើក។

លោកស្រី Armida Salsiah Alisjahbana អគ្គលេខាធិការរងអង្គការសហប្រជាជាតិ និងជាលេខាប្រតិបត្តិនៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក(ESCAP) បានសាទរការដាក់ឱ្យ

---

[27] https://www.postkhmer.com/business/

[28] សន្និបាតអប់រំឆ្នាំ២០២៣។

ប្រើប្រាស់ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០ ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបរិយាបន្ន និងការអនុវត្តគោលនយោបាយនានា[29]។




រូបភាពទី៥៖ សសរស្តម្ភទាំង៥នៃ.វ.ប.ន។

ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០ត្រូវបានតាក់តែងឡើងដោយមានសសរស្តម្ភចំនួន៥ជាមូលដ្ឋានរួមមាន៖

**២-៣-១-សសរស្តម្ភទី១ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តជាតិ**

គោលដៅពង្រឹងអភិបាលកិច្ចនៃប្រព័ន្ធវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដែលក្រសួងនេះគឺជាស្ថាប័នដឹកនាំការសម្របសម្រួលលើការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ក-គោលដៅគោលនយោបាយ

កម្ពុជាបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតាខ្ពស់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងចក្ខុវិស័យឆ្នាំ២០៥០។

- ការវិនិយោគរួមគ្នារវាងស្ថាប័នសាធារណៈ និងឯកជនទៅលើវិស័យវ.ប.ន. ត្រូវមានចំនួន១% នៃផលិតផលក្នុងស្រុកសរុប(ផ.ស.ស.)នៅឆ្នាំ២០៣០។ ការវិនិយោគពីសាធារណៈលើវិស័យវ.ប.ន.ត្រូវមានចំនួន០,៥% នៃផ.ស.ស.នៅឆ្នាំ២០៣០។
- ហិរញ្ញប្បទានសាធារណៈសម្រាប់សកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍ ផ្តោតសំខាន់ទៅលើការ

[29] https://freshnewsasia.com/index.php/en/localnews

ឈានទៅសម្រេចសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ថ្នាក់ជាតិនៅឆ្នាំ២០៣០រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) សមាហរណកម្មខ្សែច្រវ៉ាក់តម្លៃតំបន់។

ខ-សកម្មភាពដើម្បីសម្រេចគោលនយោបាយ

- កំណត់តួនាទីនៃភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយវ.ប.ន.
- ពង្រីកការយល់ដឹង និងសមត្ថភាពរបស់រដ្ឋភិបាលក្នុងការអនុវត្តគោលនយោបាយវ.ប.ន.
- ត្រួតពិនិត្យ និងវាយតម្លៃនៃផែនទីបង្ហាញផ្លូវដើម្បីរៀបចំគោលនយោបាយផ្អែកលើភស្តុតាង

**២-៣-២-សសរស្តម្ភទី២ ការអប់រំ ដើម្បីកសាងមូលធនបញ្ញាផ្នែកធនធានមនុស្ស**

គោលដៅកសាងធនធានមនុស្សក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការបង្កើនចំនួនសិស្ស និស្សិតសិក្សាផ្នែកស្ទែម(STEM) នៅតាមវិទ្យាល័យ និងសកលវិទ្យាល័យឱ្យបានយ៉ាងតិចចំនួន៥០%។ ការពង្រឹង និងលើកតម្កើងកម្មវិធី(STEM, Science Technology Engineering Mathematics)ក្នុងចំណោមយុវជន និងការទាក់ទាញបុគ្គលដែលមានទេពកោសល្យពីបរទេស។

ក-គោលនយោបាយ

ប្រទេសកម្ពុជាមានគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចផ្អែកលើឧស្សាហកម្ម និងមានមហិច្ឆតាប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០តម្រូវការនូវធនធានមនុស្សប្រកបដោយគុណភាពជាពិសេសកម្មវិធី(STEM)ពិតមានសារៈសំខាន់ខ្លាំងណាស់។ ការលើកកម្ពស់ជំនាញនៅក្នុងចំណោមកម្លាំងពលកម្មដែលមានស្រាប់ក៏ដូចជាកម្លាំងពលកម្មថ្មី ដែលធ្វើការក្នុងវិស័យនេះគឺជាកិច្ចការដ៏សំខាន់មួយ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសជាពិសេសនៅក្នុងវិស័យដែលពឹងផ្អែកលើបច្ចេកវិទ្យាអាចបង្កើតការងារក្នុងស្រុកជាមួយនឹងការបង្កើនតម្លៃបន្ថែម និងដើម្បីនាំចេញទំនិញក៏ដូចជាសេវាកម្មទៅកាន់ទីផ្សារអន្តរជាតិ។ ក្នុងន័យនេះ ការអប់រំបណ្តុះបណ្តាលធនធានមនុស្សដែលមានជំនាញកម្រិតខ្ពស់ក្នុងស្ទែម(STEM)គឺជាកិច្ចការដែលត្រូវអនុវត្ត។

ជានិច្ចកាល គេសង្កេតឃើញមានអតុល្យភាពរវាងការចុះឈ្មោះចូលរៀនក្នុងជំនាញស្ទែម និងមិនមែនស្ទែមនៅថ្នាក់ចំណេះទូទៅ និងឧត្តមសិក្សាមានកម្រិតខុសគ្នា។ នៅប្រទេសកម្ពុជាការចុះឈ្មោះចូលរៀនយ៉ាងច្រើននៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីសិក្សាលើមុខជំនាញមិនមែនស្ទែមដូចជា ផ្នែកអាជីវកម្ម ការគ្រប់គ្រងសេដ្ឋកិច្ច មនុស្សសាស្ត្រ និងគណនេយ្យ ដែលជាហេតុនាំឱ្យធនធានមនុស្សក្នុងជំនាញមិនមែនស្ទែមច្រើនហួសពីតម្រូវការទីផ្សារ។ ដូច្នេះ ដើម្បីប្រើប្រាស់ និងអភិវឌ្ឍផ្ទេរបច្ចេកវិទ្យាទៅក្នុងទីផ្សារ បានកិច្ចការចាំបាច់ដែលត្រូវធ្វើ គឺការបណ្តុះបណ្តាលអ្នកជំនាញបច្ចេកទេសនៅតាមស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(TVET) បន្ថែមលើធនធានវិស្វករ និងអ្នកវិទ្យាសាស្ត្រ ដែលមានស្រាប់។

ក្នុងរយៈពេលមធ្យម និងវែងតម្រូវការធនធានមនុស្សដែលមានជំនាញផ្នែកការបង្រៀន ការស្រាវជ្រាវ និងនវានុវត្តន៍នឹងមានការកើនឡើង។ ស្ថិតក្នុងបរិការណ៍នេះ ដើម្បីជានាឱ្យមានជំនាញទាំងនេះ គេត្រូវតែអនុវត្តសកម្មភាពដើម្បីលើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គមសំដៅកសាងធនធានមនុស្សរឹងមាំនៅក្នុងជំនាញស្ទែម និងពង្រឹងការងារបង្រៀនស្ទែមតាមរយៈគ្រឹះស្ថានចំណេះទូទៅ សាលាបណ្ដុះបណ្ដាលបច្ចេកទេស និងគ្រឹះស្ថានឧត្ដមសិក្សានានា។ គោលនយោបាយបណ្ដុះបណ្ដាលចាប់ពីថ្នាក់សិក្សាមូលដ្ឋានរហូតដល់ថ្នាក់ឧត្ដមសិក្សា គឺត្រូវមានការចូលរួមសហការគ្នាក្នុងចំណោមក្រសួងនានាដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង .វ.ប.ន.នឹងរៀបចំឡើង។ យោងតាមស្ថិតិនៃនាយកដ្ឋានឧត្ដមសិក្សាឆ្នាំ២០១០-២០១៦,MOEYS នៅក្នុងឆ្នាំ២០១៦ មាននិស្សិត ២០%(៤៤.០០០នាក់)នៃនិស្សិតបញ្ចប់ការសិក្សាចំនួន២២២.០០០នាក់ពីគ្រឹះស្ថានឧត្ដមសិក្សាដែលបានសិក្សាជំនាញ។ បើតាមផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០យ៉ាងហោចណាស់៤០%និស្សិតបញ្ចប់ការសិក្សាផ្នែកស្ទែមជាស្ត្រីនៅឆ្នាំ២០៣០[30]។

ប្រទេសជាច្រើននៅលើពិភពលោក ស្ត្រីសិក្សាផ្នែកសិក្សាស្ទែម(STEM) នៅមានភាគរយតិចតួចនៅឡើយ ប៉ុន្តែសម្រាប់នៅប្រទេសកម្ពុជាមានសហគ្រិនជាស្ត្រីបានចូលសិក្សាផ្នែកនេះមានចំនួន៣០% ប៉ុន្តែស្ត្រីបម្រើការងារផ្នែកនេះមានប្រហែល៨ទៅ១០%ប៉ុណ្ណោះ។ដោយឡែកគោលបំណងរបស់យើងនៅឆ្នាំ២០៣០ គឺចង់ឱ្យសិស្ស និស្សិតជាស្ត្រីកើនរហូតដល់៤០%បានបញ្ចប់ការសិក្សាផ្នែកស្ទែមនៅកម្រិតមធ្យមសិក្សា និងឧត្ដមសិក្សា ដែលទាមទារឱ្យមានការជំរុញចូលរៀនមុខវិទ្យាសាស្ត្រចាប់ពីកម្រិតបឋមសិក្សា និងបន្តចូលមធ្យមសិក្សាដោយមានការគាំទ្រពីរដ្ឋាភិបាល និងដៃគូឯកជនផងដែរ។

រូបភាពទី៦៖ សកម្មភាពសិស្សជាស្ត្រីចូលរួមពិសោធឆ្នាំ២០២២។

- កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតនឹងត្រូវរៀបចំឡើងដោយមានការសហការមួយវិស័យឯកជននៅមុខឆ្នាំ២០២៥ដោយនឹងបញ្ចូលកម្មវិធីស្ទែម។
- វេទិកាបច្ចេកវិទ្យា មន្ទីរពិសោធន៍ដែលមានសម្ភារៈដូចជា រ៉ូបូត សិនស័រ រូបថត(Imagery) នឹងត្រូវបង្កើតឡើងនៅតាមសកលវិទ្យាល័យ និងគ្រឹះស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងគោលបំណងអប់រំនៅឆ្នាំ ២០២៤ និងមាននិស្សិតប្រើប្រាស់ចំនួន៥០០នាក់។
- សារមន្ទីរវិទ្យាសាស្ត្រ ឬជាមជ្ឈមណ្ឌលអប់រំវិទ្យាសាស្ត្រមានតួនាទីលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រដល់កុមារនៅទូទាំងប្រទេសនៅឆ្នាំ២០២៣ ដោយមន្ទីរមួយមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ។

[30] ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០,២០២១,ទំ.១៣។

- រៀបចំព្រឹត្តិការណ៍ចំនួន២០ថ្ងៃ ដែលទាក់ទិននឹងនវានុវត្តន៍ ឬវេទិកានវានុវត្តន៍ចំនួន២០ដងគិតត្រឹមឆ្នាំ២០៣០ ដើម្បីបញ្ជ្រាបព័ត៌មានដល់ប្រជាជន១០០០០នាក់ សហគ្រាសធុនតូច និងមធ្យមចំនួន៥ ០០០ និងមន្ត្រីរាជការចំនួន១.០០០នាក់។

- បណ្ណាល័យវិទ្យាសាស្ត្រចំនួន៣ នឹងបើកដំណើរនៅក្នុងប្រទេសនៅត្រឹមឆ្នាំ២០៣០ ដោយបណ្ណាល័យមួយស្ថិតនៅក្នុងរាជធានីភ្នំពេញ។

ខ-សកម្មភាព ដើម្បីសម្រេចគោលនបាយ

- ពង្រឹងវប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គមខ្មែរ

ការកសាងយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាគប្បីរៀបចំឱ្យបាននៅក្នុងការសិក្សាគ្រប់កម្រិតទាំងអស់សំដៅលើកកម្ពស់ការយល់ដឹងអំពីអាជីពការងារ ដែលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាឌីជីថល វិទ្យាសាស្ត្រនៅក្នុងស្រទាប់យុវជន និងក្រុមគ្រួសារ។ ការកសាងយុទ្ធសាស្ត្រនេះគប្បីមានការសហការគ្នាក្នុងចំណោមក្រសួង ស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង.វ.ប.ន.។ គោលបំណងសំខាន់នៃការកសាងយុទ្ធសាស្ត្រនេះ ដើម្បីបណ្តុះចំណាប់អារម្មណ៍របស់សិស្សនិស្សិតក៏ដូចជាឥរិយាបថវិជ្ជមានចំពោះមុខវិជ្ជាវិទ្យាសាស្ត្រ នៅថ្នាក់មធ្យមសិក្សាចំណោះទូទៅព្រមទាំងដើម្បីបង្កើនទំនុកចិត្ត និងលើកទឹកចិត្តសិស្ស-និស្សិតទាំងនោះឱ្យបន្តការសិក្សាលើផ្នែកវិទ្យាសាស្ត្រ ឬមុខវិជ្ជាដែលទាក់ទងនឹងស្ទែមនៅថ្នាក់ឧត្តមសិក្សា។ យុទ្ធការទ្រង់ទ្រាយធំជាច្រើននឹងត្រូវរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយក្នុងចំណោមអាជីវកម្ម សហគ្រិន យុវជន និងសាធារណជនទូទៅរហូតដល់ឆ្នាំ២០៣០ដែលរួមមានការតាំងពិព័រណ៍វិទ្យាសាស្ត្រជាលក្ខណៈអន្តរជាតិ មហោស្រពវិទ្យាសាស្ត្រ កម្មវិធីចូលទស្សនាដោយសេរីនៅតាមសកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ យុទ្ធនាការនៅលើប្រព័ន្ធទំនាក់ទំនងសង្គម ការប្រកួតប្រជែងទាក់ទិនផ្នែកវិទ្យាសាស្ត្រ ការលេងកម្សាន្ត និងកម្មវិធីទូរស័ព្ទជាដើម។ បន្ថែមទៀតនោះ សារមន្ទីរ និងបណ្ណាល័យវិទ្យាសាស្ត្រនឹងត្រូវបានបង្កើតឡើង ដើម្បីបង្កើនការលើកកម្ពស់ជំរុញក្នុងចំណោមសាធារណជនទូទៅ និងបង្កើនការទទួលបានចំណេះរឿងសម្រាប់អ្នកមានវិជ្ជាជីវៈ។

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំសេចក្តីព្រាងគោលនយោបាយមួយក្នុងគោលបំណងលើកកម្ពស់ការតភ្ជាប់ឌីជីថល និងបញ្ចូលស្ទែមទៅក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាដូចជា៖

- ដាក់បញ្ចូលក្នុងកម្មវិធីសិក្សាផ្នែកវិទ្យាសាស្ត្រឌីជីថល និងសហគ្រិនភាពទៅក្នុងថ្នាក់កម្រិតបឋមសិក្សា និងមធ្យមសិក្សា។
- ដាក់បញ្ចូលវគ្គបណ្តុះបណ្តាលដល់គ្រូ ដែលបង្រៀនស្ទែម ដោយប្រើប្រាស់វិធីសាស្ត្រ បច្ចេកទេសបង្រៀនប្រកបដោយគំនិតនវានុវត្តន៍ អន្តរកម្ម ចំណាយតិច និងងាយស្រួលសម្រាប់គ្រូ។

- បង្កើនភាពទាក់ទាញនៅក្នុងកម្មវិធីសិក្សាជំនាញស្ទែម និងបង្កើនចំនួននិស្សិតបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា

○ បញ្ចូលវប្បធម៌វិទ្យាសាស្ត្រនិងនៅអវត្តន៍ទៅក្នុងកម្មវិធីសិក្សានៅថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។

○ ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសបង្រៀនប្រកបដោយនវានុវត្តន៍ដូចជា បច្ចេកទេសអន្តរកម្ម និងការអនុវត្តជាក់ស្តែងលើឧបករណ៍ជាដើម។

○ លើកកម្ពស់អ្នកវិទ្យាសាស្ត្រយុវជនតាមរយៈការប្រកួតប្រជែងលើនវានុវត្តន៍ និងសហគ្រិនភាពសម្រាប់និស្សិតផ្នែកស្ទែម និងលើកកម្ពស់កម្មវិធីនិស្សិតឆ្នើមផ្នែកស្ទែមប្រចាំឆ្នាំ។

○ កសាងកិច្ចសហការអន្តរជាតិជាមួយវិទ្យាស្ថានស្រាវជ្រាវ និងគ្រឹះស្ថានឧត្តមសិក្សាដែលឈានមុខសំដៅទាក់ទាញសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ ដែលមានទេពកោសល្យពីបរទេសដោយផ្តល់ជូនកញ្ចប់ថវិកាលើកទឹកចិត្ត ដែលគួរឱ្យទាក់ទាញ (Talents Grants In)។

○ ផ្តួចផ្តើម និងគាំទ្រឱ្យមានកិច្ចសហការដ៏រឹងមាំបន្ថែមទៀតជាមួយវិស័យឯកជន ដើម្បីរៀបចំបង្កើតកម្មវិធីចុះកម្មសិក្សា និងហ្វឹកហ្វឺនការងារជាប្រព័ន្ធសម្រាប់និស្សិតស្ទែម ព្រមទាំងសហការរៀបចំបង្កើតកម្មវិធីសិក្សាស្ទែមឱ្យឆ្លើយតទៅនឹងតម្រូវការក្នុងវិស័យឧស្សហកម្ម។

○ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងឧបករណ៍បច្ចេកទេសទាន់សម័យសម្រាប់ការបង្រៀន និងការរៀនអំពីរបៀបប្រើប្រាស់បច្ចេកវិទ្យារ៉ូបូត សិនស័រ រូបថត និងបច្ចេកវិទ្យាផ្សេងទៀត នឹងបំពាក់ឧបករណ៍បច្ចេកទេសទាំងនោះនៅតាមសាលារៀន។

- ពង្រឹងគុណភាពបង្រៀន និងរៀនផ្សារភ្ជាប់ជាមួយវិស័យឯកជនសម្រាប់បណ្តុះបណ្តាលវិជ្ជាជីវៈ

○ អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេសសម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដូចជា ការបណ្តុះបណ្តាលបច្ចេកវិទ្យា កម្មន្តសាលទំនើប រ៉ូបូត មេកាត្រូនិច អេឡិចត្រូនិច ដើម្បីបង្កើនគុណភាពរបស់គ្រូបង្រៀននៅតាមគ្រឹះស្ថាន។ កម្មវិធីបែបនេះ គប្បីត្រូវបានបង្កើតឡើងដោយមានការសហការជិតស្និទ្ធជាមួយវិស័យឧស្សាហកម្ម និងបញ្ចូលការបណ្តុះបណ្តាលជាក់លាក់នៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យា។

○ ផ្តួចផ្តើម និងគាំទ្រដល់កិច្ចសហការដ៏រឹងមាំបន្ថែមទៀតជាមួយវិស័យឯកជនដើម្បីស្នើសុំឱ្យមានកម្មវិធីចុះកម្មសិក្សា និងហ្វឹកហ្វឺនជាប្រព័ន្ធដល់និស្សិតផ្នែកវិជ្ជាជីវៈនៅក្នុងវិស័យឧស្សាហកម្ម ព្រមទាំងសហការរៀបចំបង្កើតកម្មវិធីសិក្សាស្ទែមឱ្យឆ្លើយតបនឹងតម្រូវការក្នុងវិស័យឧស្សាហកម្ម

○ ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងវេទិកាបច្ចេកវិទ្យាសម្រាប់ការបង្រៀន និងការរៀនពីរបៀបប្រើប្រាស់បច្ចេកវិទ្យារ៉ូបូត សិនស័រ រូបថត និងបច្ចេកវិទ្យាផ្សេងៗ ព្រមទាំងបំពាក់ឧបករណ៍ទាំងនោះនៅតាមគ្រឹះស្ថានបណ្តុះបណ្តាល។ សកម្មភាពនេះនឹងធានាឱ្យបានថា សិស្ស និស្សិតទទួលបានការអនុវត្តជាក់ស្តែង និងជំនាញដែលទីផ្សារត្រូវការជាក់ស្តែង ។

### ២-៣-៣-សសរស្តម្ភទី៣ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពនៅតាមគ្រឹះស្ថានសាធារណៈ និងសកលវិទ្យាល័យ

គោលដៅលើកកម្ពស់សមត្ថភាពនៃការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រនៅតាមគ្រឹះស្ថានសាធារណៈ និងសកលវិទ្យាល័យ ដើម្បីលើកកម្ពស់ការបង្កើតចំណេះដឹងថ្មីតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធឧត្តមសិក្សា និងការស្រាវជ្រាវក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍឆ្លើយតបទៅផលប្រយោជន៍សង្គម និងតម្រូវការវិស័យឯកជន។

ក-គោលនយោបាយ

ការកសាងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រដ៏រឹងមាំមួយទាមទារឱ្យមានលក្ខខណ្ឌដូចជា របៀបវារៈស្រាវជ្រាវជាតិរួមគ្នា ការប្តេជ្ញាចិត្តយូរអង្វែងពីសំណាក់វិស័យសាធារណៈ និងឯកជនក្នុងការបង្កើនការចំណាយលើការស្រាវជ្រាវ និងអភិវឌ្ឍលើការស្រាវជ្រាវអនុវត្ត (Applied Research) ឬការស្រាវជ្រាវបឋម (Basic Research)។ ការសហការកាន់តែរឹងមាំរវាងស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីបង្កើនគុណភាពស្រាវជ្រាវព្រមទាំងការភ្ជាប់ទំនាក់ទំនងជាមួយវិស័យធុរកិច្ច។

ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពនៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ និងសកលវិទ្យាល័យ និងដើម្បីវាស់វែងវឌ្ឍនភាព៖

- អនុម័តរបៀបវារៈស្រាវជ្រាវជាតិរយៈពេល៥ឆ្នាំដោយកំណត់ទិសដៅនៅក្នុងការស្រាវជ្រាវ និងបង្កើតមូលនិធិស្រាវជ្រាវជាតិឱ្យបានត្រឹមឆ្នាំ២០២៣។
- បង្កើនចំនួនអ្នកស្រាវជ្រាវក្នុងវិស័យសាធារណៈពីចំនួន៣០នាក់ក្នុងមួយលាននាក់ (២០១៥)។ រហូតដល់ចំនួន៧០០នាក់ក្នុងមួយលាននាក់នៅដើមឆ្នាំ២០៣០។
- បង្កើនចំនួននៃការបោះពុម្ពផ្សាយផ្នែកវិទ្យាសាស្ត្រដែលអ្នកនិពន្ធជាអ្នកវិទ្យាសាស្ត្រខ្មែរនៅតាមបណ្ណាទិនានុប្បវត្តិអន្តរជាតិ ដែលមានចំនួន២០៦អត្ថបទក្នុងឆ្នាំ២០១៤ និងជាង៥០០អត្ថបទក្នុងឆ្នាំ២០១៨ នេះបើយោងតាមUNESCO Science Report ឱ្យបាន១៥០០អត្ថបទត្រឹមឆ្នាំ២០៣០។
- បង្កើតកំណត់ និងគាំទ្រសកលវិទ្យាល័យដែលផ្តោតលើការស្រាវជ្រាវ ឬមជ្ឈមណ្ឌលស្រាវជ្រាវថ្មីផ្តោតការងារលើការស្រាវជ្រាវ និងបច្ចេកវិទ្យាសំដៅផ្តល់ការអប់រំស្រាវជ្រាវស្តង់ដាអន្តរជាតិថ្នាក់បណ្ឌិត និងផ្តល់នូវការស្រាវជ្រាវដែលមានគុណភាពខ្ពស់ជាមួយដៃគូស្រាវជ្រាវអន្តរជាតិនៅត្រឹមឆ្នាំ២០២៥។

ខ-សកម្មភាព

- កំណត់របៀបវារៈស្រាវជ្រាវជាតិ
- ផ្តល់មូលនិធិសម្រាប់ការស្រាវជ្រាវអនុវត្ត និងស្រាវជ្រាវបឋម
- បង្កបរិយាកាសដល់ការស្រាវជ្រាវ និងលើកទឹកចិត្តដល់សកម្មភាពស្រាវជ្រាវ

**២-៣-៤-សសរស្តម្ភទី៤ បង្កើនកិច្ចសហការ និងបណ្តាញក្នុងចំណោមតួអង្គពាក់ព័ន្ធក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ**

គោលដៅពង្រឹងកិច្ចសហការ និងកសាងបណ្តាញទំនាក់ទំនងក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងឡាយក្នុងគោលបំណងផ្លាស់ប្តូរគំនិតបុគ្គលតាមបណ្តាអង្គភាព វិស័យសេដ្ឋកិច្ច និងផ្នែកបច្ចេកវិទ្យា។ គោលបំណងសំខាន់នៃសសរស្តម្ភនេះ គឺការបង្កើន និងដាក់ចេញនូវប្រព័ន្ធអេកូឡូស៊ីមួយដែលអាចបង្កឱ្យមានកិច្ចសហការតាមបណ្តាតួអង្គសំដៅបង្កើតគំនិតថ្មីៗ និងនវានុវត្តន៍ក៏ដូចជាការលើកកម្ពស់ការស្រូបយកនវានុវត្តន៍ និងបច្ចេកវិទ្យាថ្មីៗដោយវិស័យឯកជន។

ក-គោលនយោបាយ

- ត្រឹមឆ្នាំ២០២៣ ការិយាល័យភ្ជាប់ទំនាក់ទំនងសកលវិទ្យាល័យ និងសហគ្រាសត្រូវមានដំណើរការនៅក្នុងសកលវិទ្យាល័យមួយចំនួននៅទូទាំងប្រទេស និងដើមឆ្នាំ២០៣០ ចំនួន៥០% នៃសកលវិទ្យាល័យទាំងអស់ត្រូវបង្កើតការិយាល័យនេះ។
- ត្រឹមឆ្នាំ២០៣០ គ្រប់កម្មវិធីថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រទាំងអស់ត្រូវបញ្ចូលកម្មវិធីចុះកម្មសិក្សានៅតាមរោងចក្រសហគ្រាសយ៉ាងហោចណាស់រយៈពេល២ខែ។
- ត្រឹមឆ្នាំ២០២២ រាជរដ្ឋាភិបាលអនុម័តគោលនយោបាយបណ្តុំ និងសួនបច្ចេកវិទ្យា នវានុវត្តន៍ និងត្រឹមឆ្នាំ២០២៣ រាជរដ្ឋាភិបាលគាំទ្រគម្រោងសាកល្បងសួនបច្ចេកវិទ្យា និងនវានុវត្តន៍ជាតិចំនួន៣ ដោយផ្សារភ្ជាប់សហគ្រាសធុនតូច និងមធ្យមក្នុងស្រុកជាមួយសាជីវកម្មធំៗ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ សកលវិទ្យាល័យ អ្នកស្រាវជ្រាវ និងវិនិយោគិន។សួនបច្ចេកវិទ្យា និងនវានុវត្តន៍ជាតិនិងដំណើរការពេញលេញត្រឹមឆ្នាំ២០២៥។

ខ-សកម្មភាព

- បើកចំហសកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវសម្រាប់ទទួលវិស័យឯកជន
- បង្កើតគម្រោងសាកល្បងបណ្តុំ និងសួនបច្ចេកវិទ្យានវានុវត្តន៍ ដើម្បីជំរុញការផ្ទេរចំណេះដឹងក្នុងចំណោមក្រុមហ៊ុនធំៗ សហគ្រិនធុនតូច និងមធ្យម និងស្ថាប័នស្រាវជ្រាវ។

**២-៣-៥-សសរស្តម្ភទី៥ ការជំរុញប្រព័ន្ធអេកូឡូស៊ី បង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយកក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។**

ក-គោលនយោបាយ

ពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមធ្វើនវានុវត្តន៍ និងស្រូបយកបច្ចេកវិទ្យា ចំណេះធ្វើ និងជំនាញកម្រិតខ្ពស់តាមរយៈការផ្ទេរបច្ចេកវិទ្យាជួយសម្រួលដល់ការទទួលបានមូលនិធិ និងលើកទឹកចិត្តដល់ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យ.វ.ប.ន. ព្រមទាំងភ្ជាប់ទំនាក់ទំនង និងកិច្ច

សហការជាមួយសហគ្រាសធុនតូច និងមធ្យមក្នុងស្រុកបន្ថែមពីលើការជួយគាំទ្រក្នុងការផ្តល់ កម្លាំងពលកម្មប្រកបដោយជំនាញសម្រាប់នវានុវត្តន៍។

ខ-សកម្មភាព

- លើកកម្ពស់នវានុវត្តន៍របស់សហគ្រាសតូច និងមធ្យម
- បង្កើនលទ្ធភាពទទួល និងប្រើប្រាស់ហិរញ្ញប្បទាននវានុវត្តន៍សម្រាប់សហគ្រាសធុនតូច និងមធ្យម
- ទាក់ទាញ និងលើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកទេស នវានុវត្តន៍។

## ២-៤-បង្កើតទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

តាមការគ្រោងទុកទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នឹងប្រព្រឹត្តទៅរយៈពេល៣ថ្ងៃ គឺចាប់ពីថ្ងៃទី២៦-២៨ខែមីនា ឆ្នាំ២០២៣ ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ការប្រាព្ធនូវទិវាជាតិវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍មានសារៈសំខាន់ណាស់ក្នុងការចូលរួមចំណែកទាក់ទាញវិនិយោគិន ធុរជន និងបុគ្គលមានគំនិតបង្កើតថ្មី និងនវានុវត្តន៍ថ្មីៗ ដើម្បីចូលរួមចំណែកលើកកម្ពស់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាពិសេសចូលរួមចំណែកបង្កើនកំណើនសេដ្ឋកិច្ចជាតិក្នុងគោលដៅសម្រេចឱ្យបាននូវចក្ខុវិស័យ ដែលកម្ពុជានឹងប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅ២០៥០។

## ២.៥.ផែនទីបង្ហាញផ្លូវវិស័យអប់រំនៅមធ្យមសិក្សាសម្រាប់ឆ្នាំ២០៣០

ចក្ខុវិស័យក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្ស[31]ប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ ដើម្បីសម្រេចចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់បេសកកម្មដឹកនាំការគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំឆ្លើយតបចំពោះតម្រូវការនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច វប្បធម៌នៃប្រជាពលរដ្ឋរបស់ខ្លួន និងស្ថានភាពតំបន់ព្រមទាំងសកលភាវូបនីយកម្ម និងបដិវត្តឧស្សាហកម្ម៤.០។

គោលដៅនៃអនុវិស័យអប់រំមធ្យមសិក្សា គឺបណ្តុះស្មារតីមោទនជាតិ ភាពជាពលរដ្ឋ សីលធម៌ ចរិយាធម៌ និងគុណធម៌កម្រិតខ្ពស់ និងភាពជឿជាក់លើការទទួលខុសត្រូវរបស់យុវជន ហើយប្រែក្លាយជាពលរដ្ឋពេញលេញក្នុងសង្គម។ សិស្សបានបញ្ចប់ការសិក្សាមធ្យមសិក្សានឹងមានកម្រិតស្តង់ដាអន្តរជាតិអាចប្រកួតប្រជែងក្នុងទីផ្សារសកល និងដើរតួនាទីជាកាតាលីករសម្រាប់អភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជា។

---

[31] យុទ្ធសាស្ត្របញ្ចកោណ(២០២៣-២០២៨)បានផ្តោតលើការអភិវឌ្ឍមូលធនមនុស្សរួមមាន(១)ពង្រឹងគុណភាពវិស័យអប់រំកីឡាវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(២)បណ្តុះបណ្តាលជំនាញបច្ចេកទេស(៣)លើកកម្ពស់សុខភាព និងសុខុមាលភាពសង្គម(៤)ពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង និង(៥)ពង្រឹងភាពជាពលរដ្ឋក្នុងសង្គម

ដើម្បីសម្រេចគោលដៅនេះ ការអប់រំកម្រិតមធ្យមសិក្សានៅកម្ពុជាមានគោលបំណងគឺៈ

- បំពាក់បំប៉នយុវជនកម្ពុជានូវចំណេះដឹង មុខវិជ្ជាជំនាញ និងសមត្ថភាពសតវត្សរ៍ទី២១( យ៉ាងហោចណាស់រួមបញ្ចូលភាសាបរទេសមួយចំនួននិងគុណតម្លៃនៃភាពជាពលរដ្ឋល្អ និងក្រមសីលធម៌ ដើម្បីឱ្យពួកគេក្លាយជាពលរដ្ឋមានផលិតភាពក្នុងសង្គមក្នុងពេលដែលកម្ពុជាកំពុងប្រែក្លាយទៅរកសេដ្ឋកិច្ចផ្អែកតាមចំណេះដឹង។ សម្តេចនាយករដ្ឋមន្ត្រីហ៊ុន ម៉ាណែតនៅតែជំរុញឱ្យមានសកម្មភាពក្រៅម៉ោងសិក្សាស្របទៅតាមតម្រូវការក្នុងការពង្រឹងចំណេះដឹង វិន័យ សីលធម៌ និងឥរិយាបថរបស់អ្នកសិក្សាដើម្បីក្លាយជាកូនល្អ មិត្តល្អ និងសិស្សល្អ។
- ផ្តល់ឱកាសស្មើភាពគ្នាដល់យុវជនកម្ពុជាគ្រប់រូបក្នុងការទទួលបានការអប់រំកម្រិតមធ្យមសិក្សាដោយមិនគិតពីយេនឌ័រ ស្ថានភាពសង្គម ភូមិសាស្រ្ត ជាតិពន្ធុ ភាសា និងសាសនា
- បើកទូលាយ និងពង្រីកគន្លងសម្រាប់ភាពរីកចម្រើននៃការអប់រំរបស់សិស្សកម្រិតមធ្យមសិក្សាដើម្បីបន្តទៅឧត្តមសិក្សា ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ឬការងារដែលមានផលិតភាព។

### ក-សាវតារនៃការរៀបចំឯកសារផែនទីបង្ហាញផ្លូវ

ប្រទេសកម្ពុជាទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សពីឆ្នាំ២០០០រហូតដល់ឆ្នាំបច្ចុប្បន្ននេះ។ក្នុងអំឡុងឆ្នាំ២០១១-២០១ ផលិតផលសរុបក្នុងស្រុកកើនឡើងក្នុងអត្រាជាមធ្យម៧,០៥%ក្នុងមួយឆ្នាំ។ ការផ្លាស់ប្តូររចនាសម្ព័ន្ធបានរួមចំណែកធ្វើឱ្យប្រទេសសម្រេចបានកំណើនជាទីគាប់ចិត្ត ក្នុងនោះវិស័យសេវាកម្មរួមចំណែក៤០% ដល់ផ.ស.ស.របស់កម្ពុជា និងវិស័យឧស្សាហកម្មរួមចំណែក៣១%ក្នុងឆ្នាំ២០១៧។ កំណើនដ៏ឆាប់រហ័ស និងការធ្វើពិពិធកម្មកើតឡើងទន្ទឹមគ្នានឹងកំណើនតម្រូវការកម្លាំងពលកម្មដែលមានជំនាញ ប៉ុន្តែប្រព័ន្ធអប់រំពុំទាន់អាចតាមទាន់ការផ្លាស់ប្តូររចនាសម្ព័ន្ធទាំងនេះឡើយ[32] ហើយបាននាំឱ្យមានកង្វះជំនាញក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់។ ខណៈពេលដែលមានការសម្រេចបានវឌ្ឍនភាពជាច្រើនក្នុងការទទួលបានការអប់រំ និងគុណភាពនៃការអប់រំនៅកម្រិតបឋមសិក្សាក៏នៅតែបន្តមានបញ្ហាប្រឈមនៅកម្រិតមធ្យមសិក្សា។

សេដ្ឋកិច្ចសកល និងភាពជឿនលឿននៃបច្ចេកវិទ្យាក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ បានជំរុញឱ្យកម្ពុជាត្រូវពង្រឹងកិច្ចខិតខំប្រឹងប្រែងកែលម្អប្រព័ន្ធអប់រំរបស់ខ្លួន ដើម្បីផលិតធនធានមនុស្ស ដែលមានជំនាញកាន់តែខ្ពស់ឆ្លើយតបនឹងបញ្ហាប្រឈម។ ជាងនេះទៅទៀត គំនិតផ្តួចផ្តើមធ្វើឱ្យកាន់តែប្រសើរនូវប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សាកម្ពុជាគឺជាអាទិភាពដ៏ចម្បងចាំបាច់ត្រូវអនុវត្ត ដើម្បីឈានសម្រេចនូវចក្ខុវិស័យរបស់កម្ពុជាចង់បាននូវសង្គមពុទ្ធិ និងយុទ្ធសាស្ត្រចតុកោណជំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ដែលកំណត់ការអភិវឌ្ឍធនធានមនុស្ស និងមូលធនមនុស្សជាសសរស្តម្ភមួយក្នុងការអភិវឌ្ឍប្រទេសជាតិ។

---

[32] ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០ ឆ្នាំ២០២១ ទំ២៣។

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ល្បឿននៃការផ្លាស់ប្តូរបច្ចេកវិទ្យាក្នុងបរិបទឌីជីថល ដែលតម្រូវឱ្យមានការកែលម្អប្រព័ន្ធអប់រំកម្រិតមធ្យមសិក្សា ឬសាលារៀនអាចតាមទាន់ការផ្លាស់ប្តូរនានា និងបំពេញគម្លាតកង្វះជំនាញដែលជាតម្រូវការរបស់ទីផ្សារ ហើយក្នុងនោះការបង្កើនអត្រានៃការចូលរៀន និងគុណភាពនៃការអប់រំកម្រិតមធ្យមឆ្លើយតបចំពោះបញ្ហាប្រឈម និងគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់មូលធនមនុស្ស។

ក្រសួងអប់រំ យុវជន និងកីឡាដោយមានសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីបានរៀបចំផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០ដោយចាប់ផ្តើមពីឆ្នាំ២០២០។ ចន្លោះពីខែមីនា ឆ្នាំ២០២០ដល់ខែកុម្ភៈឆ្នាំ២០២១ ក្រុមការងារជំនួយបច្ចេកទេស និងគោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ីបានជួបពិភាក្សាជាមួយឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋលេខាធិការទទួលបន្ទុក(គោលនយោបាយ និងផែនការមធ្យមសិក្សា) ឯកឧត្តមអគ្គនាយកអគ្គនាយករង ប្រធាននាយកដ្ឋាន អនុប្រធាន នាយកដ្ឋាន នាយកសាលា គ្រូបង្រៀនកម្រិតមធ្យមសិក្សា(ការពិភាក្សាជាក្រុម) និងបុគ្គលិកអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាពីបញ្ហាប្រឈម និងជោគជ័យនានានៅក្នុងអនុវិស័យអប់រំមធ្យមសិក្សា។ ចន្លោះខែមីនា ដល់ខែឧសភាឆ្នាំ២០២០ ក្រុមការងារជំនួយបច្ចេកទេស និងគោលនយោបាយដោយមានការគាំទ្រពីលេខាធិការដ្ឋាន និងដៃគូដទៃទៀតបានរៀបចំឯកសារសង្ខេប និងការវិភាគស្ថានភាពជាច្រើនផ្តោតលើអនុវិស័យនៃវិស័យអប់រំ ការធ្វើចំណោលពីការចូលរៀន ការវាយតម្លៃលើភាពក្រីក្រ និងការវាយតម្លៃយេនឌ័រ ទីផ្សារការងារ និងស្ថានភាពសេដ្ឋកិច្ច។ ក្នុងខែសីហា-តុលាឆ្នាំ២០២០ កិច្ចប្រជុំពិគ្រោះយល់ត្រូវបានរៀបចំឡើងដោយគណៈកម្មការបច្ចេកទេស និងក្រសួងពាក់ព័ន្ធ។ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិមានការចូលរួមពីសាលាគរុកោសល្យ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងនាយកមធ្យមសិក្សាត្រូវបានរៀបចំឡើងកាលពីចុងខែមករាឆ្នាំ២០២១ បន្ទាប់មកនៅខែកុម្ភៈឆ្នាំ២០២១មានការពិគ្រោះយោបល់ជាមួយមន្ត្រីជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡាដឹកនាំដោយឯកឧត្តបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ សេចក្តីព្រាងចុងក្រោយនៃផែនទីបង្ហាញផ្លូវត្រូវបានប្រជុំឆ្លងសម្រេចដោយគណៈកម្មាធិការដឹកនាំកាលពីខែមេសាឆ្នាំ២០១៤។ ផែនទីនេះបានកំណត់ពីអាទិភាព និងយុទ្ធសាស្ត្រគន្លឹះៗ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំកម្រិតមធ្យមសិក្សា និងជួយឱ្យកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។

ឯកសារផែនទីបង្ហាញផ្លូវនេះត្រូវបានរៀបចំឡើងផ្អែកតាមយុទ្ធសាស្ត្រគោលនយោបាយ និងទិសដៅបានដាក់ចេញផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម (២០១៥-២០២៥) គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០៣០ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន បានបញ្ជាក់ថា ផែនទីបង្ហាញផ្លូវឆ្នាំ២០៣០មាន

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ស្ដីពីការអប់រំនៅប្រទេសកម្ពុជាត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ និងការវិភាគយ៉ាងល្អិតល្អន់រវាងអន្តរក្រសួង និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យបាននូវភាពប្រទាក់ក្រឡាគ្នាទៅនឹងគោលនយោបាយមានស្រាប់ ដែលធ្វើឱ្យផែនទីបង្ហាញផ្លូវមួយនេះមានចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយប្រាកដប្រជាបំផុតក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្ដីពីការអប់រំឆ្នាំ២០៣០ និងធានាបានគុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា[33]។

## ខ-ការរៀបចំផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០

ខ១-ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីពីការអប់រំនៅកម្ពុជាបានរំលេចគោលដៅចម្បងចំនួន៥ ដែលពាក់ព័ន្ធនឹងការអប់រំមធ្យមសិក្សាចំណេះទូទៅ និងបច្ចេកទេស និងឧត្តមសិក្សាគឺ៖

- សិស្សកម្ពុជាគ្រប់រូបបញ្ចប់ការអប់រំកម្រិតមូលដ្ឋានរយៈពេល៩ឆ្នាំ (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃប្រកបដោយគុណភាពសមធម៌ បរិយាបន្ន និងទទួលបានបំណិនអាន សរសេរ លេខនព្វន្តចំណេះដឹងលើមុខវិជ្ជាផ្សេងៗបំណិនក្នុងការគិត និងភាពប៉ិនប្រសប់ក្នុងការងារដែលផ្ដល់លទ្ធភាពឱ្យពួកគេអភិវឌ្ឍសក្ដានុពលបានយ៉ាងពេញលេញ។
- សម្រេចបានស្តង់ដានៃការបង្រៀន និងការរៀនសូត្រ ដែលមានគុណភាពខ្ពស់តាមរយៈការបង្កើនការអប់រំគ្រូបង្រៀននៅកម្រិតបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន។
- សិស្សគ្រប់រូបមានលទ្ធភាពទទួលបានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលផ្ដល់ជម្រើសក្នុងការអប់រំបច្ចេកទេសវិជ្ជាជីវៈដែលមានតម្លៃសមរម្យ និងប្រកបដោយគុណភាពឬការត្រៀមខ្លួនសម្រាប់ឧត្តមសិក្សា ពោលគឺពួកគេមានសមត្ថភាពឆ្លងទៅដំណាក់កាលទាំងពីរនេះ។
- ស្តង់ដានៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងល្អនៅគ្រប់កម្រិត ដែលលើកកម្ពស់ការបង្រៀន និងការរៀនកម្រិតខ្ពស់លេចឡើងនៅគ្រប់សាលាមធ្យមសិក្សាទាំងអស់នៅទូទាំងប្រទេសកម្ពុជា។
- យុវជនកាន់តែច្រើនមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានកម្មវិធីបច្ចេកទេសវិជ្ជាជីវៈដែលមានគុណភាព និង ពាក់ព័ន្ធ ដែលឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច និងតម្រូវការឧស្សាហកម្មក្នុងមូលដ្ឋាន។

ខ២-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ រំលេចគោលដៅសំខាន់ៗចំនួន៣សម្រាប់អនុវិស័យអប់រំមធ្យមសិក្សាគឺ៖

- លើកកម្ពស់ការចូលរៀន និងរក្សាសិស្សឱ្យបានគង់វង្សប្រកបដោយគុណភាពសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា

---

[33] ហង់ ជួនណារ៉ុន កំណែទម្រង់សាលារៀនឆ្នាំ២០២១ ទំ២៥។

- កែលម្អគុណភាពបង្រៀន និងរៀនស្របតាមជំនាញសតវត្សរ៍ទី២១
- ពង្រឹងភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងនៅសាលាមធ្យមសិក្សា និងអប់រំបច្ចេកទេស

ខ២-យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

មុំទី១ ផ្តោតជាចម្បងលើការអភិវឌ្ឍមូលធនមនុស្សជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញពិពិធកម្ម កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ប្រកបដោយបរិយាបន្ន និងភាពធន់ រាជរដ្ឋាភិបាលផ្តោតលើអាទិភាពចំនួន៥រួមមាន៖

(១) ការពង្រឹងគុណភាពវិស័យអប់រំ កីឡា វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា,

(២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស,

(៣)ការលើកកម្ពស់សុខភាព និងសុខុមាលភាពប្រជាជន,

(៤)ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង,

(៥)ការពង្រឹងភាពជាពលរដ្ឋក្នុងសង្គមឱ្យមានអារ្យធម៌ខ្ពស់ ប្រកបដោយសីលធម៌ សមធម៌ និងបរិយាបន្ន។

**គ-ផែនការសកម្មភាពនៃផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០**

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានទទួលជោគជ័យជាមួយនឹងនវានុវត្តន៍ជាច្រើនដូចជា ការបង្កើតនូវគោលវិធីសាលាកុមារមេត្រី កម្រងសាលាបឋមសិក្សា ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក ការអប់រំពហុភាសា(ភាសាដើម និងភាសាខ្មែរ)ការរៀនមុខវិជ្ជាភាសាខ្មែរតាមអនឡាញ សាលារៀនជំនាន់ថ្មី គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាព បំណិនសតវត្សរ៍ទី២១ បណ្ណាល័យ និងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ តាមរយៈការណែនាំ និងការផ្តល់ប្រឹក្សាគរុកោសល្យជាដើម។ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំសាលារៀនប្រកបដោយគុណភាព ក្រោមការគាំទ្រពីគម្រោងគាំទ្រវិស័យអប់រំនៅកម្ពុជា(២០០៥-២០០៩)។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០ក្នុងឆ្នាំ ២០២០-២០២១ ដោយមានការចូលរួមសហភាព និងការពិគ្រោះយោបល់យ៉ាងល្អិតល្អន់ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានសិក្សា ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល។ ផែនទីបង្ហាញផ្លូវនេះបានបន្សុំជាមួយគោលនយោបាយ និងយុទ្ធសាស្ត្រមានស្រាប់ដូចជា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម២០១៥-២០២៥ និងផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល។ ផែនទីបង្ហាញផ្លូវនេះបានកំណត់អាទិភាពសំខាន់៧៨ ដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងការអប់រំមធ្យមសិក្សា និងជំរុញឱ្យកម្ពុជាឆ្ពោះទៅសម្រេចចក្ខុវិស័យរយៈពេលវែងក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។

សកម្មភាពអាទិភាពជាសំខាន់ៗទាំង៨រួមមាន ៖

- បង្កើនការចូលរៀន និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងសាលាមធ្យមសិក្សា
- បន្សុំកម្មវិធីសិក្សា ការបង្រៀន និងវាយតម្លៃគ្រប់មុខវិជ្ជាពិសេសវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាឱ្យស្របតាមគុណភាពអប់រំសម្រាប់សតវត្សរ៍ទី២១
- បញ្ចូលការអប់រំឌីជីថលទៅក្នុងការអប់រំកម្រិតមធ្យមសិក្សា
- រៀបចំ និងអនុវត្តគោលនយោបាយគ្រូបង្រៀន ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់កម្រិតមធ្យមសិក្សា
- បន្តផ្តោតការយកចិត្តទុកដាក់ជាប្រព័ន្ធលើការលើកកម្ពស់ការអប់រំគ្រូមធ្យមសិក្សា
- ធ្វើពិពិធកម្ម និងពង្រឹងលទ្ធផលនៃការអប់រំបច្ចេកទេសមធ្យមសិក្សា ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន
- បង្កើនសហការរវាងការអប់រំមធ្យមសិក្សានិងក្រោយមធ្យមសិក្សា និងការចូលរួមពីតួអង្គពាក់ព័ន្ធ។

### ២-៥-១-បង្កើនការចូលរៀន និងគុណភាពនៃការអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា៦៥ «រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួល បានការអប់រំមួយប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប»។
- ចក្ខុវិស័យសម្រាប់សិស្សកម្ពុជាឆ្នាំ២០៣០ គឺប្រទេសកម្ពុជានឹងមានសិស្ស ដែលមានសុខភាពល្អ ត្រៀមខ្លួនបានល្អ និងទទួលបានបរិយាកាសសិក្សាដែលមានលក្ខណៈអំណោយផល។ សិស្សនឹងទទួលបានការគាំទ្រពីគ្រូបង្រៀនមានសមត្ថភាព និងគុណវុឌ្ឍិវិជ្ជាជីវៈច្បាស់លាស់ពីសមាជិកគ្រួសារ និងសង្គមរបស់ពួកគេដោយផ្ទាល់។ បន្ទាប់ពីបញ្ចប់ការសិក្សា សិស្សនឹងមានជំនាញទាំងរឹង ទន់ ចេះធ្វើការវិនិច្ឆ័យប្រកបដោយក្រមសីលធម៌ មានភាពឆ្លាតវៃ ស្មារតីល្អ និងមានភាពជាពលរដ្ឋសកលក្នុងកម្រិតមួយខ្ពស់ដែលអាចផ្តល់លទ្ធភាពឱ្យពួកគេបានចូលរួមក្នុងសង្គមយ៉ាងសកម្ម។
- សិស្ស គ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន គ្រួសារ និងសហគមន៍ គឺជាផ្នែកមួយនៃចក្ខុវិស័យរួមសម្រាប់លើកកម្ពស់កម្រិតនៃការសិក្សានៅក្នុងសាលារៀន។គុណភាពនៃការបង្រៀន-រៀននិងការគ្រប់គ្រងសម្ភារូបវន្ត និងធនធានសម្រាប់ការសិក្សា គឺជាធាតុផ្សំដ៏សំខាន់សម្រាប់ផ្តល់ការគាំទ្រដល់កម្រិតនៃការសិក្សា និងការជំរុញឱ្យចូលរៀនជាបន្តបន្ទាប់[34]។ ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្កើនគុណភាពនៃ

[34] ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០,ដ.ឯ.ម, ទំ.១០៤។

ជាតុផ្សំនីមួយៗក្នុងចំណោមជាតុផ្សំ ដើម្បីបង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស។

ក-រៀបចំ និងផ្សព្វផ្សាយគន្លងអប់រំបណ្តុះបណ្តាល និងអាជីពដើម្បី (១)ឱកាសនៃការអប់រំ និងបណ្តុះបណ្តាលត្រូវបានបង្ហាញយ៉ាងច្បាស់ដល់សិស្ស មាតាបិតាសិស្ស និងបុគ្គលិកអប់រំ (២)បង្កើតយន្តការទទួលស្គាល់គុណភាព និងផ្តល់វិញ្ញាបនបត្របញ្ជាក់ដែលមានការទទួលស្គាល់ទៅវិញទៅមក ដើម្បីឱ្យសិស្សអាចទទួលបានក្រេឌីតនៅជំណាក់កាលផ្សេងៗក្រោយបញ្ចប់ការសិក្សា(៣)គន្លងអប់រំបណ្តុះបណ្តាល និងអាជីពមានលក្ខណៈមិនលម្អៀង មានយុត្តិធម៌យេនឌ័រ និងបរិយាបន្នសង្គម។

ខ-រំពឹងថា សិស្សថ្នាក់ទី៦ នឹងបន្តរៀននៅសាលារៀនមធ្យមសិក្សាដោយមានសមត្ថភាពអំណានសរសេរ និងលេខនព្វន្តអាចជួយឱ្យពួកគេកាន់តែទទួលបានជោគជ័យនៅកម្រិតមធ្យមសិក្សា។ ដោយឡែកសិស្សដែលមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ត្រូវបានពង្រឹងសមត្ថភាពតាមរយៈការផ្តល់ថ្នាក់បំប៉ន។

គ-ប្រើប្រាស់ទិន្នន័យបែងចែកតាមប្រភេទសិស្ស ដែលទទួលបានពីការវាយតម្លៃស្តង់ដាសម្រាប់ការអប់រំថ្នាក់មូលដ្ឋានដូចជាថ្នាក់ទី៣ ទី៦ និងទី៨ ដើម្បីវិភាគពីឧបសគ្គក្នុងការសិក្សា និងផ្តល់មតិត្រឡប់ដើម្បីកែលម្អការបង្រៀន និងរៀនក្នុងថ្នាក់។

ឃ-រាល់ការលើកទឹកចិត្តតាមរយៈការផ្តល់អាហារូបករណ៍ឱ្យចំ ដែលសិស្សមានតម្រូវការដើម្បីបង្កើនការចូលរៀនរបស់សិស្សទាំងពីរភេទ ដើម្បីឱ្យសិស្សអាចរៀនចប់កម្រិតអប់រំមធ្យមសិក្សា។

ង-ផ្តល់អាហារូបករណ៍បន្ថែម ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីកុមារដែលមានពិការភាព ជនជាតិដើមភាគតិច កុមារមកពីគ្រួសារក្រីក្រ និងក្រុមជួបការលំបាកផ្សេងទៀត។ ការផ្តល់អាហារូបត្ថម្ភនេះ ដើម្បីធានាឱ្យសិស្សបានចូលរៀនពេញលេញប្រកបដោយសុខភាពល្អ និងបន្តការសិក្សាបានចប់ចុងចប់ដើមរហូតក្លាយជាពលរដ្ឋពេញលេញ។

ច-ជួយដល់សិស្ស ដែលធ្លាប់ចាកចេញពីសាលាមធ្យមសិក្សាឱ្យត្រឡប់មកចូលរៀនវិញ និងទទួលបានគុណដែលបង្កើនឱកាសទទួលបានការងារល្អ ដោយបង្កើនការគាំទ្រដល់ការអនុវត្តកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋាន។

ឆ-ផ្តល់ជម្រើសជំនាញវិជ្ជាជីវៈសម្រាប់ការអប់រំ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាជម្រើសនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។

ជ-ប្រើប្រាស់ការបង្កើតរូបភាពឌីជីថល(ការវិភាគទិន្នន័យ និងផែនទីឌីជីថល) ដើម្បីកំណត់ពីតម្រូវការសាងសង់ ជួសជុល កែលម្អ និងស្តារសម្ភាររូបវន្តជាយុទ្ធសាស្ត្រនៅក្នុងសាលារៀន និងការពង្រាយគ្រូប្រកបដោយប្រសិទ្ធភា

ឈ-ណែនាំប្រើប្រាស់ស្តង់ដាសេវាអប្បបរមាសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធសាលារៀននិងកែលម្អប្លង់បន្ទប់រៀន ដែលគាំទ្រដល់ការអនុវត្តគរុកោសល្យបែបថ្មី។

ញ-បង្កើតកន្លែងធ្វើការសម្រាប់គ្រូ ដើម្បីឱ្យពួកគេរៀបចំ និងសហការគ្នាប្រកបដោយវិជ្ជាជីវៈ។

ដ-ធានាថា គ្រប់សាលាមធ្យមសិក្សាទាំងអស់មានបង្គន់អនាម័យអាចប្រើប្រាស់ និងបានបែងចែកតាមភេទ និងមានទឹកប្រើប្រាស់ពេញមួយឆ្នាំ មានបន្ទប់ថែទាំសុខភាព មានអាហារដ្ឋាន ដែលផ្តល់នូវអាហារប្រកបដោយអាហារូបត្ថម្ភ និងនាំមកនូវសុខភាពមាំមួន មានកម្មវិធីសិក្សាដែលផ្តោតលើប្រធានបទសុខភាពរបស់ក្មេងជំទង់ដូចជា សុខភាពផ្លូវភេទ និងបន្តពូជ អំពើហិង្សាលើយេនឌ័រ ការអប់រំអំពីជំងឺអេដស៍/មេរោគអេដស៍ ជំងឺកូវីដ-១៩ និងថ្នាំញៀន ព្រមទាំងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាពដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បន្ទប់ប្រឹក្សាគរុកោសល្យ បរិស្ថានសាលារៀនបៃតង សាលារៀនស្អាតគ្មានសំរាម និងការលើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យ។

ឋ-តម្រូវឱ្យមានការពិនិត្យសុខភាពជាប្រចាំសម្រាប់សិស្ស និងបុគ្គលិកសាលារៀនទាំងអស់ ដោយមណ្ឌលសុខភាពក្នុង មូលដ្ឋាន (វិស័យអប់រំ និងវិស័យសុខាភិបាល អាចពិចារណាបង្កើតទីតាំងដែលមានសាលាសហគមន៍ និងមណ្ឌលសុខភាពនៅជាមួយគ្នា ដើម្បីពង្រឹងការផ្តល់សេវាក្នុងមូលដ្ឋាន)។

ឌ-ធានាថា សាលាមានការគាំទ្រក្នុងការកាត់បន្ថយការរើសអើងសិស្សក្រីក្រ និងសិស្សជួបការលំបាកទាំងពីរភេទ។

ឍ)ពង្រឹងការអប់រំកាយ និងកីឡានៅតាមសាលាមធ្យមសិក្សា ដើម្បីបង្កើនសុខភាពរាងកាយ សិស្សអភិវឌ្ឍសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងសកម្មភាពអប់រំកាយ និងបំពាក់បំប៉នវិន័យផ្ទាល់ខ្លួន។

**២-៥-២-បន្តយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការដឹកនាំ និងគ្រប់គ្រងសាលារៀនមធ្យមសិក្សា**

- ចក្ខុវិស័យរបស់សាលារៀនឆ្នាំ២០៣០ គឺសាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀនទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការរៀន បង្រៀនប្រកបដោយគុណភាព ដោយប្រើប្រាស់បច្ចេកទេសជំនួយ។
- ចក្ខុវិស័យសម្រាប់បន្ទប់រៀនកម្ពុជាឆ្នាំ២០៣០ គឺបន្ទប់រៀនកម្ពុជានឹងត្រូវបានប្រែក្លាយជាបន្ទប់រៀនវៃឆ្លាតផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការសិក្សារៀនសូត្រដោយបំពាក់ធនធានអប់រំនិងបច្ចេកវិទ្យា ដើម្បីផ្តល់នូវបរិយាកាសសិក្សា ដែលមានលក្ខណៈអំណោយផលល្អសម្រាប់គ្រប់គ្នា។ គ្រូបង្រៀនជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទី ជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់សិស្សគ្រប់គ្នាតាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបអន្តរកម្មបែបសហការនិងវិធីសាស្ត្រចម្រុះ។

សាលារៀន គឺជាកោសិកាស្នូលនៃប្រព័ន្ធអប់រំ ហើយនាយកជាអ្នកដឹកនាំការរៀន និងការបង្រៀន។ សាលារៀនល្អ គឺសាលាដែលគណៈគ្រប់គ្រង និងគ្រូទាំងអស់គោរពបានយ៉ាងពេញលេញនូវតម្លៃជាមូលដ្ឋានមានបេសកកម្មច្បាស់លាស់កំណត់នូវលទ្ធផលខ្ពស់ ដែលមានគ្រូ និងសិស្សត្រូវសម្រេចឱ្យបាននិងត្រូវមាននាយក ដែលមានសមត្ថភាពក្នុងការដឹកនាំអនុវត្តនូវទស្សនវិស័យនេះ[35]។

លទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន៤គឺ៖

ទី១-នាយកល្អបង្កើតនូវបរិស្ថានល្អសម្រាប់ការរៀន និងការបង្រៀន(២៥ភាគរយនៃលទ្ធផលសិក្សារបស់សិស្ស)

ទី២-គ្រូល្អមានគុណវុឌ្ឍខ្ពស់យកចិត្តទុកដាក់ និងមានវិធីសាស្ត្របង្រៀនល្អ។ គ្រូល្អអាចបម្រើការងារនៅក្នុងសាលាបានដោយសារមាននាយកល្អ។

ទី៣-ការខិតខំប្រឹងប្រែងរបស់សិស្សខ្លួនឯង និង

ទី៤-ការជួយគាំទ្ររបស់មាតាបិតា និងសហគមន៍។

ក-កំណត់ការជ្រើសរើស និងតែងតាំងអ្នកដឹកនាំសាលារៀនផ្អែកតាមគុណសម្បត្តិការងារ និងស្តង់ដាបានកំណត់សម្រាប់នាយកសាលា។

ខ-បង្កើតកម្មវិធីត្រៀមខ្លួនដឹកនាំនិងគ្រប់គ្រងសាលារៀនសម្រាប់នាយកសាលាដែលទើបចេញបម្រើការងារថ្មីនិងអ្នកដែល មានបំណងធ្វើជានាយកសាលា និងផ្តល់ការបណ្តុះបណ្តាលអភិវឌ្ឍន៍វិជ្ជាជីវៈ ជាប្រចាំឱ្យបានទៀងទាត់ ក្នុងអំឡុងពេល នៃការបំពេញអាជីពរបស់ពួកគេ។

គ-ដាក់បញ្ចូលភាពជាអ្នកដឹកនាំក្នុងការណែនាំក្នុងកម្មវិធីត្រៀមខ្លួន និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា ដើម្បីពង្រឹងការបង្រៀន និងរៀន។

ឃ-ផ្តល់បរិយាកាសកាន់តែមានលក្ខណៈអំណោយផលសម្រាប់នាយកសាលាទាំងនេះ ដោយប្រើប្រាស់គោលវិធីគ្រប់គ្រងតាមសាលារៀនមានប្រសិទ្ធភាពរួមមាន (១)-ឯកសារពិពណ៌នាអំពីការងារត្រូវមានការរៀបរាប់កំណត់ឱ្យបានច្បាស់លាស់ពីតួនាទី សិទ្ធិ និងការទទួលខុសត្រូវ (២)-ផ្តល់អំណាចឱ្យពួកគេគ្រប់គ្រងបុគ្គលិកក្នុងសាលារៀនដោយពុំមានការរើសអើងដូចជា ត្រូវដាក់ចេញនូវគោលនយោបាយសម្រាប់ជួលបុគ្គលិក បញ្ឈប់ការងារបុគ្គលិក ដែលធ្វើការងារពុំបានល្អ និងអនុវត្តការវាយតម្លៃសមិទ្ធកម្មរបស់គ្រូទៅតាមការចាំបាច់។

ង-ក្នុងករណីសាលារៀនមានសមត្ថភាពស្រូបយកការងារបន្ថែម ត្រូវបញ្ចូលគំរូសាលារៀនជំនាន់ថ្មីយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមរយៈការលើកកម្ពស់អភិបាលកិច្ចល្អ ក្រមសីលធម៌វិជ្ជាជីវៈ កែលម្អវិធីសាស្ត្របង្រៀនផ្តល់ប្រាក់លាភការផ្អែកតាមសមិទ្ធកម្មការងារដល់គ្រូ ការ

---

[35] ហង់ ជួនណារ៉ុន, កំណែទម្រង់សាលារៀននៅកម្ពុជា, ឆ្នាំ២០២០, ទំ.១៣។

អភិវឌ្ឍវិជ្ជាជីវៈផ្ដោតលើការសិក្សាផ្អែកតាមបញ្ហាជំនាញ(STEM)ការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងការអប់រំ និងការធ្វើឱ្យកាន់តែប្រសើរនូវសេវាសម្រាប់សិស្សដូចជា ផ្ដល់ការណែនាំ និងការប្រឹក្សាអាជីព ការសិក្សាទៅតាមស្ថានភាពខុសៗគ្នារបស់សិស្ស ការសិក្សាពីចម្ងាយ និងការអប់រំបំណិនជីវិតជាដើម។

ច-បន្តអភិវឌ្ឍការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀនមានប្រសិទ្ធភាព[36]តាមរយៈគណកម្មការគ្រប់គ្រងសាលា និងវិធីដទៃទៀត ដែលនាំឱ្យមានការចូលរួមពីសំណាក់សហគមន៍(ឧ.ការបើកបវេសនកាល ការស្វែងរកថវិកា អញ្ជើញឪពុក-ម្ដាយ ឬធុរជនមកធ្វើវាគ្មិន)។នាយកសាលាត្រូវទទួលខុសត្រូវចំពោះគណៈកម្មការគ្រប់គ្រងសាលា ដែលមានតួនាទីរដ្ឋបាលក្នុងការគ្រប់គ្រងកិច្ចការសាលារៀន។

ឆ-ធានានូវប្រព័ន្ធអប់រំឆ្លើយតបនឹងយេនឌ័រ និងមានបរិយាបន្នសង្គមតាមរយៈការរៀបចំឡើងជាថ្មី និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធជនបង្គោលយេនឌ័រសម្រាប់ការណែនាំ និងពិនិត្យតាមដាន។ គ្រូបង្រៀនទាំងពីរភេទនៅកម្រិតផ្សេងៗតាមសាលានីមួយៗ នឹងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលកម្រិតខ្ពស់ស្ដីពីយេនឌ័រ និងដើរតួនាទីជាក្រុមគ្រូបង្គោល ដើម្បីផ្ដល់ការតម្រង់ទិសមូលដ្ឋានស្ដីពីយេនឌ័រដល់គ្រូបង្រៀន និងគាំទ្របុគ្គលិកគ្រប់រូប។

### ២-៥-៣.រៀបចំកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃឱ្យស្របតាមការអប់រំប្រកបដោយគុណភាពសម្រាប់សតវត្សរ៍ទី២១

ក-ធានាថា កម្មវិធីសិក្សាកម្រិតមធ្យមសិក្សា(១)-ផ្អែកតាមទស្សនាទាន (ប្រសិនបើអាច)(២)-បានត្រៀមយុវជនឱ្យឆ្លើយតបចំពោះបញ្ហាប្រឈមនានា ដែលកើតមាននាពេលអនាគត (៣)ផ្ដល់តម្លៃដល់ចំណេះដឹង និងផលិតចំណេះដឹង និងការយល់ដឹងសម្រាប់សិស្សគ្រប់រូប (៤)-អភិវឌ្ឍភាពច្នៃប្រឌិត ការសហការ និងការយល់ដឹងកម្រិតខ្ពស់អំពីវប្បធម៌ខ្មែរ(៥)លើកកម្ពស់សមធម៌ និងទទួលយកភាពចម្រុះ (៦)-ផ្ដល់អាទិភាពដល់សុខភាព និងសុខុមាលភាពសង្គម និងផ្លូវចិត្ត (៧)-ផ្ដល់ឱកាសឱ្យបុគ្គលគ្រប់រូបក្លាយជាមនុស្សល្អមានចំណេះដឹងឆ្នើម។

ខ-បញ្ចូលជំនាញសតវត្សរ៍ទី២១ដូចជា ជំនាញសហការ ការត្រិះរិះពិចារណាល្អិតល្អន់ ការគិតបែបច្នៃប្រឌិត និងការងារក្រុមចូលទៅក្នុងគ្រប់មុខវិជ្ជាទាំងអស់ជាពិសេសមុខវិជ្ជា(STEM)នៅកម្រិតមធ្យមសិក្សាដោយផ្ដោតទាំងលើខ្លឹមសារ និងដំណើរការ ។

គ-បញ្ចូលការអប់រំសិល្បៈទៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម គណិតវិទ្យា ដើម្បីលើកកម្ពស់ការគិតប្រកបដោយភាពច្នៃប្រឌិត និងបង្កើតដំណោះស្រាយ។

---

[36] សាលារៀនមានប្រសិទ្ធភាព គឺសាលារៀនបំពេញបាននូវសូចនាករនៃស្តង់ដាទាំង៩ ឬហៅថា ស្តង់ដាសាលារៀនមានប្រសិទ្ធភាព ពោលគឺដំណើរការនៃការរៀនសូត្ររបស់សិស្សក្នុងសាលារៀនមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងសាលារៀនពិសេសគាំទ្រពីសហគមន៍។

ឃ-បង្កើតគណៈកម្មាធិការតាមមុខវិជ្ជា ដើម្បីរៀបរៀងឡើងវិញនូវកម្មវិធីសិក្សាលម្អិត ដោយមានការពិពណ៌នាជាក់លាក់អំពីការសិក្សារបស់សិស្សជាពាក្យពេចន៍ដែលអាចវាស់វែងបាន។

ង-បញ្ចូលប្រធានបទបន្ថែមទៀតដែលទទួលបានចំណាប់អារម្មណ៍នាពេលបច្ចុប្បន្នដោយភ្ជាប់ជាមួយនឹងបរិបទរបស់សិស្សផ្ទាល់ជាពិសេសនៅសាលាជនបទ កសិកម្ម ការចិញ្ចឹមសត្វ បច្ចេកវិទ្យា។ល។

ច-ពង្រឹងការសិក្សាផ្តោតលើការធ្វើសកម្មភាពជាក់ស្តែងតាមរយៈគម្រោង និងគោលវិធីផ្អែកតាមការរិះរក និងការស្រាវជ្រាវមេរៀនដែលផ្សារភ្ជាប់ជាមួយនឹងការអនុវត្តផ្ទាល់ បំណិនជីវិត និងកម្មវិធីបច្ចេកទេស

ឆ-ពិចារណាអភិវឌ្ឍឯកសារអំណាន រូបភាព និងឌីជីថលបន្ថែមដើម្បីបំពេញឱ្យសៀវភៅសិក្សា។

ជ-ធានាថា សារៈសំខាន់ៗក្នុងកម្មវិធីសិក្សា និងធនធានបង្រៀន គ្មានការរើសអើងក៏ដូចជាលើកកម្ពស់សិទ្ធិមនុស្ស សមភាព យេនឌ័រ និងបរិយាបន្នសង្គម។

ឈ-ដាក់បញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាក្នុងកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន។

ញ-កែទម្រង់ការប្រឡងថ្នាក់ទី១២(១)ធានាថា ការប្រឡងនេះធ្វើតេស្តលើជំនាញគិតពិចារណាកម្រិតខ្ពស់ក៏ដូចជា ការរំឭកឡើងវិញពីខ្លឹមសារមុខវិជ្ជា (២)ផលិតចេញពីកម្រងតេស្តស្តង់ដា(៣)បូកពិន្ទុវាយតម្លៃតាមសាលារៀន (ដែលអាចបញ្ចូលទាំងកម្រងស្នាដៃសិស្ស)របស់សិស្សថ្នាក់ទី១២ម្នាក់ៗ ដើម្បីយកមកបញ្ចូលគ្នាជាមួយនឹងការដាក់ពិន្ទុប្រឡង ដែលមានការត្រួតពិនិត្យពីខាងក្រៅ ទើបផ្តល់ជាពិន្ទុសរុបដល់សិស្សម្នាក់ៗ។

### ២-៥-៤.បញ្ចូលការអប់រំឌីជីថលនៅក្នុងការអប់រំកម្រិតមធ្យមសិក្សា

ការបញ្ចូលការអប់រំឌីជីថលក្នុងវិស័យអប់រំ គឺមានន័យថា ការប្រើប្រាស់វិស័យបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ជាឧបករណ៍សម្រាប់បង្រៀន និងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំសំដៅឱ្យសិស្សនិស្សិតនូវចំណេះដឹង និងបំណិនបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សរ៍ទី២១។ ប្រើប្រាស់ការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិច(E-learning) ដើម្បីគាំទ្រឱ្យមានការផ្តល់សេវាអប់រំដល់គ្រប់អនុវិស័យទាំងអស់នៃវិស័យអប់រំសម្រាប់សិស្ស និស្សិត និងការអភិវឌ្ឍសមត្ថភាពស្ថាប័នក៏ដូចជាការរៀនពេញមួយជីវិត។

កាលពីថ្ងៃទី២មេសា ឆ្នាំ២០២៤ ក្នុងឱកាសបិទសន្និបាតអប់រំឆ្នាំ២០២៣-២០២៤ សម្តេចធិបតី ហ៊ុន ម៉ាណែតនាយករដ្ឋមន្ត្រីកម្ពុជា បានជំរុញការអភិវឌ្ឍការអប់រំឌីជីថលដោយត្រូវបន្តធ្វើសមាហរណកម្មបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត បំពាក់បន្ទប់ពិសោធន៍ឌីជីថល ភ្ជាប់បណ្តាញអគ្គិសនី និង អ៊ិនធឺណែតនៅតាមគ្រឹះស្ថានសិក្សា លើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន និងសមត្ថភាពឌីជីថលដល់គ្រូ

បង្រៀនដោយបញ្ចូលនូវការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀន និងរៀន កែលម្អមាតិកាឌីជីថល និងបង្កើតសាលាអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថលឱ្យកាន់តែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ[37]។

ក-បញ្ចូលបច្ចេកវិទ្យាឌីជីថលក្នុងបន្ទប់រៀនវៃឆ្លាតអនុញ្ញាតឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាកាន់តែច្រើនក្នុងការបង្រៀន និងរៀនក្នុងគ្រប់បណ្តាញវិទ្យាល័យធនធាន និងសាលារៀនជំនាន់ថ្មី(រួមទាំងទូរទស្សន៍ និងវិទ្យុ)។ ពង្រីកការដាក់បញ្ចូលបច្ចេកវិទ្យា ក្នុងការបង្រៀន និងរៀននៅគ្រប់សាលាមធ្យមសិក្សាទៅតាមធនធាន និងបុគ្គលិក ដែលមាន។

ខ-បង្កើតភាពជាដៃគូដ៏រឹងមាំជាមួយអ្នកផ្តល់សេវាអ៊ិនធឺណែត ដើម្បីអភិវឌ្ឍ និងទ្រទ្រង់ដល់ដំណើរការប្រព័ន្ធអប់រំឌីជីថល នៅមធ្យមសិក្សា។

គ-ដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធICT ដែលមានលក្ខណៈទូលំទូលាយសម្រាប់គាំទ្រការសិក្សាតាមប្រព័ន្ធអនឡាញរបស់សិស្ស(១)ជំរុញឱ្យមានការប្រើប្រាស់ការសិក្សាបែបចម្រុះ (ក្នុងថ្នាក់ និងអនឡាញ) ជាគំរូថ្មីសម្រាប់ការប្រាស្រ័យទាក់ទងគ្នារវាងគ្រូ និងសិស្ស (២)រៀបចំកញ្ចប់សិក្សាឱ្យស្របតាមកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាតាមរយៈនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងមជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយជាមជ្ឈមណ្ឌលថ្មី ដែលត្រូវផ្សព្វផ្សាយធនធានទាំងនេះឱ្យបានទូលំទូលាយ (៣)ទទួលបានការអនុញ្ញាតឱ្យប្រើប្រាស់ម៉ូឌុលសិក្សា ដែលផលិតទូទាំងសកលលោកបន្ទាប់ពីការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩។ ឧទាហរណ៍ដូចជាម៉ូឌុលដែលផលិតដោយភាពជាដៃគូសកលសម្រាប់ការអប់រំ និងមជ្ឈមណ្ឌលSEAMEOជាពិសេសម៉ូឌុលដែលពាក់ព័ន្ធនឹងតំបន់អាស៊ាន។



រូបភាពទី៧៖ សកម្មភាពរៀនកុំព្យូទ័ររបស់សិស្សនៅវិទ្យាល័យ

[37] https://freshnewsasia.com/

## ២-៥-៥-អនុវត្តគោលនយោបាយគ្រូបង្រៀនមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងអនុវិស័យអប់រំមធ្យមសិក្សា

ចក្ខុវិស័យសម្រាប់គ្រូបង្រៀនឆ្នាំ២០៣០ គឺគ្រូបង្រៀនកម្ពុជាមានសមត្ថភាពទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់វិជ្ជាជីវៈដើម្បីឱ្យមានភាពទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍិខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារ។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌។ គ្រូបង្រៀនត្រូវបំពេញការការប្រកបដោយក្រមសីលធម៌ស្តង់ដាវិជ្ជាជីវៈខ្ពស់ដើម្បីធានាឱ្យបានសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ។

ក-រៀបចំគោលនយោបាយគ្រូបង្រៀនគ្រប់ជ្រុងជ្រោយត្រូវបានអនុម័ត និងផ្សព្វផ្សាយសម្រាប់គ្រូដែលទើបចូលបង្រៀន និងគ្រូទាំងអស់កំពុងបង្រៀនក្នុងសាលារៀន។

គោលនយោបាយនេះរួមមាន(១)ស្តង់ដាជ្រើសរើសគរុសិស្ស ដើម្បីទទួលបានការបណ្តុះបណ្តាល និងការពន្យារពេលទទួលយកអ្នកជំនាញផ្សេងទៀត(២)ពិពណ៌នាការងារនៅគ្រប់កម្រិតទាំងអស់ ដែលផ្តល់ការគាំទ្រដល់ការងារបង្រៀនក្នុងនាមជាអាជីពមួយ (៣)កិច្ចសន្យាការងារ(អាជ្ញាប័ណ្ណសម្រាប់គ្រូបង្រៀនលក្ខខណ្ឌការងារ បៀវត្ស និងអត្ថប្រយោជន៍នានា) (៤)ស្តង់ដាសម្រាប់ការតែងតាំង និងពង្រាយគ្រូ(៥)ក្របខណ្ឌស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (ក្រមសីលធម៌)(៦)ក្របខណ្ឌស្តង់ដាវិជ្ជាជីវៈនាយកសាលា(ក្រមសីលធម៌)(៧)ការអនុវត្តគំរូការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគន្លងអាជីពគ្រូបង្រៀនដូចជាគុណវុឌ្ឍដែលបានពីការសិក្សាបទពិសោធន៍ ការងារ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការវាយតម្លៃសមិទ្ធកម្មដើម្បីទទួលបានការដំឡើងឋានៈនៅក្នុងការបំពេញ ការងារ ការផ្ទេរប៉ុស្តិ៍ការងារ និងការទទួលស្គាល់ (៨)ការបង្កើតសមាគមវិជ្ជាជីវៈព្រមទាំងក្រុមបច្ចេកទេសសម្រាប់គ្រប់មុខវិជ្ជាទាំងអស់ (៩)ការរៀបចំជាកម្រងស្នាដៃវិជ្ជាជីវៈរបស់គ្រូ និងនាយកសាលា(១០)ការលើកកម្ពស់ និងសម្របសម្រួលការផ្តល់សេវាអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដល់គ្រូ និងនាយកសាលា (១១)ការត្រួតពិនិត្យការបង្រៀនរបស់គ្រូទាំងអស់ផ្តល់ការណែនាំ និងការបង្វឹក ដើម្បីកែលម្អសមិទ្ធកម្មរបស់ពួកគ(១២)ការវាយតម្លៃសមិទ្ធកម្ម ដើម្បីកំណត់រកចំណុចខ្លាំង និងចំណុចខ្សោយ និងដាក់ចេញនូវដំណើរការសម្រាប់ធ្វើការកែលម្អ (១៣)ការកំណត់គន្លងអាជីពច្បាស់លាស់សម្រាប់ការដំឡើងឋានៈប្រាក់លាភការសម្រាប់ការផ្ទេរ (១៤)លក្ខខណ្ឌតម្រូវសម្រាប់ការព្យួរការងារ និងការបញ្ឈប់ពីការងារ(១៥)ដំណើរការសម្រាប់ការលាលែង និងការចូលនិវត្តន៍។

ខ-ធ្វើបច្ចុប្បន្នកម្ម គោលនយោបាយស្តីពីការជ្រើសរើសបុគ្គលិក ដើម្បីទាក់ទាញបេក្ខជន ដែលមានសមត្ថភាពបង្រៀនខ្ពស់(គុណវុឌ្ឍិដែលបានពីការសិក្សា និងឧបនិស្ស័យ)

គ-រៀបរាប់ពីតួនាទី និងការទទួលខុសត្រូវរបស់គ្រូក្នុងពិពណ៌នាការងារ និងកិច្ចសន្យា(បញ្ចូលជម្រើសអាចនឹងត្រូវពង្រាយ ឡើងវិញ ក្នុងករណី ដែលលើសបុគ្គលិក)។

ឃ-ធានាឱ្យមានការអនុវត្តយុទ្ធសាស្ត្រជ្រើសរើសបុគ្គលធានាបាននូវតុល្យភាពរវាងគ្រូបង្រៀនជាស្ត្រី និងគ្រូបង្រៀនជាបុរស

ង-បង្កើនប្រាក់លាភការសម្រាប់គ្រូបង្រៀនទទួលយកប៉ុស្តិ៍ការងារនៅតំបន់ខ្វះគ្រូ។ អនុវត្តកញ្ចប់លើកទឹកចិត្តសម្រាប់ការកាត់ចំនួនគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលារៀន ដើម្បីកាត់បន្ថយបញ្ហាលើសគ្រូនៅតាមសាលាមធ្យមសិក្សា(ត្រូវចំណាយដំបូងជាមុនសិនដើម្បីទទួលបានប្រយោជន៍រយៈពេលវែង)។

**២-៥-៦.បន្តយកចិត្តទុកដាក់ក្នុងលក្ខណៈជាប្រព័ន្ធលើការលើកកម្ពស់ការបណ្តុះបណ្តាលគ្រូមធ្យមសិក្សា**

ប្រវត្តិនៃការបណ្តុះបណ្តាលគ្រូនៅក្នុងប្រទេសកម្ពុជាមានស្ថានភាពពុំដូចគ្នា ដែលជាហេតុនាំឱ្យគុណវុឌ្ឍិគ្រូតាមកម្រិតសិក្សាពុំទាន់បានសមស្របតាមស្ថានភាពសង្គមសេដ្ឋកិច្ច និងតម្រូវការនៃវិស័យអប់រំជាហេតុនាំឱ្យក្រសួងអប់រំកំណត់នូវស្តង់ដាគ្រូបង្រៀន ដើម្បីមានការឯកភាពផ្ទៃក្នុង និងប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់។ ដូចនេះពាក្យស្តង់ដាត្រូវបានប្រើប្រាស់សម្រាប់កំណត់គុណភាព និងបរិមាណរបស់វត្ថុ ឬសមត្ថភាពរបស់មនុស្សទៅតាមមុខរបរ ឬអាជីពផ្សេងៗគ្នា។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជាបានកំណត់ជា៤សមាសភាគគឺ(១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ (៣)ការសិក្សាវិជ្ជាជីវៈ និង(៤)សីលធម៌វិជ្ជាជីវៈ[38]។ បច្ចុប្បន្ននេះ ស្តង់ដាគ្រូបង្រៀនបានបន្ថែមមួយទៀតគឺការអប់រំឌីជីថល ដើម្បីឆ្លើយតបនឹងបដិវត្តឧស្សាហកម្ម៤.០។

ចំពោះស្តង់ដាគ្រូឧទ្ទេសនៅតាមវិទ្យាស្ថានបណ្តុះបណ្តាលគ្រូត្រូវមានសមាសភាគទាំង៦ គឺ(១)ចំណេះដឹងវិជ្ជាជីវៈ (២)ការប្រតិបត្តិវិជ្ជាជីវៈ(៣)ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ (៤)សីលធម៌វិជ្ជាជីវៈ(៥)ការស្រាវជ្រាវអប់រំ និង(៦)ការអភិវឌ្ឍកម្មវិធីអប់រំ[39]។

ដើម្បីសម្រេចបាននូវស្តង់ដាទាំងអស់នេះក្រសួងអប់រំបានខិតខំបំពេញសកម្មភាពដូចខាងក្រោម៖

ក-ពង្រីកគំរូវិទ្យាស្ថានគរុកោសល្យទៅតំបន់ផ្សេងទៀត និងបញ្ចូលគំរូវិទ្យាគរុកោសល្យទៅក្នុងគ្រប់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំ។

ខ-កែសម្រួលកម្មវិធីសិក្សា និងវិធីសាស្ត្រដែលប្រើប្រាស់សម្រាប់បណ្តុះបណ្តាលគ្រូ ដើម្បីយកគំរូតាមវិធីសាស្ត្ររៀន និងបង្រៀនផ្អែកតាមសកម្មភាព និងផ្អែកតាមលទ្ធផលព្រមទាំងយុទ្ធសាស្ត្រវាយតម្លៃបន្តបន្ទាប់។

គ-ធានាការចូលរួមប្រកបដោយសមធម៌រវាងបេក្ខជនទាំងពីរភេទក្នុងការអប់រំគ្រូមធ្យមសិក្សា។

---

[38] ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ឆ្នាំ២០១០ ទំ៣។

[39] ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ឆ្នាំ២០២២ ទំ១។

ឃ-លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូឧទ្ទេសបានមកពីការសិក្សាបន្ថែម និងការកើនឡើងនូវចំណេះដឹង និងជំនាញគរុកោសល្យរបស់ពួកគេ។ ពង្រឹងគន្លងអាជីពគ្រូឧទ្ទេស (អត្ថប្រយោជន៍លក្ខខណ្ឌការងារ ការជ្រើសរើសផ្អែកតាមគុណសម្បត្តិការងារ ការអភិវឌ្ឍវិជ្ជាជីវជាប្រចាំ និងការវាយតម្លៃ)។

ង-ធានាថា គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលាទទួលបានការបណ្តុះបណ្តាលស្តីពីការយល់ដឹងពីយេនឌ័រ និងបរិយាបន្នសង្គម។

ច-ពង្រីកកម្មសិក្សា ការបណ្តុះបណ្តាលគ្រូ ដើម្បីផ្តល់បទពិសោធន៍ពិតប្រាកដដល់គរុសិស្ស។

ឆ-ផ្តល់ការណែនាំការងារដំបូង ដល់គ្រូបង្រៀន និងនាយកសាលាទាំងអស់ ដែលទើបចេញបម្រើការងារក្នុងនោះរួមទាំងការណែនាំអំពីការប្រើប្រាស់បច្ចេកទេសគរុកោសល្យ ដែលឆ្លើយតបចំពោះយេនឌ័រ និងជំនាញប្រើប្រាស់គោលវិធីរៀនសូត្របែបចម្រុះផងដែរ។

ជ-អនុវត្តស្វ័យសិក្សា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន និងកម្រងសមាគមវិជ្ជាជីវៈគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដោយមានការគាំទ្រពីគ្រឹះស្ថានអប់រំគ្រូ។

ឈ-ដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធ ICT ដែលមានមូលដ្ឋានទូលំទូលាយ ដើម្បីផ្តល់សេវាអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដល់គ្រូទាំងតំបន់ប្រជុំជន និងជនបទនៅកម្ពុជា រួមទាំងថ្នាល ដែលមានសុវត្ថិភាពសម្រាប់ពិនិត្យតាមដាន និងវាយតម្លៃការចូលរួមរបស់គ្រូ និងអ្នកដឹកនាំសាលារៀន។

### ២-៥-៧.ធ្វើពិពិធកម្ម ពង្រីកលទ្ធផលនៃការអប់រំមធ្យមសិក្សាបច្ចេកទេស ដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច និងទីផ្សារការងារក្នុងមូលដ្ឋាន

សាលាមធ្យមសិក្សាភាគច្រើនជាពិសេសនៅតំបន់ជនបទខ្វះខាតធាតុចូលដែលមានគុណភាពដូចជា គ្រូបង្រៀនតាមមុខវិជ្ជា សម្ភារៈបង្រៀន និងគ្រឿងបរិក្ខារ សៀវភៅសិក្សាគោល បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រនិងភាសា និងបរិក្ខារបណ្ណាល័យជាដើម។

ក-ពង្រឹងបណ្តាញវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ដែលមានស្រាប់រួមនឹងការផ្តល់អន្តេវាសិកដ្ឋានដល់សិស្ស ដែលត្រូវរស់នៅឆ្ងាយពីផ្ទះសម្រាប់ជាយុទ្ធសាស្ត្រក្នុងការពង្រីកបណ្តាញនេះ។

ខ-បំពាក់បំប៉នគ្រូបច្ចេកទេសឱ្យក្លាយជាអ្នកបង្រៀនមានសមត្ថភាព និងគុណវុឌ្ឍិឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីសិក្សា និងស្របតាមតម្រូវទីផ្សារការងាដើម្បីលើកកម្ពស់សមភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់អាស៊ានដោយផ្តោតលើសមត្ថភាពឬជំនាញជាក់លាក់។

គ-ពង្រឹងសមត្ថភាពបុគ្គលិកសម្រាប់វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសតាមរយៈការចូលរួមចែករំលែកកិច្ចសហការជាមួយគ្រូបង្រៀនមកពីមជ្ឈមណ្ឌលបណ្តុះបណ្តាល និងវិជ្ជាជីវៈខេត្ត។

ឃ-ផ្តល់ថ្នាក់រៀនគ្រប់គ្រាន់ បន្ទប់ពិសោធន៍ រោងជាង និងអគាររដ្ឋបាល ដើម្បីអនុវត្តកម្មវិធីបច្ចេកទេសប្រកបដោយជោគជ័យ។

ង-ជួយដល់ការឆ្លងភូមិសិក្សារបស់សិស្សមធ្យមសិក្សាបឋមភូមិទៅកាន់កម្មវិធីអប់រំបច្ចេកទេសនៅកម្រិតទុតិយភូមិតាមរយៈការកែសម្រួលកម្មវិធីរក្សា ការផ្តល់ការណែនាំ ការប្រឹក្សាគរុកោសល្យ និងការផ្តល់ដំបូន្មានអំពីការអប់រំ។

**២-៥-៨.បង្កើនការសហការនៃការអប់រំកម្រិតមធ្យមសិក្សា និងក្រោយមធ្យមសិក្សា**

ក-បង្កើតបណ្តាញវិទ្យាល័យធនធានក្នុងមូលដ្ឋានជាមួយគ្រឹះស្ថានឧត្តមសិក្សា មជ្ឈមណ្ឌលអប់រំក្រៅប្រព័ន្ធ មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសហគ្រាសក្នុងមូលដ្ឋានដើម្បីពង្រឹងការសហការផ្តោតលើ (១)-សកម្មភាពប្រឹក្សាអាជីពដើម្បីបង្ហាញគន្លងពីសាលាមធ្យមសិក្សាទៅគ្រឹះស្ថានឧត្តមសិក្សា (ឧ. វិស័យសិក្សាធិការ និងការអប់រំបច្ចេកទេស) (២)អញ្ជើញម្ចាស់សហគ្រាសឱ្យធ្វើជាវាគ្មិនកិត្តិយសចុះទស្សនកិច្ចដល់កន្លែងធ្វើការ បទពិសោធន៍ការងារកម្មវិធីហាត់ការ (៣)កម្មវិធីរៀនពីមុខជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ ដើម្បីឱ្យពួកគេបញ្ចប់ការសិក្សាចំណេះទូទៅ ហើយក្នុងពេលជាមួយគ្នាមានឱកាសចូលរៀនក្នុងវគ្គបណ្តុះបណ្តាល TVET ដែលផ្តល់នៅតាមមូលដ្ឋាន (៤)ឱកាសស្ម័គ្រចិត្តសម្រាប់សិស្សនៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍(សម្រាប់ការអប់រំក្រៅប្រព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីអក្ខរកម្ម។

ខ-សហការជាមួយក្រុមហ៊ុនឯកជន ដើម្បីភ្ជាប់ទំនាក់ទំនងការបណ្តុះបណ្តាលបច្ចេកទេស ដែលផ្តល់នៅតាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសជាមួយនឹងទីផ្សារការងារតាមរយៈកម្មវិធីទទួលបទពិសោធន៍នៅកន្លែងធ្វើការ កម្មវិធីហាត់ការ និងកម្មវិធីហ្វឹកហាត់កូនជាង។

គ-តម្រូវឱ្យមានវិញ្ញាបនបត្រ និងលទ្ធភាពនៃការផ្លាស់ប្តូរ(transferability)រវាងអ្នកផ្តល់សេវាអប់រំក្រោយមធ្យមសិក្សា(រដ្ឋ និងឯកជន) រួចដាក់បញ្ចូលក្នុងគន្លងអប់រំបណ្តុះបណ្តាល និងអាជីព។

ឃ-រៀបចំឱ្យមានការផ្លាស់ប្តូរបទពិសោធន៍រវាងគ្រូ និងបង្កើតសហគមន៍អ្នកសិក្សាវិជ្ជាជីវៈរវាងសាលាមធ្យមសិក្សា និងសាលាអន្តរជាតិមានគុណភាពខ្ពស់។

ដូច្នេះ សសរស្តម្ភទាំង៥នៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ឆ្នាំ២០៣០របស់រាជរដ្ឋាភិបាលកម្ពុជា និងផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាកម្ពុជាឆ្នាំ២០៣០គឺត្រីវិស័យក្នុងការអភិវឌ្ឍធនធានមនុស្សគ្រប់កម្រិតសិក្សានៅប្រទេសកម្ពុជា ជាពិសេសក្នុងបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតដើម្បីឆ្លើយតបនឹងតម្រូវការនៃបរិបទសង្គម និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ផែនទីចង្អុលផ្លូវនេះគឺជាផែនទីបណ្តុះបណ្តាលសិស្ស និស្សិតឱ្យក្លាយជាពលរដ្ឋល្អមានចំណេះដឹង សីលធម៌ ចរិយាធម៌ គុណធម៌ល្អ បំណិនជីវិតក្នុងការរស់នៅ និងជំនាញបច្ចេកទេសវិទ្យាសាស្ត្រ ព័ត៌មានវិទ្យា ជំនាញសតវត្សរ៍ទី២១ ដែលនាំឱ្យសិស្សមានសមត្ថភាពពេញលេញអាចប្រែក្លាយប្រទេសកម្ពុជាពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០២៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

## សំណួរពិភាក្សា

១-ដូចម្តេចដែលហៅថា ផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍប្រទេសជាតិ?

២-តាមរយៈយុទ្ធសាស្ត្របញ្ចកោណក្នុងមុំទី១ស្តីពីការអភិវឌ្ឍមូលធនមនុស្ស។ តើលោកគ្រូ អ្នកគ្រូត្រូវអប់រំដូចម្តេចដើម្បីឱ្យសិស្សក្លាយជាពលរដ្ឋក្នុងសង្គម?

៣-តើក្រសួងអប់រំបានកំណត់យកផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យធនធានមនុស្សមានអ្វីខ្លះ? ចូររៀបរាប់។

៤-ហេតុអ្វីបានក្រសួងអប់រំចាត់ទុកថា ការបណ្តុះបណ្តាលវិស័យ(STEM) ជាអាទិភាពដើម្បីប្រែក្លាយពីសេដ្ឋកិច្ចពលកម្មទៅជាសេដ្ឋកិច្ចចំណេះដឹង?

៥-តើក្រសួងអប់រំបានធ្វើកំណែទម្រង់សាលារៀនយ៉ាងដូចម្តេច ដើម្បីឱ្យសាលារៀនក្លាយជាកន្លែងសិក្សាសតវត្សរ៍ទី២១?

# មេរៀនទី៣៖ កំណែទម្រង់វិស័យអប់រំនៅប្រទេសកម្ពុជា

## ៣-១-វត្ថុបំណងមេរៀន

### ក-វិជ្ជាសម្បទា

- រៀបរាប់បានពីការអនុវត្តគោលនយោបាយអប់រំស្តីពីគ្រូបង្រៀនបានច្បាស់លាស់
- ពិពណ៌នាបានពីកំណែទម្រង់ការអប់រំ និងវិមជ្ឈការសាលារៀននៅប្រទេសកម្ពុជា
- បរិយាយបានពីកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គោលនយោបាយពង្រាយគ្រូបង្រៀន និងការងារលើកកម្ពស់គុណវុឌ្ឍិគ្រូបងៀន

### ខ-បំណិនសម្បទា

- វាយតម្លៃបានពីការអនុវត្តគោលនយោបាយអប់រំស្តីពីគ្រូបង្រៀន និងពីសកម្មភាពសម្រេចកំណែទម្រង់ការអប់រំ និងវិមជ្ឈការសាលារៀននៅប្រទេសកម្ពុជាតាមរយៈក្រុមពិភាក្សា
- សំយោគពីសកម្មភាពកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន គោលនយោបាយពង្រាយគ្រូបង្រៀននិងការងារលើកកម្ពស់គុណវុឌ្ឍិគ្រូបងៀន

### គ-ចរិយាសម្បទា

- មានឆន្ទៈចូលរួមអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំនៅកម្ពុជា

## ៣-២-សេចក្តីផ្តើម

សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាធ្លាប់មានប្រសាសន៍ថា ប្រសិនបើយើងមិនធ្វើកំណែទម្រង់ទេនោះគឺ៩៩% រង់ចាំតែថ្ងៃស្លាប់ ប៉ុន្តែបើយើងធ្វើកំណែទម្រង់យើងនឹងមានសង្ឃឹមរស់[40]។ ចំពោះអភិក្រមទាំង៥របស់រាជរដ្ឋាភិបាលគឺ(១)ឆ្លុះកញ្ចក់ គឺត្រូវចេះស្វ័យទិតៀន ឬដាក់ខ្លួនឱ្យមហាជនរិះគន់រាល់ចំណុចអវិជ្ជមាននានា(២)ងូតទឹក គឺត្រូវសម្អាតកាយ វាចា និងចិត្ត ពោលគឺរៀបចំការស្លៀកពាក់សមរម្យឱ្យសក្តិសមជាមន្ត្រីរាជការ និយាយស្តីពីពីរោះពិសាជាមួយមិត្តរួមការងារក៏ដូចជាមហាជនទូទៅមិនត្រូវឈ្នានីស ប្រកាន់ ច្រណែន ខឹង ស្អប់ ព្យាបាទ(៣) ដុសក្អែល គឺត្រូវលុបបំបាត់នូវទម្លាប់អាក្រក់ និងទង្វើអសកម្មទាំងឡាយដូចជាអំពើពុករលួយ បក្សពួកនិយម(៤) ព្យាបាល គឺត្រូវដាក់វិន័យរាល់កំហុសឆ្គង ចេះកែប្រែឥរិយាបថរបស់ខ្លួនដែលឆ្គាំឆ្គង ដើម្បីជាគំរូ និងជួយដាស់តឿនមនុស្សជុំវិញខ្លួន និង(៥) វះកាត់ គឺការសម្រេចចិត្តដកតួនាទី ឬបណ្តេញចេញពីមុខតំណែងក្នុងករណីរកឃើញកំហុសធ្ងន់ធ្ងរបានធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍រួមរបស់ជាតិ។ ដូចនេះ អភិក្រមនេះបានក្លាយជាប្រធានបទស្នូលសម្រាប់អនុវត្តកំណែទម្រង់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិទី៥(២០១៤-២០១៨)។ ក្នុងនេះដែរ បណ្ឌិត ហង់ ជួនណារ៉ុន ទើបបានចូលកាន់តំណែងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានៅខែកញ្ញាឆ្នាំ

[40] https://freshnewsasia.com/index.php/en/

២០១៣បានមើលឃើញថា វិស័យអប់រំកម្ពុជាត្រូវបានញាំញីដោយបញ្ហាសំខាន់ៗជាច្រើនក្នុងនោះមានដូចជា ការធ្លាក់ចុះនៃសេវាអប់រំ គុណភាពអប់រំទន់ខ្សោយនៃយុវជនបានបញ្ចប់ការសិក្សា ប្រាក់ខែគ្រូបង្រៀននៅមានកម្រិតទាប អំពើពុករលួយនៅក្នុងស្ថាប័នអប់រំ និងការប្រឡង ព្រមទាំងវិសមភាពនៃបរិមាណគ្រូបង្រៀននៅទីប្រជុំជន និងទីជនបទដាច់ស្រយាលជាដើម[41]។ ផ្អែកលើហេតុផលនេះ ទើបឯកឧត្តមរដ្ឋមន្ត្រីអប់រំ បានដាក់ចេញនូវកំណែទម្រង់ស៊ីជម្រៅលើវិស័យអប់រំកម្ពុជារហូតដល់៤ដំណាក់កាលធំៗ ដោយផ្តោតលើកំណែទម្រង់ថ្នាក់ជាតិរហូតដល់កម្រិតសាលារៀន ដើម្បីធានាបាននូវគុណផលដល់ធនធានមនុស្សនៅប្រទេសកម្ពុជា ដើម្បីឆ្លើយតបនឹងគោលដៅទី៤(គុណភាពអប់រំ)របស់អង្គការសហប្រជាជាតិ (២០១៥-២០៣០) និងមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបទៅប្រទេស មានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

### ៣.៣.ការអនុវត្តគោលនយោបាយអប់រំស្តីពីគ្រូបង្រៀន

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ វិស័យអប់រំក៏ដូចជាវិស័យផ្សេងទៀតក្នុងប្រទេសកម្ពុជាត្រូវបានស្តារឡើងវិញជាពិសេសវិស័យធនធានមនុស្ស ដើម្បីរួមចំណែកអភិវឌ្ឍប្រទេស។ នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើតឡើង និងសាលារៀនគ្រប់កម្រិតសិក្សាក្នុងទូទាំងប្រទេសត្រូវបានបើកទ្វារទទួលសិស្សានុសិស្ស។ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមជាបន្ទាន់ដោយមាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួលខុសត្រូវ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមពីការប្រមូលអតីតគ្រូបង្រៀនសិស្ស និស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួន ដែលនៅសេសសល់ពីការកាប់សម្លាប់ក្នុងរបបខ្មែរក្រហមមកបំប៉នចិត្ត-គរុកោសល្យ និងវិធីសាស្ត្របង្រៀនរយៈពេលខ្លីនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨ ហើយបញ្ជូនទៅកាន់សាលារៀនចំណោះទូទៅក្នុងទូទាំងប្រទេស។ ដោយផ្អែកតាមប្រព័ន្ធបណ្តុះបណ្តាលគ្រូខុសៗគ្នា[42] នាំគុណភាពនៃការអប់រំមានការប្រែប្រួលមួយកម្រិតគួរឱ្យកត់សម្គាល់ពិសេសកម្រិតគុណភាព និងសមត្ថភាពរបស់គ្រូបង្រៀនពុំស្មើគ្នា។ ផ្តើមចេញពីបញ្ហានេះ ក្រសួងអប់រំបានកំណត់នូវគោលនយោបាយ និងស្តង់ដាគ្រូបង្រៀនក្នុងគោលបំណងធ្វើឱ្យគ្រូបង្រៀនមានសមត្ថភាពក្នុងការបណ្តុះបណ្តាលសិស្សានុសិស្សនៅតាមសាលារៀន។

គោលនយោបាយគ្រូបង្រៀនបានបង្កើតឡើងក្នុងឆ្នាំ២០១៣ រួមចំណែកក្នុងបរិបទកំណែទម្រង់អប់រំសំដៅដល់ការកសាងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ដ៏ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង ចំណេះធ្វើជាមូលដ្ឋាន

[41] https://www.rfi.fr/km/cambodia/hang-chuon-naron-three-years-in-education-reform-05-08-2016

[42] ប្រព័ន្ធបណ្តុះបណ្តាលគ្រូបានផ្លាស់ប្តូរទៅតាមប្រព័ន្ធអប់រំ១០ឆ្នាំ ១១ឆ្នាំ និង១២ឆ្នាំ។

ក្នុងបរិបទសកលភាវូបនីយកម្ម។ គោលនយោបាយគ្រូបង្រៀននេះ គឺជាផែនទីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានបុគ្គលិកលក្ខណៈពេញលេញរួមមាន ចំណេះដឹង ជំនាញ ស្មារតីទទួលខុសត្រូវ វិធីសាស្ត្របង្រៀន គរុកោសល្យ វប្បធម៌ទូទៅ ភាសាបរទេស កាយសម្បទារឹងមាំ និងបំណិនឌីជីថល ពោលគឺគ្រូបង្រៀនជាបុគ្គលដ៏សំខាន់មានតួនាទីជាអ្នកបណ្តុះបណ្តាលធនធានមនុស្ស និងលើកកម្ពស់គុណភាពអប់រំរួមចំណែកអភិវឌ្ឍប្រទេស[43]។

អគ្គបណ្ឌិតសភាចារ្យអូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើកឡើងថា កំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូជាពិសេសវិទ្យាស្ថានគរុកោសល្យទាំងពីរ គឺជាការលើកកម្ពស់គុណភាពធនធានមនុស្សនៅវិទ្យាស្ថានគរុកោសល្យ ដោយជ្រើសរើសបន្ថែមបុគ្គលិកបំពេញកង្វះខាត និងអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស ព្រមទាំងផ្ទេរចូលបន្ថែមគ្រូបង្រៀនឆ្នើមដូចជាគ្រូបង្រៀនល្អផ្នែកអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង និងរៀបចំគុណវុឌ្ឍិគ្រូឧទ្ទេសឱ្យត្រូវតាមស្តង់ដាមានឋានៈសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ និងបង្កើតឱ្យមានមជ្ឈមណ្ឌលឌីជីថល(Digital Center)ក្នុងវិទ្យាស្ថានគរុកោសល្យ សាងសង់ផ្ទះគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ ដើម្បីទាក់ទាញគ្រូឧទ្ទេសមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតមានសមត្ថភាពចូលបម្រើការនៅវិទ្យាស្ថានគរុកោសល្យជាដើម[44]»។ រីឯបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន មានប្រសាសន៍ថា ចំណេះដឹងមានអត្ថប្រយោជន៍លុះត្រាតែគ្រូបង្រៀនចេះប្រើប្រាស់ចំណេះដឹងនេះ ដើម្បីបង្កើនគុណភាពបង្រៀន បង្កើតបរិយាកាសអំណោយផលសម្រាប់ការសិក្សាប្រើវិធីសាស្ត្របង្រៀនសមស្រប ដើម្បីកែលម្អលទ្ធផលសិក្សាសិស្សប្រសើរជាងមុន និងលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំ ដើម្បីមនុស្សជាតិទាំងមូល[45]។

**ក-គោលនយោបាយគ្រូបង្រៀន**

គោលនយោបាយគ្រូបង្រៀនក្នុងគោលបំណង

- ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន និងធានាបាននូវការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន
- កំណត់ស្តង់ដាជាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ធ្វើសនិទានកម្មគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានក្នុងសម័យឌីជីថល
- អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារតាមគ្រឹះស្ថានរដ្ឋ និងឯកជន

---

[43] អ.យ.ក,យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា,២០១៨-២០២៣, ទំ.១១។

[44] https://hslcorner.files.wordpress.com/

[45] https://www.information.gov.kh/articles

- ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន និងពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន
- កសាងផែនការសកម្មភាពជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ។
- លើកកម្ពស់ជីវភាពតម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម
- ធ្វើទំនើបកម្មស្តង់ដាកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់និងសកលលោក។

**ខ-កំណត់ស្តង់ដាជាប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន**

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
- បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ុបក្នុងក្របខណ្ឌ
- កំណត់កម្រិតស្វ័យសិក្សារបស់គ្រូបង្រៀន។

**គ.អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះដ្ឋានបណ្តុះបណ្តាលគ្រូបង្រៀន
- ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- បង្កើតគុណវុឌ្ឍិ និងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន
- ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ដើម្បីអភិវឌ្ឍវិជ្ជាជីវៈ

**ឃ-ធ្វើសនិទានកម្មគ្រូបង្រៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថាន**

- ធ្វើទំនើបកម្មផែនការតាមតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់បណ្តុះបណ្តាល
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាម និងតាមគោលការណ៍
- លើកកម្ពស់ការគ្រប់គ្រង និងរៀបចំក្របខណ្ឌគ្រូបង្រៀន
- រៀបចំនិតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អសម្រាប់ជានានិរន្តរភាពគ្រឹះស្ថានសិក្សា
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើតសមិទ្ធផលសិក្សារបស់សិស្ស។

**ង-អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ**

- បណ្តុះវប្បធម៌ពេញមួយជីវិតដោយចេះចែករំលែកចំណេះនិងបទពិសោធ
- រៀបចំយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រគ្រូបង្រៀនទៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ

**ច.លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន**

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងការរស់នៅរបស់គ្រូតាមរយៈការផ្តល់បៀវត្ស សុខុមាលភាព

សង្គម និងអត្ថប្រយោជន៍ពេលចូលនិវត្តពិសេសគ្រូដែលបម្រើការនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាកនៅទូទាំងប្រទេស

- ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- លើកកម្ពស់ភាពរីកចម្រើននៃអាជីពស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។

**ឆ.ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន**

- ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព(កែលម្អរចនាសម្ព័ន្ធមានស្រាប់ អភិវឌ្ឍធនធានមនុស្ស ទាក់ទាញការចូលរួមរបស់សហគមន៍សាលារៀន ជំរុញការបង្រៀន និងរៀន និងការផលិតសម្ភារឧបទេស)

**ជ-ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន**

- បង្កើតប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន
- បង្កើត និងប្រើប្រាស់យន្តការពិនិត្យតាមដាន និងវាយតម្លៃដើម្បីកែលម្អលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន
- បង្កើតប្រសិទ្ធភាពក្នុងការប្រើប្រាស់លទ្ធផលវាយតម្លៃ
- កំណត់សិទ្ធគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្ដីសម្រេចលើការគ្រប់គ្រងនិងអភិវឌ្ឍ

**៣-៤-កំណែទម្រង់ស៊ីជម្រៅវិស័យអប់រំចាប់ពីឆ្នាំ២០១៣**

ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្ដើមកំណែទម្រង់វិស័យអប់រំតាំងពីឆ្នាំ២០១៣ ដើម្បីផ្សារភ្ជាប់នឹងគោលដៅទី៤ «ការអប់រំប្រកបដោយគុណភាព» ដើម្បីដាក់ចេញនូវផែនការយុទ្ធសាស្ត្រ២០១៤-២០១៨ទាក់ទងនឹងចក្ខុវិស័យឆ្នាំ២០៣០របស់រដ្ឋាភិបាល «កសាងសេដ្ឋកិច្ចឱ្យមានការប្រកួតប្រជែង សុខដុមនីយកម្ម និងនិរន្តភាពទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់»។ ការពង្រឹងការអនុវត្តកំណែទម្រង់ ការគ្រប់គ្រងធនធានមនុស្សត្រូវផ្ដោតលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈជាគ្រូបង្រៀន ភាពជាអ្នកដឹកនាំគ្រប់គ្រង និងជាអ្នកស្រាវជ្រាវ និងវាយតម្លៃជាចម្បង[46]។

ចាប់ពីឆ្នាំ២០១៣-២០២៣នេះ ក្រសួងអប់រំ យុវជន និងកីឡាបាន និងកំពុងធ្វើការកែទម្រង់ស៊ីជម្រៅលើគ្រប់ផ្នែករហូតដល់៤ដំណាក់កាលធំៗដូចខាងក្រោម៖

**៣-៤-១-កំណែទម្រង់ថ្នាក់ជាតិ(២០១៣)**

កំណែទម្រង់ក្នុងដំណាក់កាលទី១នេះ គឺបានកែទម្រង់លើអនុវិស័យទាំង៧ជាកម្រិតថ្នាក់ជាតិមានដូចជា (១)អនុវិស័យកុមារតូច (២)អនុវិស័យបឋមសិក្សា (៣)អនុវិស័យមធ្យមសិក្សា និងអប់រំ

[46] https://education.ams.com.kh/education-update/national/news/ministry-of-education

បច្ចេកទេស(៤)អនុវិស័យអប់រំក្រៅប្រព័ន្ធ (៥)អនុវិស័យឧត្តមសិក្សា (៦)អនុវិស័យអភិវឌ្ឍយុវជន និង(៧)អនុវិស័យអប់រំកីឡា[47]។ ហើយអនុវិស័យនីមួយៗក្រសួងអប់រំបានរៀបចំផែនការសកម្មភាពអប់រំ៨ចំណុចដែលមានរៀបរាប់ដូចខាងក្រោមនេះគឺ៖

១-បង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ

- ផ្តួចផ្តើមរៀបចំសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យព្រះស៊ីសុវត្ថិ
- បង្កើនអាហារូបករណ៍ដល់សិស្សក្រីក្រនៅមធ្យមសិក្សាបឋមភូមិ
- រៀបចំគោលនយោបាយ និងផែនការសកម្មភាពគ្រូបង្រៀន
- រៀបចំក្របខណ្ឌការងារ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាថ្មី

២-ពង្រឹងការគ្រប់គ្រងបុគ្គលិក

- បើកប្រាក់បៀវត្សដល់បុគ្គលិកតាមប្រព័ន្ធធនាគារ
- បង្កើនបៀវត្សបុគ្គលិកអប់រំដោយចាប់សន្សំចំណាយក្នុងវិស័យអប់រំ
- អនុវត្តនយាមបុគ្គលិកថ្មី
- អនុវត្តគោលការណ៍តែងតាំងមន្ត្រីគ្រប់គ្រងដោយវាយតម្លៃដាក់ពិន្ទុសមត្ថភាពការងារ និងលក្ខណសម្បត្តិបុគ្គល(គុណាធិបតេយ្យ)

៣-ពង្រឹងការប្រឡងគ្រប់ប្រភេទ

- ការផ្ទេរការទទួលខុសត្រូវប្រឡងថ្នាក់ទី៩ដល់ថ្នាក់ក្រោមជាតិ
- ចាប់ផ្តើមកំណែទម្រង់ប្រឡងថ្នាក់ទី១២
- កំណែទម្រង់ការប្រឡងជ្រើសរើសគ្រូបង្រៀន

៤-អភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេស និងជំនាញទន់ដល់យុវជន

- រៀបចំផែនការសកម្មភាពអភិវឌ្ឍយុវជន
- រៀបចំឯកសារ និងបណ្តុះបណ្តាលជំនាញនៅមជ្ឈមណ្ឌលយុវជន

៥-កំណែទម្រង់ឧត្តមសិក្សា

- រៀបចំចក្ខុវិស័យឧត្តមសិក្សាឆ្នាំ២០៣០
- ផ្ទេរសិទ្ធឱ្យគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវក្នុងការចេញសញ្ញាបត្រ
- កំណត់ឱ្យគ្រឹះស្ថានឧត្តមសិក្សារៀបចំផែនការយុទ្ធសាស្ត្រ និងសកម្មភាពស្រាវជ្រាវ

៦- អនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បង្កើនថវិកាសម្រាប់សាលារៀនតាមរយៈប្រកាសអន្តរក្រសួង
- ផ្ទេរការទទួលខុសត្រូវដល់មន្ទីរអប់រំខេត្តក្រុងក្នុងការរៀបចំ និងអនុវត្តថវិកាក្នុងឆ្នាំ២០១៥

[47] Education Strategic Plan 2014-2018, P.17.

- បង្កើតអង្គភាពលទ្ធកម្ម
- ពិនិត្យឡើងវិញ និងរៀបចំយន្តការថ្មីក្នុងការគ្រប់គ្រងសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ

៧-អប់រំកាយ និងកីឡាឆ្ពោះទៅអាស៊ីហ្គេម

- អនុម័តគោលនយោបាយស្តីការអប់រំកាយ និងកីឡា
- ចាប់ផ្តើមបង្កើនប្រាក់រង្វាន់សម្រាប់ជ័យលាភី
- បង្កើតគណៈកម្មការគ្រប់គ្រងពហុកីឡាជាតិអូឡាំពិក

៨-បង្កើតធនាគារខួរក្បាលសម្រាប់វិស័យអប់រំ

- បង្កើតក្រុមប្រឹក្សាស្រាវជ្រាវអប់រំ

**៣-៤-២-កំណែទម្រង់កម្រិតសាលារៀន**(**២០១៥-២០១៨**)

សន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២១-២០២២ និងលើកទិសដៅឆ្នាំសិក្សា២០២២-២០២៣ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សមិទ្ធផលដែលទទួលបានពិតជាក់ស្តែងចេញពីកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហការយ៉ាងស្អិតរមួតរបស់ថ្នាក់ដឹកនាំបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ លោកគ្រូអ្នកគ្រូ មាតាបិតា សហគមន៍ និងអាជ្ញាធរដែនដីក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យមានការរីកចម្រើនទៅមុខស្របតាមតួនាទី និងភារកិច្ចរៀងៗខ្លួនជាមួយនឹងស្មារតីទទួលខុសត្រូវខ្ពស់។

កំណែទម្រង់ក្នុងដំណាក់កាលទី២បានចាប់ពីឆ្នាំ២០១៥-២០១៨ ដែលបានផ្តោតលើកម្រិតថ្នាក់ក្រោមជាតិពិសេសកម្រិតសាលាដែលមាន១៥ចំណុចគឺ៖

១-កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

- បង្កើតអង្គភាពថវិកាចំនួន៣៩នៅថ្នាក់ជាតិ និង២៥នៅថ្នាក់រាជធានី-ខេត្ត
- ដាក់ឱ្យប្រើប្រាស់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា
- ការរៀបចំសៀវភៅអនុវត្តថវិកាកែលម្អសាលារៀន
- ការផ្តល់ថវិកាសម្រាប់ទិញកុំព្យូទ័រដល់សាលារៀន

២-ការពង្រាយគ្រូបង្រៀន

- ស្វ័យវាយតម្លៃពីស្ថានភាពគ្រូលើស គ្រូខ្វះនៅតាមអនុវិទ្យាល័យ និងវិទ្យាល័យ
- រៀបចំគោលការណ៍គ្រប់គ្រងធនធានមនុស្ស
- រៀបចំបច្ចុប្បន្នក្របខណ្ឌគ្រប់គ្រង និងផ្លាស់ប្តូរបុគ្គលិកអប់រំ
- សេចក្តីណែនាំពីនិយាមប្រើប្រាស់បុគ្គលិក

៣-កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន

- ការប្រែក្លាយគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងបាត់ដំបងទៅជាវិទ្យាស្ថានគរុកោសល្យ[48]
- ស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្តង់ដាគ្រូបង្រៀន
- ដំឡើងកម្រិតបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋាន១២+២ ទៅ១២+៤
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលកម្រិតបរិញ្ញា១២+៤
- ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស

៤-ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន

- ការអនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃបុគ្គលិកអប់រំ
- បំប៉នគ្រូគណិតថ្នាក់ទី១២ និងគ្រូវិទ្យាសាស្ត្រទូទាំងប្រទេស
- លើកកម្ពស់គ្រូកម្រិតមូលដ្ឋានឆ្ពោះទៅរកកម្រិតបរិញ្ញាបត្រ
- ពន្លឿនគ្រូកម្រិតមូលដ្ឋានទៅជាគ្រូកម្រិតឧត្តម

៥-ការងារអធិការកិច្ច

- អនុម័តបញ្ញត្តិនូវការធានាគុណភាពអប់រំនៅកម្រិតមត្តេយ្យ និងអប់រំចំណេះទូទៅនៅកម្ពុជា
- អនុម័តសៀវភៅជំនួយស្មារតីអធិការកិច្ចតាមការកំណត់
- បណ្តុះបណ្តាលអធិការកិច្ចតាមប្រព័ន្ធ
- បណ្តុះបណ្តាលDTMTនៅតាមស្រុក ខណ្ឌដល់នាយកសាលា និងគ្រូបង្រៀន

៦-វង្វាយតម្លៃលទ្ធផលសិក្សា

- រៀបចំក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សា
- រៀបចំការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- ការធ្វើតេស្ត និងផ្សព្វផ្សាយវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី៣ ទី៦ ទី៨ និងទី១១សម្រាប់ភាសាខ្មែរ និងគណិតវិទ្យា
- ការធ្វើតេស្តវាយតម្លៃកម្រិតអន្តរជាតិ
- ការធ្វើតេស្តល្បឿនអំណានសិស្សថ្នាក់ទី១ ទី២ និងទី៣

៧-កំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិ

- កំណែទម្រង់ការប្រឡងដោយឈរលើគោលការណ៍ច្បាប់ យុត្តិធម៌ តម្លាភាព លទ្ធផលដែលអាចទទួលយកបាន អ្នកចេះគឺជាប់
- កំណត់មុខវិជ្ជាភាសាខ្មែរផ្តោតលើតែងសេចក្តី និងសរសេរតាមអានសម្រាប់ប្រឡងមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ

[48] អនុក្រឹតរបស់រាជរដ្ឋាភិបាលលេខ៧៣.អនក្រ.បក ចុះថ្ងៃនៅ ថ្ងៃទី ២២ ខែឧសភាឆ្នាំ២០១៧។

- ការធ្វើវិមជ្ឈការទទួលខុសត្រូវដល់រាជធានី ខេត្តឱ្យចេះរៀបចំស្តង់ដារវិញ្ញាសាសម្រាប់ប្រឡងសញ្ញាបត្របឋមភូមិ
- អនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនឹងអប់រំបច្ចេកទេសពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា ៨-កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល
- អនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសពីមត្តេយ្យសិក្សាដល់មធ្យមសិក្សា
- ការអនុម័តកម្មវិធីសិក្សាលម្អិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ គ្រប់មុខវិជ្ជាគ្រប់កម្រិតថ្នាក់
- ការរៀបចំកម្មវិធីសិក្សាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ថ្នាក់ទី៤ ដល់ទី១២
- ការកែលម្អកម្មវិធីសិក្សាសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ
- ការកែលម្អសៀវភៅសិក្សាគោលពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ គ្រប់មុខវិជ្ជា ៦៥ចំណងជើង
- ការផលិតវីឌីអូខ្លីៗស្តីពីការបង្រៀន និងរៀនកម្មវិធីអំណានដំបូង និងគណិតវិទ្យាថ្នាក់ដំបូង។

  ៩-ការសាងសង់អគារសិក្សា និងការជួសជុល

- ការកែលម្អបរិស្ថានសិក្សាគឺជាការចាំបាច់ ដែលបានសាងសង់អគារសិក្សា អគារធនធាន អណ្តូងទឹកស្អាត បន្ទប់ទឹក បង្គន់អនាម័យ និងជួសជុលកែលម្អអគារសិក្សាដែលជាមណ្ឌលប្រឡងមធ្យមសិក្សាទុតិយភូមិ អគារសិក្សាទូទៅ និងបង្គន់អនាម័យ។

១០-ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា

- ការអនុម័តស្តង់ដា និងរៀបចំសៀវភៅណែនាំស្តីពីការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា
- ការអនុវត្តការធានាគុណភាពអប់រំតាមស្តង់ដាធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្ត
- ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា
- ការបណ្តុះបណ្តាលអំពីនីតិវិធី និងដំណើរការទទួលស្គាល់គុណភាពអប់រំនៅតាមគ្រឹះស្ថានសិក្សា
- ការវាយតម្លៃលើដំណើរការបណ្តុះបណ្តាលគ្រឹះស្ថានឧត្តមសិក្សា
- ការពិនិត្យតាមដាន និងពង្រឹងការរៀបចំផែនការផ្តែកលើលទ្ធផល និងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃនៅគ្រឹះស្ថានឧត្តមសិក្សា។

១១-លើកកម្ពស់វិស័យកីឡា

- ការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាអប់រំកាយក្នុង និងក្រៅម៉ោងសិក្សានៅគ្រឹះស្ថានសិក្សា
- ការរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាកម្រិតឧត្តម
- ការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡាតាមរូបមន្ត(១២+៤)
- ការរៀបចំថ្នាលកីឡា៩ប្រភេទកីឡា មានកីឡាករថ្នាល១៧២ នាក់
- ការធ្វើវិមជ្ឈការថវិកាដល់សហព័ន្ធកីឡាជាតិ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់

- ការជួសជុលកែលម្អពហុកីឡដ្ឋានជាតិអូឡាំពិក ការជួសជុលកែលម្អទីលានបាល់បោះ បាល់ទះ

១២-ផែនការសកម្មភាពគោលនយោបាយយុវជន

- ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការកាយឫទ្ធិ
- ការបង្កើតមជ្ឈមណ្ឌលការងារនៅខេត្តបន្ទាយមានជ័យ និងព្រះសីហនុ
- ការបង្កើតមជ្ឈមណ្ឌលបច្ចេកទេសមិត្តភាពកម្ពុជា ជប៉ុន នៅខេត្តសៀមរាប
- ការបង្កើតក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមក្រសួង
- ការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារនៅខេត្តកណ្តាល កំពង់ចាម និងកំពង់ធំ

១៣-ការអប់រំបច្ចេកទេស

- អនុម័តផែនការគោល និងផែនការសកម្មភាពស្តីពីការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ
- អនុម័តស្តង់ដាវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស
- អនុម័តក្របខណ្ឌកម្មវិធីអប់រំបំណិនជីវិតថ្នាក់ទី៤ដល់ទី៩ និងកម្មវិធីសិក្សាផ្នែកអប់រំបំណិន ជីវិត
- ការអនុម័តក្របខណ្ឌកម្មវិធីសិក្សាបំណិនជីវិតតាមមូលដ្ឋាន
- ការពង្រីកវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសរដ្ឋ និងឯកជន
- ការបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល និងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ
- ការរៀបចំស្តង់ដារោងជាងអប់រំបំណិនជីវិត និងសម្ភារបរិក្ខារនៅសាលាមធ្យមសិក្សា
- កសាងឯកសារប្រឹក្សាអាជីពនិងព័ត៌មានស្តីពីជំនាញសិក្សាដើម្បីបំប៉នគ្រូប្រឹក្សាអាជីពនៅមធ្យមសិក្សាទុតិយភូមិ។

១៤-ការបង្កើតសាលារៀនជំនាន់ថ្មី

- ការបង្កើនសាលារៀនជំនាន់ថ្មីបានចំនួន១០នៅខេត្ត និងរាជធានី ក្នុងនោះបឋមសិក្សា៤ និងមធ្យមសិក្សាចំនួន៦
- ការអនុវត្តកម្មវិធីសាលារៀនជំនាន់ថ្មីមធ្យមសិក្សាដោយផ្តោតលើអភិបាលកិច្ចសាលារៀន ព័ត៌មានវិទ្យា បច្ចេកវិទ្យា និងគមនាគមន៍ និងវិទ្យាសាស្ត្រ
- ការប្រកួតវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅតាមអនុវិទ្យាល័យ និងវិទ្យាល័យក្នុងខេត្ត បាត់ដំបង កំពង់ចាម និងសៀមរាប
- រៀបចំពិព័រណ៍មហោស្រព និងលើកកម្ពស់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM)
- ការរៀបចំកម្មវិធីសិក្សាមុខវិជ្ជាបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានសម្រាប់(Coding)ចាប់ពីថ្នាក់ទី៧-៩។

១៥-ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា

○ ការអនុម័តក្របខណ្ឌគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀន

○ ការរៀបចំប្រព័ន្ធសន្សំក្រេឌីតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលា

○ ការរៀបចំក្របខណ្ឌផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់នាយកសាលា និងគ្រូបង្រៀន

○ ការបង្កើតកម្មវិធីបណ្តុះបណ្តាលដំបូងថ្មី និងកម្មវិធីបណ្តុះបណ្តាលបន្ត

○ ការបង្កើតសមាសភាពគណៈកម្មការ និងលេខាធិការដ្ឋានសម្រាប់ជំរុញការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅគ្រប់កម្រិត

○ ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន(SBM) ដល់នាយកសាលាបឋមសិក្សា ៤៧២នាក់ ស្រី៧២នាក់។

## ៣-៤-៣-កំណែទម្រង់ដំណាក់កាលទី៣(២០១៨-២០២៣)

កំណែទម្រង់វិស័យអប់រំក្នុងដំណាក់កាលនេះគឺផ្តោតលើការកសាងប្រព័ន្ធ និងអភិវឌ្ឍធនធានមនុស្សចាប់ពីឆ្នាំ២០១៨-២០២៣ ដែលក្នុងនោះមានសសរស្តម្ភទាំង៥គឺៈ

ក-សសរស្តម្ភទី១-ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

○ ការសាងសង់ និងជួសជុលអគារនៃសាលាគរុកោសល្យ

○ ការបំពាក់សម្ភារបច្ចេកវិទ្យាព័ត៌មានសម្រាប់ការរៀន និងបង្រៀននៅតាមមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

○ ការរៀបចំឧបករណ៍សម្រាប់វាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងការផ្សារភ្ជាប់គ្នារវាងគ្រូបង្រៀនល្អ នាយកល្អ និងសាលារៀនល្អ

○ ការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៅវិទ្យាស្ថានជាតិអប់រំ

○ ការអនុម័តផែនការគោលស្តីពីការដំឡើងគុណវុឌ្ឍិបុគ្គលិកអប់រំ២០២១-២០២៥

○ ការអនុម័តឯកសារស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសសម្រាប់វិទ្យាស្ថានគរុកោសល្យ

○ ការបង្កើតប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ដើម្បីពិនិត្យតាមដានវាយតម្លៃគុណភាពអប់រំជាប្រចាំ

○ ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈក្នុងចំណោមគ្រូឧទ្ទេសតាមរយៈការសិក្សាស្រាវជ្រាវប្រតិបត្តិការផ្សព្វផ្សាយ និងការបោះពុម្ពព្រឹត្តិបត្រស្រាវជ្រាវ។

ខ-សសរស្តម្ភទី២-ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា

○ ការរៀបចំឯកសារសៀវភៅណែនាំគ្រូ និងសៀវភៅជំនួយសិស្សនៃកញ្ចប់សម្ភារអំណានថ្នាក់ដំបូង

○ ការពិនិត្យ និងកែលម្អកម្មវិធីសិក្សាថ្មីលើមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា

○ ការកែលម្អសៀវភៅសិក្សាគោលមុខវិជ្ជា គណិតវិទ្យា និងវិទ្យាសាស្ត្រថ្នាក់ទី១០ ដល់ទី១២

○ ការកែលម្អសៀវភៅសិក្សាគោលមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងសិក្សាសង្គម ថ្នាក់ទី៧ ដល់ទី១២ ការ

○ បង្កើតវេទិកាឌីជីថលរួមមានបណ្តាញ YouTube ផ្លូវការរបស់ក្រសួង, ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង និងមជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង ការផលិតវីដេអូបង្រៀនសិស្សគ្រប់កម្រិតសម្រាប់មុខវិជ្ជាគោល៦រួមមាន ភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យាគីមីវិទ្យា រូបវិទ្យា និងជីវវិទ្យាសម្រាប់ថ្នាក់ទី៩ និងទី១២។

គ-សសរស្តម្ភទី៣-ការដាក់ឱ្យអនុវត្តប្រព័ន្ធអធិការកិច្ច

○ ប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ ដែលមានដំណើរការល្អនៅសាលារៀន
○ អធិការកិច្ចតាមប្រធានបទ
○ ការផ្សព្វផ្សាយលទ្ធផលរបាយការណ៍អធិការកិច្ចតាមប្រធានបទ
○ ការធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំអធិការកិច្ចតាមកាលកំណត់ និងអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការ
○ ការអនុម័តសៀវភៅណែនាំប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំសម្រាប់រាជធានី ខេត្ត
○ ការធ្វើអធិការកិច្ចសាលារៀនតាមកាលកំណត់ផ្នែកបឋមសិក្សា
○ ការបណ្តុះបណ្តាលអធិការអប់រំជំនាន់ទី៤ ទី៥ និងទី៦ ចំនួន ១២២នាក់ ស្រី ២១នាក់
○ ការពង្រឹងប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្រិតសាលារៀន និងឆ្លើយតបទៅនឹងក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សា។

ឃ-សសរស្តម្ភទី៤-ពង្រឹងវាយតម្លៃសិក្សាតាមរូបភាពផ្សេងៗដូចជាការប្រឡង

○ ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ
○ ការកែលម្អគោលការណ៍ណែនាំ និងប្រព័ន្ធការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
○ ការកសាងសមត្ថភាព និងធ្វើវិសហមជ្ឈការលើការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ
○ ការពិនិត្យឡើងវិញលើខ្លឹមសារសំណួរតេស្តថ្នាក់ជាតិថ្នាក់ទី៦ និងការបន្សុីគ្នាជាមួយនឹងក្របខណ្ឌ
○ ការដាក់បញ្ចូលតេស្តវាយតម្លៃលទ្ធផលសិក្សាក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន
○ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិថ្នាក់ទី៣ ទី៦ ទី៨ ទី១១
○ ការរៀបចំឯកសារកម្មវិធីអន្តរជាតិស្តីពី តេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (PISA)
○ ការផ្សព្វផ្សាយលទ្ធផលតេស្តវាយតម្លៃកម្រិតអន្តរជាតិសម្រាប់ប្រទេសកំពុងអភិវឌ្ឍនៅកម្ពុជា (PISA-D)

ង-សសរស្តម្ភទី៥-ការកែទម្រង់ឧត្តមសិក្សា

○ រៀបចំយុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា២០២១-២០៣០និងយុទ្ធសាស្ត្រគ្រឹះស្ថានឧត្តមសិក្សា
○ ការរៀបចំផែនការមេសម្រាប់អភិវឌ្ឍធនធានមនុស្សនៅឧត្តមសិក្សា
○ ការរៀបចំមជ្ឈមណ្ឌលឧត្តមភាពនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
○ ការកែលម្អកម្មវិធីសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សាឱ្យស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

- ការកែលម្អនិងរៀបចំយន្តការធានាគុណភាពផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- ការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- វាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា១០
- ការរៀបចំគោលនយោបាយស្តីពីការស្រាវជ្រាវ និងការអភិវឌ្ឍនៅឧត្តមសិក្សា
- ប្រព័ន្ធធានាគុណភាពអប់រំឧត្តមសិក្សាផ្ទៃក្នុង និងខាងក្រៅ។

**៣-៤-៤-កំណែទម្រង់ដំណាក់កាលទី៤(២០២៣តទៅ)**

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពក្នុងការជ្រើសរើស និងបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីបំពេញបន្ថែមនូវតម្រូវការគ្រូបង្រៀនប្រកបដោយគុណភាព ការកៀរគរ និងការផ្តល់ធនធានបន្ថែមសម្រាប់គាំទ្រដល់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន អនុវត្តការកែទម្រង់សាលារៀន ការអភិវឌ្ឍ និងការលើកកម្ពស់បំណិនសតវត្សរ៍ទី២១ដល់យុវជននូវការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការជំរុញការអប់រំឌីជីថល ការកែទម្រង់សាលាគរុកោសល្យ ការលើកកម្ពស់សុខភាពសិក្សា និងការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា។

ដូចនេះ កំណែទម្រង់ដំណាក់កាលនេះ បានផ្តោតលើការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បរិវត្តកម្មសេដ្ឋកិច្ចឌីជីថលចាប់ពីឆ្នាំ២០២៣ ដើម្បីឆ្លើយតបទៅនឹងបរិបទនយោបាយសេដ្ឋកិច្ចសង្គមឌីជីថល ដែលរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញជាគោលនយោបាយនៅឆ្នាំ២០២១-២៩៣៥ ជាផែនទីបង្ហាញផ្លូវសម្រាប់ចក្ខុវិស័យនៃការអភិវឌ្ឍប្រទេសកម្ពុជា២០៥០។ កំណែទម្រង់នេះ គឺជានាកសាងសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថលឱ្យរស់រវើកតាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបដិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គមតាមគន្លងប្រក្រតីភាពថ្មី[49]។

ក-អាទិភាពទី១-កំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធសាលារៀន

គណនេយ្យភាព និងស្វ័យភាពរបស់សាលារៀន និងដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់មាតាបិតាក្នុងការគ្រប់គ្រងសាលាការពង្រឹងទំនាក់ទំនងរវាងសាលាជាមួយអាណាព្យាបាល ការបង្កើនថវិកាដំណើរការសាលារៀន ការបន្តវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសម្ភារឧបទេសក៏ដូចជាកែលម្អវិធីសាស្ត្របង្រៀន ការបង្កើនចំនួនសាលាជំនាន់ថ្មី ស្តង់ដាសាលាគំរូ ព្រមទាំងការពង្រឹងការគ្រប់គ្រងសាលារៀនជាទូទៅការលើកកម្ពស់ការរៀនភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងភាសាបរទេសនៅកម្រិតមធ្យមសិក្សាកម្រិតទូទៅ។

- ប្រភេទទី១-សាលារៀនជំនាន់ថ្មីដោយផ្តោតលើការផ្តល់ស្វ័យភាពក្នុងការអនុវត្តកម្មវិធីសិក្សាដើម្បី

[49] រាជរដ្ឋាភិបាលកម្ពុជា ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១-២៣៥,ទំ.១។

បណ្ដុះធនធានមនុស្សមានបំណិនសតវត្សរ៍ទី២១

○ ប្រភេទទី២-សាលារៀនគំរូ[50] ឬសាលារៀនប្រកបដោយប្រសិទ្ធភាពដោយផ្ដោតលើសាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ មានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀន និងផ្ដល់ការអភិវឌ្ឍជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន ហើយសិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន ការជួយសិស្សរៀនយឺត និងផ្ដល់ព័ត៌មានដល់មាតាបិតា និងសហគមន៍។ គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងរៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ ហើយមាតាបិតាសិស្ស និងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀនជាប្រចាំ។

**ខ-អាទិភាពទី២-ការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន**

គ្រូបង្រៀនគឺជាបេះដូងនៃប្រព័ន្ធអប់រំ គ្រូបង្រៀនជាកម្លាំងជួរមុខក្នុងវិស័យអប់រំ។ ដូចនេះគ្រូបង្រៀនសតវត្សរ៍ទី២១ ត្រូវតែកំណែទម្រង់ជាបន្តបន្ទាប់ដោយផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្តជាក់ស្ដែង គឺអភិវឌ្ឍមូលធនមនុស្ស ដែលជាមុំទី១ក្នុងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១(២០២៣-២០២៨) កំណែទម្រង់គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូផ្ដោតលើ៖

(១)ការកែលម្អកម្មវិធីបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន

(២)ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេសលើផ្នែកខ្លឹមសារមេរៀន គរុកោសល្យ និងវិធីសាស្ត្របង្រៀន និងរៀនមានលក្ខណៈសម្បូរបែប និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនក្នុងបរិបទឌីជីថល

(៣)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្របតាមបច្ចេកវិទ្យាថ្មីៗ ហើយបណ្ណាល័យ បន្ទប់ពិសោធ និងសម្ភារឧបទេសបង្រៀន និងរៀនបែបទំនើប

(៤)ការអភិវឌ្ឍភាពជាអ្នកដឹកនាំ និងគ្រប់គ្រង ដើម្បីឆ្ពោះទៅរកស្តង់ដាវិទ្យាស្ថានបណ្ដុះបណ្ដាលគ្រូគំរូ

(៥)ការផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្តកម្មវិធីសិក្សាគរុកោសល្យ

(៦)ការធានាគុណភាពនៃការបណ្ដុះបណ្ដាលគ្រូ

ខ៖ កំណែទម្រង់នៅវិទ្យាស្ថានជាតិអប់រំ

**១-ចក្ខុវិស័យ**

មជ្ឈមណ្ឌលឧត្តមភាពក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀន ការអភិវឌ្ឍវិជ្ជាជីវៈ និងការស្រាវជ្រាវ។

**២-បេសកកម្ម**

---

[50] ស្តង់ដាសាលារៀនគំរូរួមមានស្តង់ដាសាលាមត្តេយ្យ ស្តង់ដាសាលាបឋម និងស្តង់ដាសាលាមធ្យមសិក្សាគំរូដែលប្រកាសដាក់ឱ្យប្រើប្រាស់តាមរយៈលេខ១២៧៧អ.យ.ក.ប្រកចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២៣របស់បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

លើកកម្ពស់ការរៀន និងបង្រៀនសតវត្សរ៍ទី២១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងអ្នកស្រាវជ្រាវ។

**៣-គុណតម្លៃរបស់វិទ្យាស្ថានជាតិអប់រំរួមមាន៖**

**គុណភាព៖** វិទ្យាស្ថានជាតិអប់រំខិតខំផ្តល់ការបណ្តុះបណ្តាលប្រកបដោយគុណភាព សធម៌ និងឱកាសសម្រាប់ការសិក្សាពេញមួយជីវិត តាមរយៈការផ្តល់នូវក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលម្អិត និងការបណ្តុះបណ្តាលស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងសម្បទាសតវត្សរ៍ទី២១។ ដោយប្រកាន់ជាប់នូវគុណភាពជាស្នូលនៃវិទ្យាស្ថានជាតិអប់រំរួមចំណែកដល់ចក្ខុវិស័យសាលារៀនរបស់ប្រទេសកម្ពុជាឱ្យក្លាយជាមជ្ឈមណ្ឌលអប់រំមួយ ដែលធានានូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា និងផលិតគ្រូបង្រៀនប្រកបដោយសមត្ថភាព មនសិការ និងវិជ្ជាជីវៈ។ វិទ្យាស្ថាននឹងបណ្តុះបណ្តាលនិស្សិតដែលមានទាំងជំនាញរឹង និងទន់ អាកប្បកិរិយា សីលធម៌ ចរិយាធម៌ល្អ បញ្ញាអារម្មណ៍ និងក្លាយជាពលរដ្ឋជាតិ និងពលរដ្ឋសកលដែលមានគុណភាពខ្ពស់ ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍប្រទេសជាតិ និងពិភពលោក។

**សុច្ចរិតភាព៖** វិទ្យាស្ថានជាតិអប់រំ ប្តេជ្ញាចំពោះគោលការណ៍តម្លាភាព គណនេយ្យភាព វិន័យ ភាពស្មោះត្រង់ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់នៅក្នុងការអនុវត្តរាល់សកម្មភាពរបស់វិទ្យាស្ថាន។ កិត្តិនាមកិត្យានុភាពរបស់វិទ្យាស្ថានជាតិអប់រំនឹងការស្វែងរកភាពល្អប្រសើរសម្រាប់គរុនិស្សិត និងនិស្សិត គឺជាគោលការណ៍គ្រឹះរបស់វិទ្យាស្ថាន ។

**ឧត្តមភាព៖** ការប្តេជ្ញាចិត្តរបស់វិទ្យាស្ថានជាតិអប់រំចំពោះឧត្តមភាព គឺការជំរុញទាំងគ្រឹះស្ថាន និងបុគ្គលិកឱ្យខិតខំអនុវត្តខ្ជាប់ខ្ជួននូវរាល់តួនាទី និងភារកិច្ចក្នុងនាមជាគ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់នូវការអប់រំគ្រូបង្រៀន និងតួនាទីជាប្រវត្តិសាស្ត្រនិងប្រពៃណីជាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ ការប្តេជ្ញាចិត្តដើម្បីឧត្តមភាព ត្រូវធ្វើឡើងនៅគ្រប់ទិដ្ឋភាពទាំងអស់របស់វិទ្យាស្ថាន រួមទាំងកម្មវិធីសិក្សា ការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត ការជ្រើសរើសបុគ្គលិក សេវាកម្មនិស្សិត បរិស្ថាន ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ប្រតិបត្តិការប្រចាំថ្ងៃ និងសេវាសហគមន៍។

**នវានុវត្តន៍៖** ជាមជ្ឈមណ្ឌលស្រាវជ្រាវអប់រំប្រកបដោយនវានុវត្តន៍ វិទ្យាស្ថានជាតិអប់រំព្យាយាមអនុវត្តការស្រាវជ្រាវដោយផ្អែកលើភស្តុតាង ការប្រើប្រាស់បច្ចេកវិទ្យា និងការអនុវត្ត សម្បទាអប់រំសតវត្សរ៍ទី២១។ វិទ្យាស្ថានជាតិអប់រំនឹងកំណត់និយមន័យស្តង់ដាឧត្តមភាពឡើងវិញជាប្រចាំ ដើម្បីរក្សាបាននូវភាពឆ្លើយតប និងលើកកម្ពស់គុណភាពប្រកបដោយចីរភាព។

**សមធម៌៖** វិទ្យាស្ថានជាតិអប់រំប្តេជ្ញាចំពោះគោលការណ៍មិនលម្អៀង ការគោរពនូវចម្រុះភាព និងជំនឿសាសនាខុសៗគ្នា។ គុណតម្លៃនេះបណ្តុះបាននូវវប្បធម៌គ្រឹះរបស់វិទ្យាស្ថាន ក្នុងការផ្តល់ឱកាសសម្រាប់ឧត្តមភាពនៃការអប់រំដល់មនុស្សគ្រប់រូប ដោយមិនគិតពីចំណុចចាប់ផ្តើមរបស់ពួកគេ។

វិទ្យាស្ថានជាតិអប់រំ (NIE) បានកំណែទម្រង់វិស័យអប់រំសម្រាប់ការបណ្តុះបណ្តាលចំនួនប្រាំបួនចំណុចចម្បងៗពង្រឹងគុណភាពអប់រំគរុកោសល្យ[51]។ កំណែទម្រង់វិស័យអប់រំរបស់វិទ្យាស្ថានជាតិអប់រំរួមមានកែលម្អកម្មវិធីសិក្សា អភិវឌ្ឍធនធានសិក្សា អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ប្រែក្លាយវិទ្យាស្ថានជាតិអប់រំទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ លើកកម្ពស់ការដឹកនាំនិងអភិបាលកិច្ចល្អ កែលម្អការជ្រើសរើសគរុនិស្សិត លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ផ្សារភ្ជាប់វិទ្យាស្ថានជាតិអប់រំនិងសាលាអនុវត្ត និងសាលាសហការ ព្រមទាំងពង្រឹងសហប្រតិបត្តិការជាតិ និងអន្តរជាតិ ។

១-កែលម្អកម្មវិធីសិក្សា៖ ការកែលម្អកម្មវិធីសិក្សាប្តូរពីប្រព័ន្ធកំណត់ដោយម៉ោងទៅជាកំណត់ដោយក្រេឌីត ដើម្បីរៀបចំកម្មវិធីសិក្សាលម្អិត។ លើសពីនេះ មានវិធីសាស្រ្តបង្រៀនផ្សេងៗ មិនច្រំដែលឯកសារបង្រៀននិងបង្រៀនមានស្តង់ដាសម្រាប់ការបណ្តុះបណ្តាលគ្រូដំបូង និងបណ្តុះបណ្តាលគ្រូបន្ត ។ ដូចគ្នា កម្មវិធីសិក្សាត្រូវតែលម្អិត វិធីសាស្រ្តបង្រៀន និងឯកសារបង្រៀនមានស្តង់ដាជំរុញការសិក្សាទទួលបានប្រសិទ្ធភាពខ្ពស់ ។

២-អភិវឌ្ឍធនធានសិក្សា ៖ កសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីឆ្លើយតបនឹងកម្មវិធីបណ្តុះបណ្តាល និងស្តង់ដាសាលាគរុកោសល្យជំនាន់ថ្មី។ វិទ្យាស្ថានជាតិអប់រំនឹងរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្ណាល័យសម្តេចសង្ឃរាជជួន ណាត ដែលមានកម្ពស់៥ជាន់ស្ថិតនៅបងខាងលិចដែលឧបត្ថម្ភពីធនាគារអភិវឌ្ឍអាស៊ី(ADB)។ លើសពីនេះ ដាក់ចេញផែនការជួសជុលអគារចាស់ៗទាំងអស់របស់វិទ្យាស្ថានជាតិអប់រំក្រោមគម្រោងរបស់ ADB និងរាជរដ្ឋាភិបាល ដើម្បីប្រែក្លាយវិទ្យាស្ថានជាតិអប់រំឱ្យក្លាយទៅជាសាលាគរុកោសល្យជំនាន់ថ្មី។

៣-អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ៖ បន្តបណ្តុះបណ្តាលមត្ថភាពវិជ្ជាជីវៈគ្រូឧទ្ទេស គណៈគ្រប់គ្រង និងមន្ត្រីជាប្រចាំ។ ជារៀងរាល់ឆ្នាំវិទ្យាស្ថានជាតិអប់រំបញ្ជូនមន្ត្រីទៅសិក្សានៅបរទេសទាំងរយៈពេលខ្លី និងរយៈពេលវែង ដើម្បីអប់រំគ្រូបង្រៀនឱ្យស្របតាមនិន្នាការគ្រូបង្រៀននៅក្នុងតំបន់អាស៊ាន ។

៤-ប្រែក្លាយវិទ្យាស្ថានជាតិអប់រំទៅជាគ្រឹះស្ថានឧត្តមសិក្សាពេញលេញ ៖ វិទ្យាស្ថានជាតិអប់រំមានបំណងរៀបចំឱ្យមានមហាវិទ្យាល័យនៅក្រោមវិទ្យាស្ថានជាតិអប់រំពីព្រោះសព្វថ្ងៃនេះ មានត្រឹមថ្នាក់ការិយាល័យ។ លើសពីនេះ បង្កើតជាគ្រឹះស្ថានមួយដែលមានថ្នាក់មហាវិទ្យាល័យសម្រាប់បណ្តុះបណ្តាលសិស្ស ១២ + ៤ និងបរិញ្ញាបត្រ+២ផងដែរ ។

៥-លើកកម្ពស់ការដឹកនាំ និងអភិបាលកិច្ចល្អ ៖ ដាក់ចេញគោលការលើកកម្ពស់ការដឹកនាំគ្រប់គ្រង និងអភិបាលកិច្ចល្អដោយគ្រប់គ្រងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ ទន្ទឹមនឹងនេះ ព្យាយាមធ្វើយ៉ាណាឱ្យការដឹកនាំគ្រប់គ្រង និងអភិបាលកិច្ចល្អមានប្រសិទ្ធភាពខ្ពស់ ។

---

[51] https://education.ams.com.kh/national-institute-of-education

៦-កែលម្អការជ្រើសរើស ៖ កែលម្អការជ្រើសរើសឱ្យកាន់តែមានភាពសុក្រឹតលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីផ្សារភ្ជាប់ទៅនឹងគោលនយោបាយជាមួយសាលាគរុកោសល្យ និងសាលារៀន ។ ម្យ៉ាងវិញទៀត វិទ្យាស្ថានជាតិអប់រំ សាលាអនុវត្តន៍ និងប្រែក្លាយទៅជាសាលាគំរូ ។

៧-លើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍៖ អភិវឌ្ឍសមត្ថភាពស្រាវជ្រាវលើវិជ្ជាជីវៈជំនាញ និងកសាងវប្បធម៌ស្រាវជ្រាវក្នុងវិស័យអប់រំច្រើនជាងការបង្រៀន និងរៀនជាមួយគ្រូ។ វិទ្យាស្ថានកសាងធនធានមនុស្សកម្រិតខ្ពស់ដែលមានភាពច្នៃប្រឌិត ការទទួលខុសត្រូវប្រកបដោយសមត្ថភាព ត្រិះរិះត្រឹមត្រូវ និងសកម្មភាពជាវិជ្ជមាន ។

៨-ផ្សារភ្ជាប់វិទ្យាស្ថានជាតិអប់រំ សាលាអនុវត្ត និងសាលាសហការ ៖ វិទ្យាស្ថានជាតិអប់រំលើកកម្ពស់ការស្រាវជ្រាវ និងនវានុវត្តន៍ដើម្បីផ្សារភ្ជាប់សាលាគរុកោសល្យនិងសាលាអនុវត្ត ដើម្បីប្រែក្លាយជាសាលាអនុវត្តន៍ជំនាន់ថ្មី។ វិទ្យាស្ថានមានសាលាសហការ ដែលជាដៃគូអនុវត្តផែនការអប់រំប្រកបដោយប្រសិទ្ធភាព ។

៩-សហប្រតិបត្តិការជាតិ និងអន្តរជាតិ៖ វិទ្យាស្ថានជាតិអប់រំនៅតែបន្តកិច្ចសហប្រតិបត្តិការទាំងក្នុងនិងក្រៅប្រទេសសំដៅដល់ការបណ្តុះបណ្តាលគ្រូឧបទ្ទេសសម្របតាមលក្ខណៈស្តង់ដារគ្រូបង្រៀននៅក្នុងតំបន់អាស៊ាន។ ទន្ទឹមនឹងនេះ ពង្រឹងទំនាក់ទំនង និងធ្វើយ៉ាងណាឱ្យវិទ្យាស្ថានជាតិអប់រំជាគ្រឹះស្ថានសិក្សាមានលក្ខណៈស្តង់ដារជាសកល។

គ-អាទិភាពទី៣-

បដិវត្តន៍ឧស្សាហកម្ម៤.០ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសកលបាន និងកំពុងលេចរូបរាងនិងមានការវិវឌ្ឍយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យាឌីជីថលបាន និងកំពុងដើរតួនាទីជាស្នូល និងចលករនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គមមានភាពសម្បូរបែបប្រសិទ្ធភាព និងផលិតភាពនៃប្រតិបត្តិការការងារត្រូវបានហៅជារួមថា "បរិវត្តកម្មឌីជីថល" នៅជុំវិញការរស់នៅប្រចាំថ្ងៃ។ បរិវត្តកម្មនេះបាន និងកំពុងផ្សារភ្ជាប់យ៉ាងស្អិតល្មួតនៅក្នុងគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច និងសង្គម ដែលបង្កើតបានជាសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថល។

នៅក្នុងដំណាក់កាលកូវីដ-១៩ កម្ពុជាបានដើរទៅមុខ១០ឆ្នាំមុនកាលកំណត់ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យអប់រំ។ គ្រូបង្រៀនបានខិតខំរៀនពីការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីបង្រៀនសិស្សនៅពេលសាលាត្រូវបានផ្អាកដំណើរការជាបណ្តោះអាសន្ន។ ក្រសួងនឹងបន្តលើកកម្ពស់ការអប់រំឌីជីថលតាមរយៈ(១)ការកែលម្អវេទិកាឌីជីថលដែលមានស្រាប់ និងការបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងពីចម្ងាយ (២)ការផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោល និងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះនិងផ្សព្វផ្សាយលើវេទិកាឌីជីថលដែលមានស្រាប់ (៣)ការបញ្ចូលការប្រើប្រាស់បច្ចេកវិទ្យាទៅក្នុងការបង្រៀននិងរៀន (៤)ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅតាមសាលារៀនដូចជាការរៀបចំបន្ទប់ឌីជីថល ការបំពាក់

ប្រព័ន្ធគ្រប់គ្រងការសិក្សា និងប្រព័ន្ធគ្រប់គ្រងការសិក្សានៅតាមសាលារៀន (៥)ការបង្កើតកម្មវិធីអប់រំឌីជីថលដូចជា coding, app, robotics and animation។

ការអប់រំបែបឌីជីថលជាការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថលក្នុងការរៀន និងបង្រៀនក៏ដូចជាការគ្រប់គ្រងដែរ។ សព្វថ្ងៃនេះគ្រឹះស្ថានសិក្សាមួយចំនួនទាំងរដ្ឋ និងឯកជនបានប្រើប្រាស់នូវកម្មវិធីសិក្សាដែលមានដូចជា (១)ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក(E-Learning) ជាប្រព័ន្ធនៃការអប់រំតាមបែបឌីជីថលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ ប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ។(២)ការអប់រំពីចម្ងាយ (Distance Learning) ជាវិធីសាស្ត្រមួយ ដែលសិស្សអាចទទួលបានការអប់រំសម្រាប់ការអភិវឌ្ឍសម្បទាទាំង៤ (ពុទ្ធិសម្បទា បំណិនសម្បទា កាយសម្បទា និងចរិយាសម្បទា) ដោយពុំចាំបាច់មានវត្តមាន ឬជួបគ្រូដោយផ្ទាល់។ (៣)គ្រឹះស្ថានសិក្សាមួយចំនួនក៏បានផ្សារភ្ជាប់កម្មវិធី ការអប់រំពីចម្ងាយជាមួយប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ (Blended Learning) ឬ ដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)។

ឃ-អាទិភាពទី៤-ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា(STEM)

ការបង្កើនចំនួនសិស្ស និងទាក់ទាញសិស្សនៅមធ្យមសិក្សា និងឧត្តមសិក្សាឱ្យចូលរៀនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាកត្តាសំខាន់ ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្ម៤.0 និងគោលនយោបាយជំរុញឌីជីថលរបស់រាជរដ្ឋាភិបាល។ ដូចនេះក្រសួងនឹង(១) បង្កើនចំនួនសាលារៀនជំនាន់ថ្មី សាលារៀនស្វែម និងបង្កើនម៉ោងបង្រៀន និងការបង្រៀនផ្តោតលើមុខវិជ្ជាស្វែម (២)វិនិយោគបន្ថែម និងបង្កើនគុណភាពការបណ្តុះបណ្តាលគ្រូមុខវិជ្ជាស្វែមឱ្យដល់កម្រិតស្តង់ដាវិជ្ជាជីវៈ (៣)កែលម្អវិធីសាស្ត្របង្រៀនតាមមុខវិជ្ជាស្វែមដោយផ្តោតលើវិធីវិទ្យាសាស្ត្រ វិធីរិះរក និងវិធីផ្សេងទៀតសម្រាប់ការបង្រៀនគណិតវិទ្យា និងវិទ្យាសាស្ត្រ (៤)វិនិយោគបន្ថែមលើការបំពាក់សម្ភារឧបទេស និងការធ្វើពិសោធន៍នៅតាមវិទ្យាល័យធនធាន សាលាគំរូ និងសាលារៀនជំនាន់ថ្មី (៥)ជំរុញការបង្កើតក្លឹបសិក្សាក្រោយម៉ោងសិក្សា និងពង្រឹងក្រុមប្រឹក្សាយុវជន និងបង្កើតប្រព័ន្ធអេកូឡូស៊ីដូចជា ការតាំងពិព័រណ៍វិទ្យាសាស្ត្រ ការប្រកួតប្រជែងស្នាដៃ និងការបង្កើតភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សា និងក្រុមហ៊ុនឯកជន។

ង-អាទិភាពទី៥-ការលើកកម្ពស់សុខភាពសិក្សា

ក្នុងបរិបទនៃគន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ សាលារៀនត្រូវធានាបាននូវនិរន្តរភាពនៃដំណើរការ និងធានាសុវត្ថិភាពសុខភាពរួមទាំងសុខភាពផ្លូវចិត្តសម្រាប់បុគ្គលិកអប់រំ និងសិស្សានុសិស្ស។ ដូចនេះសាលារៀនត្រូវ (១)បង្កើតគណៈកម្មការសុខភាពសិក្សានៅតាមសាលារៀន (២)កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាពដូចជា រៀបចំបន្ទប់សុខភាពស្តង់ដា បរិស្ថានសាលារៀនបៃតង សាលាស្អាតគ្មានសំរាម (៣) លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងអនាម័យផ្តោតលើទឹកទទួលទាន កន្លែងលាងដៃ បង្គន់អនាម័យ ការពាក់ម៉ាស និងការរក្សាគម្លាត (៤)លើកកម្ពស់អាហារូបត្ថម្ភដោយផ្តោតលើសុវត្ថិភាពចំណីអាហារ និងការ

ផ្តល់អាហារតាមសាលារៀន (៥)អប់រំអំពីសុខភាពសិក្សា និងគន្លងប្រក្រតីភាពថ្មីដោយអនុវត្តតាមខ្លឹមសាររបស់កម្មវិធីសិក្សាមុខវិជ្ជា សុខភាពសិក្សា ការហាត់ប្រាណ និងលេងកីឡា។

**ច-អាទិភាពទី៦-ការអភិវឌ្ឍយុវជន ដើម្បីលើកកម្ពស់បំណិនសតវត្សរ៍ទី២១**

យុវជននឹងត្រូវទទួលបាននូវការអភិវឌ្ឍលើគ្រប់ទិដ្ឋភាព និងតាមគ្រប់រូបភាពក្នុងនោះ (១)កម្មវិធីអភិវឌ្ឍយុវជនទាំងបំណិនរឹង និងបំណិនទន់ ដោយផ្តោតលើបំណិនសតវត្សទី២១ និងលើកកម្ពស់ភាពជាអ្នកដឹកនាំ (២)ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងការអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបំណិនទន់ ដើម្បីឱ្យយុវជនមានសមត្ថភាពចូលរួមដោះស្រាយបញ្ហារួមរបស់ប្រទេសជាតិ មានភាពក្លាហាន និងមានភាពឈ្លាសវៃក្នុងការបញ្ចេញមតិ មានសមត្ថភាពត្រិះរិះពិចារណា សិក្សាស្រាវជ្រាវ ចែករំលែកគំនិត និងជំនាញក្នុងការនិយាយសាធារណៈ ប្រកបដោយក្រមសីលធម៌ និងចំណេះដឹងពិតប្រាកដ(៣)ការផ្តល់ឱកាសឱ្យយុវជនបញ្ចេញគំនិតយោបល់ បង្ហាញទេពកោសល្យ ដើម្បីបង្កើតសង្គមពុទ្ធិ និងស្វែងរកសុខដុមនីយកម្មសម្រាប់ទាំងអស់គ្នា បង្កើតទំនាក់ទំនងល្អរវាងយុវជន និងយុវជន និងលើកកម្ពស់តម្លៃមិត្តភាព (៤)បង្កើតជាថ្នាលសម្រាប់យុវជនហាត់ការឱ្យមានភាពរឹងមាំ មានភាពចាស់ទុំគំនិត និងចេះគិតហ្មត់ចត់

ឆ-អាទិភាពទី៧-ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា

១-គ្រឹះស្ថានឧត្តមសិក្សាត្រូវផ្តោតលើការពង្រឹងអភិបាលកិច្ច ការលើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យឱ្យមានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

២-កសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ

៣-រៀបចំ និងអនុវត្តកម្មវិធី ឬគំនិតផ្តួចផ្តើមថ្នាក់ជាតិក្នុងការអភិវឌ្ឍ និងការបណ្តុះបណ្តាលធនធានមនុស្ស ដែលមានទេពកោសល្យឌីជីថល

៤-រៀបចំ និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទេពកោសល្យជំនាញ និងការបណ្តុះគំនិតថ្មីដោយផ្អែកលើតម្រូវការជំនាញថ្មី

៥-ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍព្រមទាំងនវានុវត្តផ្នែកឌីជីថលនៅតាមសកលវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ វិទ្យាស្ថាននិងមជ្ឈមណ្ឌលស្រាវជ្រាវនានា

៦-កសាងក្របខណ្ឌភាពជាដៃគូជាមួយនឹងវិស័យឯកជនក្នុងការជំរុញ និងការអភិវឌ្ឍការងារស្រាវជ្រាវ និងនវានុវត្តន៍។

ជ-អាទិភាពទី៨-ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

វិស័យអប់រំទាមទារចាំបាច់នូវភាពជាអ្នកដឹកនាំមានភាពវៃឆ្លាតរស់រវើក បុរេសកម្ម និងទន់ភ្លន់ក្នុងការដោះស្រាយបញ្ហា និងឆ្លើយតបភ្លាមៗចំពោះវិបត្តិបង្កឱ្យមានការអាក់ខានក្នុងការបង្រៀន និងរៀននៅទូទាំងប្រទេស។ ប្រព័ន្ធអប់រំត្រូវតែមានភាពធន់តាមរយៈភាពរស់រវើកក្នុងការកំណត់អាទិភាពទាំងផ្នែកចំណាយ និងការបំពេញការងាររួមទាំងការចាប់យកឱកាសប្រែក្លាយវិបត្តិទៅជាឱកាសក្នុងការធ្វើកំណែទម្រង់។

**ឈ-អាទិភាពទី៩-ការអភិវឌ្ឍការអប់រំកាយ និងកីឡា**

ក្រសួងបន្តលើកកម្ពស់វិស័យកីឡា ដើម្បីកសាងមនុស្សគ្រប់រូបឱ្យមានសុខភាព និងសុខុមាលភាពល្អ កាយសម្បទាមាំមួន ឆន្ទៈមោះមុត អំណត់ព្យាយាម មានវិន័យ មានស្មារតីក្រុម គំនិតច្នៃប្រឌិត និងមានការតស៊ូស្វិតស្វាញស្របតាមពាក្យស្លោក «កីឡារស់ប្រកបដោយសុខដុមរមនាក្នុងសង្គមក្រោមម្លប់សន្តិភាព »ព្រមទាំងបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។

ក្រសួងជំរុញការអនុវត្តកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំកាយ និងកីឡាតាមរយៈការពង្រឹងការគ្រប់គ្រងវិស័យអប់រំកាយ និងកីឡា ការពង្រឹងយន្តការដែលមានស្រាប់រួមទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡា ការបណ្តុះបណ្តាលធនធានមនុស្ស និងការលើកទឹកចិត្ត ។

ក្រសួងជំរុញការលើកទឹកចិត្ត និងបណ្តុះវប្បធម៌អប់រំកាយនិងកីឡាដល់ប្រជាជនឱ្យយល់ដឹងអំពីសារៈសំខាន់នៃការហាត់ប្រាណ និងលេងកីឡាជាប្រចាំ ដើម្បីសុខភាពផ្សារភ្ជាប់ទៅនឹងកិច្ចការសង្គមវប្បធម៌ ដើម្បីឱ្យប្រជាជនរស់នៅប្រកបដោយភាពស៊ីវិល័យ និងសុខដុមនីយកម្មក្នុងសង្គម។

ដូចនេះ បដិវត្តន៍ឌីជីថលបានផ្លាស់ប្តូររបៀបរស់នៅធ្វើការ និងរៀនសូត្រសម្រាប់អនាគត ដែលតម្រូវឱ្យមានជំនាញផ្សេងៗដូចជា គំនិតច្នៃប្រឌិត ការគិតរិះគន់ ការដោះស្រាយបញ្ហា ការសម្រេចចិត្ត ចំណេះដឹងផ្នែកព័ត៌មានវិទ្យា និងការសហការដើម្បីត្រៀមខ្លួនសម្រាប់យុគឌីជីថលនៃការអប់រំសតវត្សរ៍ទី២១នេះ។

ដូច្នេះ វិស័យអប់រំនៅកម្ពុជានាសតវត្សរ៍ទី២១នេះត្រូវបានកែទម្រង់ជាច្រើនដំណាក់កាល ដើម្បីឆ្លើយតនឹងបរិបទសង្គម កំណើនបច្ចេកវិជ្ជាវិទ្យាសាស្ត្រ តម្រូវការសេដ្ឋកិច្ចជាពិសេសចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រែក្លាយជាប្រទេសអភិវឌ្ឍក្នុងឆ្នាំ២០៥០។ ដំណើរការនៃការកែទម្រង់នេះក្រសួងអប់រំបានផ្តោតយកចិត្តទុកលើគ្រប់អនុវិស័យជាពិសេសស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីធានាឱ្យគ្រូបង្រៀនដែលបានបញ្ចប់ការបណ្តុះបណ្តាល ហើយត្រឡប់ទៅបំពេញការងារវិជ្ជាជីវៈជាគ្រូបង្រៀនប្រកបដោយសក្តានុពល ដែលអាចបណ្តុះបណ្តាលសិស្សឱ្យក្លាយជាពលរដ្ឋពេញលេញជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## សំណួរពិភាក្សា

១-តើក្រសួងអប់រំបានធ្វើការកែទម្រង់ប៉ុន្មានដំណាក់កាល និងលើផ្នែកណាខ្លះចាប់២០១៣-២០២៤?

២-តើក្រសួងអប់រំបានធ្វើការកែទម្រង់អ្វីខ្លះលើវិស័យគ្រូបង្រៀនណោកម្ពុជាចាប់ពី២០១៣-២០២៤?

៣-ចូរប្អូនពន្យល់អំពីនាយកល្អ គ្រូឆ្នើម នាំឱ្យសាលាមានឧត្តមានុវត្ត។

## មេរៀនទី៤៖ និន្នាការទំនើបកម្មនៃការបង្រៀន និងរៀន

### ៤-១-វត្ថុបំណងមេរៀន

#### ក-វិជ្ជាសម្បទា

- បង្ហាញបានពីរចនាសម្ព័ន្ធ និងដំណើរការនៃចំណេះដឹង
- ពិពណ៌នាបានពីភាពចម្រុះនៃការរៀន និងបង្រៀន
- ពន្យល់បានពីវិធីសាស្ត្រក្នុងការស្ថាបនា និងការផ្ទេរចំណេះដឹង
- រៀបរាប់បានពីនិន្នាការនៃការប្រឡង និងវង្វាយតម្លៃថ្នាក់រៀនតាមគំរូComputerized adaptive testing (CAT)

#### ខ-បំណិនសម្បទា

- វិភាគបានពីរចនាសម្ព័ន្ធ និងដំណើរការនៃចំណេះដឹង
- សំយោគបានពីភាពចម្រុះនៃការរៀន និងបង្រៀន
- អនុវត្តបានពីវិធីសាស្ត្រក្នុងការស្ថាបនា និងការផ្ទេរចំណេះដឹង
- វាយតម្លៃបានពីនិន្នាការនៃការប្រឡង និងថ្នាក់រៀនតាមគំរូ CAT

#### គ-ចរិយាសម្បទា

- បណ្តុះស្មារតីស្រឡាញ់ការសិក្សាស្រាវជ្រាវ ដើម្បីបំពេញបន្ថែមនូវចំណេះនិងជំនាញដែលមានស្រាប់។

### ៤-២-សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡាបានពង្រឹងសមត្ថភាពគ្រូក្នុងការបង្រៀន និងរៀនឱ្យចេះអនុវត្តនូវវិធីសាស្ត្របង្រៀនតាមបែបថ្មី និងមានលក្ខណៈសម្បូរបែប ដើម្បីឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននាសតវត្សរ៍ទី២១។ គ្រូបង្រៀនត្រូវចេះផ្លាស់ប្តូរវិធីសាស្ត្របង្រៀនទៅតាមស្ថានភាពជាក់ស្តែង ដើម្បីបង្រៀនសិស្សឱ្យសិស្សចេះអាន សរសេរ លេខនព្វន្ត ភាសាបរទេស ប្រព័ន្ធបច្ចេកវិទ្យា ការត្រិះរិះពិចារណា វិភាគច្នៃប្រឌិត ដោះស្រាយបញ្ហា សម្រេចចិត្តដោយភាពឆ្លាតវៃ ចង់ចេះ ចង់ដឹង និងចេះផ្តួចផ្តើមធ្វើអ្វីថ្មីៗ ហើយត្រូវមានវិន័យ សីលធម៌ ទន់ភ្លន់ សុចរិត មានស្មារតីទទួលខុសត្រូវខ្ពស់ ចេះប្រាស្រ័យទាក់ទង សហការ និងចេះធ្វើការជាក្រុមរួមជាមួយមនុស្សមានគំនិត ជំនឿ វប្បធម៌ ឬជាតិសាសន៍ផ្សេងៗគ្នា។

ការបង្កើនសមត្ថភាពគ្រូបង្រៀន ការពង្រឹងការគ្រប់គ្រងថ្នាក់រៀន ផ្តល់វិធីសាស្ត្របង្រៀនថ្មីៗ និងអន្តរកម្មរវាងសាលារៀនទៅនឹងអាណាព្យាបាល(សហគមន៍)ជាកត្តាសំខាន់ក្នុងការពង្រឹងប្រសិទ្ធភាពការរៀន និងបង្រៀន ដើម្បីជំរុញឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលគាប់ប្រសើរ រួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់គុណភាពអប់រំក្នុងបរិបទគន្លងថ្មី។

ទំនើបកម្មនៃវិធីសាស្ត្របង្រៀន និងរៀន គឺជានិន្នាការថ្មីមួយ ដើម្បីឆ្លើយតបនឹងបរិបទបច្ចេកវិទ្យា យុគសម័យបដិវត្តឧស្សាហកម្ម៤.០កំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងសម័យសកលភាវូបនីយកម្ម ពោល គឺជារបត់នៃប្រព័ន្ធបណ្តុះបណ្តាលសិស្ស ដែលជំនួសសកម្មភាពបង្រៀនរបស់គ្រូទៅជាសកម្មភាពរៀន របស់សិស្សតាមរយៈសម្ភារបរិក្ខារទំនើបសម្រាប់ជំនួយដល់សិស្សក្នុងការពិភាក្សាក្រុម ក្លឹបសិក្សា(សិក្សា ក្រៅម៉ោង) ឬសកម្មភាពសិស្សបង្រៀនសិស្ស ពោលប្តូរពីគោលវិធីសាស្ត្រគ្រូមជ្ឈមណ្ឌលទៅជាវិធីសាស្ត្រ បង្រៀនថ្មីតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្របែបស្ថាបនានិយម[52]។ មួយវិញទៀត ការកែ ទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន គឺដើម្បីលើកកម្ពស់ប្រព័ន្ធអប់រំកម្ពុជា ដែលត្រូវប្រណាំងប្រជែង ជាមួយនឹងបណ្តាប្រទេសផ្សេងៗក្នុងតំបន់ ដើម្បីទទួលបានលទ្ធផលសិក្សារបស់សិស្សល្អប្រសើរ[53]។

## បុព្វហេតុនៃការធ្វើកំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន




រូបភាពទី៨៖ ហង់ជួន ណារ៉ុន,កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន,ឆ្នាំ២០២០

### ៤.៣-រចនាសម្ព័ន្ធ និងដំណើរការនៃចំណេះដឹង

### ៤-៣-១-រចនាសម្ព័ន្ធចំណេះដឹង

លោកអារីស្តូត បានបង្ហាញចំណាត់ថ្នាក់នៃចំណេះដឹង(classification of knowledge)ជា៣ទម្រង់ នៃចំណេះដឹងរបស់មនុស្សគឺ(១)ចំណេះដឹងវិទ្យាសាស្ត្រ (២)ចំណេះដឹងជំនាញ និងសិប្បកម្ម) និង(៣)

---

[52] https://www.postkhmer.com/

[53] ហង់ជួន ណារ៉ុន រដ្ឋមន្ត្រី ក្នុងកម្មវិធីបើកនៃការប្រារព្ធពិធីទិវាគ្រូបង្រៀន ៥តុលា ឆ្នាំ២០១៩។

ចំណេះដឹងផ្នែកសីលធម៌[54]។ ចំពោះគ្រូបង្រៀនវិញ ចំណេះដឹងទាំង៣នេះអាចចាត់ទុកជាចំណេះដឹងគរុកោសល្យ ទ្រឹស្តី និងបញ្ញត្តិ ដែលជាចំណុចសំខាន់នៃការអប់រំក្នុងសាលារៀន។

ចិត្តវិទូDavid Krathwohl (២០០២) បានធ្វើបច្ចុប្បន្នភាពនៃទ្រឹស្តីប្លូម(Benjamin Bloom, ១៩៥៦) និងបែងចែកចំណេះដឹងជា៤ប្រភេទ(១)-ចំណេះជាព័ត៌មាន(factual knowledge) (២)-ចំណេះដឹងបញ្ញត្តិ(Conceptual knowledge) (៣)ចំណេះដឹងក្នុងពេលប្រតិបត្តិ(procedural knowledge) និង(៤) ចំណេះដឹងជាវិជ្ជា(Metacognitive Knowledge) គឺជាការសិក្សាស្តីពីការគិត ឆ្លុះបញ្ចាំងពីចំណេះដឹងមានស្រាប់ និងអាចជាបំណិនរួមមាន(ក)សមត្ថភាពវិភាគព័ត៌មាន(Information processing) (ខ)ពុទ្ធិបញ្ញាជួបប្រទះញឹកញាប់(គ)យុទ្ធសាស្ត្រសម្រាប់ដោះស្រាយបញ្ហា។ តាមរយៈការបំបែកនៃប្រភេទចំណេះដឹងនេះពិតជាមានសារៈសំខាន់សម្រាប់គ្រូបង្រៀន អ្នកអប់រំក្នុងពេលបង្រៀនសិស្ស និស្សិតឱ្យកាន់តែយល់ដឹងស៊ីជម្រៅនៃចំណេះដឹងដ៏សម្បូរបែប ហើយក៏ជាគរុកោលស្យមួយរបស់គ្រូក្នុងការជំរុញសិស្សឱ្យចេះរិះរក ប្រៀបធៀបចំណេះដឹងទូទៅ ចំណេះដឹងក្នុងពេលប្រតិបត្តិ ចំណេះដឹងវិទ្យាសាស្ត្រ និងចំណេះដឹងមានស្រាប់ ដែលទាក់ជាមួយមេរៀនប្រចាំថ្ងៃ។

ក-ចំណេះដឹងអំពីព័ត៌មាន(Factual Knowledge)គឺជាតុផ្សំដំបូង ឬមូលដ្ឋាន ដែលមាននៅផ្ទៃខាងលើនៃជាតុនានា អ្នកសិក្សាត្រូវទទួលបានជាព័ត៌មាននេះដំបូងគេ។ ជាទូទៅអ្នកសិក្សាចាំទុក ឬសម្គាល់ នូវរូបវត្ថុ ឬនាមវត្ថុមួយចំនួននៃព្រឹត្តិការណ៍ក្នុងវិញ្ញាណតាមរយៈភ្នែក ត្រចៀក អណ្តាត ច្រមុះ និងរាងកាយ (បញ្ចឥន្រ្ទីយ៍)។

ខ-ចំណេះដឹងជាបញ្ញត្តិ(Conceptual Knowledge) គឺជាប្រមូលបានសំណុំនៃជាតុផ្សំជាច្រើនដែលបង្កប់ក្នុងកញ្ចប់ព័ត៌មាន។ ចំណេះដឹងបញ្ញត្តិ គឺកើតឡើងដោយការគិត ឆ្ងល់ បង្កើតសំណួរ សួរ និងការពន្យល់ពីច្រើនប្រភព។ លោកលីន អេរីកសុន(Lynn Erickson)ពន្យល់ថា បញ្ញត្តិ(Concepts គឺជាគំនិតមានលក្ខណៈអរូបី សកល គ្មានការកំណត់ពេលវេលា និងជំរុញសិស្ស និស្សិតឆ្ពោះទៅរកការគិតកម្រិតខ្ពស់។ ចំណេះដឹងបញ្ញត្តិ គឺជាគំនិតទូលំទូលាយ ទស្សនៈ ដែលមានដែនកំណត់ជាក់លាក់តាមមុខវិជ្ជានីមួយៗ។

គ-ចំណេះដឹងក្នុងពេលប្រតិបត្តិ(Procedural knowledge) គឺជាចំណេះដឹងកើតក្នុងអនុវត្ត ដែលមានភស្តុតាងវិទ្យាសាស្ត្រអំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃជាតុផ្សំនៃចំណេះដឹង។ ជាទូទៅក្នុងដំណើរការអនុវត្ត(Practical knowledge) គឺមានលក្ខណៈខុសគ្នាពីទ្រឹស្តី ដែលបានរៀននៅក្នុងសាលាព្រោះវាបានផ្លាស់ប្តូរទៅតាមស្ថានភាព ពេលវេលា និងជីវភាពជាក់ស្តែង។ ចំណេះដឹងទាំងនេះបានក្លាយជាបំណិន ឬជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ។

---

[54] https://eera-ecer.de/ecer-programmes/conference/

ឃ-ចំណេះដឹងជាវិជ្ជា(Metacognitive knowledge)គឺជាការមានចំណេះដឹង ឬវិជ្ជាច្រើនស៊ីជម្រៅតាមរយៈការអានច្រើន។ ចំណេះដឹង គឺជាវិជ្ជា សំដៅលើការគិតលំដាប់ខ្ពស់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងសកម្មលើដំណើរការយល់ដឹងចូលរួមក្នុងការរៀនសូត្រ ដែលមានសកម្មភាពដូចជា ការធ្វើផែនការពីរបៀបសិក្សារៀនសូត្រ ការឆ្លុះបញ្ចាំង ការវាយតម្លៃ ការគិតស្ដីការអភិវឌ្ឍ ការត្រួតពិនិត្យការយល់ដឹង និងការវាយតម្លៃវឌ្ឍនភាពឆ្ពោះទៅរកការបញ្ចប់ការសិក្សា។ ចំណេះដឹងជាផែនទីបង្ហាញផ្លូវសម្រាប់អ្នកសិក្សាចេះប្រៀបធៀបចំណេះដឹងផ្ទាល់ខ្លួន ចេះសួរខ្លួនឯង និងចេះរៀបចំគំនិតសម្រាប់ការសរសេរ ឬការវិភាគ។

ជាទូទៅ ការសិក្សាផ្ដោតលើចំណេះដឹងទាំង៣ប្រភេទគឺ (១)ចំណេះដឹងប្រកាស(declarative knowlege)វិជ្ជាសម្បទា (២) ចំណេះដឹងក្នុងពេលប្រតិបត្តិ(procedural knowledge)បំណិនសម្បទា និង(៣)ចំណេះដឹងស្វ័យគ្រប់គ្រង(self-regulated knowledge)ជាចំណេះដឹងក្នុងការអនុវត្ត។ បំណិនស្ដីពីការសិក្សា(Metacognition skills)ចែកចេញជា៣ផ្នែកគឺ(១) ការធ្វើផែនការការកំណត់ចំនួនពេលយុទ្ធសាស្ត្រ របៀប ធនធាន និងលំដាប់លំដោយក្នុងការដោះស្រាយបញ្ហា (២)ការតាមដាន និងត្រួតពិនិត្យ ការយល់ដឹងដំណើរការបំពេញការងារភាពត្រឹមត្រូវនៃដំណើរការសិក្សា និង(៣) វង្វាយតម្លៃដំណើរការ និងលទ្ធផល ការគិត និងការសិក្សា។ ដើម្បីអនុវត្តក្នុងការបង្រៀន គ្រូបង្រៀនត្រូវចេះធ្វើការឆ្លុះបញ្ចាំង (Reflection) ពីការបង្រៀនរបស់ខ្លួន ដើម្បីកែលម្អវិធីសាស្ត្របង្រៀនជាប្រចាំ។

លោកJean Piaget បានបង្កើតទ្រឹស្ដីការអភិវឌ្ឍសតិបញ្ញាសិក្សា(Cognitive development) នេះឡើងដោយបញ្ជាក់ថា ការគិតរបស់មនុស្សតែងប្រែប្រួលបន្តិចម្ដងៗចាប់ពីកំណើតដល់ការវ័យចាស់ ដោយសារមនុស្សចង់យល់ដឹងពីពិភពជុំវិញ។ លោក Jean Piaget បានចែកការអភិវឌ្ឍសតិបញ្ញាសិក្សា (cognitive development)ជា៤ដំណាក់កាល[55]៖

ដំណាក់កាលទី១-ចិត្តចលនា (Sensorimotor)៖ ពីអាយុ0ដល់២ឆ្នាំ។កុមាររៀនតាមរយៈរំញោច (Reflexes)ញាណ និងចលនាជាសកម្មភាពចំពោះបរិស្ថាន។ កុមារចាប់ផ្ដើមធ្វើតាមគេ ចងចាំព្រឹត្តិការណ៍ និងគិតតាមនិមិត្តរូប(Symbolic thinking)។ កុមារយល់ថា ទោះបីជាមើល មិនឃើញវត្ថុអ្វីមួយក៏ដោយក៏គេដឹងថាវត្ថុនោះនៅតែមានអត្ថិភាពដដែល និងចាប់ផ្ដើមផ្លាស់ប្ដូរពីអំពើដែលត្រិះរិះ មកសកម្មភាពដោយចេតនា។

ដំណាក់កាលទី២-មុនប្រតិបត្តិការ(Preoperational)៖ពីពេលកុមារចេះនិយាយដល់អាយុ៧ឆ្នាំ។ កុមារចាប់ផ្ដើមចេះនិយាយ និងចាប់ផ្ដើមប្រើនិមិត្តរូប ដើម្បីតំណាងវត្ថុ។ កុមារនៅមានការលំបាកក្នុងការគិតពីអតីតកាល និងអនាគតកាល ហើយគិតតែពីបច្ចុប្បន្នកាល។ កុមារអាចគិតពីប្រតិបត្តិការបាន

[55] ចាន់វឌ្ឍសុផា ចិត្តវិទ្យាអប់រំ ឆ្នាំ២០០៥ ទំ២៨។

ប្រកបដោយតក្កកម្មតែក្នុងឯកទិស។ កុមារមានការលំបាកក្នុងការយល់ទស្សនៈ និងគំនិតរបស់មនុស្សផ្សេងទៀត។

ដំណាក់កាលទី៣-ប្រតិបត្តិការរូបី(Concrete Operational ពីថ្នាក់ទី១ដល់មុនពេលពេញវ័យគឺអាយុ១១ឆ្នាំ។ កុមារអាចគិតពីបញ្ហារូបីប្រកបដោយតក្កកម្ម។ កុមារយល់ពីការអភិរក្ស និងចេះធ្វើចំណាត់ថ្នាក់វត្ថុទៅតាមលក្ខណៈវិនិច្ឆ័យ និងប្រភេទ។ កុមារចេះគិតបញ្ច្រាស និងមានសកម្មភាពបញ្ច្រាស។ កុមារចេះយល់ដឹងពីអតីតកាល បច្ចុប្បន្នកាល និងអនាគតកាល។

ដំណាក់កាលទី៣-ប្រតិបត្តិការអរូបី (Formal Operational)៖ ពីការពេញវ័យ (adolescence) ដល់វ័យវិឡ្ឍនការ(adulhood)។ មនុស្សចេះគិតតាមសម្មតិកម្ម និងចេះធ្វើអនុមានញែក។ ការគិតមានលក្ខណៈវិទ្យាសាស្ត្រ ចេះដោះស្រាយចំណោទអរូបីប្រកបដោយតក្កកម្ម ចេះមានទស្សនវិស័យច្រើន និងចាប់ផ្តើមមានការព្រួយបារម្ភពីបញ្ហាសង្គម មានអត្តសញ្ញាណផ្ទាល់ខ្លួន និងយុត្តិធម៌។

ដូចនេះ គ្រូបង្រៀនត្រូវយល់ដឹងពីដំណាក់កាលនៃការអភិវឌ្ឍសតិបញ្ញារបស់សិស្ស ដែលជាដំណាក់កាលនៃការទទួលបាននូវចំណេះដឹង និងការស្គាល់ពីរបៀបរៀនរបស់សិស្ស ដែលអាចឱ្យសិស្សចេះគិត យល់ដឹង ចង់ចាំ វិនិច្ឆ័យ និងដោះស្រាយបញ្ហា ហើយគ្រូបង្រៀនត្រូវចេះកែលម្អ និងប្រើប្រាស់វិធីសាស្ត្របង្រៀនទៅតាមដំណាក់កាលនីមួយៗនៃការអភិវឌ្ឍសតិបញ្ញា។

### ៤-៣-២-កម្រិតចំណេះដឹងតាមទ្រឹស្តីប្លូម

ទ្រឹស្តីរបស់លោក Blooms ត្រូវបានបែងចែកជា៦កម្រិត។ កម្រិតទាំងនេះ នឹងត្រូវយកទៅអនុវត្តនៅក្នុងកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ(Curriculums) កម្មវិធីសិក្សាលម្អិត (syllabuses) វិធីសាស្ត្របង្រៀន(Methodologies) ការវាយតម្លៃការរៀន និងបង្រៀន (Assessment) និងកិច្ចតែងការបង្រៀន ដែលផ្តោតសំខាន់ទៅលើកម្រិតនៃការសិក្សា និងការគិតរបស់សិស្ស។

កម្រិតនៃការសិក្សាបែបBloom's Taxonomy នេះត្រូវបានកែសម្រួលឡើងវិញដោយកូនសិស្សរបស់លោក Benjamin Bloom ឈ្មោះលោក Lorin Andersonទសវត្សរ៍ទី៩0ដោយប្តូរពីនាម(Noun)មកជាកិរិយាសព្ទ(Verb)វិញ។ កម្រិតទាំង៦របស់ Bloom's Taxonomyរួមមាន(១)កម្រិតចងចាំ(Remembering)គឺមានន័យថា សិស្សអាចចងចាំ ឬនិយាយឡើងវិញនូវព័ត៌មាន ឬចំណេះដឹងដែលបានរៀនរួចហើយ។ (កិ) ប្រើជាមួយកម្រិតនេះដូចជា ចងចាំ និយាយឡើងវិញ ស្គាល់ រាយនាម ពិព័រណនា សម្គាល់កិនភាគ ដាក់ឈ្មោះ កំណត់ទីតាំង ស្វែងរក តភ្ជាប់ បង្ហាញ បែងចែកជាដើម។(២)កម្រិតយល់ដឹង គឺមានន័យថា សិស្សអាចពន្យល់ បកស្រាយគំនិត បញ្ញត្តិបានយ៉ាងក្បោះក្បាយ។(កិ) ដែលប្រើជាមួយកម្រិតយល់ដឹងមានដូចជា បកស្រាយ កំណត់អត្តសញ្ញាណ លើកឧទាហរណ៍ សង្ខេប ទាយ ធ្វើចំណាត់ថ្នាក់ ប្រៀបធៀប ពន្យល់ ពិភាក្សា បរិយាយឡើងវិញ ប៉ាន់ប្រមាណ។(៣)កម្រិតអនុវត្ត គឺមានន័យថា សិស្សអាចប្រើប្រាស់ព័ត៌មាន ចំណេះដឹងទៅប្រើប្រាស់ក្នុងវិធីផ្សេងៗទៀត។ (កិ) ដែលប្រើជាមួយ

កម្រិតអនុវត្តមានដូចជាអនុវត្ត ប្រើប្រាស់គណនា ធ្វើផ្លាស់ប្តូរ សម្តាស បង្ហាញ ប្រមូលផ្តុំ ដោះស្រាយ កសាង ប្រតិបត្តិ គូរ បង្រួម និងអនុម័ត។ល។(៤)កម្រិតវិភាគ គឺមានន័យថា សិស្សអាចវែកញែក និងវិភាគ រកខុសត្រូវ ល្អ និងអាក្រក់ស និងខ្មៅនូវអ្វីដែលពួកគេបានរៀន។ (ក) ប្រើជាមួយកម្រិតអនុវត្តមានដូចជា ប្រៀបធៀប រៀបចំ រកឱ្យឃើញ បញ្ចូល ត្រួតពិនិត្យ ចោទសួរ សាកសួរ ស៊ើបអង្កេត ស្រាវជ្រាវ រិះគន់ វែកញែក ផ្តាច់ពីគ្នា ផ្ទុយពីគ្នា។ល។(៥)កម្រិតវាយតម្លៃ គឺជាកម្រិតដែលសិស្សអាចវិនិច្ឆ័យ វាយតម្លៃ ផ្តល់នូវភាពត្រឹមត្រូវ ដើម្បីសម្រេចចិត្តជ្រើសរើសយកអ្វីមួយជាប្រយោជន៍។ (ក)ដែលប្រើជាមួយកម្រិតវាយតម្លៃរួមមានគឺត្រួតពិនិត្យ បង្កើតសម្មតិកម្ម រិះគន់កាត់ក្តី ធ្វើតេស្ត ពិនិត្យតាមដាន ព្យាករណ៍ ដាក់ពិន្ទុ ការពារ បដិសេធ សម្រេចចិត្ត។ល។(៦)កម្រិតបង្កើតថ្មី គឺមានន័យថា សិស្សអាចបង្កើតនូវទស្សនៈ គំនិត ផលិតផលថ្មី ដែលពួកគេអាចរកឃើញដោយខ្លួនឯង។ (ក) ដែលអាចប្រើជាមួយកម្រិតបង្កើតថ្មីរួមមាន តាក់តែង បង្កើត ធ្វើផែនការ ផលិត សរសេរ រៀបចំ ផ្តុំ ចងក្រង អភិវឌ្ឍ ព្យាករណ៍ ស្នើសុំ ។ល។

### ៤.៤.ការស្ថាបនាចំណេះដឹង និងការផ្ទេរចំណេះដឹង

#### ៤-៤-១-ការស្ថាបនាចំណេះដឹង

ទ្រឹស្តីសិក្សាតាមបែបស្ថាបនានិយម(Constructivism) គឺជាទ្រឹស្តី ដែលអ្នកសិក្សាត្រូវស្ថាបនានូវចំណេះដឹងដោយខ្លួនឯង ជាជាងចាំទទួលយកព័ត៌មានពីអ្នកដទៃដោយអសកម្ម។ ទ្រឹស្តីនេះសង្កត់ធ្ងន់លើតួនាទីដ៏សកម្មរបស់សិស្សក្នុងការកសាងចំណេះដឹង ការយល់ដឹងលើខ្លឹមសារមេរៀន។ អ្នកសិក្សាត្រូវចេះឆ្លុះបញ្ចាំងពីបទពិសោធន៍ក្នុងសង្គមរស់នៅ បង្កើតចម្ងល់លើបាតុភូត និងបញ្ចូលចំណេះដឹងថ្មីៗទៅក្នុងគ្រោងការណ៍សិក្សារៀនសូត្រ ជំរុញឱ្យមានការសិក្សារៀនសូត្រ និងការយល់ដឹងកាន់តែស៊ីជម្រៅ។ ទ្រឹស្តីសិក្សាបែបស្ថាបនានិយមនេះក៏ជាវិធីសាស្ត្របង្រៀន និងរៀនដែលធ្វើឱ្យសិស្សបង្កើតចំណេះដឹងផ្ទាល់ខ្លួនយ៉ាងសកម្មតាមរយៈបទពិសោធន៍ និងអន្តរកម្មនៃចំណេះដឹងមានស្រាប់ និងព្រឹត្តិការណ៍ថ្មីៗ។

ទ្រឹស្តីសិក្សាបែបស្ថាបនានិយម គឺដាក់អ្នកសិក្សាជាមជ្ឈមណ្ឌលនៃដំណើរការអប់រំនៅលើការយល់ដឹង បង្កើតយ៉ាងសកម្មនូវចំណេះដឹងជាជាងចាំទទួលដោយអសកម្ម។ ដូច្នេះ ចំណេះដឹងរបស់បុគ្គល គឺជាមុខងារទទួលបានដោយខ្លួនឯង[56]។

- ទ្រឹស្តីស្ថាបនានិយម គឺជាទស្សនវិទ្យាមួយ ដែលបង្កើតឡើងឈរលើមូលដ្ឋាននៃការស្រាវជ្រាវរបស់លោក Piaget, Vygotsky, Dewey និងចិត្តវិទូដទៃទៀត។ ទ្រឹស្តីស្ថាបនានិយមពុំមែនមានតែមួយទេគឺមានជាច្រើន និងពេលខ្លះគេប្រើពាក្យរួមគ្នាទ្រឹស្តីស្ថាបនានិយមក៏ពិតមែនតែសំដៅលើទស្សនទានផ្សេងគ្នា។ ទ្រឹស្តីទាំងនេះមានចំណុចរួមចំនួន២ គឺ(១)អ្នកសិក្សាមានលក្ខណៈសកម្មក្នុងការស្ថាបនា ការយល់ដឹងដោយបង្កើតចំណេះដឹងថ្មីលើសពីព័ត៌មានដែលគេទទួល និង(២)អន្តរសកម្មសង្គមមានតួនាទីសំខាន់ក្នុងដំណើរការស្ថាបនាចំណេះដឹង។ ចំណែកឯទ្រឹស្តីរបស់Piaget ផ្តោតលើការស្ថាបនាចំណេះដឹងសកល

[56]UNESCO, Curriculum/IBE_GlossaryCurriculumTerminology2013, P.13.

ដែលជាលទ្ធផលនៃការឆ្លុះបញ្ចាំង និងសម្របសម្រួលដំណើរការពុទ្ធិ និងការគិតផ្ទៃក្នុងដែលខុសពីការចម្លងតថភាពពីខាងក្រៅរបស់ទ្រឹស្តីវិភាគព័ត៌មាន។ លោកPiagetយល់ថា បរិស្ថានសង្គម គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍតែពុំបានចាត់ទុកអន្តរសកម្មសង្គមថា ជាកត្តាស្ថាបនាចំណេះដឹងឡើយ។ ទ្រឹស្តីទាំងនេះមានន័យថា ការសិក្សា គឺជាការស្ថាបនាចំណេះដឹងដោយអ្នកសិក្សាម្នាក់ៗខ្លួនឯង។ ឧទាហរណ៍អ្នកសិក្សាធ្វើពិសោធន៍លើរូបមន្តគីមីក្នុងបន្ទប់ពិសោធ ហើយលទ្ធផលដែលគេទទួលបានជួយឱ្យគេស្ថាបនាចំណេះដឹងអំពីប្រតិកម្មគីមី។

- លោកប្លូមបានណែនាំពីរបៀបរៀនបែបសកម្ម និងអកម្មតាមរយៈសកម្មភាពមួយចំនួនដូចជា[57]៖

- ការសិក្សាបែបសកម្ម គឺជាការដឹកនាំខ្លួនឯង កសាងចំណេះដឹងដោយផ្អែកលើចំណេះដឹងមានស្រាប់ និងបទពិសោធ ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងបញ្ញត្តិផ្សេងៗ ដើម្បីបង្កើតបញ្ញត្តិថ្មី និងការផ្លាស់ប្តូរគំនិតរួមគ្នាតាមរយៈតាមរយៈការសហការ ជំរុញឱ្យមានការបង្កើតថ្មី។ ការរៀនបែបសកម្មដូចជា ការធ្វើបទបង្ហាញ ការសំដែង ការអនុវត្តជាក់ស្តែង(និយាយ និងអនុវត្តបាន៩០%) ការចូលរួមពិភាក្សា និងការធ្វើបទបង្ហាញផ្ទាល់(និយាយចាំបាន៧០%)។

- ការរៀនបែបអកម្មមានដូចជា ការទស្សនាភាពយន្ត ការពណ៌នា និងការទស្សនាដល់ទីតាំង(មើលឃើញ ឮ ចាំបាន៥០%) ការមើល(មើលឃើញចាំបាន៣០%) ការស្តាប់(ស្តាប់ចាំបាន២០%) ការអាន(អានចាំបាន១០%)។

ប្រទេសកម្ពុជាក្នុងសតវត្សរ៍ទី២១ មានតម្រូវការជាច្រើនសម្រាប់ប្រព័ន្ធអប់រំ ដើម្បីផលិតកម្លាំងការងារ ដែលមានការគិតស៊ីជម្រៅអាចដោះស្រាយបញ្ហា និងចេះសហការគ្នាធ្វើការ។ វិធីសាស្រ្តបង្រៀនផ្តោតតែលើការសិក្សាបែបទន្ទេញ ឬសូត្រតាមតែមួយមុខមិនអាចឆ្លើយតបទៅនឹងតម្រូវកាបានទេ។ ដូចនេះការសិក្សាបែបស្ថាបនានិយមបានបង្កើតក្នុងគោលបំណងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈម។

ការសិក្សាបែបស្ថាបនានិយម(Constructivism)គឺជាទស្សនវិស័យទូលំទូលាយផ្តោតលើកត្តានៃការសិក្សា២គឺ(១) កត្តាសង្គម និង(២) កត្តាវប្បធម៌។ ទ្រឹស្តីស្ថាបនានិយមសង្គមវប្បធម៌មានដើមកំណើតចេញពីទ្រឹស្តីអភិវឌ្ឍពុទ្ធិ តែបានវិវត្តយ៉ាងខ្លាំងឆ្ពោះទៅរកយុទ្ធសាស្រ្តបង្រៀនផ្តោតលើការសម្របសម្រួលរបស់គ្រូ ការសិក្សាតាមបែបរិះរក ការសិក្សាតាមបែដោះស្រាយបបញ្ហា ការសិក្សាតាមបែបសហការ ការហាត់ការពុទ្ធិបញ្ញា បទពិសោធន៍ ការឆ្លុះបញ្ចាំង ការវិភាគ បច្ចេកវិទ្យា និងការបង្រៀនគ្នាទៅវិញទៅមក។

ដូចនេះ ទ្រឹស្តីស្ថាបនានិយម គឺជាការស្ថាបនាពុទ្ធិ(Cognitive constructivism)ដែលអ្នកសិក្សាប្រើព័ត៌មាន ធនធាន និងការគាំទ្រពីអ្នកផ្សេង ដើម្បីស្ថាបនាចំណេះដឹង។ អ្នកសិក្សាអាចស្ថាបនារចនាសម្ព័ន្ធពុទ្ធិ បញ្ញារបស់ខ្លួនដោយពិចារណាលើបទពិសោធ និងឈ្វេងយល់ចំណេះដឹងថ្មី។ ជាទូទៅសិស្សរៀន

---

[57] ក្រសួងអប់រំ យុវជន និងកីឡា,កម្មវិធីសាលាជំនាន់ថ្មី, ការសិក្សាតាមបែបស្ថាបនានិយម, ឆ្នាំ២០២០, ទំ១៨។

សូត្រតាមរយៈការសង្កេតបាតុភូតធនធានធម្មជាតិ និងបរិស្ថានជុំវិញខ្លួន ដែលទទួលតាមឥន្ទ្រីយារម្មណ៍ពីខាងក្រៅ។




រូបទី៩៖ សម្ភារៈបច្ចេកវិទ្យាជំនួយដល់ការរៀនតាមបែបស្ថាបនាចំណេះដឹង

ការសិក្សានៅសតវត្សរ៍ទី២១ជារបៀបរៀន និងបង្រៀនតាមអនឡាញ (Online Learning E-Learning ឬ E-School) ការរៀនកូនកាត់ (Hybrid Learning) ដោយការរៀនប្រើប្រាស់កុំព្យូទ័រ និងប្រើបណ្តាញអ៊ិនធឺណេត ឬមិនប្រើអ៊ិនធឺណេត (offline) ដូចជាការប្រើCD។ល។

**ក-សកម្មភាពរៀនតាមបែបស្ថាបនាចំណេះដឹង**

បើតាមទ្រឹស្តីសិក្សាតាមបែបអភិវឌ្ឍចំណេះដឹង (Cognitive Learning) គឺមានតាំងពីជំនាន់ទស្សនវិទូក្រិកមកម្លេះ ដោយបានចាត់ទុកថា មនុស្សជាអ្នកវិភាគព័ត៌មានយ៉ាងសកម្ម។ ទ្រឹស្តីនេះគឺដំបូងសិក្សាផ្តោតលើការទទួលចំណេះដឹង និងពេលបន្ទាប់គឺផ្តោតលើការស្ថាបនាចំណេះដឹង។ ចំពោះវិទ្យាសាស្ត្រស្តីអំពីពុទ្ធិគឺសិក្សាអំពីការគិត ភាសា និងខួរក្បាល។ ចំពោះទ្រឹស្តីលំនឹក(Memory)គឺជាទ្រឹស្តីដែលសំខាន់ជាងគេ។ ទ្រឹស្តីនេះដំបូងលំនឹកដូចកុំព្យូទ័រដោយខួរក្បាលទទួលយកព័ត៌មាន និងប្រតិបត្តិវិភាគព័ត៌មាន ដើម្បីផ្លាស់ប្តូរទម្រង់ ខ្លឹមសារ រក្សាទុក និងទាញយកមកប្រើនៅពេលដែលត្រូវការ។ លំនឹកកើតចេញពីបរិស្ថានខាងក្រៅចូលទៅក្នុងសរីរាង្គឥន្ទ្រីយ៍(ចក្ខុវិញ្ញាណ សោតវិញ្ញាណ និងឃានវិញ្ញាណ)។ ព័ត៌មានខ្លះត្រូវបានផ្លាស់ប្តូរសណ្ឋានទៅតាមលំនឹករយៈពេលខ្លី និងរយៈពេលវែង[58]។

សកម្មភាពរៀនដែលសិស្សអាចស្ថាបនាចំណេះដឹងរួមមាន៖

- ការសិក្សាតាមបែបរិះរក គឺជាការសិក្សាបែបស្ថាបនានិយមលើកកម្ពស់គំនិតដែល យើងអាចចងចាំ

[58] ហង់ជួន ណារ៉ុន,បំណិនសតវត្សទី២១ និងកំណែទម្រង់វិធីសាស្ត្របង្រៀន,ឆ្នាំ២០២១, ទំ៥៥។

អ្វីៗកាន់តែល្អ ប្រសិនបើយើងរិះរកវាដោយខ្លួនឯងតាមរយៈការពិភាក្សា ការពិសោធ និងយុទ្ធសាស្ត្រសិក្សាបែបសកម្មផ្សេងៗទៀត។

- ប្លូមតាក់សូណូមី( Bloom's Taxonomy )គឺជាការសិក្សាបែបស្ថាបនានិយមផ្តោតខ្លាំងលើបំណិនការគិតកម្រិតខ្ពស់ រួមមានការវិភាគ វាយតម្លៃ និងបង្កើតថ្មី។
- ការគិតពិចារណាស៊ីជម្រៅដូចជា ការវិភាគ ការវាយតម្លៃ និងបង្កើតថ្មីគឺជាបំណិនសំខាន់ៗក្នុងការគិតបែបស៊ីជម្រៅ។
- ការសហការ គឺជាការធ្វើការងារជាមួយអ្នកផ្សេងទៀតក្នុងក្រុម ដើម្បីផ្លាស់ប្តូរគំនិត យោបល់គ្នាអាចធ្វើទៅបានលុះត្រាតែតាមរយៈការពិភាក្សា ហើយការពិភាក្សានេះនាំឱ្យមានការបង្កើតបញ្ញត្តិ និងជំរុញឱ្យសិស្សអាចសំយោគគំនិតប្លែកៗ ។
- ការសិក្សាតាមបែបស្រាវជ្រាវ គឺការបង្កើតបញ្ញត្តិតាមរយៈការស្រាវជ្រាវ ការពិភាក្សាក្រុម និងការប្រើប្រាស់បច្ចេកវិទ្យាជាមធ្យោបាយ។
- បច្ចេកវិទ្យាព័ត៌មានបានជួយបង្កើនប្រសិទ្ធភាពនៃការសិក្សាបែបស្ថាបនានិយម ដើម្បីលើកកម្ពស់ការសិក្សាបែបសហការ( ឧទាហរណ៍តាមរយៈបណ្តាញNetwork ) សិស្សបង្កើត និងសំយោគព័ត៌មានថ្មីៗ ( ឧទាហរណ៍តាមរយៈការធ្វើបទបង្ហាញPowerPoint )និងដោះស្រាយបញ្ហាផ្សេងៗ( ឧទាហរណ៍តាមរយៈកម្មវិធីគ្រប់គ្រងនិងរៀបចំទិន្នន័យជាដើម )។
- ឧបករណ៍ទូរគមនាគមន៍ដូចជាអ៊ីម៉ែល និងអ៊ិនធើណែតផ្តល់នូវមធ្យោបាយសម្រាប់ការសន្ទនាពិភាក្សា និងជជែកដេញដោលជាដើម ដែលជាអន្តរកម្មនាំទៅរកការបង្កើតអត្ថន័យសង្គម។
- បទបង្ហាញជា PowerPoints បទបង្ហាញដែលបង្កើតឡើងដោយសិស្សនៅក្នុងក្រុមរបស់ពួកគេក៏បានផ្តល់នូវបណ្តាញសង្គមដ៏មានប្រយោជន៍សម្រាប់សិស្សធ្វើការរួមគ្នាជាក្រុមក្នុងការផលិតជាផលិតផលសិក្សាប្រកបដោយការច្នៃប្រឌិត ដើម្បីចែករំលែកជាមួយសិស្សក្នុងថ្នាក់។ សាលាគួរតែមានម៉ាស៊ីនLCD សម្រាប់បញ្ចាំង ដែលទាំងគ្រូ និងសិស្សអាចប្រើប្រាស់បានសម្រាប់គោលបំណងនេះ។
- សម្ភារបរិក្ខារបំពាក់អ៊ិនធើណែត ក្នុងបណ្ណាល័យការបង្កើតឱ្យមានសម្ភារបរិក្ខារ ដែលងាយស្រួលចូលប្រើអ៊ីនធើណែតនៅក្នុងបណ្ណាល័យ គឺជាមធ្យោបាយមួយទៀតសម្រាប់សិស្សធ្វើការជាមួយគ្នាលើកិច្ចការផ្សេងៗ។

ចំពោះវិធីសាស្ត្របង្រៀន និងរៀនដែលជួយសិស្សក្នុងការស្ថាបនាចំណេះដឹងរួមមាន៖

- វិធីសាស្ត្របង្រៀនបែបរិះរក
- វិធីសាស្ត្របង្រៀនបែបដោះស្រាយបញ្ហា
- វិធីសាស្ត្របង្រៀនបែបគម្រោង
- វិធីសាស្ត្របែបពិភាក្សាក្រុម

- ការបង្រៀន និងរៀនតាមបែបវិទ្យាសាស្ត្រ
- ការបង្រៀន និងរៀនតាមបែបគោលវិធីស្វែម
- វិធីសាស្ត្របង្រៀនតាមបែបថ្នាក់រៀនត្រឡប់(Flipped Classroom)
- វិធីសាស្ត្របង្រៀនបែបសហការជាដើម។

**ខ-សារៈសំខាន់នៃការស្ថាបនាចំណេះដឹង**

ការស្ថាបនាចំណេះដឹង គឺជាស្ថាបនានូវចំណេះដឹងឱ្យចងចាំយូរអង្វែង ហើយត្រូវធ្វើសមាហរណកម្មចំណេះដឹងថ្មី ជាមួយចំណេះដឹងមានស្រាប់នៅក្នុងពេល ដែលយើងស្ថាបនាការយល់ដឹង ដោយប្រើយន្តការដូចជាការពង្រីក(Elaboration) ដោយបន្ថែមអត្ថន័យឱ្យព័ត៌មានថ្មី ដើម្បីស្ថាបនាការយល់ដឹង។ មេរៀនដែលបានពង្រីកនៅពេល ដែលយើងបានសិក្សាជាលើកដំបូងងាយស្រួលរម្លឹកមកវិញ ដោយសារព័ត៌មាននេះត្រូវបានវិភាគ និងភ្ជាប់ទៅនិងព័ត៌មានដែលមានស្រាប់។

ដូចនេះ សិស្សត្រូវចេះយកគំនិតថ្មីមកវិភាគ បកស្រាយ និងពង្រីកឱ្យក្លាយជាគំនិតរបស់ខ្លួន។ ការយល់ដឹងកាន់តែស៊ីជម្រៅ ការចងចាំបានល្អ។ សិស្សមិនត្រូវទន្ទេញចាំមាត់នូវចម្លើយ ដែលមានស្រាប់ក្នុងសៀវភៅឡើយតែត្រូវចេះបង្កើតចម្លើយដោយខ្លួនឯងដោយ(១) សរសេរជាពាក្យរបស់ខ្លួន (២) បង្កើតឧទាហរណ៍ផ្ទាល់ខ្លួន (៣) ពន្យល់ដល់មិត្តភក្តិ (៤) បង្កើតរូបារម្មណ៍ប្រៀបធៀប (៥) បង្កើតដ្យាក្រាម (៦) បង្កើតផែនទីគំនិត (៧)អនុវត្តចំពោះបញ្ហាថ្មីៗ។

**គ-ការសិក្សាតាមបែបបញ្ញត្តិ**

ការសិក្សាតាមបែបបញ្ញត្តិ(Concept Based Learning) គឺជាវិធីសាស្ត្របង្រៀនមួយដែលជំរុញឱ្យសិស្សគិត ពិភាក្សា ដោះស្រាយ និងពន្យល់ឆ្ពោះទៅរកការកំណត់បញ្ញត្តិ ដោយខ្លួនឯងក្រោមការសម្របសម្រួលរបស់គ្រូ។ ដើម្បីអនុវត្តការសិក្សាតាមបែបបញ្ញត្តិឱ្យបានល្អ គ្រូត្រូវរៀបចំគម្រោងផែនការបង្រៀន និងកិច្ចតែងការបង្រៀន ផលិតសម្ភារឧបទេសងាយៗមានទំនាក់ទំនងទៅនិងបញ្ញត្តិ ដែលត្រូវបង្រៀន។ សម្ភារឧបទេសអាចជួយបំផុសគំនិតសិស្សឱ្យឆ្ងល់ វិភាគ ដោះស្រាយ និងពន្យល់បានមិនគ្រាន់តែចាំនោះទេ។ គ្រូត្រូវរៀបចំសំណួរងាយៗ ដែលមានលក្ខណៈច្បាស់លាស់មិនទូទៅក្នុងការជួយសិស្សឱ្យឈានទៅរកការកំណត់បញ្ញត្តិបានច្បាស់លាស់។

ក្នុងដំណើរការបង្រៀនតាមបែបបញ្ញត្តិត្រូវបានអនុវត្តតាមជំហានដូចខាងក្រោម[59]៖

- ជំហានទី១ គ្រូត្រូវបំផុសគំនិតសិស្សតាមរយៈការបង្ហាញរូបភាព ឬល្បែងកម្សាន្តដែលទាក់ទងទៅនឹងមេរៀន ដើម្បីឱ្យសិស្សមានចម្ងល់។
- ជំហានទី២ តាមរយៈចម្ងល់របស់សិស្ស គ្រូត្រូវកំណត់បញ្ហាមួយជាបញ្ហារួម ដែលមានទំនាក់ទំនង

[59] ហង់ជួន ណារ៉ុន កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន និងរៀន (បទបង្ហាញនៅវិទ្យាស្ថានជាតិអប់រំថ្ងៃ ២៧ មករា ឆ្នាំ២០២០)។

នឹងបញ្ញត្តិរួចសរសេរនៅលើក្តារខៀន។ នៅពេលមានបញ្ហានៅលើក្តារខៀនធ្វើឱ្យពួកគេមានបំណងចង់ដោះស្រាយ។

- ជំហានទី៣ គ្រូបង្រៀនរៀបចំឱ្យសិស្សពិភាក្សាជាដៃគូជាក្រុម ដើម្បីដោះស្រាយបញ្ហានោះ។ ក្នុងការពិភាក្សាក្រុមសិស្សត្រូវបែងចែកភារកិច្ចប្រធាន អ្នកសង្កេត អ្នកស្រាវជ្រាវ និងអ្នកកត់ត្រាដោយធ្វើយ៉ាងណាឱ្យពួកគេអាចដោះស្រាយ សន្និដ្ឋាន និងកំណត់បញ្ញាតិបានព្រមទាំងអាចពន្យល់ បញ្ញត្តិ នោះបានគ្រប់គ្នាក្នុងក្រុមដោយមិនទុកឱ្យនរណាម្នាក់នៅទំនេរឡើយ។

- ជំហានទី៤ សិស្សដែលបានពិភាក្សាចប់សព្វគ្រប់ត្រូវបិទបញ្ញាត្តិ ដែលក្រុមខ្លួនរកឃើញនៅលើជញ្ជាំង ដើម្បីពន្យល់សិស្សផ្សេងទៀតក្នុងករណីពួកគេមិនយល់ច្បាស់។ ក្នុងជំហាននេះគ្រូអាចសួរសំណួរដល់សិស្សផងដែរ។

- ជំហានទី៥ គ្រូសម្របសម្រួលសន្និដ្ឋានសរុបបញ្ញត្តិ ដែលសិស្សរកឃើញជារួមរួចសរសេរបញ្ញត្តិទាំងនោះនៅលើក្តារខៀន។

ដូចនេះ ការសិក្សាតាមបែបបញ្ញត្តិធ្វើឱ្យសិស្សរវល់ច្រើន ក្នុងការរៀបចំគម្រោង ផែនការបង្រៀន រៀបចំកិច្ចតែងការបង្រៀន និងរៀបចំសម្ភារឧបទេសបង្រៀន និងដំណើរការបង្រៀនចំណាយពេលច្រើនបន្តិច ប៉ុន្តែលទ្ធផលទទួលបានគឺការចាប់អារម្មណ៍រៀនសូត្រសប្បាយរីករាយ និងការចូលរួមយ៉ាងសកម្មពីសិស្ស ព្រោះថាវិធីនេះបានធ្វើឱ្យសិស្សចេះឆ្ងល់ កំណត់បញ្ហា ចេះពិភាក្សា ចេះដោះស្រាយ ចេះពន្យល់រហូតដល់អាចកំណត់បញ្ញត្តិបាន។

### ៤-៤-២-ការផ្ទេរចំណេះដឹង

ការសិក្សា គឺជាការកែប្រែអាកប្បកិរិយាជាផលទទួលបានពីបទពិសោធន៍ ដែលមនុស្សទទួលបានពីការជួបប្រសព្វជាមួយបរិស្ថានជុំវិញ ឬពីការហ្វឹកហាត់រួមទាំងការប្រែប្រួលនៃបរិមាណចំណេះដឹងរបស់អ្នកសិក្សា។ ដូចនេះគ្រូបង្រៀនមានភារកិច្ចក្នុងការជួយសិស្សគ្រប់រូប ឱ្យចេះរៀន មានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាទៅតាមកម្មវិធីសិក្សាកំណត់។ គ្រូត្រូវរៀបចំស្ថានភាពក្នុងថ្នាក់រៀន ដើម្បីបង្កើតបរិយាកាសសម្រាប់ការរៀន និងជួយសិស្សឱ្យកែប្រែផ្លាស់អាកប្បកិរិយា ទៅតាមគោលដៅនកម្មវិធីសិក្សា។

ការសិក្សា គឺជាដំណើរការផ្ទេរព័ត៌មានពីលំនឹកបំពេញការងារទៅលំនឹករយៈពេលវែង ដែលសិស្សអាចរម្លឹកព័ត៌មានបានមកវិញ។ ការហ្វឹកហាត់ទន្ទេញចាំមាត់ និងការអនុវត្តសកម្មភាពសិក្សាជួយដល់ការចងចាំ និងការអនុវត្តបែបវិជ្ជមាន។

វិធីសាស្ត្របង្រៀនតាមប្រពៃណី គឺនៅពេលដែលសិស្សរៀនមិនចេះ គ្រូដាក់ទណ្ឌកម្មច្រើនប្រភេទដើម្បីពង្រឹងអំណាចរបស់ខ្លួននៅក្នុងថ្នាក់រៀនដូចជា៖

(១)ទណ្ឌកម្មលើរាងកាយ ដោយគ្មានការប៉ះពាល់ផ្ទាល់ឈរជើងមួយ ឈរក្រោមកម្ដៅថ្ងៃរយៈពេលយូរវត់ជុំវិញសាលារៀន ប្រានឱ្យវារលើឥដ្ឋ ឱ្យលើកដៃហើយហាមាត់ ប្រើធ្វើពលកម្មដូចជា លាងបង្គន់ យួរទឹក ស្រោចផ្កា ឬដាក់ជីផ្កា និងកាត់ស្មៅ។

(២)ទណ្ឌកម្មលើរាងកាយ វាយដោយខ្សែក្រវាត់វាយដំច្រើនកន្លែងលើរាងកាយ បើរំពាត់ ឬបន្ទាត់តូចវាយលើចុងក្រចក បង្ខំឱ្យដាល់តុ ឬក្ដារខៀន ឬបុកម្រាមដៃទៅនឹងវត្ថុអ្វីមួយ

(៣)ទណ្ឌកម្មក្រៅរាងកាយមិនឱ្យចូលថ្នាក់រៀនក្នុងថ្នាក់ ពិន័យពេលមកយឺត បង្ខំឱ្យទិញក្រដាស ឬសៀវភៅឱ្យគ្រូដាក់អវត្តមាននៅពេលពួកគេចតម៉ូតូខុសកន្លែងជាដើម។

អំពើហិង្សា និងទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីពុំមែនជាវិន័យទេ។ អំពើហិង្សាបង្កការឈឺចាប់មិនលើកទឹកចិត្តសិស្សធ្វើឱ្យសិស្សបាត់បង់ទំនុកចិត្ត និងធ្វើឱ្យពួកគេមិនចូលចិត្ត ឬរហូតដល់ស្អប់សាលាថែមទៀត និងជាការរំលោភលើសិទ្ធិកុមារទៀតផង។ ពេលខ្លះគ្រូប្រើប្រាស់ការលើកសរសើរជាវិជ្ជមាន និងប្រើប្រាស់ចំណាត់ថ្នាក់សិស្សដើម្បីលើកទឹកចិត្តប៉ុន្តែពុំមែនដើម្បីឱ្យមានកិច្ចប្រឹងប្រែងនោះទេ។

ដូច្នេះ គ្រូបង្រៀនគួរខិតខំរកវិធីជួយសិស្សឱ្យរៀនឆាប់យល់ ឆាប់ចងចាំមេរៀន និងចេះអនុវត្ត ហើយគ្រូបង្រៀនត្រូវរៀបចំមេរៀនបង្រៀនក៏ឱ្យសិស្សងាយយល់ បង្កើតទំនាក់ទំនងរវាងមេរៀនចាស់ទៅនឹងមេរៀនថ្មី និងគំនិតដែលសិស្សធ្លាប់រៀន ព្រមទាំងប្រើប្រាស់សម្ភារឧបទេសជាជំនួយក្នុងការបង្រៀនជាពិសេសបង្កឱកាសឱ្យសិស្សស្ថាបនាចំណេះដឹងដោយខ្លួនឯង។ ចំពោះការរៀនសូត្រតាមបែបប្រពៃណី គឺជាទម្លាប់មួយធ្វើឱ្យចំណេះដឹង និងជំនាញរបស់សិស្សធ្លាក់ចុះ និងពុំមានគំនិតច្នៃប្រឌិតបង្កើតថ្មីនោះទេ។ អាស្រ័យដូចនេះ ក្រសួងអប់រំបានចាប់ផ្ដើមធ្វើកំណែទម្រង់តាំងពីឆ្នាំ២០១៤ បានផ្ដោតលើគុណវឌ្ឍិគ្រូបង្រៀនជាគោលក្នុងនោះវិធីសាស្ត្របង្រៀន និងរៀន គឺជាចំណេះដឹងចាំបាច់ ដែលត្រូវកែលម្អមុនគេ។

## សំណួរពិភាក្សា

១-ហេតុអ្វីបានជាក្រសួងអប់រំត្រូវការកែទម្រង់វិធីសាស្ត្របង្រៀនជាបន្ទាន់?

២-ចូរអ្នកជ្រើសរើសយកវិធីសាស្ត្របង្រៀនចំនួន២ ដើម្បីបញ្ជាក់ថា ជាវិធីសាស្ត្របង្រៀនទំនើប។

៣-ចូរអ្នករៀបរាប់អំពីរៀនរបស់សិស្សមានអ្វីខ្លះ ដែលបញ្ជាក់ថា ជាការស្ថាបនាចំណេះដឹង។

៤-ចូរអ្នកប្រាប់ពីគុណសម្បត្តិ និងគុណវិបត្តិអំពីការបង្រៀន និងរៀនតាមបែបស្ថាបនា និងផ្ទេរចំណេះដឹង។

៥-តើការបង្រៀននៅសាលាចំណេះទូទៅនាពេលបច្ចុប្បន្នជាការបង្រៀនតាមបែបស្ថាបនា ឬជាការផ្ទេរចំណេះដឹង? ចូរពន្យល់។

## មេរៀនទី៥៖ ការអប់រំបំណិនឌីជីថល

### ៥-១-វត្ថុបំណងមេរៀន

### ក-វិជ្ជាសម្បទា

- កំណត់បានពីការបង្រៀន និងរៀនតាមបែបបច្ចេកវិទ្យាឌីជីថលស្របតាមការអប់រំក្នុងសតវត្សរ៍ទី២១
- បកស្រាយបានពីការសិក្សាតាមបែបចម្រុះដោយបង្ហាញពីការរៀន និងការរៀនបានដោយខ្លួនឯង
- រៀបរាប់បានពីតម្រូវការនៃការបង្រៀន និងរៀនតាមអនឡាញ

### ខ-បំណិនសម្បទា

- អនុវត្តបានការបង្រៀន និងរៀនតាមបែបបច្ចេកវិទ្យាឌីជីថល
- សំយោគបានពីការសិក្សាតាមបែបចម្រុះ (ការរៀនរួមគ្នា និងការរៀនដោយខ្លួនឯង)
- វាយតម្លៃបានពីតម្រូវការនៃការបង្រៀន និងរៀនតាមអនឡាញ

### គ-ចរិយាសម្បទា

- ចូលរួមគាំទ្រ និងអនុវត្តការបង្រៀន និងរៀនតាមបែបបច្ចេកវិទ្យាឌីជីថល ស្របតាមការអប់រំក្នុងសតវត្សរ៍ទី២១។

### ៥-២-សេចក្តីផ្តើម

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ ដែលក្នុងនោះបញ្ចកោណទី៥ បានកំណត់អំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ហើយបញ្ចកោណនេះអាចសម្រេចលទ្ធផលទៅបាន អាស្រ័យលើការអភិវឌ្ឍមូលធនមនុស្សក្នុងបរិការណ៍បរិវត្តកម្មសង្គម និងសេដ្ឋកិច្ចឌីជីថល ដែលត្រូវបន្តធ្វើសមាហរណកម្មវិស័យបច្ចេកវិទ្យាឌីជីថលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិតនៃប្រព័ន្ធអប់រំ ដែលបំពាក់នូវបន្ទប់ពិសោធន៍ឌីជីថល តភ្ជាប់បណ្តាញអគ្គិសនី និងប្រព័ន្ធអ៊ិនធឺណែតនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនលើកកម្ពស់គុណវុឌ្ឍិដល់គ្រូបង្រៀនផ្នែកឌីជីថល ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន និងរៀន ការបង្កើតមជ្ឈមណ្ឌលអប់រំឌីជីថល និងផ្សព្វផ្សាយវេទិកាឌីជីថលឱ្យកាន់តែទូលំទូលាយ យល់ដឹងអំពីសាលាឌីជីថល(SalaDigital) គេហទំព័រធនធានអប់រំសម្រាប់ការបង្រៀន និងរៀនស្វ័យសិក្សា ការស្រាវជ្រាវ និងស្វែងរកឯកសារដ៏សម្បូរបែបតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីឆ្លើយតបនឹងបរិបទថ្មីនៃការអប់រំបែបឌីជីថល និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា២០២៣-២០៣៥។

### ៥.៣.ការអប់រំនៅសតវត្សរ៍ទី២១

### ក-បំណិនសតវត្សរ៍ទី២១

បំណិនសតវត្សរ៍ទី២១ គឺជាបំណិនឌីជីថល ដែលមានសារៈសំខាន់សម្រាប់យុវជនកម្ពុជាបាន

ចូលរួមពង្រឹងសមត្ថភាពយុវជនឱ្យខិតខំរៀនសូត្រ ដើម្បីចូលរួមប្រកួតប្រជែងការងារ។ ដើម្បីឆ្លើយតបបំណិនសតវត្សរ៍ទី២១ សិស្សានុសិស្សត្រូវស្វ័យសិក្សាជាប្រចាំនូវបំណិនសិក្សាពេញមួយជីវិតរួមមាន វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងមានបំណិនល្អក្នុងការរស់នៅ។ លើសពីនេះ បុគ្គលដែលសុខភាពល្អអាស្រ័យលើមានបំណិនរស់នៅល្អ ចរិយាសម្បទា សីលធម៌ ជាទុនមួយនាំឱ្យមនុស្សក្លាយជាអ្នកដឹកនាំល្អ។ យុវជនឪដីថលត្រូវរៀនសម្របខ្លួនជាមួយបច្ចេកវិទ្យា ផ្គត់គំនិតប្រកបដោយសីលធម៌ និងសីលធម៌ វិន័យ ខិតខំរៀនសូត្រ ធ្វើការឱ្យតម្លៃទៅលើការងារ និងមានទំនាក់ទំនងល្អក្នុងសង្គម។

បំណិនសតវត្សរ៍ទី២១មាន៣សំខាន់ៗរួមមាន ៖

ទី១-បំណិននៃការសិក្សារៀនសូត្រផ្តោតលើការត្រិះរិះពិចារណា ការគិតដោយមានភាពច្នៃប្រឌិត ការសហការ និងការទំនាក់ទំនង។

ទី២-បំណិននៃការទទួលព័ត៌មានថ្មីៗដូចជាសិស្សត្រូវមានចំណេះដឹងផ្នែកព័ត៌មានវិទ្យា ចំណេះដឹងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងចំណេះដឹងផ្នែកបច្ចេកវិទ្យា។

ទី៣-បំណិនជីវិត ផ្តោតលើការចេះរស់នៅចុះសម្រុងជាមួយអ្នកដទៃ ការចេះផ្តួចផ្តើមគំនិត ភាពជាអ្នកដឹកនាំ និងផលិតភាពការងារ។

## ខ-ការសិក្សារៀនសូត្ររបស់សិស្សនៅសតវត្សរ៍ទី២១

ចំពោះការសិក្សានៅសតវត្សរ៍ទី២១គឺជាការប្រមូលផ្តុំនៃធនធានមនុស្ស ដែលមានចំណេះដឹងទម្លាប់ការងារ ជំនាញទន់ អក្ខរកម្មឪដីថល ការគិតត្រិះរិះពិចារណា និងការដោះស្រាយបញ្ហាអាចជួយសិស្ស និស្សិតដឹកនាំអាជីពឆ្ពោះទៅរកភាពជោគជ័យក្នុងកន្លែងការងារទំនើប។ ការសិក្សានេះសំដៅលើការអភិវឌ្ឍការសិក្សារៀនសូត្រ បំណិនជីវិត និងការសិក្សាពេញមួយជីវិតជាផ្នែកមួយនៃបទពិសោធន៍សិក្សាក្នុងសាលារៀន ដែលជំនាញសិក្សាទាំងនោះរួមមានការគិតបែបរិះរក ត្រិះរិះពិចារណា ការច្នៃប្រឌិត ការសហការ និងការប្រាស្រ័យទាក់ទងមានសារៈសំខាន់សម្រាប់ការសម្របខ្លួនទៅនឹងបរិយាកាសសង្គមបែបទំនើប។ បំណិនជីវិតរួមមានភាពបត់បែន ភាពជាអ្នកដឹកនាំ គំនិតផ្តួចផ្តើម ផលិតភាព និងជំនាញសង្គម ដែលជំនាញទាំងនេះ អាចជួយសិស្ស និស្សិតក្នុងការសរសេរគម្រោង ការរៀបចំបណ្តាញ ការអភិវឌ្ឍជំនាញ ការផលិតខ្លឹមសារមេរៀននៅក្នុងថ្នាក់រៀន ពោលគឺការសិក្សាដែលឆ្លើយតបនិងទិដ្ឋភាពនៃការរៀនសូត្រតាមប្រព័ន្ធឪដីថលក្នុងបរិបទសតវត្សរ៍ទី២១។ ជំនាញនៃការសិក្សារៀនសូត្រ(Learning Skills) គឺជាការបង្រៀនសិស្សអំពីដំណើរការផ្លូវចិត្ត ដែលតម្រូវឱ្យសម្របខ្លួន និងកែលម្អលើបរិយាកាសការងារទំនើបជាពិសេសផ្អែកលើ(8C)មានដូចជា(១)បំណិនការគិតត្រិះរិះពិចារណា និងដោះស្រាយបញ្ហា (Critical thinking and problem solving)(២) បំណិនច្នៃប្រឌិត និងនវានុវត្តន៍(Creativity and Innovation)(៣)ការយល់ដឹងពីពហុវប្បធម៌(Cross-cultural understanding)(៤)បំណិនសហការ និងធ្វើការជាក្រុម និងភាពជាអ្នកដឹកនាំ(Collaboration teamwork) (៥)បំណិនទំនាក់ទំនង

(Communication) (៦)បំណិនកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាន(Computing and ICT literacy)(៧) បំណិនអាជីព និងរៀន(Caree and learning skills)(៨)បំណិនខាងផ្នែកផ្លាស់ប្តូរ(Change)។




រូបភាពទី១០៖ បំណិនសតវត្សរ៍ទី២១

ចំពោះប្រទេសម៉ាឡេស៊ីឆ្នាំ២០១៤បានបញ្ជាក់ថា ការសិក្សានៅសតវត្សរ៍ទី២១ គឺជាដំណើរការសិក្សា ដែលផ្តោតលើសកម្មភាពសិក្សារបស់សិស្សដូចជា ការសហការ ការប្រាស្រ័យទាក់ទង ការច្នៃប្រឌិត និងការត្រិះរិះពិចារណា ដើម្បីបង្កើនជំនាញក្នុងការសិក្សា និងស្រាវជ្រាវរបស់សិស្សក្នុងថ្នាក់រៀន ពោលគឺ

ផ្តោតលើសកម្មភាព(4C)[60]។ ក្រៅពីនេះនៅមាន (១)អក្ខរកម្មព័ត៌មាន (Information ) (២)អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (Media) (៣)អក្ខរកម្មបច្ចេកវិទ្យា (Technology) និង ភាពបត់បែន (Flexibility) គឺការចេះបង្វែរផែនការតាមភាពចាំបាច់ ភាពជាអ្នកដឹកនាំ(Leadership) ការជំរុញក្រុមដើម្បីសម្រេចគោលដៅ គំនិតផ្តួចផ្តើម (Initiative) ចាប់ផ្តើមគម្រោង យុទ្ធសាស្ត្រ និងផែនការដោយខ្លួនឯង ផលិតភាព (Productivity) រក្សាប្រសិទ្ធភាពក្នុងភាពជាយុវវ័យ និងជំនាញសង្គម (Social Skill)។

ខាងក្រោមនេះគឺជាបំណិន(4C)សម្រាប់សិស្សអនុវត្តក្នុងការសិក្សារៀនសូត្រ៖

**៥-៣-១-ការគិតត្រិះរិះពិចារណា**(Critical thinking)

ការគិតការគិតត្រិះរិះពិចារណាក្នុងសតវត្សរ៍ទី២១ត្រូវបានពិពណ៌នាថា សមត្ថភាពក្នុងការរចនា ការគ្រប់គ្រង និងដោះស្រាយបញ្ហា ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពដោយប្រើឧបករណ៍ និងធនធានផ្សេងៗនៃការអប់រំសម្រាប់ដោះស្រាយបញ្ហាតម្រូវការជាក់ស្តែង។

គ្រូបង្រៀនភាគច្រើនបានកំណត់និយមន័យនៃការគិតត្រិះរិះពិចារណាដោយសំដៅទៅលើជំនាញនៃការគិតលំដាប់ខ្ពស់ ដែលតម្រូវឱ្យចេះគិតឱ្យស៊ីជម្រៅ រកហេតុផលនានា ដើម្បីធ្វើការសម្រេចចិត្ត។ លោកBloom បានចាត់ទុកនៃឋានានុក្រមកម្រិតលំដាប់ទាំង៣ គឺការវិភាគ វាយតម្លៃ បង្កើតថ្មី គឺជាបំណិននៃការគិតត្រិះរិះពិចារណាកម្រិតខ្ពស់[61] ដែលការវិភាគសំដៅលើការវិភាគរកខុសត្រូវ ល្អអាក្រក់ គុណសម្បត្តិ គុណវិបត្តិ គឺជាកម្រិតមួយបន្ទាប់នៃការយល់ដឹងរួមបញ្ចូលទាំងសមត្ថភាពក្នុងការទាញសេចក្តីសន្និដ្ឋានតាមបែបឡូស៊ីកដោយផ្អែកលើការពិត។ ចំពោះការវាយតម្លៃមានន័យថា កំណត់ភាពត្រឹមត្រូវដែលសិស្សនឹងអាចកំណត់អត្តសញ្ញាណគុណសម្បត្តិជាអំណះអំណាង ឬទស្សនៈ ថ្លឹងថ្លែងពីភាពខ្លាំងដែលទាក់ទងគ្នានៃចំណុចនីមួយៗ។ រីឯការបង្កើតថ្មី(លំដាប់ខ្ពស់)គឺកម្រិតចុងក្រោយនៃទ្រឹស្តីBloom ដែលសិស្សអាចបង្កើតនូវអ្វីដែលថ្មី ហើយកំណត់នូវលក្ខណៈច្នៃប្រឌិត ការរចនា និងការបង្កើតបានស្នាដៃដែលពុំមានពីមុនមក។

ការគិតត្រិះរិះពិចារណាជាដំណើរការដែលពាក់ព័ន្ធនឹងការចោទសួរសំណួរសមស្រប ការប្រមូលផ្តុំ និងការតម្រៀបប្រកបដោយភាពច្នៃប្រឌិតតាមរយៈព័ត៌មានពាក់ព័ន្ធរវាងព័ត៌មានថ្មី និងព័ត៌មានមានស្រាប់ (ចំណេះដឹង) ពិនិត្យឡើងវិញនូវជំនឿ និងការសន្មតហេតុផលបែបឡូកស៊ីក និងការទាញយកនូវអ្វីដែលអាចទុកចិត្តបាន ដើម្បីធ្វើការសន្និដ្ឋាន។ ការត្រិះរិះពិចារណាទាមទារនូវការខិតខំប្រឹងប្រែងយ៉ាងខ្ជាប់ខ្ជួន ដើម្បីអនុវត្តការស្ថាបនាទ្រឹស្តី ស្វែងយល់ពីបញ្ហា ពិចារណាដោយភស្តុតាង និងវាយតម្លៃវិធីសាស្ត្រ ឬបច្ចេកទេស ដើម្បីបង្កើតការវិនិច្ឆ័យ។ ជំនាញនៃការយល់ដឹងក្នុងការវិភាគ ការបកស្រាយ ការសន្និដ្ឋាន

---

[60] (១) (Critical thinking and problem solving) (២) (Creativity and Innovation) (៣) (Collaboration teamwork) (៤) (Communication)។

[61] https://helpfulprofessor.com/higher-order-thinking-skills-examples

ការពន្យល់ ការវាយតម្លៃ និងការត្រួតពិនិត្យ និងកែតម្រូវហេតុផលផ្ទាល់ខ្លួននៅក្នុងបេះដូងនៃការគិតត្រិះរិះពិចារណា។ ការចូលរួមវិភាគទានដូចជា ការចង់ដឹង ចង់ឃើញ និងភាពបត់បែន និងឥរិយាបទសំណួរដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការរិះរក ការគិត ការត្រិះរិះ ដែលជាសមត្ថភាព និងជំនាញការអប់រំសតវត្សរ៍ទី២១[62]។

ចំពោះលោកRuggiero(២០១២)បានកំណត់ថា ការគិតត្រិះរិះពិចារណាស៊ីជម្រៅបាននាំឱ្យបុគ្គលម្នាក់ៗមានសមត្ថភាពដូចជា៖

- ទទួលស្គាល់ដែនកំណត់សមត្ថភាពផ្ទាល់ខ្លួន។
- មើលឃើញពីបញ្ហានានាជាបញ្ហាប្រឈមដ៏គួរឱ្យចាប់អារម្មណ៍។
- មានការយល់ដឹងខ្ពស់ចំពោះគោលដៅ។
- ចេះប្រើប្រាស់ភស្តុតាង ដើម្បីធ្វើការវិនិច្ឆយ។
- ចាប់អារម្មណ៍លើគំនិតរបស់អ្នកដទៃ។
- មានការសង្ស័យចំពោះទស្សនៈជ្រុលនិយម។
- គិតមុនពេលធ្វើសកម្មភាព។
- ជៀសវាងអារម្មណ៍រំជួលចិត្ត
- បើកចិត្តឱ្យទូលាយ
- ចូលរួមក្នុងការស្តាប់សកម្ម




រូបភាពទី១១៖ បង្ហាញពីអត្ថប្រយោជន៍នៃការត្រិះរិះពិចារណា

ដូចនេះការគិតត្រិះរិះពិចារណា ស៊ីជម្រៅទាមទារឱ្យមានវិធីសាស្ត្រជាប្រព័ន្ធក្នុងការវាយតម្លៃ

[62] UNESCO, Glossary of Curriculum Terminology,2013, P.15

ព័ត៌មានថ្មីៗ និងលើកទឹកចិត្តឱ្យចេះចោទសួរ បង្កើតចម្ងល់ និងឆ្លុះបញ្ចាំងពីចំណេះដឹងផ្ទាល់ខ្លួន បទពិសោធ ដើម្បីធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។

ក-សកម្មភាពត្រិះរិះពិចារណារបស់សិស្សក្នុងថ្នាក់រៀន

អ្នកស្រាវជ្រាវបានរកឃើញថា គ្រូបង្រៀនភាគច្រើន(៨៩%)បានបញ្ជាក់ថា ការគិតត្រិះរិះស៊ីជម្រៅមានសារៈសំខាន់នៅក្នុងថ្នាក់រៀន ប៉ុន្តែក៏មានតែ១១%ទៀតថា ជាកម្រិតមធ្យម។ លើសពីនេះ ភាគច្រើនក៏បានអះអាងទៀតថា ការបណ្ដុះការគិតបែបត្រិះរិះពិចារណាចំពោះសិស្សនៅក្នុងថ្នាក់រៀនគឺជាការលើកកម្ពស់សមត្ថភាពដល់សិស្សក្នុងពេលកំពុងសិក្សារៀនសូត្រ[63]។ បច្ចុប្បន្ននេះ ការត្រិះរិះពិចារណាស៊ីជម្រៅបានក្លាយជាប្រធានដ៏មានប្រជាប្រិយភាពនៅក្នុងមជ្ឈដ្ឋានអប់រំ ជាពិសេសក្នុងការបង្រៀនជំនាញពិចារណាឱ្យចេះថ្លឹងថ្លែងអំពីអ្វីជាព័ត៌មាន និងខ្លឹមសារមេរៀន។ ការគិតត្រិះរិះពិចារណាតម្រូវឱ្យសិស្សនិស្សិតទទួលបាននូវការបកស្រាយ វែកញែក និងវិភាគស៊ីជម្រៅលើប្រភពព័ត៌មានជាច្រើន ដើម្បីឈានដល់ការសម្រេចចិត្តប្រកបដោយការយល់ដឹង និងចក្ខុវិស័យច្បាស់លាស់។ ឧបករណ៍ធនធានឌីជីថលបានក្លាយជាសម្ភារឧបទេសសម្រាប់ជំរុញសិស្ស ក្នុងការគិតត្រិះរិះពិចារណាប្រកបដោយភាពប៉ិនប្រសប់ក្នុងការស្វែងរកបញ្ញត្តិ ចំណេះដឹងថ្មីៗ និងចេះដោះស្រាយបញ្ហាបានគ្រប់យ៉ាង។ លោកBloom កំណត់ថា ការត្រិះរិះពិចារណាស៊ីជម្រៅ គឺជាជំនាញនៃការគិតលំដាប់ខ្ពស់ហួសពីការសង្កេតជាមូលដ្ឋាននៃការពិត និងការទន្ទេញចាំមាត់ ហើយសិស្សចេះធ្វើការវាយតម្លៃ ច្នៃប្រឌិត និងបង្កើតថ្មីក្នុងគោលដៅ ដើម្បីផ្លាស់ទីសិស្សពីការគិតកម្រិតទាបទៅលំដាប់ខ្ពស់ដោយពីចំណេះដឹង (ការប្រមូលព័ត៌មាន) ដល់ការយល់ដឹង (បញ្ជាក់) ពីកម្មវិធីប្រើប្រាស់ចំណេះដឹងដល់ការវិភាគ ពីការវាយតម្លៃ (ការវិនិច្ឆ័យលទ្ធផល) ដល់ការសំយោគ (ដាក់ព័ត៌មានរួមគ្នា) និងការបង្កើតថ្មី និងការលើកទឹកចិត្តដើម្បីប្រែក្លាយសិស្សទៅជាអ្នកផលិតប្រកបដោយភាពច្នៃប្រឌិត។

លោកសូក្រាត(Socratic)បានលើកទឹកចិត្តសិស្សឱ្យមានការត្រិះរិះពិចារណា តាមរយៈការសួរសំណួររបស់លោកចំពោះសិស្ស(វិធីសន្ទនា) ដើម្បីស្វែងយល់យ៉ាងស៊ីជម្រៅលើការគិតរបស់សិស្ស ជួយសិស្សឱ្យចាប់ផ្ដើមបែងចែកនូវអ្វីដែលពួកគេអាចធ្វើបាន និងយល់ ឬមិនយល់ និងអភិវឌ្ឍបញ្ញាឱ្យកាន់តែខ្ពស់។ មួយវិញទៀតដើម្បីពង្រឹងសមត្ថភាពរបស់សិស្សក្នុងការសួរសំណួរសាកល្បង ជួយសិស្សឱ្យទទួលបាននូវអានុភាពក្នុងជីវិតប្រចាំថ្ងៃ។

ការបង្រៀនសិស្សឱ្យចេះត្រិះរិះពិចារណា គឺមានវិធីជាច្រើន ដើម្បីណែនាំសិស្សចេះគិតពិចារណាទៅក្នុងថ្នាក់រៀនទាំងសកម្មភាពដាច់ដោយឡែក ឬបញ្ចូលទៅក្នុងខ្លឹមសារមេរៀន។ ជាទូទៅគ្រូបង្រៀនអាចបង្រៀនសិស្ស និស្សិតឱ្យចេះត្រិះរិះពិចារណាផ្ដោតលើការវិភាគសម្មតិកម្ម ការពិសោធ ភស្តុតាង និង

---

[63] https://musa.news/km/cose-il-pensiero-critico-non-e-quello-che-pensi-ma-come-pensi

ព្រឹត្តការណ៍នានា ដើម្បីឆ្ពោះទៅការសន្និដ្ឋានមួយច្បាស់លាស់។ កាលពីអតីតកាលគ្រូបង្រៀនច្រើនតែផ្តោតសំខាន់ទៅលើការទន្ទេញចាំមាត់លើខ្លឹមសារមេរៀនដូចជា មុខវិជ្ជាប្រវត្តិវិទ្យា ភូមិវិទ្យា សង្គមវិទ្យាជាដើម។ ទន្ទឹមនឹងនេះគ្រូបង្រៀនភាគច្រើននៅតែអះអាងថា ពួកគេបានបង្រៀនសិស្សឱ្យចេះពិចារណាវិភាគស៊ីជម្រៅ ចេះប្រៀបធៀបថ្លឹងថ្លែង រកហេតុផលផ្សារភ្ជាប់នឹងការរស់នៅប្រចាំថ្ងៃ ប៉ុន្តែជាក់ស្តែងគ្រូបង្រៀនភាគច្រើនគឺបង្រៀនទៅតាមខ្លឹមសារមេរៀន ដែលជាមុខវិជ្ជាជំនាញរបស់ខ្លួនតែប៉ុណ្ណោះ។

ដូចនេះ ការបង្រៀន និងរៀនក្នុងសតវត្សរ៍ទី២១ គឺតម្រូវឱ្យសិស្សចេះត្រិះរិះពិចារណាស៊ីជម្រៅ ថ្លឹងថ្លែងរកហេតុផល វិភាគរកខុស និងត្រូវ ដើម្បីជាប្រយោជន៍សម្រាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

**៥-៣-២-គំនិតច្នៃប្រឌិត និងនវានុវត្តន៍**( Creativity and Innovation )

គំនិតច្នៃប្រឌិត និងនវានុវត្តន៍ទាក់ទងនឹងដំណើរការនៃការបង្កើត និងអនុវត្តចំណេះដឹងថ្មីៗដែលមានមនុស្សតិចតួចណាស់ ដែលចេះបង្កើត និងប្រើប្រាស់បានល្អ។ ការសិក្សាជាច្រើនបានបង្ហាញពីសារៈសំខាន់នៃភាពច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍសង្គម សមត្ថភាពក្នុងការប្រកួតប្រជែងក្នុងអាជីវកម្ម និងកំណើនសេដ្ឋកិច្ច។ លទ្ធផល PISA 2012 កត់សម្គាល់ទំនាក់ទំនងរវាងសមិទ្ធផលសិក្សាខ្ពស់ដូចជាការដោះស្រាយបញ្ហា និងការច្នៃប្រឌិត។ ការច្នៃប្រឌិតត្រូវបានពិពណ៌នាថា ជាការស្វែងរកគំនិតថ្មីៗ ឬផលិតផលដែលបំពេញតម្រូវការនៅក្នុងពិភពលោក។ការច្នៃប្រឌិតរួមមានគំនិតនៃសេដ្ឋកិច្ចសហគ្រិនភាពសង្គម ភាពជាអ្នកដឹកនាំសម្រាប់សកម្មភាព និងការច្នៃប្រឌិតសម្រាប់ការបង្រៀន និងរៀននៅក្នុងថ្នាក់រៀនបានផ្តល់ឱ្យសិស្សនូវបទពិសោធទាក់ទងនឹងស្ថានភាពនៃជីវភាពរស់នៅតាមរយៈសកម្មភាពការស្រាវជ្រាវ និងការពិសោធ។ គោលបំណងនៃគំនិតច្នៃប្រឌិតសម្រាប់គ្រូបង្រៀនគឺ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបង្រៀន អនុវត្តវិធីសាស្ត្របង្រៀនសម្បូរបែប និងចម្រុះ មានការវាយតម្លៃសិស្សចម្រុះ និងសម្រេចបាននូវគោលដៅអប់រំ និងវត្ថុបំណងមេរៀន។

ការច្នៃប្រឌិត និងនវានុវត្តន៍ គឺជាប្រពៃណីនៃការច្នៃប្រឌិតត្រូវបានគេមើលឃើញថា ជាសមត្ថភាពមួយឆ្លើយតបទៅនឹងតម្រូវការសម្រាប់វិធីសាស្ត្រ និងផលិតផលថ្មី។ ជារឿយៗវាត្រូវបានកំណត់ថាជាសមត្ថភាពនាំយកអ្វី ដែលថ្មីទៅក្នុងអត្ថិភាពតាមគោលបំណង។ បញ្ញត្តិនៃគំនិតច្នៃប្រឌិតត្រូវបានពង្រីក និងផ្លាស់ប្តូរក្នុងពេលថ្មីៗនេះដោយសង្កត់ធ្ងន់ថ្មីលើជីវភាពប្រចាំថ្ងៃ និងការច្នៃប្រឌិតសង្គម ដែលកំពុងផ្លាស់ប្តូរផ្នត់គំនិត និងភាពប៉ិនប្រសប់របស់បុគ្គលក្នុងវិស័យមួយចំនួន( ឧ. វិចិត្រសិល្បៈ និងវិទ្យាសាស្ត្រកម្រិតខ្ពស់ )ដើម្បីសហការនូវការច្នៃប្រឌិតក្នុងជីវិតប្រចាំថ្ងៃជាមួយអ្វីដែលថ្មីសម្រាប់ការសិក្សា និងការអប់រំ

ដើម្បីបណ្តុះសមត្ថភាពសិស្សក្នុងការរៀន ការគិតប្រកបដោយស្ថិរភាព និងមានអាកប្បកិរិយាប្រកបដោយភាពច្នៃប្រឌិត គឺត្រូវមានការណែនាំដូចខាងក្រោម៖

( ១ )-បង្កើតរចនាសម្ព័ន្ធដោយរួមបញ្ចូលគ្នានៃផ្លូវចិត្តផ្សេងៗ និងយន្តការនីមួយៗដើរតួនាទីក្នុងប្រភេទជាក់លាក់ណាមួយ ក្នុងស្ថានភាព ឬដំណាក់កាលជាក់លាក់នៃដំណើរការច្នៃប្រឌិត។ ( ២ )-ប្រើ

ប្រាស់សម្ភារៈដែលអាចធ្វើត្រាប់តាមស្ថានភាពជីវិតពិត ឬយ៉ាងហោចណាស់ជួយសិស្ស និស្សិតឱ្យទទួលស្គាល់នូវទំនាក់ទំនងរវាងការងារបណ្ដុះបណ្ដាល និងស្ថានភាពការងារផ្សេងៗ។(៣)-ការពិចារណាលើជំនឿខ្លួនឯងជាបុគ្គល និងទំនោរទៅរកការគិតប្រកបដោយភាពច្នៃប្រឌិត និងចាប់ផ្ដើមដំណើរការបង្រៀន និងរៀនពីគំនិតច្នៃប្រឌិត។ ជាមួយក្ដីសង្ឃឹមនៃការផ្លាស់ប្ដូរតាមរយៈជំនឿខ្លួនឯង ទំនោរ និងយុទ្ធសាស្ត្រតាមមធ្យោបាយនៃដំណើរការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងឡើងវិញ (៤)-បង្ហាញនូវការយល់ឃើញពីបញ្ញាកម្រិតខ្ពស់មានន័យថា បណ្ដុះបណ្ដាលសិស្សពុំត្រឹមតែការប្រតិបត្តិប៉ុណ្ណោះទេ ប៉ុន្តែត្រូវគ្រប់គ្រងនូវការប្រតិបត្តិផងដែរ។(៥)-លើកទឹកចិត្តសិស្សឱ្យចេះទទួលយកហានិភ័យ និងបញ្ហាប្រឈមនានាក្នុងការច្នៃប្រឌិត និងជៀសវាងនូវទំនោរក្នុងការប្រកាន់ខ្ជាប់នូវអ្វីជាទម្លាប់ និងជំរុញសិស្សចេះស្វែងរកគំនិតថ្មី។ ដូចនេះការច្នៃប្រឌិត និងនវានុវត្តន៍បានរាប់បញ្ចូលក្នុងចំណោមសមត្ថភាព និងជំនាញសតវត្សរ៍ទី២១[64]។

ក-ការច្នៃប្រឌិត និងនវានុវត្តនៅក្នុងថ្នាក់រៀន

ការរៀនប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តន៍បានអនុញ្ញាតឱ្យសិស្សបញ្ចេញមតិដោយសេរីដែលផ្ទុយពីវិធីសាស្ត្របង្រៀនបែបបុរាណ។ សិស្សត្រូវបានផ្ដល់ឱកាសឱ្យចេញទៅក្រៅសាលា ដើម្បីបានចូលរួមក្នុងការប្រកួតប្រជែង និងការពិភាក្សា។ ការច្នៃប្រឌិតបានលើកទឹកចិត្តសិស្សានុសិស្ស និងគ្រូឱ្យចេះស្រាវជ្រាវរិះរក និងប្រើប្រាស់ឧបករណ៍ទាំងឡាយ ដើម្បីស្វែងរកអ្វីដែលថ្មី។ ការច្នៃប្រឌិតពាក់ព័ន្ធនឹងវិធីផ្សេងគ្នាដើម្បីស្វែងរកបញ្ហា និងដោះស្រាយបញ្ហា ហើយបានជំរុញសិស្សឱ្យប្រើកម្រិតខ្ពស់នៃការគិតដើម្បីឆ្ពោះទៅការបង្កើតថ្មី ។

លោកWu(២០០២)បានចង្អុលបង្ហាញថា ការច្នៃប្រឌិតក្នុងការបង្រៀន និងរៀន(អំឡុងពេលដំណើរការបង្រៀន) គឺជាពេលដែលគ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចម្រុះ និងខ្លឹមសារមេរៀនសម្បូរបែប ដើម្បីជំរុញចំណាប់អារម្មណ៍ខាងក្នុងរបស់សិស្សក្នុងពេលរៀនក្នុងថ្នាក់។ លោក Bruce, R (១៩៨៩)ទំនោរអន្តរកម្មរវាងអ្នកសិក្សា និងបរិយាកាសថ្នាក់រៀនក្នុងពេលដែលយុទ្ធសាស្ត្រ និងជំនាញសមស្របត្រូវបានអនុវត្តក្នុងការប្រើប្រាស់បច្ចេកវិទ្យា ដែលជាឧបករណ៍ដ៏សំខាន់ក្នុងការបង្រៀនកាន់តែល្អប្រសើរឡើងប្រកបដោយគំនិតច្នៃប្រឌិត និងជាការអភិវឌ្ឍអាកប្បកិរិយាវិជ្ជមានរបស់សិស្សឆ្ពោះទៅរកការរៀនសូត្របែបសកម្ម ដើម្បីពង្រឹកសមត្ថភាព។

អាស្រ័យហេតុនេះ ការបង្រៀន និងរៀនបែបច្នៃប្រឌិតអាចបែងចែកជាពីរផ្នែកដូចខាងក្រោម៖

(១)ការបង្កើតថ្មីនៃវិធីសាស្ត្របង្រៀនមានន័យថា គ្រូបង្រៀនប្រើវិធីសាស្ត្រថ្មី ដោយប្រើប្រាស់បច្ចេកវិទ្យាតាមរយៈអ៊ិនធើណែត និងការប្រើប្រាស់ក្ដារខៀនអេឡិចត្រូនិច ដើម្បីដោះស្រាយបញ្ហាបង្រៀន។

[64] UNESCO, Op.cit, P.14.

(២)ការច្នៃប្រឌិតនៃការបង្រៀន និងរៀនមានន័យថា អនុវត្តនៃការសិក្សាប្រកបដោយភាពច្នៃប្រឌិតរស់រវើកបំផុសគំនិតសិស្សឱ្យបញ្ចូលចំណេះដឹង បទពិសោធ និងសមត្ថភាពច្នៃប្រឌិតដែលអាចបត់បែនបានតាមស្ថានភាពជាក់ស្តែង ដែលអាចឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងពេលបង្រៀន និងរៀន។

យោងតាមលោកChen(២០១០)ការច្នៃប្រឌិតក្នុងពេលបង្រៀនមានន័យថា គ្រូបង្រៀនមានភាពច្នៃប្រឌិត និងប្រើប្រាស់វិធីសាស្រ្តបង្រៀនយ៉ាងរស់រវើក ដើម្បីធ្វើឱ្យសិស្សចាប់អារម្មណ៍ក្នុងការរៀនដូចជា៖

- អភិវឌ្ឍសមត្ថភាពសិស្សក្នុងការវិភាគ ការគិត និងការវិនិច្ឆ័យ។
- ជំរុញចំណាប់អារម្មណ៍របស់សិស្ស និងការលើកទឹកចិត្តក្នុងពេលបង្រៀន និងរៀន
- ទាញយកសក្តានុពលរបស់សិស្សក្នុងការច្នៃប្រឌិត និងការដោះស្រាយបញ្ហា
- បង្កើនសមត្ថភាពទំនោររបស់សិស្សក្នុងការសិក្សាបន្ត។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំពោះមាតា បិតា លោកគ្រូ អ្នកគ្រូបានជ្រើសរើសល្បែងកម្សាន្តត្រឹមត្រូវសម្រាប់សិស្សបឋមសិក្សារៀនសូត្រ ដែលមិនត្រឹមតែផ្តល់ភាពរីករាយជូនកុមារទេថែមទាំងជួយឱ្យកុមារបានអភិវឌ្ឍច្រើនផ្នែកដូចជារាងកាយ បញ្ញា ភាសា អារម្មណ៍ ទំនាក់ទំនងសង្គម និងវិញ្ញាណ។

១-បំណិនចលករះចលនាជាច្រើនដែលពាក់ព័ន្ធនឹងការបង្កើតសិល្បៈដូចជា ការកាន់ជក់គូរគំនូរ ឬការគូសវាសជាមួយនឹងខ្មៅដៃពណ៌ មានសារៈសំខាន់ចំពោះការរីកលូតលាស់នៃបំណិនចលករល្អៗចំពោះកុមារតូចៗ។ ដំណាក់កាលសំខាន់ៗនៃការអភិវឌ្ឍរបស់កុមារនៅអាយុប្រហែល៣ឆ្នាំ រួមមានការគូររង្វង់ និងការចាប់ផ្តើមប្រើប្រាស់កន្ត្រៃសុវត្ថិភាព។ នៅអាយុប្រហែល៤ឆ្នាំ កុមារអាចមានលទ្ធភាពគូររូបជារាងការ៉េ និងចាប់ផ្តើមប្រើកន្ត្រៃដើម្បីកាត់តាមបណ្តោយខ្សែត្រង់។ កម្មវិធីមតេយ្យសិក្សាជាច្រើនផ្តោតលើការប្រើប្រាស់កន្ត្រៃ ពីព្រោះវាអភិវឌ្ឍជំនាញដែលកុមារនឹងត្រូវការសម្រាប់ការសរសេរ។

២-ការអភិវឌ្ឍភាសា៖ សម្រាប់កុមារតូច ពេលយើងនាំគាត់បង្កើតសិល្បៈ ឬគ្រាន់តែនិយាយទាក់ទងនឹងសិល្បៈគឺមានន័យថា គាត់បានទទួលឱកាសរៀនពាក្យដែលទាក់ទងនឹងពណ៌ រូបរាង និងសកម្មភាព។ នៅពេលកុមារចេះដើរតេសតាសមានអាយុមួយឆ្នាំ ឪពុកម្តាយអាចធ្វើសកម្មភាពសាមញ្ញៗដូចជាមូរក្រដាសឱ្យក្លាយទៅជាបាល់មួយ។ ពេលរៀនដល់ថ្នាក់បឋមសិក្សា កុមារអាចចេះប្រើប្រាស់ពាក្យពេចន៍ពិពណ៌នា និងពិភាក្សាអំពីគំនិតច្នៃប្រឌិតផ្សេងៗគ្នារបស់ពួកគេ។

៣-ការធ្វើសេចក្តីសម្រេចចិត្ត៖យោងតាមរបាយការណ៍មួយដែលចេញផ្សាយដោយអង្គការអាមេរិកដើម្បីសិល្បៈ (Americans for the Arts) ការអប់រំសិល្បៈជួយពង្រឹងការដោះស្រាយបញ្ហា និងបំណិនត្រិះរិះពិចារណា។ បទពិសោធនៃការធ្វើសេចក្តីសម្រេចចិត្ត និងជម្រើសក្នុងពេលដែលបង្កើតសិល្បៈបន្តកើតមានក្នុងផ្នែកផ្សេងៗទៀតនៃជីវិត។ លោកស្រី MaryAnn Kohl អ្នកអប់រំផ្នែកសិល្បៈ និងអ្នកនិពន្ធសៀវភៅជាច្រើនក្បាលដែលនិយាយអំពីការអប់រំសិល្បៈរបស់កុមារបានឱ្យដឹងថា ប្រសិនបើពួកគេកំពុងរិះ

រក និងកំពុងគិត ព្រមទាំងកំពុងរិះរកបទពិសោធ និងព្យាយាមសាកល្បងគំនិតថ្មីៗនៅពេលនោះ ភាពច្នៃប្រឌិតរីកលូតលាស់ឡើងហើយ។

៤-ការរៀនសូត្រអំពីគំហើញ៖ ការគូរសូនរូបជាមួយដីឥដ្ឋ និងការក្រេងគ្រាប់អង្កាំដោយខ្សែអំបោះ សុទ្ធតែជួយអភិវឌ្ឍបំណិនគំឃើញដែលមានសារៈសំខាន់ខ្លាំងមិនធ្លាប់មាន។ សូម្បីតែកុមារចេះដើរតេសតាសក៏អាចដឹងអំពីរបៀបប្រតិបត្តិការទូរសព្ទដៃទំនើប ឬធេប្លែត ដែលមានន័យថា មុនពេលពួកគេចេះអាន កុមារយល់អំពីព័ត៌មានគំហើញមុន។

៥-ការច្នៃប្រឌិត៖ នៅពេលកុមារត្រូវបានលើកទឹកចិត្តឱ្យបញ្ចេញគំនិតផ្ទាល់ខ្លួន និងមិនខ្លាចក្នុងការបង្កើតការច្នៃប្រឌិតថ្មីដោយខ្លួនឯង ពេលនោះពួកគេនឹងអភិវឌ្ឍការច្នៃប្រឌិតនៅក្នុងខ្លួនដែលនឹងមានសារៈសំខាន់នៅក្នុងជីវិតពួកគេពេលធំពេញវ័យ។ លោកស្រី Kohl បានឱ្យដឹងថា ប្រភេទមនុស្សដែលសង្គមត្រូវការដើម្បីធ្វើឱ្យសង្គមដើរទៅមុខ គឺជាប្រភេទមនុស្សដែលមានការគិតច្នៃប្រឌិត ដែលព្យាយាមស្វែងរកមធ្យោបាយ និងការកែលម្អថ្មីៗ មិនមែនមនុស្សដែលអាចត្រឹមតែអនុវត្តតាមទិសដៅនោះទេ៉។ លោកស្រីបានឱ្យដឹងទៀតថា សិល្បៈគឺជាវិធីសាស្ត្រមួយ ដើម្បីជំរុញដំណើរការ និងបទពិសោធនៃការគិត និងធ្វើឱ្យអ្វីៗកាន់តែមានភាពប្រសើរ។

៦-ការយល់ដឹងពីវប្បធម៌៖ ខណៈពេលដែលយើងរស់នៅក្នុងសង្គមមួយដែលចម្រុះដោយមនុស្សគ្រប់ជាតិសាស្ត្រអ្វីៗដែលយើងឃើញក្នុងប្រព័ន្ធផ្សព្វផ្សាយ ក៏បង្ហាញពីខ្លឹមសារចម្រុះខុសៗគ្នាផងដែរ។ ការបង្រៀនកុមារឱ្យស្គាល់ពីជម្រើសនានា ដែលវិចិត្រករ ឬអ្នករចនាបង្កើតឡើងនៅក្នុងវត្ថុមួយ នឹងជួយកុមារឱ្យយល់ពីគោលគំនិតថាអ្វីដែលពួកគេមើលឃើញ អាចជាការបកស្រាយនៃភាពពិតប្រាកដរបស់អ្នកណាម្នាក់។

៧-ធ្វើឱ្យការរៀនសូត្ររបស់កុមារកាន់តែល្អ៖ ការស្រាវជ្រាវបានបង្ហាញពីទំនាក់ទំនងយ៉ាងស្អិតរមួតរវាងសិល្បៈ និងសមិទ្ធផលរបស់កុមារ។ របាយការណ៍មួយរបស់អង្គការអាមេរិកដើម្បីសិល្បៈបានឱ្យដឹងថា មនុស្សវ័យក្មេងដែលចូលរួមក្នុងសិល្បៈជាប្រចាំ(បីម៉ោងក្នុងមួយថ្ងៃ បីថ្ងៃក្នុងមួយសប្តាហ៍ក្នុងរយៈពេលពេញមួយឆ្នាំ) អាចមានឱកាសរៀនពូកែមុខវិជ្ជា គណិតវិទ្យា វិទ្យាសាស្ត្រ និងសំណេរ ពូកែជាងអ្នកដែលមិនចូលរួមសោះបួនដង។

**៥-៣-៣-បំណិនទំនាក់ទំនង** (Communication skill)

ការប្រាស្រ័យទាក់ទងគ្នាក្នុងបរិបទនៃសតវត្សរ៍ទី២១ គឺពុំត្រឹមតែសំដៅទៅលើសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពតាមរយៈការនិយាយផ្ទាល់មាត់ ការសរសេរ និងឧបករណ៍ឌីជីថលតែប៉ុណ្ណោះទេ ប៉ុន្តែបំណិននេះមានសារៈសំខាន់បំផុតសម្រាប់មនុស្សម្នាក់ៗក្នុងការរស់នៅប្រចាំថ្ងៃ ដើម្បីបង្កើតបានសុខដុមនីយកម្មក្នុងសហគមន៍ និងសង្គមជាតិ។

បញ្ញត្តិនៃបំណិនទំនាក់ទំនងបានវិវត្តយ៉ាងឆាប់រហ័ស ដែលគ្របដណ្តប់លើចំណេះដឹងសព្វថ្ងៃនេះបានយ៉ាងទូលំទូលាយ។ ក្រុមប្រឹក្សាអឺរ៉ុបចាត់ទុកថា បំណិនទំនាក់ទំនង(Communication skill) មានធាតុផ្សំសំខាន់ចំនួន៦រួមមាន បំណិនភាសា បំណិនសង្គមភាសា បំណិននិយាយ បំណិនសង្គមវប្បធម៌ បំណិនយុទ្ធសាស្ត្រ និងបំណិនសង្គម។ បំណិនទាំងអស់នេះ ដែលអ្នកនិពន្ធជាច្រើនបានចាត់ទុកថា ជាបំណិនសកលសម្រាប់ទំនាក់ទំនងរបស់បុគ្គលម្នាក់ៗក្នុងការរស់នៅប្រចាំថ្ងៃ។

លោកClark & Delia (1979)កំណត់ថា ការប្រាស្រ័យទាក់ទងប្រកបដោយជោគជ័យគឺជាបញ្ហាដ៏ស្មុគស្មាញ ដែលទាមទារឱ្យមនុស្សមានការស្ទាត់ជំនាញនូវចំណេះដឹង ឬសមត្ថភាពផ្សេងៗជាច្រើនប្រភេទរួមបញ្ចូលគ្នាដែលមានដូចខាងក្រោម៖

១-ដើម្បីទំនាក់ទំនងដោយជោគជ័យ មនុស្សត្រូវតែចេះពីច្បាប់ភាសា វេយ្យាករណ៍ដែលអាចឱ្យពួកគេបង្កើត និងយល់ប្រយោគជាភាសាជាក់លាក់មួយដូចជាភាសាអង់គ្លេស ឬចិន។ ចំណេះដឹងបែបនេះត្រូវបានគេហៅថាសមត្ថភាពភាសា។ ជំនាញប្រភេទនេះត្រូវបានសិក្សាភាគច្រើនដោយអ្នកភាសាវិទ្យា និងអ្នកចិត្តសាស្ត្រ ។

២-អ្នកប្រាស្រ័យទាក់ទងដែលជោគជ័យត្រូវតែដឹងពីច្បាប់សង្គម និងការគ្រប់គ្រងនៃការប្រើប្រាស់ភាសាបានសមរម្យស្របតាមស្ថានភាពរបស់ក្រុមមនុស្សផ្សេងៗគ្នា។ ការយល់ដឹងពីរបៀបប្រើប្រាស់ និងបកស្រាយតាមស្ថានភាពសង្គមបានត្រឹមត្រូវ ឬសមស្របប្រៀបដូចជាបានយល់ពីច្បាប់នៃសហគមន៍ ឬក្រុមពាក់ព័ន្ធក្នុងសង្គម។ សមត្ថភាពប្រភេទនេះត្រូវបានសិក្សាភាគច្រើនដោយអ្នកសង្គមវិទូ និងអ្នកស្រាវជ្រាវផ្នែកនរវិទ្យាព្យាយាមកំណត់អត្តសញ្ញាណច្បាប់សម្រាប់ការនិយាយត្រឹមត្រូវនៅក្នុងក្រុមផ្សេងៗ។

៣-អ្នកទំនាក់ទំនង ដែលទទួលបានជោគជ័យត្រូវតែដឹងពីរបៀបបង្កើត និងដំណើរការសារតាមរបៀប ដែលអាចឱ្យពួកគេសម្រេចបាននូវគោលដៅផ្ទាល់ខ្លួន និងសង្គមរបស់ពួកគេប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ អ្នកប្រាស្រ័យទាក់ទងដ៏ប៉ិនប្រសប់ត្រូវតែដឹងពីរបៀបបង្កើតសារដែលប្រាប់អ្នកដទៃយ៉ាងច្បាស់នូវការបញ្ចុះបញ្ចូលដោយភាពជឿជាក់ និងលួងលោបានយ៉ាងឆាប់រហ័ស។ អ្នកមានជំនាញប្រាស្រ័យទាក់ទងដ៏ប៉ិនប្រសប់ក៏ត្រូវតែដឹងអំពីភាពខុសគ្នានៅក្នុងសារទៅកាន់អ្នកដទៃ ហើយថែមទាំងមានសមត្ថភាពក្នុងការអាន ដើម្បីទាញយកអត្ថន័យតាមមានបំណង និងជួនកាលពុំមានបំណង។ ការដឹងពីរបៀបបង្កើតសារ និងការបកស្រាយទៅកាន់អ្នកដទៃសម្រេចបាននូវគោលដៅ ត្រូវបានគេហៅថា សមត្ថភាពខាងវោហាសាស្ត្រ។

### ក-បំណិនប្រាស្រ័យទាក់ទង គឺជាគន្លឹះដ៏សំខាន់នៅក្នុងថ្នាក់រៀន

បំណិននៃការប្រាស្រ័យទាក់ទងក្នុងថ្នាក់រៀនពិតជាមានសារៈសំខាន់ណាស់ ព្រោះថ្នាក់រៀនគឺជាកន្លែងទំនាក់ទំនងមួយដ៏ស្មុគស្មាញ ដែលបន្ថុំទៅដោយចម្រុះជាតិសាសន៍ វប្បធម៌ និងអាកប្បកិរិយា។

ជាទូទៅការបង្រៀន និងរៀនទទួលបានជោគជ័យត្រូវបានចាត់ទុកថា ការអនុវត្តចំណេះដឹងបាន ៥០%នៃបំណិនទំនាក់ទំនង។ គ្រូបង្រៀនគួរតែស្គាត់នៃបំណិនទំនាក់ទំនងទាំង៤ដូចជា ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ហើយគួរតែដឹងពីរបៀបប្រើប្រាស់បំណិននេះឱ្យមានប្រសិទ្ធភាពនៅក្នុងបរិយាកាសថ្នាក់រៀន។ លទ្ធផលបានបង្ហាញថា ភាពជោគជ័យរបស់សិស្សដែលសម្រេចបាននៅក្នុងជីវិតសិក្សារបស់គេក៏ដូចជាភាពជោគជ័យក្នុងអាជីពរបស់គ្រូជាអ្នកបង្រៀន។ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងវិស័យអប់រំគឺផ្អែកលើសមត្ថភាពរបស់គ្រូក្នុងការបង្ហាញពីគំនិត និងទស្សនៈ វិធីសាស្ត្ររបស់ខ្លួនបានយ៉ាងច្បាស់ដោយមានទំនុកចិត្ត និងមានខ្លឹមសារស្របតាមជំនាញ ពោលគឺអន្តរកម្មរវាងគ្រូ និងសិស្សអាចរួមចំណែកដល់ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងថ្នាក់រៀន។

**ខ-យុទ្ធសាស្ត្រក្នុងថ្នាក់រៀន ដើម្បីកែលម្អជំនាញទំនាក់ទំនងរបស់សិស្ស**

ការចេះប្រាស្រ័យទាក់ទងគ្នាគឺជាឆ្អឹងខ្នងដ៏សំខាន់សម្រាប់អ្នកអប់រំ គ្រូបង្រៀនដ៏មានប្រសិទ្ធភាព។ ការប្រាស្រ័យទាក់ទងពុំត្រឹមតែបញ្ជូនព័ត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែបានលើកទឹកចិត្តដល់ការខិតខំប្រឹងប្រែងកែប្រែអាកប្បកិរិយា និងជំរុញការគិតរបស់សិស្ស។ ការប្រាស្រ័យទាក់ទង គឺជាដំណើរការនៃការយល់ដឹង និងការចែករំលែកព័ត៌មាន ចំណេះដឹង ជំនាញ និងបទពិសោធរបស់គ្រូ សិស្ស ដើម្បីបង្កើតនូវសកម្មភាពរៀនរបស់សិស្ស។ ការប្រាស្រ័យទាក់ទងជាបុគ្គលរួមមានការរៀបចំផែនការ ការដោះស្រាយបញ្ហា ការពន្យល់ដោយខ្លួនឯង និងការវាយតម្លៃខ្លួនឯង។ ការប្រាស្រ័យទាក់ទងរវាងបុគ្គល គឺជាការចែករំលែកអត្ថន័យរវាងខ្លួនឯង និងអ្នកដទៃជាដៃគូ។ ការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃពុំត្រឹមតែដឹងតាមពាក្យសំដីដែលកំពុងប្រព្រឹត្តតែប៉ុណ្ណោះទេ ប៉ុន្តែយើងបានដឹងពីចលនារូបរាង កាយវិការ ឥរិយាបថ ទំនាក់ទំនងភ្នែក របៀបឈរ អង្គុយ និងទឹកមុខរបស់សិស្សក្នុងដំណាក់កាលកំពុងកំពុងបង្រៀន និងរៀន។

ខ១-ទំនាក់ទំនងជាមួយសិស្ស

បំណិនទំនាក់ទំនង ពិតជាមានសារៈសំខាន់បំផុតសម្រាប់ការប្រាស្រ័យទាក់ទងជាមួយសិស្ស ក្នុងសកម្មភាពនៃការបង្រៀន និងរៀនរបស់គ្រូបង្រៀន ដែលមានតួនាទីជាអ្នកទទួលខុសត្រូវក្នុងការស្វែងយល់ និងបំបែកព័ត៌មានស្មុគស្មាញ និងបញ្ជូនព័ត៌មាននេះឱ្យបានច្បាស់លាស់ដល់សិស្ស (ពាក្យសំដី និងសំណេរអក្សរ) និងដោះស្រាយសំណួរ ឬបញ្ហាផ្សេងៗរបស់សិស្សប្រកបដោយគរុគោសល្យ។ សកម្មភាពទំនាក់ទំនងជាមួយសិស្សស្របតាមទម្រង់វិធីសាស្ត្របង្រៀន និងខ្លឹមសារមេរៀន ដើម្បីជំរុញសិស្ស និស្សិតឱ្យចូលរួមសិក្សារៀនសូត្រតាមរយៈការលើកទឹកចិត្ត និងការយល់ចិត្ត គ្រប់គ្រងថ្នាក់រៀន ផ្តល់មតិកែលម្អ និងផ្តល់ព័ត៌មានត្រឡប់ ដើម្បីឱ្យថ្នាក់រៀនមានបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព និងភាពរស់រវើក។ ជំនាញទំនាក់ទំនងរបស់គ្រូ និងសិស្សអ្នកកាន់តែសកម្ម នោះការអនុវត្តការងារក្នុងថ្នាក់រៀនកាន់តែមានប្រសិទ្ធភាពខ្ពស់ ហើយការសិក្សារបស់សិស្សកាន់តែរីកចម្រើនក្នុងការសិក្សាបន្ថែមទៀត។ ការសិក្សាបានរកឃើញថា ភាពជោគជ័យរបស់សិស្ស គឺទាក់ទងដោយផ្ទាល់ទៅនឹងបរិយាកាសបង្រៀនរបស់គ្រូ និងការ

ចូលរួមរបស់សិស្ស។ លើសពីនេះទៀត វិធីសាស្ត្រដែលអ្នកប្រាស្រ័យទាក់ទងជាមួយសិស្សទទួលបានឥទ្ធិពលជាវិជ្ជមានតាមរយៈតួនាទីរបស់គ្រូនៅក្នុងថ្នាក់រៀន សាលារៀន និងសមត្ថភាពជំនាញ ព្រមទាំងការលើកទឹកចិត្តចំពោះសិស្សដើម្បីទទួលបានជោគជ័យ។

ដូចនេះ ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពរវាងគ្រូ និងសិស្ស គឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីអភិវឌ្ឍការសិក្សារបស់សិស្សតាមទ្រឹស្តីស្ថាបនានិយម។

៦២-ការប្រាស្រ័យទាក់ទងជាមួយមាតាបិតាសិស្ស

ជំនួបរវាងលោកគ្រូ អ្នកគ្រូ និងមាតាបិតាសិស្សអាចជួយគ្រូនិងមាតាបិតាអភិវឌ្ឍបានជោគជ័យនូវភាពជាដៃគូក្នុងការជួយសិស្សឱ្យសម្រេចបានជោគជ័យក្នុងការសិក្សា និងរស់នៅក្នុងសង្គម។ លោកគ្រូ អ្នកគ្រូតែងតែបង្ហាញនូវវិធីសាស្ត្របង្រៀន ការពង្រឹងវិន័យដល់សិស្ស និងគោលការណ៍ក្នុងថ្នាក់រៀនជូនដល់មាតាបិតាសិស្ស។ រីឯមាតាបិតាសិស្សវិញ គួរពិពណ៌នាពីសកម្មភាពរបស់កូនពេលចេញពីរៀន ទំនាក់ទំនងកូននិងក្រុមគ្រួសារ និងទម្លាប់របស់កូនចូលចិត្តធ្វើអ្វីនៅពេលទំនេរ ដើម្បីជាជំនួយឱ្យគ្រូបានដឹងជាប្រយោជន៍គឺធ្វើឱ្យគ្រូងាយស្រួលក្នុងការបង្រៀន។ ការបង្ហាញពីការយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនឱ្យគ្រូបានដឹងដោយមាតាបិតាពន្យល់គ្រូពីរបៀបតាមដាន និងការជួយកូនរបស់ខ្លួនពេលធ្វើលំហាត់នៅផ្ទះនិងការងារផ្សេងៗដែលគ្រូបានដាក់ឱ្យធ្វើការរីកចម្រើន និងចំណុចត្រូវកែតម្រូវ។ល។

ក្នុងនាមជាគ្រូបង្រៀន ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពជាមួយឪពុកម្តាយ គឺជាកត្តាសំខាន់ ដែលអាចកើតឡើងនៅគ្រប់មជ្ឈដ្ឋាន និងគ្រប់ទម្រង់រួមទាំងការហៅទូរសព្ទ អ៊ីមែល តេលេក្រាម បណ្តាញសង្គម និងការប្រជុំដោយផ្ទាល់តាមពាក្យសំដី និងសំណេរជាដើម។ ការពិភាក្សាជាមួយមាតាបិតាសិស្សលើប្រធានបទសើបមួយចំនួនដូចជាបញ្ហាអាកប្បកិរិយា បញ្ហានៃការសិក្សា ចំណុចខ្លាំង និងចំណុចខ្សោយ និងលទ្ធផលសិក្សារបស់សិស្ស។ ការផ្សារភ្ជាប់ទំនាក់ទំនងរវាងមាតាបិតាសិស្ស និងគ្រូបង្រៀនគឺជាចំណុចដ៏ល្អមួយ ដែលអាចឱ្យដឹងពីចំណុចល្អ ចំណុចខ្វះខាតរបស់កូនៗ និងជំរុញយ៉ាងណាឱ្យពួកគេទទួលបាននូវចំណេះដឹងកាន់តែប្រសើរ ក្រមសីលធម៌ និងសុជីវធម៌ល្អក្នុងការរស់នៅក្នុងសង្គម។ ការទទួលជោគជ័យក្នុងការអប់រំសិស្សមិនអាចពឹងផ្អែកតែលើសាលារៀនទាំងស្រុងនោះទេ គឺត្រូវទាមទារឱ្យមានការសហការយ៉ាសកម្ម និងយកចិត្តទុកដាក់ខ្ពស់ជាពិសេសតាមដានការសិក្សារបស់កូនៗពីសំណាក់មាតាបិតា និងអាណាព្យាបាលសិស្សគ្រប់រូបដោយមិនអាចខ្វះបាន។ ការចូលរួមរបស់មាតាបិតា អាណាព្យាបាលក្នុងការអប់រំជាកត្តាសំខាន់បំផុត និងទទួលបាននូវលទ្ធផលយ៉ាងល្អប្រសើរដូចជាសិស្សទទួលបានលទ្ធផលល្អក្នុងកាសិក្សា អត្រាការប្រឡងជាប់ខ្ពស់ ព្រមទាំងសិស្សទាំងអស់អាចជៀសឆ្ងាយពីគ្រឿងញៀន គ្រឿងស្រវឹង និងសកម្មភាពក្មេងទំនើងជាដើម។

មាតាបិតាសិស្សមានតួនាទីតាមដានការសិក្សារៀនសូត្ររបស់កូន

មាតាបិតា ឬអាណាព្យាបាលសិស្សត្រូវ៖

○ ជួយអប់រំកូន និងជំរុញឱ្យខំរៀនសូត្រដោយបង្កលក្ខណៈទាំងសម្ភារ និងពេលវេលាពិសេសកូនស្រី

○ ជួយតាមដាន និងជំរុញកូនឱ្យធ្វើកិច្ចការផ្ទះជាប្រចាំ ជួយតាមដាន និងផ្តល់ព័ត៌មានត្រឡប់លើលទ្ធផលសិក្សាក្នុងសៀវភៅតាមដានការសិក្សារបស់កុមារ ដែលគ្រួសារសិស្សទទួលបាន ពីសាលារៀន ជារៀងរាល់ខែ

- ○ ទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូ និងលោកនាយកសាលាឱ្យបានញឹកញាប់ដោយផ្ទាល់មាត់ ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា
- ○ ចូលរួមប្រជុំដើម្បីទទួលព័ត៌មានពីការសិក្សារបស់កូនចៅ
- ○ ជួយផ្តល់មតិយោបល់មានប្រយោជន៍ដល់សាលារៀនពិសេសជាមួយគណៈគ្រប់គ្រងសាលារៀន
- ○ ចូលរួមទស្សនកិច្ចសាលា និងជួយផ្តល់បទពិសោធនន៍ល្អៗយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ
- ○ ជួយឧបត្ថម្ភដល់កុមារជួបការលំបាក
- ○ ចូលរួមក្នុងពិធីចែករង្វាន់សិស្សពូកែ
- ○ ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងសីលធម៌/សុជីវធម៌ដល់កុមារ
- ○ ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កុមារ
- ○ តាមដានត្រួតពិនិត្យការសិក្សារបស់កូន នៅសាលារៀន និងជួយបង្រៀនកូននៅផ្ទះ
- ○ ជួយឧបត្ថម្ភ និងផ្តល់នូវមូលដ្ឋានសម្ភារ ដែលមាននៅក្នុងមូលដ្ឋាន ដើម្បីបម្រើដល់សកម្មភាពបង្រៀន និងរៀនដល់កុមារ (សម្ភារសម្រាប់ផលិតសម្ភារឧបទេស ... )។

៩៣-ការប្រាស្រ័យទាក់ទងជាមួយមិត្តរួមការងារ

ការបង្រៀនពុំមែនការងារឯករាជ្យនោះទេ តែត្រូវមានការសហការជាមួយសការីក្នុងអង្គភាព ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធការងារ។ បច្ចុប្បន្នភាពមិត្តរួមការងារក្នុងសាលាបានរួមចំណែកអភិវឌ្ឍសមត្ថភាពសិស្ស និងចែករំលែកបញ្ហាគន្លឹះអំពីរបៀបដោះស្រាយបញ្ហានៅក្នុងថ្នាក់រៀន។

ការប្រាស្រ័យទាក់ទងជាមួយសហការីក្នុងសាលារៀន គឺជាការសិក្សារៀនសូត្របំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក[65] ដែលមានដូចជា៖

○ ទទួលបានការបង្ហាត់បង្ហាញពីអ្នកគ្រប់គ្រង ឬមិត្តភ័ក្តរបស់អ្នកដែលមានទំនុកចិត្តលើរបៀបដែលអ្វីៗកំពុងដំណើរការនឹងជួយអ្នករៀនលើជំនាញបន្ថែមក្នុងការអនុវត្តការបង្រៀន និងរៀន។

- ○ ការសង្កេត និងកត់ចំណាំរបស់គ្រូផ្សេងទៀត ដែលជោគជ័យក្នុងការងារបង្រៀន និងរៀន។
- ○ អំពីការអនុវត្តល្អបំផុតរបស់ពួកគេ និងរបៀប ដែលពួកគេអាចយកឈ្នះលើបញ្ហាប្រឈមនានា។
- ○ សមាជិកភាពនៅក្នុងអង្គការវិជ្ជាជីវៈអាចបង្កើនជំនាញវិជ្ជាជីវៈរបស់អ្នក និងពង្រីកសមត្ថភាព

[65] Southeast Asia Teachers Competency Framework,2018, P.25.

ដែលទាក់ទងនឹងការងាររបស់អ្នកកាន់តែល្អ។ ការសួរសំណួរ គឺជាមធ្យោបាយដ៏ល្អមួយ ដើម្បីស្វែងយល់អំពីការងារក្នុងសាលា និងអ្នកពាក់ព័ន្ធ។

- ការពិភាក្សាពាក់ព័ន្ធនឹងការផ្លាស់ប្តូរគំនិត និងព័ត៌មានជាមួយគ្រូ និងបុគ្គលិកសាលាដទៃទៀត។
- មធ្យោបាយនៃការតភ្ជាប់បណ្តាញជាមួយអ្នកជំនាញផ្សេងទៀតមានន័យថា ការទាក់ទងជាមួយពួកគេតាមរយៈអ៊ីម៉ែល ទូរសព្ទ ការជួបទល់មុខគ្នា ឬការប្រជុំដោយអនឡាញ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងការផ្ញើសារ។

គ-យុទ្ធសាស្ត្រសម្រាប់ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពក្នុងថ្នាក់រៀន



រូបភាពទី១២៖ ការប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការបង្រៀន និងរៀន

ការណែនាំជាយុទ្ធសាស្ត្រចំនួន៨ ដែលអាចអនុវត្តចំពោះបរិបទនីមួយៗក្នុងថ្នាក់រៀន

១-បង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពដោយមានទំនាក់ទំនងគាំទ្ររវាងសិស្ស និងគ្រូមានឥទ្ធិពលវិជ្ជមានទៅលើការចូលរួមក្នុងថ្នាក់ និងសមិទ្ធផលរបស់សិស្ស។ សិស្សមានអារម្មណ៍ថា មានការគាំទ្រ ពួកគេកាន់តែមានផាសុកភាពក្នុងការបញ្ចេញគំនិតនៅក្នុងការពិភាក្សាក្នុងថ្នាក់ ការព្យាយាមចូលរួមកាន់តែខ្ពស់នាំឱ្យចំណេះដឹងកាន់តែរីកចម្រើន និងសមិទ្ធផលកាន់តែច្រើន។

២-ការងារជាក្រុម

ការងារជាក្រុម និងការពិភាក្សាជាក្រុមបានរួមចំណែកធ្វើឱ្យថ្នាក់រៀនមានបរិយាកាសកាន់តែមានសភាពរស់រវើកតាមរយៈជាក្រុមតូច និងក្រុមធំ។ សិស្សអាចចែករំលែកគំនិតរបស់ពួកគេកាន់តែងាយស្រួល និងបង្កើនជំនាញទំនាក់ទំនងផ្ទាល់ខ្លួនរបស់ពួកគេ។ សកម្មភាពទាំងនេះក៏ផ្តល់ឱ្យពួកគេនូវឱកាសដ៏ល្អក្នុងការសួរសំណួរ និងទទួលបានមតិកែលម្អលើការងាររបស់ពួកគេ ដែលនាំឱ្យមានការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងការយល់ដឹងកាន់តែប្រសើរឡើងអំពីមេរៀន និងអត្ថប្រយោជន៍សិក្សា។

៣-ភាសាកាយវិការ

ការប្រាស្រ័យទាក់ទងមិនត្រឹមតែជាពាក្យសំដីប៉ុណ្ណោះទេ ប៉ុន្តែអាចប្រើប្រាស់ភាសាកាយវិការជាសញ្ញាសម្រាប់ទំនាក់ទំនងជាវិជ្ជមាន ប្រកបដោយទំនុកចិត្ត និងការចូលរួម។ ជាឧទាហរណ៍ ការទំនាក់ទំនងភ្នែកជាមួយសិស្សនៅពេលអ្នកកំពុងនិយាយបានបង្ហាញថា អ្នកកំពុងត្រូវបានសិស្សគាំទ្រ និងយកចិត្តទុកដាក់ស្តាប់។ ការទំនាក់ទំនងដោយប្រើក្រសែភ្នែក គឺជារឿងសំខាន់មួយ ដែលបង្ហាញប្រាប់ដល់សិស្សក្នុងថ្នាក់ទាំងមូលឱ្យយកចិត្តទុកដាក់ និងជំរុញពួកគេឱ្យខិតខំសិក្សារៀន។ នៅពេលអ្នកបង្រៀន អ្នកគួរតែប្រើកាយវិការដូចជា ស្នាមញញឹម ងក់ក្បាល និងលើកមេដៃឡើង ដើម្បីលើកទឹកចិត្តដល់សិស្សនៅពេលពួកគេចូលរួម។

៤-ការស្តាប់សកម្ម

សមត្ថភាពនៃការស្តាប់ គឺជាបំណិនប្រាស្រ័យទាក់ទងមួយមិនគួរត្រូវបានមើលរំលងឡើយពោលគឺមនុស្សប្រមាណ៦០%នៃការយល់ច្រឡំបណ្តាលមកពីការស្តាប់គ្នាមិនសូវច្បាស់។

ការស្តាប់សកម្ម គឺជាបំណិនស្តាប់ ដើម្បីបង្កើនការយល់ដឹង និងទំនាក់ទំនងល្អរវាងអ្នកស្តាប់ និងអ្នកនិយាយ។ អ្នកស្តាប់សកម្មត្រូវយកចិត្តទុកដាក់ស្តាប់អ្នកនិយាយឱ្យបានល្អទាំងភាសានិយាយ និងភាសា កាយវិការ បន្ទាប់មកសង្ខេប ឬនិយាយឡើងវិញនូវចំណុចសំខាន់ៗ នៃសាររបស់អ្នកនិយាយ ។

គោលបំណងនៃការស្តាប់សកម្មគឺៈ

- លើកទឹកចិត្តអ្នកនិយាយ
- លើកកម្ពស់ការទុកចិត្ត និងការគោរពទៅវិញទៅមក
- ជួយឱ្យអ្នកស្តាប់ទទួលព័ត៌មានបានល្អ និងគ្រប់ជ្រុងជ្រោយ
- លើកកម្ពស់ទំនាក់ទំនង
- ដោះស្រាយបញ្ហាបានកាន់តែប្រសើរ
- ទទួលបានការសហការល្អ
- លើកកម្ពស់ការយល់ត្តគ្នា ។

ការស្តាប់បានល្អនៅក្នុងថ្នាក់រៀន អាចផ្តល់អត្ថប្រយោជន៍ដល់អ្នកតាមវិធី២យ៉ាងគឺៈ

ទី១-អ្នកនឹងក្លាយជាគំរូល្អសម្រាប់សិស្សក្នុងថ្នាក់ ដែលនឹងបង្កើនជំនាញស្តាប់របស់សិស្សក្នុងការសិក្សាមេរៀនប្រចាំថ្ងៃបានប្រសើរជាងមុន។

ទី២-ដោយប្រើការស្តាប់សកម្ម អ្នកអាចកែតម្រូវការយល់ច្រឡំ និងពង្រីកការរៀនសូត្រ ដែលនាំឱ្យការអប់រំកាន់តែប្រសើរឡើង។

៥-ការផ្តល់ព័ត៌មានត្រឡប់

ការផ្តល់ព័ត៌មានត្រឡប់ គឺការទទួលស្គាល់ភាពវិជ្ជមាននៃការងារដែលសិស្ស និស្សិតអនុវត្តបានល្អ ឬការកែលម្អតាមបែបស្ថាបនាទៅលើបំណិន ឬកិច្ចការដែលបំពេញមិនទាន់បានល្អ[66]។ ការផ្តល់ព័ត៌មានត្រឡប់គឺជាការផ្តល់ឱ្យនូវចំណុចល្អ ចំណុចខ្វះខាត និងអនុសាសន៍ ដោយគ្រូប្រចាំថ្នាក់ ឬគ្រូឧទ្ទេសអំពីទិដ្ឋភាពនៃការអនុវត្តការងារ ឬការយល់ដឹងរបស់អ្នកណាម្នាក់។ ការផ្តល់ព័ត៌មានត្រឡប់ គឺជាការផ្តល់នូវព័ត៌មានជាក់លាក់អំពីឥរិយាបថនរណាម្នាក់ ដើម្បីដឹងថា គួរបន្តរក្សាឥរិយាបថមិនល្អ ឬក៏ត្រូវផ្លាស់ប្តូរចេញ

លោកPartner(២០០៣)ការផ្តល់ព័ត៌មានត្រឡប់ត្រូវគោរពនូវគោលការណ៍ដូចខាងក្រោម៖

- គោរពគ្នាទៅវិញទៅមកទាំងពាក្យសំដី និងសកម្មភាព
- និយាយក្នុងនាមខ្លួនយើងផ្ទាល់ជាអ្នកផ្តល់ព័ត៌មានត្រឡប់ដោយជាក់លាក់ និងស្មោះត្រង់
- និយាយពីអ្វី ដែលកើតឡើងក្នុងពេលបច្ចុប្បន្ន(ការបង្រៀនថ្មីៗ) មិននិយាយពីអ្វីដែលបានកើតឡើងតាំងពីយូរមកហើយនោះទ
- រក្សាទុកជាការសម្ងាត់នូវអ្វីដែលបានពិភាក្សា គឺសម្រាប់តែអ្នកផ្តល់ព័ត៌មានត្រឡប់ និងកម្មសិក្សាយកចិត្តទុកដាក់ខ្លាំង លើការរៀនសូត្រជាមួយគ្នាអំពីការបង្រៀន និងរៀន ។

ដូចនេះ ការផ្តល់មតិត្រឡប់ គឺជាធាតុផ្សំដ៏សំខាន់នៃការទំនាក់ទំនងគ្រូ និងសិស្សនៅក្នុងថ្នាក់រៀន។ ការសិក្សាជាច្រើនបានផ្តោតលើមតិកែលម្អ បង្កើនទំនុកចិត្តដល់សិស្ស និងជួយបង្កើតបរិយាកាសគាំទ្រ និងបង្កើនភាពជោគជ័យក្នុងការសិក្សា។

៦-អារម្មណ៍នៃការលេងសើច

ការប្រើពាក្យកំប្លែងក្នុងថ្នាក់ត្រូវបានរកឃើញថា ដើម្បីបង្កើនការរៀនសូត្រ ការលើកទឹកចិត្តខ្លួនឯង និងទំនាក់ទំនងជាវិជ្ជមានរវាងសិស្ស និងគ្រូ និងបង្កើតទំនាក់ទំនងជាមួយថ្នាក់រៀនរបស់អ្នក ហើយធ្វើឱ្យពួកគេចាប់អារម្មណ៍ក្នុងមេរៀន។ ជាឧទាហរណ៍អ្នកអាចនិយាយរឿងកំប្លែង ឬរឿងកំប្លែងខ្លីៗផ្តល់ជាឧទាហរណ៍ផ្ទាល់ខ្លួន ដើម្បីបានសើចសប្បាយក្នុងថ្នាក់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកគួរតែធានាថា អ្នកមិនប្រើការលេងសើចអវិជ្ជមានដូចជា ការបង្អាប់ ឬធ្វើឱ្យអាម៉ាស់ដល់សិស្ស ឬការលេងសើចដែលមិនទាក់ទងនឹងមេរៀន ការរំខាន ហិង្សា ផ្លូវភេទ ឬការបង្ខំ។

ដូចនេះ ទំនាក់ទំនងដើម្បីទាក់ទាញអារម្មណ៍សិស្សគឺបង្កើតជាមធ្យោបាយកំប្លែងដែលទាក់ទងការអប់រំ មេរៀន និងជីវភាពប្រចាំថ្ងៃ។

៧-ជំនាញបច្ចេកទេស

ការប្រើប្រាស់ជំនួយការបង្រៀនថ្មីៗដូចជាកុំព្យូទ័រ វីដេអូ និងធនធានអនឡាញ គឺជាវិធីមួយផ្សេងទៀត ដើម្បីរក្សាសិស្សឱ្យចូលរួម និងពង្រឹងការយល់ដឹងរបស់ពួកគេ និងបង្កើនប្រសិទ្ធភាពនៃការប្រាស្រ័យ

---

[66] អ.យ.ក, បំណិនផ្តល់ព័ត៌មានត្រឡប់,នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ឆ្នាំ២០១៦, ទំ.៦។

ទាក់ទងរបស់អ្នកជាមួយសិស្ស ដែលមានទម្រង់សិក្សាខុសៗគ្នា ហើយអាចទទួលបានអត្ថប្រយោជន៍ច្រើនពីធនធានលើអ៊ិនធឺណែតជាជាងការបរិយាយច្រើន។

៨-ភាពច្បាស់លាស់របស់គ្រូ

ការប្រាស្រ័យទាក់ទងល្អ និងការបង្រៀនល្អ គឺគ្រូបង្រៀនគួរតែមានភាពច្បាស់លាស់ក្នុងការបង្រៀន និងរៀនតាមរយៈការគោរពម៉ោងបង្រៀន និងខ្លឹមសារមេរៀន។ គ្រូបង្រៀនជាអ្នកសាបព្រោះចំណេះដឹង និងលើកកម្ពស់គុណភាពអប់រំនៅក្នុងសង្គម ហើយគ្រូបង្រៀនចេះប្រើប្រាស់ចំណេះដឹង ដើម្បីបង្កើនគុណភាពបង្រៀន បង្កើតបរិយាកាសអំណោយផលសម្រាប់ការសិក្សា ប្រើវិធីសាស្ត្របង្រៀនសមស្របដើម្បីកែលម្អលទ្ធផលសិក្សាសិស្សប្រសើរជាងមុន និងលើកកម្ពស់គុណភាពនៃប្រព័ន្ធអប់រំ ដើម្បីមនុស្សជាតិទាំងមូល។ គ្រូបង្រៀនជាគំរូទាំងចំណេះដឹង និងសីលធម៌រស់នៅក្នុងការរស់នៅ។ បើគ្រូបង្រៀនប្រកាន់នូវភាពច្បាស់លាស់ នោះវានឹងក្លាយជាគំរូល្អសម្រាប់សិស្សគ្រប់ជំនាន់។

**៥-៣-៤-កិច្ចសហប្រតិបត្តិការ** ( Collaboration )

កិច្ចសហប្រតិបត្តិការ គឺជាភាពជាដៃគូ សហជីពមួយ សកម្មភាពផលិត ឬបង្កើតអ្វីមួយរួមគ្នា។ ការសហការគ្នាអាចកើតឡើងរវាងមនុស្សពីរនាក់ ឬមនុស្សជាច្រើន មនុស្សចម្លែក ឬមិត្តល្អបំផុត ដើម្បីសហការគ្នា គឺត្រូវប្តេជ្ញាចំពោះលទ្ធភាពនៃការផលិតលទ្ធផលធំជាងមួយដែលនឹងត្រូវបានបង្កើតឡើងនៅក្នុងកិច្ចសហការក្នុងបរិបទនៃសតវត្សរ៍ទី២១ទាមទារសមត្ថភាពក្នុងការធ្វើការជាក្រុម និងរួមចំណែកដល់ការរៀនសូត្ររបស់អ្នកដទៃ ប្រើប្រាស់ជំនាញបណ្តាញសង្គម និងបង្ហាញពីការយល់ចិត្តក្នុងការធ្វើការជាមួយអ្នកដទៃចម្រុះ។ កិច្ចសហការក៏តម្រូវឱ្យសិស្សអភិវឌ្ឍបញ្ញាសមូហភាព និងបង្កើតអត្ថន័យរួមគ្នាក្លាយជាអ្នកបង្កើតខ្លឹមសារក៏ដូចជាអ្នកប្រើប្រាស់ផងដែរ។ ជំនាញ និងចំណេះដឹងថ្មីគឺចាំបាច់ដើម្បីឱ្យសមាជិកក្រុមអាចសហការគ្នាជាលក្ខណៈឌីជីថល និងរួមចំណែកដល់មូលដ្ឋានចំណេះដឹងរួមមិនថាធ្វើការពីចម្ងាយ ឬក្នុងកន្លែងចែករំលែក។

ការសហការគ្នាមិនត្រឹមតែមានសារៈសំខាន់សម្រាប់ដំណើរការនៃស្ថាប័នរបស់អ្នកតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់អត្ថប្រយោជន៍បន្ថែមមួយចំនួនទៀត។ ដំណើរការសិក្សារួមគ្នា គឺជាដំណើរការ ដែលសិស្សនៅផ្សេងៗគ្នាកម្រិតនៃការអនុវត្តធ្វើការរួមគ្នាជាក្រុមតូចៗឆ្ពោះទៅរកគោលដៅរួម គឺជាការផ្តោតលើអ្នកសិក្សាវិធីសាស្ត្រ ដែលបានមកពីទ្រឹស្តីសិក្សាសង្គមផងដែរ។ ជាទស្សនវិស័យសង្គមស្ថាបនាលើការរៀនសូត្រ។

ការរៀនរួមគ្នា គឺជាទំនាក់ទំនងរវាងអ្នកសិក្សាដែលជំរុញឱ្យមានការពឹងផ្អែកគ្នាទៅវិញទៅមកជាវិជ្ជមាន បុគ្គលគណនេយ្យភាព និងជំនាញអន្តរបុគ្គលសម្រាប់ការរៀនសហការគ្នាឱ្យមានប្រសិទ្ធភាព ការបង្រៀនត្រូវតែមានចាត់ទុកថាជាដំណើរការនៃការអភិវឌ្ឍន៍ និងពង្រឹងសមត្ថភាពរៀនរបស់សិស្ស។ តួនាទីរបស់គ្រូគឺមិនត្រូវបញ្ជូនព័ត៌មាន ប៉ុន្តែបម្រើជាអ្នកសម្របសម្រួលសម្រាប់ការរៀន។ នេះពាក់ព័ន្ធនឹងការ

បង្កើត និងការគ្រប់គ្រងបទពិសោធន៍សិក្សាដ៏មានអត្ថន័យ និងជំរុញទឹកចិត្តការគិតរបស់សិស្សតាមរយៈបញ្ហាក្នុងពិភពពិត។ ពេលខ្លះ ការសហការ និងសហការការសិក្សាត្រូវបានគេប្រើជំនួសគ្នា ប៉ុន្តែមានការសហការការងារជាធម្មតាពាក់ព័ន្ធនឹងការបែងចែកការងារក្នុងចំណោមក្រុមសមាជិក ខណៈពេលដែលការងារសហការមានន័យថាក្រុមទាំងអស់។សមាជិកដោះស្រាយបញ្ហារួមគ្នាក្នុងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល។ កិច្ចសហការត្រូវបានរួមបញ្ចូលក្នុងចំណោម សមត្ថភាព និងជំនាញសតវត្សរ៍ទី២១[67]។




រូបភាពទី១៣៖ សិស្សប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការរៀន

ក-ជំនាញសហការក្នុងការបង្រៀន

ជំនាញសហការគឺជាវិធីជាក់លាក់មួយ ដែលសិស្សត្រូវបានរំពឹងថា នឹងមានឥរិយាបថដើម្បីសម្រេចបាននូវបទដ្ឋានថ្នាក់។ ការសហការរបស់គ្រួមមានការជជែកពិភាក្សា ការធ្វើផែនការ និងការដោះស្រាយបញ្ហារួមគ្នា ការសាកសួររួមគ្នា ប្រើប្រាស់ភស្តុតាង និងការស្រាវជ្រាវ ដើម្បីណែនាំការសម្រេចចិត្តប្រើកម្លាំងរួមគ្នាទៅវិញទៅមក។

គោលបំណងនៃកិច្ចសហការគឺ៖

១-ចែករំលែកចំណេះដឹងក្នុងចំណោមគ្រូ និងសិស្ស

នៅក្នុងថ្នាក់រៀនបែបប្រពៃណីពាក្យប្រៀបធៀបលេចធ្លោសម្រាប់ការបង្រៀន គឺគ្រូជាអ្នកផ្តល់ព័ត៌មាន។ ចំណេះដឹងហូរចេញតែមួយផ្លូវពីគ្រូទៅសិស្ស។ ផ្ទុយទៅវិញ ពាក្យប្រៀបធៀបសម្រាប់ថ្នាក់រៀនសហការ គឺជាការចែករំលែកចំណេះដឹង។ គ្រូមានចំណេះដឹងសំខាន់ៗអំពីខ្លឹមសារ ជំនាញ និងការណែនាំ ហើយនៅតែផ្តល់ព័ត៌មាននោះដល់សិស្ស។ ទោះជាយ៉ាងណាក៏ដោយ គ្រូដែលសហការគ្នាក៏ផ្តល់តម្លៃ និង

[67] UNESCO, Op.cit, P.13.

កសាងលើចំណេះដឹង បទពិសោធន៍ផ្ទាល់ខ្លួន ភាសា យុទ្ធសាស្ត្រ និងវប្បធម៌ដែលសិស្សនាំយកមកក្នុងស្ថានភាពសិក្សា។

២-ការចែករំលែកសិទ្ធិអំណាចក្នុងចំណោមគ្រូ និងសិស្ស

នៅក្នុងថ្នាក់រៀនដែលសហការគ្នា គ្រូបង្រៀនចែករំលែកសិទ្ធិអំណាចជាមួយសិស្សតាមរបៀបជាក់លាក់។ នៅក្នុងថ្នាក់រៀនតាមបែបប្រពៃណីភាគច្រើន គ្រូបង្រៀនពុំមានទទួលខុសត្រូវក្នុងការកំណត់គោលដៅ រចនាកិច្ចការសិក្សា និងវាយតម្លៃអ្វីដែលបានរៀន។ គ្រូដែលសហការគ្នាខុសគ្នាត្រង់ថា ពួកគេអញ្ជើញសិស្សឱ្យកំណត់គោលដៅជាក់លាក់ក្នុងក្របខណ្ឌនៃអ្វីដែលកំពុងបង្រៀន ផ្តល់ជម្រើសសម្រាប់សកម្មភាព និងកិច្ចការដែលចាប់យកចំណាប់អារម្មណ៍ និងគោលដៅផ្សេងៗរបស់សិស្ស និងលើកទឹកចិត្តសិស្សឱ្យវាយតម្លៃអ្វីដែលពួកគេរៀន។ គ្រូបង្រៀនដែលសហការគ្នាលើកទឹកចិត្តសិស្សឱ្យប្រើប្រាស់ចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគេ ធានាថាសិស្សចែករំលែកចំណេះដឹង និងយុទ្ធសាស្ត្រសិក្សារបស់ពួកគេ ប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយការគោរព និងផ្តោតលើកម្រិតខ្ពស់នៃការយល់ដឹង។ ពួកគេជួយសិស្សឱ្យស្តាប់យោបល់ចម្រុះ គាំទ្រការទាមទារចំណេះដឹងជាមួយនឹងភស្តុតាងចូលរួមក្នុងការគិតប្រកបដោយការរិះគន់ និងប្រកបដោយភាពច្នៃប្រឌិត និងចូលរួមក្នុងការសន្ទនាបើកចំហ និងមានអត្ថន័យ។ ចំណុចសំខាន់នៅទីនេះមានពីរយ៉ាងគឺ(១) សិស្សមានឱកាសសួរ និងស៊ើបអង្កេតសំណួរដែលចាប់អារម្មណ៍ផ្ទាល់ខ្លួន និង (២) ពួកគេមានសំឡេងក្នុងដំណើរការធ្វើការសម្រេចចិត្ត ហើយឱកាសទាំងនេះមានសារៈសំខាន់សម្រាប់ទាំងការរៀនគ្រប់គ្រងដោយខ្លួនឯង និងការលើកទឹកចិត្ត។

៣-គ្រូបង្រៀនជាអ្នកសម្របសម្រួល

ដោយសារចំណេះដឹង និងសិទ្ធិអំណាចត្រូវបានចែករំលែកក្នុងចំណោមគ្រូបង្រៀន និងសិស្ស។ តួនាទីរបស់គ្រូកាន់តែសង្កត់ធ្ងន់ទៅលើការរៀនសម្របសម្រួល។ ការសម្រុះសម្រួលដោយជោគជ័យជួយសិស្សភ្ជាប់ព័ត៌មានថ្មីទៅនឹងបទពិសោធន៍របស់ពួកគេ និងដើម្បីសិក្សាផ្នែកផ្សេងទៀត ជួយសិស្សឱ្យដឹងអំពីអ្វីដែលត្រូវធ្វើនៅពេលពួកគេជាប់គាំង និងជួយពួកគេឱ្យរៀនពីរបៀបរៀន។ លើសពីនេះទៅទៀត គ្រូដែលជាអ្នកសម្របសម្រួលកម្រិតនៃព័ត៌មាន និងការគាំទ្រ ដើម្បីបង្កើនសមត្ថភាពក្នុងការទទួលខុសត្រូវក្នុងការសិក្សា។

៤-ការរៀបចំថ្នាក់របស់សិស្សពុំមានភាពទៀងទាត់

ទស្សនវិស័យ បទពិសោធន៍ និងប្រវត្តិរបស់សិស្សទាំងអស់មានសារៈសំខាន់សម្រាប់ការពង្រឹងការសិក្សានៅក្នុងថ្នាក់រៀន។ ដោយសារចំនួនសិស្សរៀនលើសពីថ្នាក់រៀន ដែលទាមទារឱ្យមានការយល់ឃើញពីទស្សនៈចម្រុះ នោះចាំបាច់ណាស់ក្នុងការផ្តល់ឱកាសដល់សិស្ស ដើម្បីធ្វើកិច្ចការរួមគ្នាក្នុងបរិបទជាច្រើននៅក្នុងសាលារៀន។ ថ្នាក់រៀនសហការគឺសិស្សចូលរួមក្នុងសកម្មភាពគិត ពិភាក្សា សួរដេញដោលក្នុងក្រុម

តូច ក្រុមធំ និងថ្នាក់រៀនទាំងមូល ហើយគ្មានសិស្សណាម្នាក់ត្រូវបានដកហូតឱកាសក្នុងការរួមចំណែកសិក្សារៀនសូត្រជាមួយអ្នកដទៃឡើយ។

### ៥.៤.ភាពចម្រុះនៃការរៀន និងបង្រៀន

#### ៥-៤-១-បញ្ញត្តិភាពចម្រុះនៃការរៀន និងបង្រៀន

បញ្ញត្តិនៃការរៀនបែបចម្រុះ(Blended learning) គឺជាការរៀនបែបកូនកាត់(hybrid learning) ដោយផ្អែកតាមប្រព័ន្ធបច្ចេកវិទ្យា។ ការរៀន និងបង្រៀនបែបនេះធ្វើឱ្យកាន់ប្រសើរឡើងតាមរយៈប្រព័ន្ធគេហទំព័រ ដែលអាចបង្រៀនបានគ្រប់ទីកន្លែង និងស្ថានភាព។ បញ្ញត្តិនៃការរៀនបែបចម្រុះ(Blended learning) ដំបូងឡើយមានភាពមិនច្បាស់លាស់ដោយរួមបញ្ចូលនូវបច្ចេកវិទ្យា និងវិធីសាស្ត្រគរុកោសល្យជាច្រើននៅក្នុងបន្សំផ្សេងៗគ្នា។ ក្នុងឆ្នាំ២០០៦បញ្ញត្តិនេះកាន់តែមានភាពច្បាស់លាស់ជាមួយការបោះពុម្ពសៀវភៅណែនាំជាលើកដំបូងរបស់លោកក្រាហាម(Graham)។ លោកបានពន្យល់យ៉ាងទូលាយអំពីនិយមន័យ និងកំណត់បានពីប្រព័ន្ធនៃការរៀនបែបចម្រុះជាប្រព័ន្ធសិក្សាដែលរួមបញ្ចូលគ្នានូវការបង្រៀនទល់មុខ និងការបង្រៀនពីចម្ងាយ (The computer is classroom)។ ការរៀន និងរៀនតាមបែបចម្រុះតម្រូវឱ្យមានសម្ភារបង្រៀនទាំងគ្រូ និងសិស្ស និងជាគុសំខាន់មួយចំនួនទៀតនៃការគ្រប់គ្រងសិស្សលើពេលវេលា ទីកន្លែង និងល្បឿនអ៊ិនធើណែត។ ទោះបីជាសិស្សនៅតែបន្តការចូលរៀននៅសាលារៀនជាបន្តបន្ទាប់ ដែលមានវត្តមានគ្រូបង្រៀនធ្វើសកម្មភាពបង្រៀនទល់មុខគ្នាជាមួយសិស្សរួមជាមួយសម្ភារបង្រៀនដូចជាកុំព្យូទ័រ ស្លាយ LCD ខ្លឹមសារមេរៀនជាដើម ហើយគ្រូបង្រៀនត្រូវមានកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីឆ្លើយតបនឹងស្ថានភាពថ្មីនេះ។




រូបភាពទី១៤៖ ការអប់រំតាមបែបឌីជីថល គឺសិស្សអាចរៀនបានគ្រប់ទីកន្លែង។

ការអប់រំឌីជីថល(Digital Education) គឺជាការប្រើប្រាស់ប្រកបដោយនវានុវត្តន៍នៃឧបករណ៍ និងបច្ចេកវិទ្យាឌីជីថលក្នុងការបង្រៀន និងរៀនដូចជា ការគ្រប់គ្រងការបង្រៀន និងការរៀន។ ការអប់រំឌីជីថលក្នុងបរិបទឧស្សាហកម្ម៤.០ មានសារៈសំខាន់សម្រាប់កម្ពុជាក្នុងការបោះជំហានឱ្យក្លាយជាប្រទេសមានសេដ្ឋកិច្ចឌីជីថល និងរដ្ឋាភិបាលឌីជីថលព្រោះផ្នែកទាំងអស់នេះត្រូវការអ្នកជំនាញជាច្រើនដើម្បីបំពេញការងារ និងគ្រប់គ្រងប្រព័ន្ធឆ្លាតវៃទាំងអស់។

ការអប់រំបច្ចេកវិទ្យាឌីជីថល គឺជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងឧបករណ៍ក្នុងការច្នៃប្រឌិតសម្រាប់ការបង្រៀន និងរៀន។ ការអប់រំតាមបែបឌីជីថលអាចឱ្យសិស្សរៀនបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

- ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក(E-Learning) ជាប្រព័ន្ធនៃការអប់រំតាមបែបឌីជីថលមួយបែបដែលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ និងប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ។
- ការអប់រំពីចម្ងាយ (Distance Leaming) ជាវិធីសាស្ត្រមួយ ដែលសិស្សអាចទទួលបានការអប់រំសម្រាប់ការអភិវឌ្ឍសម្បទាទាំង៤ (ពុទ្ធិសម្បទា បំណិនសម្បទា កាយសម្បទា និងចរិយាសម្បទា) ដោយពុំចាំបាច់មានវត្តមាននៅសាលារៀន ឬជួបជាមួយគ្រូដោយផ្ទាល់។
- គ្រឹះស្ថានសិក្សាមួយចំនួនផ្សារភ្ជាប់កម្មវិធី «ការអប់រំពីចម្ងាយ» ជាមួយនឹង «ប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ»(Blended Learning) ឬដែលផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)។
- ផ្អែកលើបទពិសោធន៍នៃការអប់រំតាមប្រព័ន្ធអេឡិចត្រូនិកនាពេលកន្លងមក និងផ្អែកលើតម្រូវការសម្រាប់បន្តអនុវត្តនៅពេលអនាគត ក្រសួងនឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយមានសមាសភាគចំនួន៤រួមមាន៖
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យនៃការអប់រំឌីជីថល ដោយផ្តោតលើការរៀបចំបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Data Center)។
- សកម្មភាពផលិតវីដេអូនៃការបង្រៀន ដោយរួមបញ្ចូលនូវការបញ្ជ្រាបវិធីសាស្ត្របង្រៀនបែបថ្មីនិងការឆ្លើយតបចំពោះការអប់រំបរិយាបន្ន(ការអប់រំពិសេស)។
- ហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផលិតវីដេអូនៃការបង្រៀន ដោយផ្តោតលើការបង្កើតស្ទូឌីយូសម្រាប់
- ផលិតវីដេអូបង្រៀន និងមាតិកាឌីជីថលដទៃ និងស្ទូឌីយូខ្នាតធំសម្រាប់វេទិកាអប់រំ។
- វេទិកាឌីជីថលសម្រាប់ការអប់រំ តាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្តោតលើការរៀបចំបង្កើត App និង Website សម្រាប់ការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធគ្រប់គ្រងការសិក្សា ដោយផ្អែកលើបរិបទនៃការអប់រំនៅកម្ពុជា។




រូបភាពទី១៥(មជ្ឈមណ្ឌលសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ ថ្ងៃទី២២ មិថុនា ២០២០)

## ៥-៤-២-ការរៀនពីចម្ងាយក្នុងបរិបទកូវីដ-១៩

យោងតាមប្រពន្ធ័អេឡិចត្រូនិក និងកម្មវិធីពេញនិយមក្នុងការគាំទ្រការបង្រៀននិងរៀពីចម្ងាយដែលមានដូចជា៖

(១) Zoom Video Communication ងាយស្រួលក្នុងការចែកបន្តសម្រាប់សមាជិកច្រើន ឯកសារភ្ជាប់មានទម្រង់ច្រើន សំឡេង វីដេអូ រូបភាពផ្សេងៗ អាចចែករំលែកបទបង្ហាញផ្ទាល់ និងអាចរក្សាទុកជាវីដេអូពីការប្រជុំ។

(២) ការប្រើប្រាស់កម្មវិធីSkype ឥតបង់ថ្លៃ ងាយស្រួលក្នុងការចែកបន្តរសម្រាប់សមាជិកច្រើន ឯកសារភ្ជាប់មានទម្រង់ច្រើន សំឡេង វីដេអូ រូបភាពផ្សេង

(៣) កម្មវិធី YouTube ឥតបង់ថ្លៃប្រើជាប្រភពព័ត៌មានបន្ថែម អាចចូលទស្សនាដោយមិនមានកំណត់ ផ្តល់ជម្រើសច្រើនលើខ្លឹមសារតែមួយត្រូវការទំហំទិន្ន័យកម្រិតទាប។

(៤) កម្មវិធី Telegram ឥតបង់ថ្លៃ និងងាយស្រួលក្នុងការចែកបន្តសម្រាប់សមាជិកច្រើន ឯកសារភ្ជាប់មានទម្រង់ច្រើន សំឡេង វីដេអូ រូបភាពផ្សេងៗ អាចរក្សាទុកបានច្រើន។

(៥) កម្មវិធី Facebook ឥតបង់ថ្លៃងាយស្រួលក្នុងការចែកបន្តរសម្រាប់សមាជិកច្រើន ឯកសារភ្ជាប់មានទម្រង់ច្រើនសំឡេងវីដេអូ រូបភាពផ្សេងៗ អាចបញ្ចូលសៀវភៅក្នុងទម្រង់រូបភាព ងាយស្រួលក្នុងការអាន និងសួរ-ឆ្លើយ។

(៦) ការប្រើប្រាស់កម្មវិធីGoogle Classroom ងាយស្រួលប្រើប្រាស់អាចប្រើលើឧបករណ៍អេឡិចត្រូនិច (Computer ,smartphone, tablet) ងាយស្រួលក្នុងការចែករំលែក សុវត្ថិភាពក្នុងការប្រើប្រាស់ផ្ទុកឯកសារក្នុងប្រព័ន្ធ Cloud។

(៧) កម្មវិធី Microsoft Teams អាចវីដេអូ Call ដូចកម្មវិធី Zoom ដែរ ហើយក៏មានមុខងារថតរក្សាវីដេអូទុកដែរ និងយើងអាចធ្វើការ Share Screen សម្រាប់ធ្វើការបង្រៀន ឬក៏ការធ្វើបទបង្ហាញរបស់សាស្ត្រចារ្យនិងសិស្សមានភាពងាយស្រួលក្នុងការរៀនពីចម្ងាយ ងាយស្រួលក្នុងការដាក់កិច្ចការងារឱ្យសិស្ស និងងាយស្រួលក្នុងការកែកិច្ចការដែលសិស្សបានធ្វើងាយស្រួលក្នុងការស្រង់ពិន្ទុ(Grade)។




រូបភាពទី១៦៖ប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

### ៤-៤-៣-ប្រភេទនៃការរៀនបែបចម្រុះ

- បើតាមការសិក្សារបស់ Prestwick House ការរៀនតាមបែបចម្រុះ គឺជាការរួមបញ្ចូលគ្នានៃវិធីសាស្ត្របង្រៀនតាមបែបប្រពៃណីបង្រៀនទល់មុខគ្នាក្នុងថ្នាក់ និងការបង្រៀនតាមអ៊ិនធើណែត។ ការរៀនតាមបែបចម្រុះពឹងផ្អែកលើបច្ចេកវិទ្យា ដើម្បីគាំទ្រដល់ការរៀនសូត្ររបស់សិស្សតាមរយៈធនធានអនឡាញដូចជា សៀវភៅសិក្សា ឬវីដេអូ ឬដោយការប្រើឧបករណ៍អប់រំឌីជីថលដូចជា Google Classroom ឬ Quizlet ជាដើមការរៀនតាមបែបចម្រុះ(Blended Learning) រួមមាន[68]៖

ទី១-ការបង្រៀនបែបប្រពៃណីទល់មុខគ្នារវាងគ្រូ និងសិស្សនៅដដែលមិនមានអ្វីផ្លាស់ប្តូរទេ។

ទី២-ការផ្តល់មេរៀនបែបឌីជីថលដូចជាវីដេអូអប់រំដែលបានថតទុក និងសៀវភៅអេឡិចត្រូនិក

[68] https://thmeythmey.com

(សៀវភៅឌីជីថល)សិស្សអាចទាញយក (Download) ទុកក្នុងកុំព្យូទ័រ ទូសព្ទដៃ ឬថេបប្លេត(Tablet) សម្រាប់មើល អាន និងរៀនដោយខ្លួនឯង។

ទី៣-ការបង្រៀនតាមប្រព័ន្ធអនឡាញ និងពីចម្ងាយ (Virtual teaching)។

ទី៤-ការបង្រៀនបែបបញ្ច្រាស់ (Flipped Classroom) ដែលសិស្សត្រូវធ្វើស្វ័យសិក្សាជាមុនតាមមេរៀនឌីជីថល ឬការស្រាវជ្រាវតាមឯកសារនានា ហើយមកអនុវត្តពិភាក្សាក្រោមការសម្របសម្រួល និងណែនាំបន្ថែមពីគ្រូនៅសាលា

ទី៥-ការសិក្សាពីចម្ងាយ (Distance Learning) គឺជាការផ្ញើមេរៀន និងសន្លឹកកិច្ចការជាច្បាប់បោះពុម្ព (Hard Copy) ឬច្បាប់ចម្លងទន់ (Soft Copy) ដល់សិស្សានុសិស្ស ដើម្បីសិក្សានៅផ្ទះ ។

### ៤-៤-៤-គោលបំណងនៃការរៀនតាមបែបចម្រុះ

ការរៀនតាមបែបចម្រុះ មានគោលបំណងផ្តល់ការរៀនដោយផ្ទាល់ និងរៀនតាមអ៊ិនធើណែតជាការបំពេញបន្ថែម។ បើតាមការសិក្សារបស់Learning A-Z បានបង្ហាញថា សិស្សអាចចូលប្រើសម្ភារៈសិក្សាក្នុងបណ្ណាល័យដែលសមស្របនឹងការអភិវឌ្ឍន៍គ្រប់ទីកន្លែងដែលពួកគេមានការតភ្ជាប់អ៊ីនធើណែត ឬចូលទៅកាន់ឧបករណ៍ចល័តមានន័យថា សិស្សានុសិស្សអាចបន្តរៀននៅវិស្សមកាលនៅចុងសប្តាហ៍ មិនថានៅទីណាក៏ដោយតាមដែលពួកគេចង់បាន។ ការរៀនតាមបែបចម្រុះផ្តល់អត្ថប្រយោជន៍ទាំងសិស្ស និងគ្រូដោយសារតែសិស្សទាំងអស់រស់នៅក្នុងពិភព ដែលជំរុញដោយបច្ចេកវិទ្យា រៀនតាមបែបចម្រុះអាចមានប្រយោជន៍ដល់សិស្សគ្រប់រូប។ ទន្ទឹមគ្នានេះ ការចូលប្រើតាមទូរសព្ទដៃមានន័យថា គ្រូបង្រៀនអាចកំណត់ពេលកិច្ចការបានយ៉ាងងាយស្រួល ដាក់ពិន្ទុលើការបញ្ជូនសិស្ស និងតាមដានភាពរីកចម្រើនរបស់សិស្សតាមរយៈមជ្ឈមណ្ឌលគ្រប់គ្រងគ្រូតាមអ៊ិនធើណែតមិនថាថ្ងៃ ឬយប់។ លើសពីនេះ ការរៀនតាមបែបចម្រុះជួយឱ្យគ្រូរក្សារបៀបរៀបរយ និងភ្ជាប់ទំនាក់ទំនងកាន់តែមានន័យជាមួយសិស្ស មានភាពបត់បែន ហើយវិធីសាស្ត្ររៀនតាមបែបចម្រុះអាចត្រូវបានដាក់បញ្ចូលទៅក្នុងថ្នាក់រៀនស្ទើរតែទាំងអស់។

- ចំពោះការអនុវត្តវិធីសាស្ត្រ គ្រូបង្រៀនត្រូវមានភាពទន់ភ្លន់ ចេះបត់បែន ដើម្បីឈានទៅរកការផ្លាស់ប្តូរនីតិវិធីនៃការបង្រៀន ឬវិធីសាស្ត្រថ្មីដែលអាចធ្វើទៅបានតាមតម្រូវការគ្រូយល់កាន់តែស៊ីជម្រៅនិងច្បាស់លាស់ពីភាពចម្រុះនៃវិធីសាស្ត្របង្រៀនផ្សារភ្ជាប់ចាំបាច់ទៅនឹងស្ថានភាពជាក់ស្តែង ពោលគឺប្រើវិធីសាស្ត្របង្រៀនមានលក្ខណៈជំរុញឱ្យសិស្សចេះត្រិះរិះពិចារណា ចេះថ្លឹងថ្លែង វិភាគ សំយោគ និងវាយតម្លៃទៅលើខ្លឹមសារ សកម្មភាពសិក្សានានាជាក្រុម ឬជាបុគ្គលដោយឈរលើមូលដ្ឋាននៃលទ្ធភាពជាក់ស្តែង។ កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀនថ្មីដែលផ្តោតលើគោលវិធីសិស្សមជ្ឈមណ្ឌល(Learner-centered approaches)ដោយឈរលើមូលដ្ឋាននៃកម្មវិធីសិក្សាតាមបែបបញ្ញត្តិ (Concept-based curriculum) និងដោយប្រើប្រាស់វិធីសាស្ត្ររៀនតាមបែបរិះរក មានគោលដៅពង្រឹងបំណិនត្រិះរិះពិចារណា ដោះស្រាយបញ្ហា សន្ទនា ការធ្វើការងារជាក្រុម និងពង្រឹងការគិតរបស់សិស្ស ដែលជាវិធីសាស្ត្រ

មានឧត្តមភាពបើប្រៀបធៀបជាមួយវិធីសាស្ត្រប្រពៃណីដូចជាការសូត្របបកថា ការទន្ទេញចាំមាត់ និងការរំលឹកមេរៀនជាដើម។ ពេលបច្ចុប្បន្នមានទ្រឹស្តីធំៗមួយចំនួនពាក់ព័ន្ធនឹងការសិក្សាដូចជា(១) អាកប្បកិរិយានិយម (២) ពុទ្ធិបញ្ញា (៣)ដំណើរការរៀនបែបចម្រុះ (៤)ស្ថាបនានិយម (៥) ពុទ្ធិបញ្ញាសង្គម (៦) ការលើកទឹកចិត្ត (motivation) (៧)បរិស្ថាននៃការរៀនសូត្រ។ ជានិច្ចកាលគ្រូបង្រៀនត្រូវប្រើវិធីបង្រៀនផ្សេងៗដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចឱ្យបានតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួងមានដូចជា អនុមានរួម អនុមានញែក ការងារក្រុមពន្យល់បង្ហាញពីដំណោះស្រាយបញ្ហា ជាពិសេសអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលបានត្រឹមត្រូវស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្ស ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់ដោយគំនិតច្នៃប្រឌិត។

### ៤-៤-៥-យុទ្ធសាស្ត្រលើកកម្ពស់ការអប់រំតាមបែបឌីជីថល

យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការអប់រំតាមបែបឌីជីថលរបស់ក្រសួងអប់រំរួមមាន៖

-បញ្ជ្រាបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ប.ព.ស)ឱ្យក្លាយជាឧបករណ៍សម្រាប់បង្រៀន និងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំទាំងមូលសំដៅឱ្យសិស្សនិស្សិតនូវចំណេះដឹង និងបំណិន ប.ព.ស ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សរ៍ទី២១

-ប្រើប្រាស់ដំណើរការគ្រប់គ្រង និងបែបបទការងារថ្មី ដើម្បីធ្វើទំនើបកម្មការអនុវត្តការងារ និងបង្កើនប្រសិទ្ធភាព តម្លាភាព និងភាពស័ក្តិសិទ្ធិនៃអភិបាលកិច្ច និងការពិនិត្យតាមដានលទ្ធផលការងារក្នុងវិស័យអប់រំ

-ធានាឱ្យសិស្សនិស្សិតកម្ពុជាគ្រប់រូបបញ្ចប់ការសិក្សាក្នុងប្រព័ន្ធមានចំណេះដឹង និងបំណិនប.ព.ស ដើម្បីមានលទ្ធភាពបន្តការសិក្សា និងបំពេញការងារវិជ្ជាជីវៈ

-បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀន និងរៀននៅតាមសាលាគរុកោសល្យ សាលារៀន និងគ្រឹះស្ថានសិក្សាដទៃទៀតតាមរយៈការប្រើប្រាស់ឧបករណ៍ប.ព.ស និងធនធានអប់រំអេឡិចត្រូនិក

-ប្រើប្រាស់ការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីគាំទ្រឱ្យមានការផ្តល់សេវាអប់រំដល់គ្រប់អនុវិស័យទាំងអស់នៃវិស័យអប់រំសម្រាប់សិស្ស និស្សិត និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ក៏ដូចជាការរៀនពេញមួយជីវិត

-បង្កើនប្រសិទ្ធភាពក៏ដូចជាសមត្ថភាពរបស់ខ្លួនក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមភស្តុតាង និងការចែករំលែកចំណេះដឹងតាមរយៈការប្រើប្រាស់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធក្នុងពេលតែមួយជាមួយគ្នា ដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការងាររដ្ឋបាលអប់រំ ប្រតិបត្តិការ និងការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល

-បង្កើតស្តង់ដាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ការភ្ជាប់ទំនាក់ទំនងបណ្តាញអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ទៅក្នុងប្រព័ន្ធតភ្ជាប់ផ្ទៃក្នុង

-ផ្តល់ធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីគាំទ្រដល់ការប្រើប្រាស់ប.ព.ស ក្នុងវិស័យអប់រំ ដោយប្រើប្រាស់ថវិការបស់រដ្ឋាភិបាល និងធ្វើការសម្របសម្រួលភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍នានាសម្រាប់រ៉ាប់រងចំណាយមូលធន និងចំណាយចរន្ត។ (បច្ចេកវិទ្យាព័ត៌មានអប់រំចុះថ្ងៃទី២៩មិថុនា, ២០២០)។

## ៥.៥.ភាពច្នៃប្រឌិតនៃយុទ្ធសាស្ត្រក្នុងការរៀន និងបង្រៀន

ពិភពលោកបានផ្លាស់ប្តូរពីថ្នាក់រៀនធ្វើពីឥដ្ឋទៅជាថ្នាក់រៀនតាមប្រព័ន្ធអ៊ិនធើណែត។ កម្មវិធីឌីជីថលបានជួយគ្រូបង្រៀន និងសិស្សឱ្យឈានដល់គំនិតច្នៃប្រឌិត និងផ្តល់ឱ្យសិស្សនូវលទ្ធភាពចូលរៀនបានកាន់តែប្រសើរឡើង។ វិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត គឺពុំមែនគ្រាន់តែប្រើបច្ចេកវិទ្យាទំនើបក្នុងថ្នាក់ ឬតាមទាន់និន្នាការនៃការអប់រំចុងក្រោយបំផុតនោះទេ ពោលគឺយុទ្ធសាស្ត្រនៃការបង្រៀនបែបថ្មីបានផ្តោតលើសកម្មភាពសិក្សារបស់សិស្សកាន់តែច្រើន។ គំនិតច្នៃប្រឌិតទាំងនេះបានក្លាយជាការលើកទឹកចិត្តសិស្សឱ្យចូលរួមយ៉ាងសកម្ម និងមិត្តរួមថ្នាក់ក្នុងអំឡុងពេលគ្រូកំពុងបង្រៀនមេរៀន។ ជាមួយគ្នានេះ សិស្សនឹងត្រូវធ្វើការកាន់តែច្រើនមិនដូចការបង្រៀនបែបប្រពៃណីគ្រូផ្តោតសំខាន់លើចំណេះដឹងហើយពុំអនុញ្ញាតឱ្យសិស្សប្រើប្រាស់វិធីច្នៃប្រឌិតដឹកជ្រៅទាញយកចេញខ្លឹមសារមេរៀនពីអ្វីដែលគ្រូកំពុងបង្រៀនក្នុងថ្នាក់ឡើយ។

លោក ដាវិស (Davis) ១៩៩៧ បានអះអាងថា ការជ្រើសរើសវិធីសាស្ត្របង្រៀនត្រូវតែផ្អែកទៅលើខ្លឹមសារ និងវត្ថុបំណងមេរៀនដោយមិនពឹងផ្អែកលើធម្មជាតិរបស់មុខវិជ្ជា ឬចំណង់របស់សិស្សនោះទេ។ និន្នាការនៃការបង្រៀនបច្ចុប្បន្នក្នុងពិភពលោកគឺជំរុញសិស្សឱ្យចេះច្នៃប្រឌិតដោយផ្អែកលើមូលដ្ឋានហេតុផល និងសម្ភារឧបទេស[69]។

លោកPaulo Freire វិធីសាស្ត្របង្រៀនគឺជាសិល្បៈ និងវិទ្យាសាស្ត្រផង។និយមន័យដ៏ទូលំទូលាយនេះគ្របដណ្តប់លើទិដ្ឋភាពផ្សេងៗនៃការបង្រៀន និងរៀនរួមមានបែបបទការបង្រៀន ការផ្តល់ព័ត៌មានត្រឡប់ និងការវាយតម្លៃជាដើម។

ក-ការបង្រៀន គឺជាសិល្បៈ

ក្នុងនាមជាគ្រូបង្រៀន ត្រូវស្វែងរកវិធីសាស្ត្រ និងយុទ្ធសាស្ត្រថ្មីៗ ដែលមានប្រសិទ្ធភាពបំផុតសម្រាប់បង្រៀនសិស្ស។ គ្រូបង្រៀនគួរសម្របខ្លួនឱ្យសមស្របនឹងស្ថានភាពបង្រៀនជាក់លាក់ ដើម្បីក្លាយជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាព ដែលត្រូវតែមានទស្សនវិជ្ជាបង្រៀនផ្ទាល់ខ្លួន និងស្វែងយល់ពីទេពកោសល្យក្នុងការបង្រៀន។ ការបង្រៀន គឺជាសិល្បៈដែលបង្ហាញពីវិធីច្នៃប្រឌិតដ៏សម្បូរបែប ដើម្បីបង្រៀនសិស្សឱ្យចេះចាប់អារម្មណ៍ក្នុងការរៀន និងទទួលបានលទ្ធផល។

---

[69] គួយ សូគាន, វិធីសាស្ត្របង្រៀន និងរៀន, ឆ្នាំ២០១៦, ទំ.៦។

ខ-ការបង្រៀន គឺជាវិទ្យាសាស្ត្រ

ការបង្រៀនគឺជាវិទ្យាសាស្ត្របង្ហាញពីវិធី ដែលគ្រូអាចប្រើវិធីសាស្ត្រសមហេតុសមផលបន្ថែមលើសម្ភារឧបទេសដល់សិស្ស។ តាមបែបប្រពៃណី ការបង្រៀនរបស់គ្រូក្នុងថ្នាក់គឺផ្តោតលើប្រធានបទ និងខ្លឹមសារមេរៀន។ ការបង្រៀនប្រភេទនេះមានទំនោរទៅរកភាពឯកកោ និងគួរឱ្យធុញ ហើយគ្រូប្រឈមមុខនឹងពេលវេលាដ៏លំបាកក្នុងការរក្សាការយកចិត្តទុកដាក់របស់សិស្ស។ ការបង្រៀន គឺជាវិទ្យាសាស្ត្រមួយ ដែលគ្រូប្រមូលទិន្នន័យដោយការសង្កេត ការស្រាវជ្រាវ ការពិសោធ និងមានប្រភពឯកសារច្បាស់លាស់សម្រាប់បង្រៀនសិស្សប្រកបដោយប្រសិទ្ធភាព។

ដូចនេះ ដើម្បីក្លាយជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាព ដែលការបង្រៀនត្រូវមានលក្ខណៈសិល្បៈផង និងវិទ្យាសាស្ត្រផង។

កំណែទម្រង់វិស័យអប់រំឆ្នាំ២០១៨-២០២៣ បានផ្តោតលើកំណែទម្រង់ការគ្រប់គ្រងការសិក្សារៀនសូត្ររបស់សិស្សជាពិសេសការកែលម្អវិធីសាស្ត្របង្រៀន និងរៀនដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពថ្នាក់ជាតិ និងសកលលោក សំដៅឱ្យគ្រូបង្រៀនចេះប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ឆ្លើយតបនឹងបរិបទបរិវត្តកម្មឌីជីថលក្នុងគោលបំណងបង្កើនលទ្ធផលសិក្សារបស់សិស្សតាមរយៈគោលវិធីសិស្សមជ្ឈមណ្ឌល និងទ្រឹស្តីតាមបែបស្ថាបនានិយម ដែលតម្រូវឱ្យសិស្សរៀនជាបុគ្គល ដៃគូ ឬជាក្រុម។ ធនធានបច្ចេកវិទ្យាជាច្រើនមានដូចជាYoutube, facebook, Cisco, Google Meet, Zoomសម្រាប់ឱ្យលោកគ្រូអ្នកគ្រូចេះកៃច្នៃប្រឌិតក្នុងការផលិតសម្ភារឧបទេស និងការអនុវត្តវិធីសាស្ត្របង្រៀនបានល្អដូចជាការសិក្សាគម្រោង(Project Based Learning) ជួយសិស្សមានគំនិតច្នៃប្រឌិត បង្កើនចំណេះដឹង និងទំនាក់ទំនងការរៀនសូត្រផ្អែកលើគម្រោងធ្វើឱ្យថ្នាក់រៀនកាន់តែមានភាពសប្បាយរីករាយ និងទាក់ទាញសិស្សចូលចិត្តរៀនសូត្រ និងអភិវឌ្ឍជំនាញការស្រាវជ្រាវ។ការសិក្សាតាមវិធីនេះ អាចនាំឱ្យមានការចូលរួម និងការយល់ដឹងកាន់តែប្រសើរ ជំរុញឱ្យពួកគេមានគំនិតច្នៃប្រឌិត និងជំរុញការសិក្សាពេញមួយជីវិត។ ការសិក្សាបែបរិះរក(Inquiry Based learning)សិស្សមានឱកាសផ្លាស់ប្តូរចំណេះដឹង និងបង្កើនភាពក្លាហានក្នុងការសួរសំណួរគ្នាទៅវិញទៅមក។ ក្រៅពីនេះ នៅមានជាច្រើនទៀតដូចជា វិធីវិទ្យាសាស្ត្រ(Scientific method) វិធីដោះស្រាយបញ្ហា(Solving problem) វិធីសាស្ត្រស្ទែម(STEM method)ជាដើម ដែលទាមទារឱ្យលោកគ្រូ អ្នគ្រូចេះច្នៃប្រឌិតក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់សិស្សប្រកបដោយគុណភាពអប់រំ។

ក្រសួងអប់រំបានអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យមានចំណេះដឹងច្បាស់លាស់ និងស៊ីជម្រៅទៅលើកម្មវិធីសិក្សា និងអនុវត្តវិធីសាស្តបង្រៀន ការផលិតសម្ភារឧបទេស ដើម្បីមានសមត្ថភាពវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្សតាមកម្រិតថ្នាក់ និងសាលារៀន។ ជាមួយគ្នានេះ វិទ្យាស្ថានជាតិអប់រំបានកែលម្អការបណ្តុះបណ្តាលគ្រូបង្រៀន ដោយប្រើវិធីសាស្ត្របង្រៀនថ្មីៗ និងការប្រើបច្ចេកវិទ្យាព័ត៌មានក្នុងដំណើរការ

បង្រៀន និងរៀន។ វិធីសាស្ត្របង្រៀនថ្មីៗរួមមានការរៀនសូត្រសកម្ម ការរៀនបែបស្ថាបនា ការរៀនតាមបែបដោះស្រាយបញ្ហា ការរៀនតាមបែបស្រាវជ្រាវ និងការរៀនតាមបែបរិះរក ពោលគឺការប្រើវិធីសាស្ត្របង្រៀនមួយដែលមានលក្ខណៈឱ្យសិស្សចេះត្រិះរិះពិចារណា ចេះថ្លឹងថ្លែង វិភាគ សំយោគ និងវាយតម្លៃទៅលើខ្លឹមសារ សកម្មភាពសិក្សាជាក្រុម ឬជាបុគ្គលដោយឈរលើមូលដ្ឋានគោលវិធីសិស្សមជ្ឈមណ្ឌល។

វិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិតគឺៈ

- ជំរុញការស្រាវជ្រាវ គឺជាវិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិតក្នុងការរៀនសូត្រលើកទឹកចិត្តសិស្សឱ្យស្វែងរក និងស្វែងរកវត្ថុ និងឧបករណ៍ថ្មីៗដើម្បីពង្រីកគំនិតរបស់ពួកគេ។
- ពង្រឹងជំនាញការដោះស្រាយបញ្ហា និងការត្រិះរិះពិចារណា គឺជាវិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិត អនុញ្ញាតឱ្យសិស្សរៀនតាមល្បឿនផ្ទាល់ខ្លួនរបស់ពួកគេ ហើយប្រកួតប្រជែងពួកគេឱ្យគិតពីរបៀបថ្មីដើម្បីដោះស្រាយបញ្ហាជំនួសឱ្យការស្វែងរកចម្លើយបានសរសេររួចហើយនៅក្នុងសៀវភៅសិក្សា
- ជៀសវាងការទទួលបានចំណេះដឹងច្រើនក្នុងពេលតែមួយ គ្រូប្រើវិធីសាស្ត្រថ្មីនៅតែផ្តល់ព័ត៌មានដល់សិស្សប៉ុន្តែពួកគេមានទំនោរបំបែកវាជាផ្នែកតូចៗ។ ឥឡូវនេះព័ត៌មានសង្ខេបអាចចូលប្រើបានកាន់តែច្រើន ហើយការរក្សារឿងខ្លីៗជួយសិស្សឱ្យទទួលបានមូលដ្ឋានគ្រឹះលឿនជាងមុន។
- ទទួលយកជំនាញទន់បន្ថែមទៀត សិស្សត្រូវប្រើឧបករណ៍ស្មុគស្មាញនៅក្នុងថ្នាក់ដើម្បីបញ្ចប់ការងាររបស់ពួកគេ ដែលជួយពួកគេរៀនអ្វីថ្មីៗ និងជំរុញការច្នៃប្រឌិតរបស់ពួកគេ។ ដូចគ្នានេះផងដែរនៅពេលធ្វើគម្រោងបុគ្គល ឬជាក្រុម សិស្សដឹងពីរបៀបគ្រប់គ្រងពេលវេលារបស់ពួកគេ កំណត់អាទិភាពកិច្ចការទំនាក់ទំនង ធ្វើការជាមួយអ្នកដទៃកាន់តែប្រសើរ។
- ពិនិត្យមើលការយល់ដឹងរបស់សិស្ស - ថ្នាក់ និងការប្រឡងអាចនិយាយបានខ្លះៗ ប៉ុន្តែមិនមែនអ្វីៗទាំងអស់អំពីសមត្ថភាពសិក្សា និងចំណេះដឹងរបស់សិស្សទេ (ជាពិសេសប្រសិនបើមានការលួចបន្លំអំឡុងពេលធ្វើតេស្ត) គំនិតច្នៃប្រឌិតនៃការបង្រៀនអនុញ្ញាតឱ្យគ្រូត្រួតពិនិត្យថ្នាក់រៀន និងដឹងកាន់តែច្បាស់អំពីអ្វីដែលសិស្សរបស់ពួកគេតស៊ូដើម្បីស្វែងរកដំណោះស្រាយសមស្របបំផុត។
- កែលម្អការវាយតម្លៃខ្លួនឯង ជាមួយនឹងវិធីសាស្ត្រដ៏អស្ចារ្យពីគ្រូ សិស្សអាចយល់ពីអ្វីដែលពួកគេបានរៀន និងអ្វីដែលពួកគេកំពុងបាត់។ តាមរយៈការស្វែងរកអ្វីដែលពួកគេនៅតែត្រូវដឹង នោះពួកគេអាចយល់ពីមូលហេតុដែលត្រូវរៀនអ្វីពិសេស ហើយកាន់តែចង់ធ្វើវា។
- ថ្នាក់រៀនមានជីវិត កុំឱ្យថ្នាក់រៀនរបស់អ្នកពោរពេញដោយសំឡេងរបស់អ្នក ឬភាពស្ងៀមស្ងាត់ដែលឆ្គាំឆ្គង។ វិធីសាស្ត្របង្រៀនប្រកបដោយភាពច្នៃប្រឌិតផ្តល់ឱ្យសិស្សនូវអ្វីប្លែកៗដើម្បីរំភើបចិត្តលើកទឹកចិត្តពួកគេឱ្យនិយាយ និងប្រាស្រ័យទាក់ទងគ្នាកាន់តែច្រើន។

ដូចនេះ គ្រូបង្រៀនមានភាពទន់ភ្លន់ចេះបត់បែន ហើយនឹងអាចឈានទៅរកការផ្លាស់ប្តូរនីតិវិធីនៃការបង្រៀន ឬវិធីសាស្រ្តថ្មី ដែលអាចធ្វើទៅបាន ដែលចំណុចនេះវាតម្រូវឱ្យគ្រូយល់កាន់តែស៊ីជម្រៅនិងច្បាស់លាស់ពីគោលវិធីសិស្សមជ្ឈមណ្ឌលដោយផ្សារភ្ជាប់ចាំបាច់ទៅនឹងស្ថានភាពរបស់ថ្នាក់រៀន។

### ៥.៦-ទំនើបកម្មនៃការផ្ទេរចំណេះដឹងក្នុងយុគសម័យបច្ចេកវិទ្យា

### ក-ការផ្ទេរចំណេះដឹងក្នុងសម័យបុរាណ

ការបង្រៀន និងរៀនក្នុងសម័យបុរាណ គ្រូបង្រៀនផ្តោតយ៉ាងខ្លាំងលើការអភិវឌ្ឍសមត្ថភាពសិស្សតាមគោលវិធីគ្រូមជ្ឈមណ្ឌល(Teacher Center) គ្រូបង្រៀនហាក់បីជាអ្នកមានកម្មសិទ្ធិចំណេះដឹងនិងជំនាញតែម្នាក់ឯង ហើយអ្នករៀនត្រូវតែយកគំរូតាមគ្រូបង្រៀន និងចាំទទួលយកចំណេះដឹង[70]ដោយមិនអាចតវ៉ាបានឡើយ។ គ្រូបង្រៀនត្រូវមានសកម្មភាពដូចជា ស្វែងរកឯកសារសម្រាប់បង្រៀន គ្រូហៅមេរៀនឱ្យសិស្សកត់ត្រាតាម សិស្សត្រូវសូត្រចាំមាត់ដូចអ្វីដែលគ្រូហៅឱ្យកត់ គ្រូគ្មានសម្ភារឧបទេស និងសិទ្ធិតស៊ូមតិរបស់សិស្សបានឡើយ។

ក្នុងសម័យកាលនោះគ្រប់មុខវិជ្ជាដូចជាភូមិសាស្រ្ត សិល្បៈ លេខនព្វន្ត ប្រវត្តិសាស្រ្ត អក្សរសាស្រ្ត ភាសាជាដើម....។ល។ គ្រូច្រើនបង្ខំសិស្សឱ្យរៀនទន្ទេញចាំមាត់ដូចម៉ាស៊ីនដោយគ្មានឱ្យសិស្សយល់ គិត អាន ការស្រាវជ្រាវនោះទេ។ វិធីសាស្រ្តនេះតម្រូវឱ្យសិស្សសូត្រចាំមាត់ទាំងងងឹតងងុលដោយពុំបានគិតថាតើចង់ចេះពីអ្វីនោះទេ ពោលគឺពួកគេត្រូវថាតាម សូត្រលោកគ្រូ អ្នកគ្រូ ដែលបង្រៀនសិស្សទាំងខុស ទាំងត្រូវនោះដោយគ្មានឈរលើមូលដ្ឋានឯកសារណាមួយពិតប្រាកដនោះទេ គឺសិស្សចេះចាំតៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតពីមនុស្សមួយជំនាន់ទៅមួយជំនាន់ទៀត។




រូបភាពទី១៧៖ បង្ហាញពីការចាក់បញ្ចូកចំណេះដឹងរបស់គ្រូដល់សិស្ស។

សិស្សរៀនទាំងអស់សុទ្ធតែបានគិតថា គ្រូបង្រៀនជាប្រភពនៃចំណេះដឹងមិនចេះរីងស្ងួត ហើយអ្វីដែលគ្រូបានលើកឡើងសុទ្ធតែជាការត្រឹមត្រូវទាំងអស់។ ប្រសិទ្ធភាពនៃវិធីសាស្រ្តបង្រៀនបែបនេះគឺប្រើ

---

[70] គ្រូបង្រៀនជាអ្នកចាក់បញ្ចូកចំណេះដឹងដល់សិស្ស ហើយសិស្សចាំទទួលយកចំណេះដឹងវិញដោយបង្ខំ។

រំពាត់ ការដាក់ទណ្ឌកម្មលើរាងកាយផ្លូវ ចិត្ត ស្ដីបន្ទោស ហើយថែមទាំងបណ្ដេញសិស្សឱ្យចេញពីសាលារៀនផង។ លោក(Montaigne)បានកំណត់ថា គ្រូបង្រៀនជាប៉ូលិសម្នាក់ចាំចាប់ចោរនៅក្នុងថ្នាក់រៀន ហើយសិស្សមានសភាពភិតភ័យ បាក់ស្បាត់ គេចវេសមិនព្រមទៅសាលារៀន ដែលជាប្រការមួយធ្វើឱ្យសិស្សខ្សោយក្នុងវិស័យអប់រំ[71]។ ការបង្រៀនបែបទន្ទេញចាំមាត់ជាប្រការធ្វើឱ្យសិស្សគ្មានគំនិតច្នៃប្រឌិត ខ្វះការស្រាវជ្រាវ ខ្វះការបង្កើតថ្មីសិស្សគ្មានការប្រុងប្រយ័ត្នគំនិត ប្រាជ្ញាមិនភ្លឺថ្លា សិស្សរៀនដើម្បីជៀសវាងការដាក់ទណ្ឌកម្មពីគ្រូ។ ចំណេះដឹងពុំអាចយកទៅប្រើការជាវិជ្ជាជីវៈ(បំណិន)បានទេហើយថ្នាក់រៀនពុំមានសកម្មភាពក្នុងការសិក្សាតែជាសកម្មភាពរបស់គ្រូតែម្នាក់ឯងតែប៉ុណ្ណោះ និងពង្រឹងសមត្ថភាពចំណេះដឹងរបស់គ្រូកាន់តែរឹងមាំដែលមានន័យថា គ្រូសិក្សារៀនសូត្រស្រាវជ្រាវនៅឯផ្ទះបានច្រើនហើយ តែពេលមកដល់ថ្នាក់រៀនគ្រូនៅតែសិក្សារៀនសូត្រតែខ្លួនឯងទៀតចំណែកឯសិស្សស្ថិតនៅអសកម្ម។

វិធីសាស្ត្របង្រៀនតាមប្រពៃណីគឺនៅពេលដែលសិស្សរៀនមិនចេះ គ្រូដាក់ទណ្ឌកម្មច្រើនប្រភេទដើម្បីពង្រឹងអំណាចរបស់គ្រូនៅក្នុងថ្នាក់រៀនដូចជា[72]៖

(១)ទណ្ឌកម្មលើរាងកាយដោយគ្មានការប៉ះពាល់ផ្ទាល់ ឈរជើងមួយ ឈរក្រោមកម្ដៅថ្ងៃរយៈពេលយូរ រត់ជុំវិញសាលារៀន ប្រានឱ្យវារលើឥដ្ឋ ឱ្យលើកដៃហើយហាមាត់ ប្រើធ្វើពលកម្មដូចជា លាងបង្គន់ យួរទឹក ស្រោចផ្កា ឬដាក់ជីផ្កា និងកាត់ស្មៅ។

(២)ទណ្ឌកម្មលើរាងកាយ៖ វាយដោយខ្សែក្រវាត់វាយដំច្រើនកន្លែង លើរាងកាយ ប្រើរំពាត់ ឬបន្ទាត់តូចវាយលើចុងក្រចក បង្ខំឱ្យដាល់តុ ឬក្ដារ ខៀន ឬបុកម្រាមដៃទៅនឹងវត្ថុរឹងអ្វីមួយ

(៣) ទណ្ឌកម្មក្រៅរាងកាយ៖ មិនឱ្យចូលថ្នាក់រៀន ពិន័យពេលមក យឺត បង្ខំឱ្យទិញក្រដាស ឬសៀវភៅឱ្យគ្រូដាក់អវត្តមាននៅពេលពួកគេចត ម៉ូតូខុសកន្លែង។

អំពើហិង្សានិងទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតីមិនមែនជាវិន័យទេ។ អំពើហិង្សាបង្កការឈឺចាប់ មិនលើកទឹកចិត្តសិស្សធ្វើឱ្យសិស្សបាត់បង់ ទំនុកចិត្ត និងធ្វើឱ្យពួកគេមិនចូលចិត្ត ឬហួតដល់ស្អប់សាលាថែមទៀតផង និងជាការរំលោភលើសិទ្ធិកុមារទៀតផង។

### ខ-ទំនើបកម្មនៃការផ្ទេរចំណេះដឹងក្នុងបរិបទឌីជីថល

ការគ្រប់គ្រងថ្នាក់រៀន គឺជាបញ្ញត្តិមួយគ្រូបង្រៀន និងអ្នកអប់រំប្រើប្រាស់ដើម្បីពណ៌នាអំពីការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនប្រកបដោយជោគជ័យ។ ម្យ៉ាងវិញទៀត ការគ្រប់គ្រងថ្នាក់រៀន សំដៅលើជំនាញ និងបច្ចេកទេសដ៏ធំទូលំទូលាយ ដែលគ្រូបង្រៀនប្រើប្រាស់ ដើម្បីរក្សាសិស្សឱ្យមានរបៀបរៀបរយ សណ្ដាប់ធ្នាប់ និងចាប់អារម្មណ៍យកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រក្នុងថ្នាក់។ ខណៈពេលដែលយុទ្ធសាស្ត្រគ្រប់គ្រងថ្នាក់រៀនត្រូវបានប្រតិបត្តិប្រកបដោយប្រសិទ្ធភាព គឺមានន័យថា គ្រូបង្រៀនបានកាត់

---

[71] UNESCO, ការអប់រំសម័យបុរាណ, ក្រសួងអប់រំជាតិ,ឆ្នាំ១៩៦២, ទំ.១៣។

[72] ហង់ជួន ណារ៉ុន, ដ.ឯ.ម,Sipar, ២០២១, ទំ.៥១។

បន្ថយអាកប្បកិរិយាផ្នែករដ្ឋបាលថ្នាក់រៀនសម្រាប់សិស្សម្នាក់ៗ និងក្រុមបានយ៉ាងល្អ ហើយជំនួសមកវិញនូវសកម្មភាពជួយសិស្សក្នុងការសិក្សារៀនសូត្របានពេញលេញ។




រូបភាព១៨៖ ត្រីកោណបង្ហាញពីតួនាទីនៃសកម្មភាពរៀន និងបង្រៀនរបស់គ្រូ និងសិស្ស ក្នុងនោះគ្រូបង្រៀនដូចជាការកំណត់វត្ថុបំណងមេរៀន និងលទ្ធផលរំពឹងទុក និងសកម្មភាពសិស្សរួមមានការចូលរួម ការសង្កេត និងការឆ្លើយតប។ ដោយឡែកខ្លឹមសារមេរៀនរួមមានសម្ភារឧបទេស ទម្រង់វាយតម្លៃ បំណិនពន្យល់។

ខ១-បរិស្ថានសម្រាប់អប់រំឌីជីថល

បច្ចេកវិទ្យាមានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សា ហើយគ្រូបង្រៀន និងសិស្សអាចប្រើកុំព្យូទ័រ ទូរស័ព្ទដៃ ឧបករណ៍អេឡិចត្រូនិកផ្សេងទៀត ប្រព័ន្ធបណ្តាញសង្គមដូចជា Facebook, YouTube, WhatsApp, Telegram, Apps, Google, Microsoft Team,E-book and E-library ដើម្បីបង្កើតជាប្រព័ន្ធសិក្សាអេឡិចត្រូនិក និងវេទិកាឌីជីថល ដើម្បីសម្រួលដល់ការសិក្សា។ ការរៀបចំបរិស្ថានសម្រាប់ការសិក្សាក្នុងយុគសម័យឌីជីថល គឺជាកត្តាគន្លឹះនៃការអប់រំឌីជីថលសម្រាប់ការបង្រៀន និងរៀន។

បរិស្ថានសម្រាប់ការសិក្សានៅក្នុងយុគសម័យឌីជីថលរួម[73]៖

ប្រព័ន្ធគ្រប់គ្រងការសិក្សា(Learning Management System-LMS)៖ ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្តល់ការអប់រំអេឡិចត្រូនិកតាមរយៈការប្រើប្រាស់កម្មវិធី Apps ដូចជា Google suit, Moodle, BlackBoard ដែលជាប្រព័ន្ធធំ និងស្មុគស្មាញ ដើម្បីគ្រប់គ្រងការរៀន និងបង្រៀនពីចម្ងាយតាមបែបអេឡិចត្រូនិកដោយគ្រូបង្រៀនផ្សាយពីចម្ងាយដោយប្រើប្រាស់បទបង្ហាញ Power Point, ហើយសិស្សចូលរៀននៅក្នុងបន្ទប់រៀនសិប្បនិម្មិត(Virtual) មានបន្ទប់ពិភាក្សាជំណភ្ជាប់វេបសាយ(Weblinks) បណ្ណាល័យប្រតិទិន និងធនធានសិក្សាផ្សេងទៀត។ ប្រព័ន្ធគ្រប់គ្រងការសិក្សាខ្លះមានលក្ខណៈជាវេបសាយ ដែល

[73] ហង់ជួន ណារ៉ុន, បរិវត្តកម្មឌីជីថលនៃការអប់រំបំណិនស.វទី២១,Sipar, ២០២១, ទំ.១៧-២០។

សិស្សអាចចុះឈ្មោះចូលរៀនតាមមុខវិជ្ជា តាមកម្រិតថ្នាក់ដោយគ្មានគ្រូបង្រៀន ហើយមានការធ្វើតេស្តជាស្វ័យប្រវត្តិតាមម៉ូឌុលមុននឹងអាចឡើងថ្នាក់រៀនក្នុងកម្រិតខ្ពស់ជាងមុន។ ប្រព័ន្ធនេះជួយសម្រួលឱ្យសិស្សអាចចូលរៀនពេលណាក៏បានពីទីណាក៏បានជាពិសេសងាយស្រួលរៀនសម្រាប់ សិស្សដែលនៅក្រៅសាលារៀនដូចជាកម្មវិធីសមមូលអប់រំមូលដ្ឋាន។ ក្រុមហ៊ុនឯកជនមួយចំនួនបានបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សាសម្រាប់សាលារៀនមួយៗ ដោយមានប្រព័ន្ធគ្រប់គ្រងវត្តមានសិស្សប្រព័ន្ធ គ្រប់គ្រងការរៀននិងបង្រៀន ប្រព័ន្ធគ្រប់គ្រងធនធានសិក្សា និងប្រព័ន្ធទំនាក់ទំនងជាមួយមាតាបិតាផង។ គេអាចបង្កើតកម្មវិធីកុំព្យូទ័របែបAppsផ្ទុកនូវខ្លឹមសារឌីជីថលជាវីដេអូមេរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់រៀន ដើម្បីជួយសិស្សក្នុងការទាញយក និងផ្ទុកក្នុងកុំព្យូទ័រផ្ទាល់ខ្លួន ឬទូរស័ព្ទដៃដើម្បីធ្វើការសិក្សាជាលក្ខណៈឯកជន។

ប្រព័ន្ធគ្រប់គ្រងការសិក្សាផ្ទាល់ខ្លួន(Personal learning System-PLS)៖ គឺជាឧបករណ៍គាំទ្រដល់ការសិក្សាផ្ទាល់ខ្លួន ដោយប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក។ សិស្សអាចទាញយកខ្លឹមសារឌីជីថលជាអត្ថបទបទបង្ហាញPowerPoint ឬវីដេអូ ដើម្បីរក្សាទុកក្នុងឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួនទុកសម្រាប់សិក្សានៅកន្លែងណា និងពេលណាដែលខ្លួនចង់រៀន។ សិស្សនិងគ្រូអាចចងក្រុមជាបណ្តាញអ្នកសិក្សាដោយប្រើប្រាស់កម្មវិធីTelegram, Messenger ឬ WhatsApp ដើម្បីផ្លាស់ប្តូរព័ត៌មានចែករំលែកធនធានសិក្សា និងពិគ្រោះយោបល់។

ការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស(Flipped Classroom)៖ នៅក្នុងការបង្រៀនសិស្សតាមបែបប្រពៃណី គ្រូបង្រៀនមេរៀនដោយផ្ទាល់ និងផ្តល់បាឋកថានៅក្នុងថ្នាក់រៀន។ចំណែកសិស្សត្រូវកត់មេរៀននិងស្តាប់គ្រូពន្យល់ក្នុងថ្នាក់រៀន។ នៅក្រៅថ្នាក់រៀន សិស្សត្រូវធ្វើកិច្ចការនៅផ្ទះ សរសេរគម្រោង និងធ្វើការអនុវត្តលើមេរៀន។ នៅក្នុងបរិបទនៃការអប់រំឌីជីថលគេអាចអនុវត្តការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាស់ ដោយសិស្សអាចប្រើប្រាស់ខ្លឹមសារមេរៀន បទបង្ហាញដែលគ្រូបានថតជាវីដេអូ និងធនធានសិក្សា អេឡិចត្រូនិកដទៃទៀត ដែលទទួលបានតាមអ៊ិនធើណិត និងយូធូប ដើម្បីសិក្សាស្រាវជ្រាវមេរៀននៅផ្ទះ ទៅតាមល្បឿនដែលខ្លួនចង់។ នៅក្នុងថ្នាក់រៀន គ្រូមានតួនាទីជាអ្នកសម្របសម្រួលការពិភាក្សា ការធ្វើពិសោធន៍ ផ្តល់ ការគាំទ្រ និងមតិត្រឡប់។ ការសិក្សាក្នុងថ្នាក់រៀនបញ្ច្រាសប្រែក្លាយថ្នាក់រៀនទៅជាកន្លែងសិក្សាតាមបែបសហការប្រកបដោយជីវភាព និងលើកកម្ពស់អន្តរសកម្មសង្គម ដែលជួយពង្រឹងគុណភាពនៃលទ្ធផលសិក្សា និងការចងចាំរបស់សិស្ស។

ឧ២-ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាពរួមបញ្ចូល៖

(១) ទំនាក់ទំនងវិជ្ជមានរវាងគ្រូបង្រៀន និងសិស្ស

(២)ការបង្រៀនបែបច្នៃប្រឌិត និងដើរតួនាទីជាគំរូល្អ

(៣)គោលការណ៍សម្រាប់ថ្នាក់រៀនច្បាស់លាស់

(៤) ការលើកសរសើរ និងការលើកទឹកចិត្តបែបវិជ្ជមាន

(៥)ណែនាំសិស្ស ដោយប្រើប្រាស់ការឆ្លើយតបបានត្រឹមត្រូវ និងអហិង្សាជំនួសទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី

(៦)ការផ្តល់ប្រឹក្សាដល់សិស្ស និងឈ្វេងយល់បញ្ហារបស់សិស្ស រួមទាំងបញ្ហានៅផ្ទះដែរ ដោយសាកសួរអំពីតម្រូវការ និងការព្រួយបារម្ភរបស់សិស្ស។

ដើម្បីគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនអាចបើ ប្រាស់វិធីសាស្ត្រគ្រប់គ្រងថ្នាក់រៀនផ្សេងៗទៀតដូចជា៖

កិច្ចសន្យាគ្រូ-សិស្សគ្រូបង្រៀនអាចរៀបចំជាកិច្ចសន្យាជាមួយសិស្សម្នាក់ៗ ដោយកំណត់កិច្ចការ និងភារកិច្ចដែលសិស្សម្នាក់ៗត្រូវធ្វើ ដើម្បីទទួលបាននូវបុព្វសិទ្ធិ និងរង្វាន់។ សិស្សត្រូវកំណត់អាកប្បកិរិយា ដែលត្រូវពង្រឹង និងរង្វាន់ដែលគេអាចទទួល។ ក្នុងន័យនេះ សិស្សត្រូវរៀន ដាក់ចេញគោលដៅ និងអនុវត្តកិច្ចសន្យា តាមកាលវិភាគដែលបានឯកភាពជាមួយគ្រូ។

ការគ្រប់គ្រងសិស្សមានអាកប្បកិរិយាមិនល្អ៖ មូលហេតុ ដែលមានសិស្សខ្លះរំខាននៅក្នុងថ្នាក់រៀនមានច្រើនដូចជាសិស្សខ្លះធុញទ្រាន់នឹងការរៀនសូត្រ ដោយសារតែពួកគេចេះហើយ ឬដោយសារតែសិស្សទាំង នោះមានបញ្ហាក្នុងការរៀនសូត្រ ខ្វះបំណិនសង្គម និងរំខានដល់គេ ដើម្បីទទួលបានការយកចិត្តទុកដាក់។ ដើម្បីពង្រឹងវិន័យក្នុងថ្នាក់រៀន និងលើកទឹកចិត្តឱ្យសិស្សខំប្រឹងរៀន គ្រូអាចប្រើការពង្រឹងបែបអវិជ្ជមាន (negative reinforcemen) ដូចជាកាត់បន្ថយបុព្វសិទ្ធិរបស់សិស្ស ប្រសិនបើពួកគេមិន កែលម្អអាកប្បកិរិយា។ ឧទាហរណ៍ គ្រូមិនអនុញ្ញាតឱ្យសិស្សចេញលេង ប្រសិនបើមិនបានធ្វើកិច្ចការហើយ ក្នុងគោលដៅឱ្យសិស្សចេះគ្រប់គ្រងខ្លួន។

ឧ៣-ថ្នាក់រៀនបែបវៃឆ្លាត(Smart Classroom) ជាប្រភេទថ្នាក់រៀនមានលក្ខណៈខុសប្លែកពីថ្នាក់រៀនបែបប្រពៃណីដោយមានប្រើឧបករណ៍ឌីជីថល និងបច្ចេកវិទ្យាទំនើប ដើម្បីអនុវត្តដំណើរការអប់រំ។ សព្វថ្ងៃនេះការបង្រៀន និងរៀនបានផ្លាស់ប្តូរទៅកម្រិតជឿនលឿន ដើម្បីផ្តល់ឱ្យសិស្សានុសិស្សទទួលបានបទពិសោធន៍ នៃការរៀនសូត្រ ដែលមានសកម្មភាពកាន់តែច្រើន។

១-ងាយស្រួលទទួលព័ត៌មាន គឺថ្នាក់រៀនឆ្លាតវៃផ្តល់ភាពងាយស្រួលដល់សិស្សានុសិស្សក្នុងការទទួលព័ត៌មានដោយសារតែថ្នាក់រៀនបែបនេះប្រើឧបករណ៍ជាច្រើនតភ្ជាប់អ៊ិនធើណែតដូចជា ទូរស័ព្ទចល័ត កុំព្យូទ័រយួរដៃ និងបន្ទះតភ្ជាប់(Tabs) ជាដើម។ ឧបករណ៍ទាំងអស់នេះ កាន់តែផ្តល់ភាពងាយស្រួលសម្រាប់សិស្សចូលប្រើព័ត៌មាននៅលើអ៊ីនធឺណិត ។ បច្ចុប្បន្ន សិស្សមានព័ត៌មានទាំងអស់ដែលពួកគេត្រូវការអំពីប្រធានបទណាមួយដែលពួកគេចង់ដឹងដោយគ្រាន់តែចុងម្រាមដៃរបស់ពួកគេ។ សម្រាប់គ្រូបង្រៀនក៏ទទួលបានប្រយោជន៍ពីឧបករណ៍តភ្ជាប់អ៊ីនធឺណិតទាំងនេះ ហើយសិស្សអាចរៀននៅខាងក្រៅកម្មវិធីសិក្សាបានផងដែរ។

២-ការចំណាំឧបករណ៍ផ្ទុកឌីជីថល គឺលក្ខណៈពិសេសដ៏ធំបំផុតមួយរបស់សាលាឆ្លាតវៃ គឺសិស្សអាចយកកំណត់ត្រារបស់ពួកគេដោយប្រើឧបករណ៍ឌីជីថលដូចជា ប៊ិច និងថេបប្លេតជាដើម។ វិធីនេះពួកគេអាចសន្សំប្រាក់យ៉ាងច្រើន នៃពេលវេលារៀនសូត្ររបស់ពួកគេផងដែរ។ សិស្សានុសិស្សមិនចាំបាច់អនុវត្តសៀវភៅកត់ត្រា និងសៀវភៅពុម្ពធ្ងន់ៗទាំងអស់ទៀតទេ។ បច្ចេកវិទ្យាដូចជា Google Docs ក៏បានធ្វើឱ្យគ្រូកាន់តែងាយស្រួលក្នុងការបង្កើតឯកសារ និងបទបង្ហាញផងដែរ។

៣-ការយល់ដឹងកាន់តែច្បាស់អំពីប្រធានបទតាមរយៈឧបករណ៍ឌីជីថល ប្រសិនបើសិស្សរៀនប្រធានបទតាមរបៀបដែលប្រសើរជាងនេះថ្នាក់រៀនឆ្លាតវៃគឺសាកសមបំផុត។ វគ្គសិក្សានៅថ្នាក់រៀនឆ្លាតវៃជាធម្មតាប្រើជំនួយជាក់ស្តែងជាច្រើនរួមបញ្ចូលទាំងការធ្វើបទបង្ហាញតាមរយៈPowerPoint ឯកសារពាក្យសំឡេង និងបញ្ចាំងវីដេអូបានដើរតួយ៉ាងសំខាន់ក្នុងការបញ្ជូនមេរៀនតាមរបៀបដែលអាចយល់បានច្រើន

៤-ជម្រើសដ៏ល្អសម្រាប់សិស្សដែលអវត្តមាន សាលារៀនឆ្លាតវៃតែងតែត្រូវបានថតកត់ត្រាទុកជាប្រចាំមានន័យថា បើទោះជាអ្នកខកខានពីរបីវគ្គសិក្សាក៏ដោយក៏អ្នកមិនត្រូវព្រួយបារម្ភដែរ ដោយសារតែមានការថតវីដេអូទុកហើយអ្នកអាចត្រឡប់មករៀនវិញក្នុងករណីដែលអ្នកត្រូវការ។ លើសពីនេះ អ្នកអាចមើលវីដេអូ ផ្ញើអ៊ីមែលទៅលោកគ្រូ អ្នកគ្រូក្នុងករណីដែលអ្នកមានចម្ងល់។ ដោយឡែកនៅក្នុងថ្នាក់រៀនបែបប្រពៃណីសិស្សតែងតែពិបាកក្នុងការចម្លងព័ត៌មានទាំងអស់ភ្លាមៗនៅពេលគ្រូបង្រៀនពួកគេផ្តល់ឱ្យ។

៥-រៀនតាមរបៀបឌីណាមិច ចំណេះដឹងទូទៅសិស្សទាំងអស់ក្នុងថ្នាក់មិនមានសមត្ថភាពដូចគ្នាក្នុងការចាប់យកមេរៀនទាំងនោះទេ។ ចំពោះសិស្សខ្សោយតែងតែពិបាកក្នុងថ្នាក់ប្រពៃណី ប៉ុន្តែសាលារៀនឆ្លាតវៃបានផ្តល់ភាពងាយស្រួលសម្រាប់សិស្សរៀនក្នុងល្បឿនដែលពួកគេពេញចិត្ត។ មេរៀនត្រូវតែធ្វើឡើងពីគំនិតបែបផែនរូបភាពដែលត្រូវប្រើប្រាស់នៅក្នុងថ្នាក់រៀនឆ្លាតវៃ។ ឥទ្ធិពលទាំងនេះធ្វើឱ្យមេរៀនទាំងមូលកាន់តែច្បាស់ ហើយផ្តល់អត្ថប្រយោជន៍ដល់សិស្សខ្សោយបានយ៉ាងច្រើន។

៦-បរិយាកាសបង្រៀនមានលក្ខណៈអន្តរកម្ម បច្ចុប្បន្នឧបករណ៍ឌីជីថលគឺជាផ្នែកសំខាន់មួយនៃថ្នាក់រៀនឆ្លាតវៃ។ជាមូលហេតុដែលបរិយាកាសបង្រៀនមានទំនាក់ទំនងគ្នា ហើយជាកន្លែងមួយដែលសិស្ស និងគ្រូបង្រៀនមានតួនាទីច្បាស់លាស់។ ប្រភេទនៃការសិក្សានេះ ធ្វើឱ្យដំណើរការទាំងមូលមានតម្លាភាព។ លើសពីនេះធ្វើឱ្យប្រសើរឡើងនូវចំណងរវាងគ្រូ និងសិស្សដោយសារតែពួកគាត់អាចទំនាក់ទំនងពីក្រៅសាលាបានដោយមានជំនួយពីអ៊ីមែល និងសារអេឡិចត្រូនិច។

៧-ប្រើឧបករណ៍ឌីជីថលជំនួសក្រដាស ជារៀងរាល់ឆ្នាំ សិស្សប្រើក្រដាសរាប់តោន ដើម្បីកត់ចំណាំ។ តាមរយៈការជួយសម្រួលដល់ការកត់ចំណាំលើឧបករណ៍ឌីជីថលព្រមទាំងចូលរួមថែរក្សាបរិស្ថានលើសពីនេះ ថ្នាក់រៀនឆ្លាតវៃចូលរួមបង្កើតវិធីសាស្ត្រមួយ ដើម្បីជំនួសការប្រើប្រាស់ និងការខ្ជះខ្ជាយក្រដាសផងដែរ។ ជាពិសេសមិនមានកន្លែងសម្រាប់ថតចម្លង និងបោះពុម្ពអាចជួយកាត់បន្ថយកាបោន។

៨-ងាយស្រួលក្នុងការថែទាំក្នុងថ្នាក់រៀនប្រពៃណី សិស្សត្រូវចំណាយប្រាក់ច្រើនក្នុងមួយឆ្នាំៗ ដើម្បីទិញសម្ភារៈសិក្សាចាំបាច់ដូចជាសៀវភៅ ខ្មៅដៃ និងប៊ិកជាដើម។ ថ្នាក់រៀនឆ្លាតវៃនឹងចូលរួមកាត់បន្ថយការចំណាយលើសម្ភារៈសិក្សាទាបបំផុត។ នៅក្នុងថ្នាក់ទាំងនេះអ្វី ដែលអ្នកត្រូវធ្វើគឺត្រូវវិនិយោគម្តងក្នុងឆ្នាំដំបូងប៉ុណ្ណោះ ហើយទិញឧបករណ៍អេឡិចត្រូនិកទាំងនោះសម្រាប់ការសិក្សា។

ឧ៤-ក្នុងយុគសម័យឌីជីថលគ្រូបង្រៀនត្រូវមានលក្ខណសម្បត្តិ៥យ៉ាងដែលមាននៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺ៖

ទីមួយ-ចំណេះដឹងខ្លឹមសារមេរៀនរឹងមាំ និងមានវប្បធម៌ទូទៅទូលំ ទូលាយ (រួមទាំងចំណេះដឹងផ្នែកភាសាបរទេសដែរ)

ទីពីរ-បំណិនវិជ្ជាជីវៈ ជាពិសេសចំណេះដឹងខាងផ្នែកចិត្តវិទ្យា និង គរុកោសល្យ រួមទាំងមានសមត្ថភាពក្នុងការស្រាវជ្រាវ

ទីបី-ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីមានបទពិសោធន៍វិជ្ជាជីវៈកាន់ តខ្លាំងក្លាឡើង

ទីបួន-សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើតវប្បធម៌សាលារៀនវិជ្ជមាន និង ផ្តល់ឱកាសឱ្យសិស្សបានសិក្សារៀនសូត្រ ដើម្បីសម្រេចបានសក្តានុពល

ទីប្រាំ-បំណិនឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការអនុវត្ត វិធីសាស្ត្របង្រៀន ដើម្បីអប់រំសិស្ស ឱ្យមានបំណិនសតវត្សទី២១។ សរុបមក ដើម្បីបណ្តុះបណ្តាលធនធានមនុស្សសម្រាប់សតវត្សរ៍ទី២១ គេត្រូវបណ្តុះបណ្តាលគ្រូ ដែលមានចំណេះដឹង បំណិន និងសមត្ថភាពសតវត្សទី២១។

ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក(E-book) មនុស្សគ្រប់រូបនាសម័យឌីជីថល គប្បីរៀនសូត្រ និងចេះអានតាមប្រព័ន្ធអេឡិចត្រូនិក ឬអីប៊ុកដែលមានភាពងាយស្រួលក្នុងការតាមដានតាមគ្រប់ព័ត៌មាន និងហេតុការណ៍ទាំងឡាយពីព្រោះថា សព្វថ្ងៃនេះ យើងគប្បីរៀនសូត្រពីគ្នាទៅវិញទៅមកដោយមិនត្រូវគិតថា ខ្លួនចេះគ្រប់យ៉ាងដោយមិនព្រមដាក់ខ្លួនរៀនសូត្រពីមនុស្ស ដែលនៅជុំវិញទៅតាមជំនាញរបស់ខ្លួន និងឯកទេសរបស់ខ្លួន។ ជំនាញណាក៏ដោយឱ្យតែយើងចេះប្រាកដ យើងអាចស្វែងរកលាភសក្ការៈពីជំនាញនោះ ឬទុកអាជីពនោះជាឆ្នាំងបាយសម្រាប់ជីវិតរបស់ខ្លួន។ ជាក់ស្តែងសិស្ស និស្សិត អាចសិក្សារៀនសូត្រ ធ្វើលំហាត់ ធ្វើកិច្ចការស្រាវជ្រាវជាដើមបានយ៉ាងងាយស្រួល និងឆាប់រហ័សបានផលច្រើន។ សម្រាប់អ្នកសិក្សា អ្នកចងក្រង អ្នកនិពន្ធ អ្នកសរសេរសៀវភៅជាដើម គេអាចស្រាវជ្រាវដកស្រង់ខ្លឹមសារៈសំខាន់ៗតាមស៊ីប៊ុកនេះ។ ន័យត្រង់នេះជាការលើកទឹកចិត្តឱ្យមនុស្សព្យាយាមអានគ្រប់កាលៈទេសៈ។

ឧ៥-គោលការណ៍នៃការបង្រៀន និងរៀនក្នុងបរិបទឌីជីថល

ទ្រឹស្តីអប់រំបែបស្ថាបនានិយម គឺជាទ្រឹស្តីនៃការរៀន និងបង្រៀនដែលផ្តោតលើគំនិតដែលថាសិស្សកសាងចំណេះដឹងយ៉ាងសកម្មដោយខ្លួនឯង។ ការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្របង្រៀនតាមទ្រឹស្តីអប់រំបែបស្ថាបនានិយមបានផ្តល់អត្ថប្រយោជន៍ដល់អ្នកសិក្សាដូចខាងក្រោម៖

- ចេះកំណត់បញ្ហា
- ចេះគិតបែបស៊ីជម្រៅ និងបែបយុទ្ធសាស្ត្រ
- ចេះដោះស្រាយបញ្ហា
- ចេះស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ
- ចេះវិភាគវែកញែក
- ចេះធ្វើសេចក្តីសន្និដ្ឋាន និងសំយោគ
- ចេះធ្វើការងារជាក្រុម
- មានបំណិនសតវត្សរ៍ទី២១

១-ការបង្រៀន គឺជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស ដើម្បីឱ្យពួកគេមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល ។

២-ការបង្រៀនគឺជាសកម្មភាពជួយនិងលើកទឹកចិត្តសិស្ស ឱ្យពួកគេចេះពីរបៀបរៀនដោយខ្លួនឯងយ៉ាងសកម្មមានប្រសិទ្ធភាព និងទទួលខុសត្រូវ ដើម្បីស្វែងយល់ ធ្វើវិចារ និងអនុវត្តចំណេះដឹង សម្រាប់ការសិក្សានិងការរស់នៅប្រចាំថ្ងៃ ដោយប្រើប្រាស់វិធីសាស្ត្រទំនើប ដូចជាសហការ...។

៣-ការបង្រៀនត្រូវបន្តពង្រឹងនិងពង្រីកចំណេះដឹង បទពិសោធ ទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់សិស្ស ដើម្បីឱ្យពួកគេស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សា។

៤-ការបង្រៀនត្រូវផ្សារភ្ជាប់នឹងបរិស្ថានជុំវិញតាមរយៈការប្រើប្រាស់វិធីសាស្ត្រ និងសម្ភារឧបទេសរួមទាំងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្បូរបែប និងមានបច្ចុប្បន្នភាព ។

ជំហានសំខាន់ៗនៃការបង្រៀន និងរៀនតាមបែបបញ្ញត្តិ

ជំហានទី១៖គ្រូត្រូវបំផុសគំនិតសិស្សតាមរយៈការបង្ហាញរូបភាព វីដេអូ ឬលេងល្បែង កម្សាន្តទាក់ទងជាមួយខ្លឹមសារមេរៀន ដើម្បីបង្កើតចម្ងល់ដល់សិស្ស និស្សិត។

ជំហានទី២៖ តាមរយៈចម្ងល់របស់សិស្ស និស្សិត គ្រូបង្រៀនត្រូវកំណត់បញ្ហាដែលជាលក្ខណៈរួមទាក់ទងជាមួយបញ្ញត្តិ រួចសរសេរលើក្តារខៀន ដើម្បីសិស្សដោះស្រាយ។

ជំហានទី៣៖ គ្រូត្រូវរៀបចំសិស្សឱ្យពិភាក្សាជាដៃគូ ក្រុមតូច ក្រុមធំ ដើម្បីដោះស្រាយបញ្ហាដោយបែងចែកភារកិច្ចដូចជាប្រធានក្រុម អ្នកកត់ត្រា អ្នកសង្កេត អ្នកស្រាវជ្រាវ ដោយប្រើយុទ្ធសាស្ត្រយ៉ាងណាដើម្បីសិស្សម្នាក់ៗអាចដោះស្រាយ ពន្យល់ បកស្រាយបញ្ញត្តិ ទាញយកបញ្ញត្តិ និងធ្វើការសន្និដ្ឋាន។

ជំហានទី៤៖ ក្រុមដែលបានពិភាក្សាចប់សព្វគ្រប់ ត្រូវបិទលទ្ធផលនៅលើក្តារខៀន និងជញ្ជាំងដើម្បីពន្យល់ដល់សិស្ស និស្សិតដទៃទៀតក្នុងថ្នាក់រៀន។ករណីចំណុចណាមិនច្បាស់ គ្រូអាចសួរសំណួរដល់សិស្សក្នុងក្រុមឱ្យជួយពន្យល់បន្ថែម។

ដំហានទី៥៖គ្រូសម្របសម្រួលសន្និដ្ឋានលើបញ្ញត្តិសិស្សបានរកឃើញរួចសរសេរលើក្ដារខៀន ដើម្បីធ្វើការសន្និដ្ឋាន[74]។

ការសិក្សាតាមបែបបញ្ញត្តិធ្វើឱ្យគ្រូរវល់ច្រើនក្នុងការរៀបចំគម្រោង ផែនការបង្រៀន រៀបចំកិច្ចតែងការបង្រៀន និងរៀបចំសម្ភារឧបទេសបង្រៀន និងដំណើរការបង្រៀនចំណាយពេលច្រើនបន្តិចប៉ុន្តែលទ្ធផលដែលទទួលបានគឺការចាប់អារម្មណ៍រៀនសូត្រសប្បាយរីករាយ និងការចូលរួមយ៉ាងសកម្មពីសិស្ស ព្រោះថាវិធីនេះបានធ្វើឱ្យសិស្សចេះឆ្ងល់ កំណត់បញ្ហា ចេះពិភាក្សា ចេះដោះស្រាយ ចេះពន្យល់រហូតដល់អាចកំណត់បញ្ញត្តិ។

ការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំ សំដៅជានាសិទ្ធិសេរីភាព និងសុភ មង្គល បុគ្គល គ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការសិក្សាពេញមួយជីវិតជាដំណើរ ការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការតាំងពីការចាប់កំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាឱ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នា ប្រកបដោយភាពសុខដុមនៅក្នុងសង្គម។ ស្ថិតក្នុងបរិការណ៍នៃសកលភាវូបនីយកម្មសតវត្សរ៍ទី២១ និងការប្រកួត ប្រជែងទាំងក្នុងតំបន់ សកលលោក ផ្នែកសង្គម សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យា បុគ្គល គ្រប់រូបត្រូវទទួលបានការបណ្ដុះបណ្ដាលវប្បធម៌សិក្សាពេញមួយជីវិត។




រូបភាពទី១៩៖សារប្រយោជន៍នៃការរៀនតាមបច្ចេកវិទ្យា

---

[74] ហង់ជួន ណារុន, កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន, វិទ្យាស្ថានជាតិអប់រំ,២០២០, ទំ.១២។

# មេរៀនទី៦៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## ៦-១-វត្ថុបំណងមេរៀន

### ក-វិជ្ជាសម្បទា

- កំណត់បានពីចំណុចអាទិភាព និងប្រព័ន្ធគាំទ្រក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- កំណត់បានពីនិយមន័យ និងបញ្ញត្តិទូទៅនៃសហគមន៍សិក្សាវិជ្ជាជីវៈ
- ពិពណ៌នាបានពីដំណើការសហគកមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូមធ្យមសិក្សា
- ពន្យល់បានពីប្រព័ន្ធនៃការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ

### ខ-បំណិនសម្បទា

- វិភាគបានពីចំណុចអាទិភាព និងប្រព័ន្ធគាំទ្រក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- វាយតម្លៃបានពីដំណើការ និងប្រព័ន្ធនៃការគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ

### គ-ចរិយាសម្បទា

- បណ្តុះស្មារតី និងលើកទឹកចិត្តឱ្យស្រឡាញ់ការសិក្សាពេញមួយជីវិត

## ៦-២-សេចក្តីផ្តើម

ការអប់រំសតវត្សរ៍ទី២១ គឺគោលនយោបាយនៃការសិក្សាពេញមួយជីវិត បានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំសំដៅជានាសិទ្ធិសេរីភាព និងសុភមង្គលបុគ្គល គ្រួសារ និងសង្គម ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មីៗ ឬអាចនិយាយបានថា ការសិក្សាពេញមួយជីវិតជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការដែលចាប់ផ្តើមពីកំណើតរហូតដល់វ័យជរា ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាទាំងឡាយឱ្យក្លាយជាពលរដ្ឋពេញលេញ និងចេះរួមរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម និងពិភពលោក។

ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា[75]បានដាក់ចេញនៅឆ្នាំ២០១០ ដើម្បីធានាឱ្យគ្រូបង្រៀនកម្ពុជាមានគុណវុឌ្ឍិ និងសមត្ថភាពប្រហាក់ប្រហែលគ្នានៅទូទាំងប្រទេសក្នុងនោះបានផ្តោតលើ៖

(១)ចំណេះដឹងវិជ្ជាជីវៈ គឺគ្រូបង្រៀនត្រូវមានចំណេះដឹងស្គាល់ពីពីប្រវត្តិរូប តម្រូវការសិក្សា សមត្ថភាពរបស់សិស្ស និងរបៀបរៀន ឬអាកប្បកិរិយាក្នុងការសិក្សារៀនសូត្រ និងត្រូវស្គាល់ពីស្ថានភាពផ្ទះ ឬគ្រួសាររបស់សិស្ស(ឧ-យេនឌ័រ ប្រវត្តិសេដ្ឋកិច្ចសង្គម ឬស្ថានភាពគ្រួសារ)អាចប៉ះពាល់ដល់ការសិក្សា និងជួយដោះស្រាយបញ្ហាគ្រួសារ ហើយគ្រូបង្រៀនត្រូវយល់ដឹងពីខ្លឹមសារនៃមុខវិជ្ជា ស្វែងយល់ពីច្បាប់ និងគោលនយោបាយអប់រំ និងកម្មវិធីសិក្សាជាតិ ស្វែងយល់ពីបរិបទអប់រំនៃថ្នាក់រៀន និងសាលារៀនសហគម

---

[75] ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេសវិញ ក្រសួងអប់រំបានដាក់ចេញនូវឆ្នាំ២០២២បានកំណត់លើស្តង់ដាសំខាន់ៗចំនួន៦គឺ(១)ចំណេះដឹងវិជ្ជាជីវៈ (២)បំណិនវិជ្ជាជីវៈ(៣)អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ(៤)ក្រមសីលធម៌វិជ្ជាជីវៈ(៥)ការស្រាវជ្រាវ និងនវានុវត្តន៍(៦)ការអភិវឌ្ឍកម្មអប់រំ។

ន៍ ស្វែងយល់ពីរបៀបរៀនរបស់សិស្ស គ្រូបង្រៀនគួរតែមានសមត្ថភាពក្នុងការគ្រប់គ្រងការរៀនសូត្ររបស់សិស្សផ្ដល់បរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព។

(២)ការអនុវត្តវិជ្ជាជីវៈ គឺរៀបចំផែនការមេរៀន និងកម្មវិធីបង្រៀនច្បាស់លាស់ និងមានប្រសិទ្ធភាពរៀបចំឧបករណ៍បង្រៀន និងសម្ភារៈសិក្សា ប្រើវិធីសាស្ត្រសមស្របជាច្រើន ផ្ដល់មតិកែលម្អដល់សិស្ស និងឪពុកម្ដាយ ឬអាណាព្យាបាលអភិវឌ្ឍនូវចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រើប្រាស់វិធីសាស្ត្របង្រៀនយ៉ាងទូលំទូលាយសម្រួលដល់ការសិក្សារបស់សិស្ស និងស្របតាមស្តង់ដាកម្មវិធីសិក្សាពកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ហើយប្រើប្រាស់ICT ដើម្បីធ្វើឱ្យការបង្រៀនរបស់គ្រូកាន់តែមានប្រសិទ្ធភាព។

(៣) ការរៀន និងស្រាវជ្រាវបន្ត គឺគ្រូបង្រៀនត្រូវចូលរួមក្នុងសកម្មភាពសិក្សាដោយខ្លួនឯង វាយតម្លៃជាប្រចាំនូវយុទ្ធសាស្ត្របង្រៀន និងអភិវឌ្ឍខ្លួនឯងផែនការសម្រាប់ ការសិក្សាវិជ្ជាជីវៈដែលដឹកនាំដោយខ្លួនឯង អភិវឌ្ឍចំណេះដឹង និងជំនាញ ICT កែលម្អជំនាញទំនាក់ទំនង ដើម្បីទំនាក់ទំនងកាន់តែប្រសើរឡើងសិស្ស និងឪពុកម្ដាយជាមួយមិត្តរួមការងារ និងសមាជិកនៃសហគមន៍។

(៤)ក្រមសីលធម៌ គឺគ្រូបង្រៀនគួរយកចិត្តទុកដាក់ និងបង្ហាញការយកចិត្តទុកដាក់ចំពោះសិស្ស ហើយតែងតែធ្វើការឆ្ពោះទៅរកផលប្រយោជន៍រួម និងសង្គម[76]។ ធ្វើជាគំរូវិជ្ជមាននៃអាកប្បកិរិយាសីលធម៌ និងជំរុញឱ្យមានសុខដុមរមនាទំនាក់ទំនងជាមួយសិស្ស និងសហគមន៍សាលាទាំងមូល។

មួយវិញទៀត ប្រព័ន្ធនៃការបណ្ដុះបណ្ដាលគ្រូបង្រៀននៅកម្ពុជាចាប់ពីកម្រិតបឋមរហូតដល់ឧត្តម ពុំដូចគ្នាឡើយ គឺអាស្រ័យទៅតាមការផ្លាស់ប្ដូរនៃប្រព័ន្ធអប់រំកម្ពុជាពី១០ឆ្នាំ ទៅ១១ឆ្នាំ និង១២ឆ្នាំ។ កត្តាទាំងអស់នេះនាំឱ្យគុណវុឌ្ឍិគ្រូបង្រៀននៅទូទាំងប្រទេសពុំដូចគ្នាឡើយ ដែលជំរុញឱ្យក្រសួងអប់រំបានធ្វើការបណ្ដុះបណ្ដាល(In-service)វគ្គខ្លី វគ្គវែងជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងបរិបទនៃតម្រូវការរបស់សង្គមកម្ពុជា។

## ៦.៣.ការបន្តអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤មានមុំទី១ស្ដីពី«ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា»បានផ្ដល់អាទិភាពលើចំណុចសំខាន់ៗចំនួន៧រួមមាន(១)ការយកចិត្តទុកដាក់លើគ្រូបង្រៀន (២)ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត (៣)ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន (៤)ការជំរុញការអប់រំបច្ចេកទេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ (៥)ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ (៦)ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង(៧)ការត្រៀមប្រកួតកីឡាស៊ីហ្គេម២០២៣។ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនពិតជាមានសារៈ

---

[76] ក្រសួងអប់រំ យុវជន និងកីឡា, ស្តង់ដាគ្រូបង្រៀន, ឆ្នាំ២០១០, ទំ២១។

សំខាន់ព្រោះគ្រូបង្រៀនត្រូវមានសមត្ថភាពទាំងចំណេះដឹង និងចំណេះធ្វើ បំណិនឌីជីថល ដែលអាចផ្តល់ការអប់រំមួយប្រកបដោយគុណភាពធ្វើឱ្យសិស្សចូលរៀន រៀនចេះ រៀនចប់ ប្រឡងជាប់ និងទទួលបាននូវការងារមួយស្របទៅតាមសមត្ថភាព និងចំណេះដឹងរបស់ពួកគេផងដែរ[77]។

លោក Elmore (2014) បានផ្តល់នូវទស្សនៈយល់ស្របអំពីការអភិវឌ្ឍវិជ្ជាជីវៈដែលមានប្រសិទ្ធភាព (១) ផ្តោតលើការរៀនសូត្ររបស់សិស្សអំពីមុខវិជ្ជាស្នូលនិងជំនាញ (២) ទាញយកពីការវិភាគនៃការរៀនសូត្ររបស់សិស្សអំពីខ្លឹមសារជាក់លាក់នៅក្នុងទម្រង់ជាក់លាក់ (៣) ផ្តោតលើបញ្ហាជាក់លាក់នៃកម្មវិធីសិក្សានិងគរុកោសល្យ (៤) ទាញចេញពីការស្រាវជ្រាវនិងការអនុវត្តគំរូ (៥) ផ្សារភ្ជាប់បញ្ហាជាក់លាក់នៃការបង្រៀន និងការរៀនសូត្ររបស់សិស្សអំពីមុខវិជ្ជា និងជំនាញទៅក្នុងបរិបទថ្នាក់រៀន (៦) អភិវឌ្ឍពង្រឹង និងទ្រទ្រង់ការងារជាក្រុម (៧) ជានានូវការអនុវត្តរួមគ្នានៅក្នុងសាលារៀន និងបណ្តាញសាលា (៩) ការចូលរួមយ៉ាងសកម្មរបស់ថ្នាក់ដឹកនាំសាលា និងបុគ្គលិក (១០) បន្តកែលម្អ ក្នុងរយៈពេលមួយ (១១) ផ្តល់គំរូនៃការអនុវត្តប្រកបដោយប្រសិទ្ធភាព (១២) ផ្តល់ឱ្យដល់សាលារៀននិងថ្នាក់រៀន (១៣) ការអនុវត្តស្របនឹង ខ្លឹមសារ (១៤) ប្រើប្រាស់រង្វាយតម្លៃការសិក្សារបស់សិស្សនិងការវាយតម្ល (១៥) ឃ្លាំមើលការរៀន សូត្ររបស់សិស្សជាប្រចាំ និង (១៦) ផ្តល់នូវយោបល់ត្រឡប់លើការរៀនសូត្ររបស់គ្រូ និងកិច្ចការបង្រៀន។

ប្រទេសភាគច្រើន ការបណ្តុះបណ្តាលគ្រូបង្រៀនគឺជាដំណើរការដែលធ្វើជាប់ជាប្រចាំ ពោលគឺចាប់ផ្តើមនៅពេលគរុសិស្ស គរុនិស្សិតទទួលការបណ្តុះបណ្តាលដំបូង។ក្រោយពីបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ និងទទួលបានសញ្ញាបត្រគ្រូបង្រៀនត្រូវបន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនពេញមួយជីវិត ព្រោះការសិក្សាពេញមួយជីវិតបានក្លាយជាប្រធានបទដ៏សំខាន់សម្រាប់ការអប់រំសំដៅធានាសិទ្ធិ សេរីភាព និងសុភមង្គល បុគ្គល គ្រួសារ និងសង្គម ឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មីៗ ឬអាចនិយាយបានថាការសិក្សាពេញមួយជីវិតជាដំណើរការរៀនសូត្រទាំងនៅក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការតាំងពីការចាប់កំណើតរហូតដល់វ័យជរាក្នុងគោលដៅអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទាឱ្យក្លាយជាពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នាប្រកបដោយភាពសុខដុមនៅក្នុងសង្គម[78]។ គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតម្រូវឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំក្លាយទៅជាអ្នកសិក្សារៀនពេញមួយជីវិត។

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគួរតែ៖

- ធ្វើឡើងជាប្រចាំ
- ធ្វើស្វ័យភាព និងគ្រប់គ្រងការសិក្សាដោយខ្លួនឯង

---

[77] https://m.freshnewsasia.com/index.php/en/localnews/

[78] ក្រសួងអប់រំ យុវជន និងកីឡា, សៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, ឆ្នាំ២០២១, ទំ.៨។

- អនុវត្តផ្អែកតាមតម្រូវការ និងស្ថានភាពអភិវឌ្ឍន៍បច្ចុប្បន្នរបស់បុគ្គលម្នាក់ៗ
- កំណត់ពីលទ្ធផលការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈឱ្យបានច្បាស់លាស់ ដើម្បីបំពេញទៅតាមតម្រូវការរបស់បុគ្គល និងអង្គភាព
- វាយតម្លៃលទ្ធផលសិក្សាដោយផ្អែកលើសកម្មភាព និងភស្តុតាងជាក់លាក់
- ទិដ្ឋភាពនៃការអភិវឌ្ឍវិជ្ជាជីវៈត្រូវធ្វើឡើងតាមវិធីច្រើនយ៉ាងដូចជា សិក្ខាសាលា វគ្គបំប៉ន វគ្គបណ្តុះបណ្តាល សន្និសីទជាដើម។

គោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀនដោយកំណត់ឱ្យចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំចំនួន១០០ម៉ោងក្នុងមួយឆ្នាំ គឺប្រហែលជា៣ម៉ោងក្នុងមួយសប្តាហ៍។ គោលនយោបាយនេះផ្តល់អនុសាសន៍ឱ្យគ្រូបង្រៀនត្រូវចំណាយពេលមិនបង្រៀន៥ថ្ងៃក្នុងមួយឆ្នាំ ស្មើនឹង៤០ម៉ោងដែលមានន័យថា ចាំបាច់ត្រូវចំណាយពេលផ្ទាល់ខ្លួន៦០ម៉ោងទៀតសម្រាប់ចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទើបអាចបាន១០០ម៉ោង។ នៅក្នុងការអនុវត្តជាក់ស្តែងគ្រូបង្រៀនមានសិទ្ធិ និងលទ្ធភាពចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំយ៉ាងហោចណាស់៣ម៉ោងក្នុងមួយសប្តាហ៍ ដោយប្រើប្រាស់ម៉ោងបំពេញការងារ។

ឧទាហរណ៍ គ្រូបង្រៀនបឋមសិក្សាមិនបង្រៀននៅថ្ងៃព្រហស្បតិ៍សប្តាហ៍ទី៤នៃខែនីមួយៗ ដែលជាថ្ងៃសម្រាប់ប្រជុំបច្ចេកទេស ប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ(PLC)ជួយសិស្សរៀនយឺតជាដើម ហើយផ្តល់ឱកាសឱ្យគ្រូបង្រៀនបឋមសិក្សាចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរយៈពេល៣ម៉ោងនៅក្នុងអំឡុងពេលនេះ។ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិបង្រៀន១៨ម៉ោង និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិបង្រៀន១៦ម៉ោង ដែលផ្តល់លទ្ធភាពឱ្យពួកគេមានពេល៣ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ក្នុងករណីគ្រូបង្រៀន បង្រៀនពីរវេន នៅតាមសាលារៀនដែលជួបប្រទះនឹងការខ្វះគ្រូបង្រៀន អាចប៉ះពាល់ដល់ការចូលរួមក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ បន្ថែមលើកាតព្វកិច្ចចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ១០០ម៉ោងក្នុង មួយឆ្នាំ ដើម្បីទទួលបានក្រេឌីតបន្ថែម គ្រូបង្រៀនដែលមានបំណងចូលរួមសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលចុងសប្តាហ៍ និងវិស្សមកាល។

### ៦-៣.១.ការរៀបចំផែនការសិក្សាវិជ្ជាជីវៈ

គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗត្រូវមានផែនការអភិវឌ្ឍវិជ្ជាជីវៈ ដែលនៅក្នុងបរិបទនេះគេហៅថា ផែនការសិក្សាវិជ្ជាជីវៈ[79]។ នៅក្នុងផែនការនេះ ត្រូវមានសមាសភាពដូចជា៖
- ផ្នែកអនុវត្ត ឬចំណេះដឹងដែលត្រូវផ្តោតការយកចិត្តទុកដាក់ ដែលតម្រូវឱ្យមានការវាយតម្លៃ

[79] ក្រសួងអប់រំ យុវជន និងកីឡា,សៀវភៅណែនាំការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ, អ.យ.ក,ឆ្នាំ២០២១ ទំ១២។

- គោលបំណង ដែលរំពឹងថា នឹងសម្រេចបាន
- ជំនាញសំខាន់ៗដែលចាំបាច់ដើម្បីសម្រេចគោលបំណងនីមួយៗ
- សកម្មភាព ឬវិធីសម្រេចគោលបំណង
- លក្ខណៈវិនិច្ឆយកំណត់ភាពជោគជ័យ

ផែនការសិក្សាវិជ្ជាជីវៈ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងការងារប្រចាំឆ្នាំរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ។

### **៦.៣.២ ប្រព័ន្ធគាំទ្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ**

**៦-៣-២.១-បើតាមសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំយុវជន និងកីឡាបានកំណត់ប្រព័ន្ធគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរួមមាន៖**

ក-ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់ គឺជាសកម្មភាពផ្តល់ដោយអ្នកសេវាអប់រំដែលមានការទទួលស្គាល់គុណភាព និងមានការកំណត់ច្បាស់លាស់នូវសកម្មភាពបណ្តុះបណ្តាលផ្ទាល់ដែលធ្វើឡើងជាទម្រង់សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន សកម្មភាពស្រាវជ្រាវជាក្រុម ឬសកម្មភាពដទៃទៀត។ ជាទូទៅអ្នកសិក្សាបានចូលរួមសកម្មភាពផ្ទាល់ដែលមួយម៉ោងត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់២ម៉ោងបន្ថែម ហើយគ្រូបង្រៀនត្រូវមាននាទីសំខាន់ និងជាម្ចាស់ការក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានរចនាសម្ព័ន្ធច្បាស់លាស់ក៏តម្រូវឱ្យធ្វើស្វ័យសិក្សាក្នុងក្របខណ្ឌពេលវេលាមួយសមស្រប ដែលតម្រូវឱ្យគ្រូបង្រៀន ឬនាយកសាលាបង្ហាញថា ពិតជាបានចូលរួមនៅក្នុងដំណើរការអភិវឌ្ឍវិជ្ជាជីវៈពិតប្រាកដមែន ហើយបង្ហាញពីភស្តុតាងមេរៀនដែលទទួលបានអាចយកទៅប្រើប្រាស់នៅក្នុងថ្នាក់រៀន ឬសាលារៀន ដើម្បីឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងនីតិវិធីដែលជួយឱ្យការបង្រៀន និងការដឹកនាំកាន់តែមានភាពល្អប្រសើរ។

ខ-ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯង

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដោយខ្លួនឯងធ្វើឡើងផ្អែកទៅតាមប្រភពជាតុចូល និងលក្ខខណ្ឌតម្រូវដែលគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗស្វែងរកដោយខ្លួនឯង ដោយមិនប្រើប្រាស់សេវារបស់អ្នកផ្តល់សេវា។ ប្រភពជាតុចូលទាំងនេះរួមមានៈវគ្គបណ្តុះបណ្តាលអនឡាញបើកទូលាយ ការចូលរួមនូវបទបង្ហាញស្នាដៃស្រាវជ្រាវល់ខ្លួននៅក្នុងសន្និសីទ ឬសកម្មភាពសិក្សាវិជ្ជាជីវៈដទៃទៀត ការចូលរួមនៅក្នុងការស្រាវជ្រាវ ការអានឯកសារស្រាវជ្រាវវិជ្ជាជីវៈក្នុងទម្រង់ជាព្រឹត្តិបត្រស្រាវជ្រាវ ឬសៀវភៅ ការស្រាវជ្រាវ និងបោះពុម្ពផ្សាយអត្ថបទអ្វីមួយជាដើម។

ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺរៀនដោយខ្លួនឯងពីប្រភពមិនទាន់មានការទទួលស្គាល់គុណភាពក៏អាចទទួលបានក្រេឌីតដែរ។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវដាក់សំណើសុំការ

ទទួលស្គាល់គុណភាពទៅការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើប្រភេទដែលខ្លួនបានសិក្សា។ ចំពោះការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរៀនដោយខ្លួនឯងពីប្រភពណាមួយក្នុងរយៈពេល១ម៉ោង អ្នកចូលរួមត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់២ម៉ោងបន្ថែម។ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំត្រូវបង្ហាញពីការចូលរួមយ៉ាងសកម្មក្នុងដំណើរការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈការផ្តល់ជាភស្តុតាងបញ្ជាក់ថា ពិតជាបានយកទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈនៅក្នុងថ្នាក់រៀន សាលារៀន និងត្រូវធ្វើការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងបង្ហាញពីរបៀបការសិក្សា ដែលជួយឱ្យការបំពេញការងារកាន់តែល្អប្រសើរជាងមុន។

**៦-៣-២.២-ចំពោះឯកសារស្តីពីក្របខណ្ឌអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនអាស៊ាន**(Southeast AsiaTeachers Competency Framework Published in 2018 by the Teachers' Council of Thailand Bangkok)បានកំណត់ស្តីពីការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនក្នុងក្របខណ្ឌអាស៊ានមានចំនួន ៣គឺ[80]៖

## ក-ការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈការងារប្រចាំថ្ងៃ

ការចូលបំពេញការងារវិជ្ជាជីវៈក្នុងអង្គភាព ដែលមានការចាត់តាំងត្រឹមត្រូវនៅក្នុងផ្នែកណាមួយ គឺជាឱកាសល្អ ដើម្បីស្វែងយល់បន្ថែមអំពីចំណេះដឹង និងបទពិសោធថ្មីលើការងារប្រចាំថ្ងៃដែលលោកគ្រូ អ្នកគ្រូកំពុងអនុវត្តដូចជាការបង្រៀន ការស្រាវជ្រាវ ការងារពិសោធវិទ្យាសាស្ត្រ និងការងាររដ្ឋបាលជាដើម ហើយការងារទាំងអស់នេះបានជួយបង្កើនសមត្ថភាពថ្មីជាច្រើនទៀតដល់លោកគ្រូ អ្នកគ្រូសម្រាប់យកទៅបង្រៀនសិស្ស និស្សិត និងការគ្រប់គ្រងនៅក្នុងអង្គភាព។ ការបង្វឹក គឺជាដំណើរការនៃការផ្តល់សេចក្តីណែនាំជាជំហានៗ អំពីរបៀបអភិវឌ្ឍជំនាញជាក់លាក់ទាក់ទងនឹងការបង្រៀន។ ការបង្វឹកគ្រូផ្សេងទៀត គឺជាវិធីនៃការអនុវត្តអ្វីដែលអ្នកដឹងអំពីការអនុវត្តន៍ការបង្រៀន និងការរៀនពីរបៀបដែលអ្នកអាចកែលម្អលើលើកំហុសឆ្គង។ ការរៀនតាមរយៈការពិសោធន៍មានន័យថា សិក្សាពីរបៀបដែលអ្វីៗតែងតែត្រូវបានធ្វើ និងព្យាយាមតាមរបៀបថ្មី។ តាមរយៈសកម្មភាពនេះ យើងអាចបង្រៀនខ្លួនយើង និងបង្កើតការយល់ដឹងកាន់តែទូលំទូលាយអំពីកិច្ចការកាន់តែប្រសើរជាងមុន។

## ខ-ការរៀនពីអ្នកដទៃ(បុគ្គលិកក្នុងអង្គភាពជាមួយគ្នា)

ការទទួលបានការហ្វឹកហាត់ពីអ្នកគ្រប់គ្រង ឬមិត្តភ័ក្ត ដៃគូរបស់អ្នកក្នុងស្ថាប័ន ឬអង្គភាព ដែលមានទំនុកចិត្តលើរបៀបដែលអ្វីៗកំពុងដំណើរការបានជួយអ្នកឱ្យរៀនជំនាញថ្មីបន្ថែម ក្នុងការអនុវត្តការបង្រៀន និងរៀន។ ការសង្កេត និងការកត់ចំណាំរបស់គ្រូបង្រៀនល្អផ្សេងទៀត ដែលទទួលបានជោគជ័យក្នុងការងារបានបង្រៀនអ្នកអំពីការអនុវត្តល្អបំផុតរបស់យើង និងរបៀបដែលពួកយើងអាចយកឈ្នះលើបញ្ហាប្រឈមនានា។ សមាជិកភាពនៅក្នុងអង្គការវិជ្ជាជីវៈអាចបង្កើនជំនាញវិជ្ជាជីវៈ និងពង្រីកសមត្ថភាព

[80] Southeast AsiaTeachers Competency Framework, Thailand Bangkok, 2018.p22.

ដែលទាក់ទងនឹងការងារប្រចាំថ្ងៃ ហើយបានអនុញ្ញាតឱ្យយើងមានទំនាក់ទំនងជាមួយបុគ្គលផ្សេងទៀត ដែលមានចំណាប់អារម្មណ៍ដូចគ្នា និងបញ្ហាប្រឈមការងារស្រដៀងគ្នា។

ការសួរសំណួរ គឺជាមធ្យោបាយដ៏ល្អមួយដើម្បីស្វែងយល់អំពីការងាររបស់យើង សាលារបស់យើង និងអ្នកពាក់ព័ន្ធទាំងឡាយ។ ការពិភាក្សាអំពីការផ្លាស់ប្តូរគំនិត និងព័ត៌មានជាមួយគ្រូបង្រៀន និងបុគ្គលិកសាលា សិស្ស និងឪពុកម្តាយផ្សេងទៀត គឺបានអនុញ្ញាតឱ្យយើងបានយល់ដឹងអំពីទស្សនៈ និងបញ្ហានានាផ្សេងទៀត។ មធ្យាបាយនៃការភ្ជាប់បណ្តាញទំនាក់ទំនងជាមួយអ្នកជំនាញផ្សេងទៀតមានដូចជា អ៊ីមែល ទូរស័ព្ទ ការជួបទល់មុខគ្នា ឬការប្រជុំ ប្រព័ន្ធផ្សព្វផ្សាយសង្គម បណ្តាញសិក្សាវិជ្ជាជីវៈ តេលេក្រាម និងបណ្តាញផ្សេងៗជាច្រើនទៀត ដើម្បីរៀនពីបទពិសោធន៍ និងគំនិតផ្សេងទៀត ព្រមទាំងការចែករំលែករបស់អ្នកដទៃផ្សេងទៀត។

ដូច្នេះ ទិដ្ឋភាពនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានច្រើនទម្រង់ជាពិសេសក្នុងបរិបទឌីជីថល ដែលព័ត៌មាន និងចំណេះដឹងមានលក្ខណៈសម្បូរបែបអាចរកបាននៅស្ទើរគ្រប់ទីកន្លែង។

### គ-ការរៀនតាមរចនាសម្ព័ន្ធ

វគ្គបណ្តុះបណ្តាលមានរចនាសម្ព័ន្ធបានរៀបចំឡើងតាមផែនការសកម្មភាពរបស់អង្គភាព និងស្ថាប័ន ដែលដឹកនាំដោយគ្រូបង្រៀន និងអ្នកជំនាញច្បាស់លាស់ ហើយសកម្មភាពនេះផ្អែកលើជំនាញមួយពិតប្រាកដជាតម្រូវការរបស់អង្គភាព។ ជាធម្មតា ជាការបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូបង្រៀន និងមន្ត្រីគ្រប់គ្រងតាមអង្គភាព ឬតាមស្ថាប័នត្រូវបានគេរៀបចំ និងគ្រប់គ្រងដោយអង្គភាពផ្ទាល់ ឬអញ្ជើញអ្នកបណ្តុះបណ្តាលមកពីខាងក្រៅ ដែលត្រូវបានផ្តល់សេវាដោយក្រសួងអប់រំ។ ការអានជាជម្រើសដ៏មានប្រសិទ្ធភាពមួយដែលអាចដំណើរការបានយ៉ាងល្អក្នុងការពង្រឹងសមត្ថភាពបន្ថែម។ ការអានសៀវភៅ ឯកសារវិទ្យាសាស្ត្រ ឯកសារជំនួយនានា រឿងប្រលោមលោក គឺជាការបំពេញតម្រូវការសិក្សារបសអ្នកស្រាវជ្រាវ។ ការទស្សនាវីដេអូដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាលអាចផ្តល់នូវការយល់ដឹងបន្ថែមអំពីរបៀបអភិវឌ្ឍ និងពង្រឹងសមត្ថភាពក្នុងនាមជាគ្រូបង្រៀន។

ដូចនេះ សន្និសីទ សិក្ខាសាលា និងការប្រជុំពិគ្រោះយោបល់ គឺពិតមានសារៈសំខាន់សម្រាប់គ្រូបង្រៀន ដែលអនុញ្ញាតឱ្យគ្រូបង្រៀនទទួលបានព័ត៌មាន និងចំណេះដឹងថ្មីៗអំពីបញ្ហាសំខាន់ៗដែលទាក់ទងដល់ការបង្រៀន និងរៀនប្រចាំថ្ងៃតាមរយៈការចែករំលែកចំណេះដឹង ជំនាញ ការផ្លាស់ប្តូរបទពិសោធន៍ និងគំនិតក្នុងអង្គសិក្ខាសាលា។

### ៦.៤.សហគមន៍សិក្សាវិជ្ជាជីវៈគ្រូមធ្យមសិក្សា

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តនូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន គោលនយោបាយស្តីពីគ្រូបង្រៀន ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ក្របខណ្ឌស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន និងនាយកសាលា

ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀននិងសេចក្តីណែនាំប្រតិបត្តិក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនក្នុងគោលដៅអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន និងនាយកសាលា ដើម្បីបណ្តុះបណ្តាលវប្បធម៌រៀនពេញមួយជីវិត។ ក្នុងបរិការណ៍នេះ ក្រសួងបានការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀននៅក្នុងប្រព័ន្ធអប់រំកម្ពុជាដែលជាការឆ្លើយតបមួយដ៏ចាំបាច់ក្នុងការបង្កើនសមត្ថភាពបង្រៀនរបស់គ្រូ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

ដូចនេះ សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាក្រុមការងារដែលគ្រូបង្រៀនអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតតាមរយៈការសហការ ការចែករំលែក ការវិភាគ ការស្រាវជ្រាវប្រតិបត្តិ និងការឆ្លុះបញ្ចាំងលើការបង្រៀន និងរៀន។ សហគមន៍នេះទទួលបានការចាប់អារម្មណ៍ និងអនុវត្តក្នុងប្រព័ន្ធអប់រំទាំងនៅក្នុងពិភពលោក និងបណ្តាប្រទេសក្នុងតំបន់ដូចជាប្រទេសកូរ៉េខាងត្បូង សិង្ហបុរី ថៃ និងម៉ាឡេស៊ីជាដើម។ សហគមន៍សិក្សាវិជ្ជាជីវៈ ជាគ្រូបង្រៀន គ្រូឧទ្ទេស និងនាយកសាលា ដែលជាធ្វើការងាររៀនសូត្ររួមគ្នា រៀនសូត្រពីគ្នាទៅវិញទៅមកក្នុងដំណើរការស្រាវជ្រាវប្រតិបត្តិ ការសិក្សាស្រាវជ្រាវមេរៀន និងស្វ័យឆ្លុះបញ្ចាំងលើការប្រតិបត្តិ ដើម្បីធ្វើឱ្យប្រសើរដល់ទឹកចិត្តក្នុងការបំពេញការងារ លទ្ធផលការងារ និងលទ្ធផលសិក្សារបស់សិស្ស ដែលពួកគេកំពុងបង្រៀន។ សហគមន៍សិក្សាវិជ្ជាជីវៈ គឺជាសហគមន៍ដែលផ្តល់ការគាំទ្រចាំបាច់សម្រាប់ការបង្រៀននៅគ្រឹះស្ថានសិក្សា ដើម្បីឱ្យគ្រូបង្រៀនចេះរួបរួមគ្នាក្នុងការកំណត់សកម្មភាព និងអភិវឌ្ឍសមត្ថភាពជាប្រចាំដើម[81]។

សហគមន៍សិក្សាវិជ្ជាជីវៈ(PLC) គឺជាបណ្តុំនៃក្រុមអ្នកអប់រំដែលជួបជុំគ្នាជាទៀងទាត់ចែករំលែកចំណេះដឹង ជំនាញ និងធ្វើការរួមគ្នា ដើម្បីបង្កើនជំនាញបង្រៀន និងអនុវត្តការសិក្សារបស់សិស្ស។ បញ្ញត្តិសហគមន៍សិក្សាវិជ្ជាជីវៈនេះ ត្រូវបានគេអនុវត្តនៅតាមសាលារៀន និងមហាវិទ្យាល័យមាន ដែលន័យថាការសហការជាក្រុមតូច ដើម្បីសិក្សារៀនសូត្រ។ លោក ស៊ើលី ហាត(Shirley Hord) អ្នកជំនាញភាពជាអ្នកដឹកនាំសាលារៀនបានចេញមកពិពណ៌នាអំពីយុទ្ធសស្រ្តដ៏មានប្រសិទ្ធភាពនូវពាក្យថា អភិវឌ្ឍវិជ្ជាជីវៈត្រូវភ្ជាប់ជាមួយពាក្យថា ក្រុម សហគមន៍ និងសិក្សារៀនសូត្រ។ គួរកត់សម្គាល់ថា សហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានគេហៅបានច្រើនបែបច្រើនយ៉ាងពីសាលាមួយទៅសាលា ឬកន្លែងមួយទៅកន្លែងមួយទៀតដូចជាក្រុមសិក្សាវិជ្ជាជីវៈ សហគមន៍សិក្សារួមគ្នា ឬសហគមន៍អនុវត្តនៃការសិក្សា ត្រូវបានអនុវត្តជាក្រុមតូចៗចន្លោះពី៤ទៅ៨នាក់។ នៅប្រទេសជប៉ុន សហគមន៍សិក្សាវិជ្ជាជីវៈត្រូវបានគេហៅថា ការសិក្សាមេរៀន ឬការស្រាវជ្រាវមេរៀន(Lesson Study)។ លើសពីនេះសហគមន៍សិក្សាវិជ្ជាជីវៈអាចយកទម្រង់ផ្សេងៗគ្នា ឬរៀបចំសម្រាប់គោលបំណងផ្សេងៗ។ ខណៈពេលខ្លះទៀត អ្នកអប់រំកំណត់សហគមន៍សិក្សាវិជ្ជាជីវៈតាមរបៀបជាក់លាក់មួយ។ លោក រីឆាត ឌូហ្វ័រ(Richard DuFour)ត្រូវបានគេចាត់ទុកថា ជាអ្នកជំនាញ

---

[81] ក្រសួងអប់រំ យុវជន និងកីឡា, សៀវភៅស្តីការបង្កើតសហគមន៍សិក្សាវិជ្ជាជិវៈនៅតាមគ្រឹស្ថានសិក្សាសាធារណៈ, អ.យ.ក, ឆ្នាំ២០២១, ទំ.អារម្ភកថា។

សំខាន់ម្នាក់លើផ្នែកសហគមន៍សិក្សាវិជ្ជាជីវៈបានសរសេរក្នុងឆ្នាំ២០០៤ថា សហគមន៍សិក្សាវិជ្ជាជីវៈគួរត្រូវបានអនុវត្តចំពោះសាលារៀន ដែលគ្រូបង្រៀន និងអ្នកដឹកនាំសាលាទាំងអស់ប្រើជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សមត្ថភាពគ្រូបង្រៀន។

សហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន (Professional Learning Community,PLC) ជាកន្លែងមួយដែលគ្រូបង្រៀនគាំទ្រគ្នាទៅវិញទៅមក ចែករំលែកនិងការពង្រឹងបទដ្ឋានអាកប្បកិរិយាវិជ្ជមានគ្នាបានយ៉ាងល្អ ។ វិធានការសំខាន់ៗមួយចំនួន ដើម្បីធានាថាមានសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន សាលារៀនត្រូវកសាងវប្បធម៌បែបវិជ្ជាជីវៈច្បាស់លាស់ ដោយគ្រូបង្រៀនរួមមានការតាំងចិត្តអនុវត្តទៅតាមបទដ្ឋានសាលារៀន គ្រូបង្រៀនត្រូវមានផែនការប្រជុំ និងចែករំលែកចំណេះដឹងដល់គ្នាឱ្យបានទៀងទាត់គ្រូបង្រៀនចេះប្រើប្រាស់បណ្ដាញសង្គម ដើម្បីចែករំលែកព័ត៌មានធនធានអប់រំ។ ទន្ទឹមគ្នានេះ គ្រូអាចជជែកកម្សាន្តជាមួយគ្នាក្រៅផ្លូវការខណៈពេលសម្រាកអាហារថ្ងៃត្រង់ឬពេលម៉ោងទំនេរបង្កើនការប្រាស្រ័យទាក់គ្នា។

### ៦.៥.សកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈ

ការបង្កើត និងដំណើរការសហគមន៍សិក្សាត្រូវផ្អែកលើគោលការណ៍សំខាន់ៗ គឺវប្បធម៌សហការការផ្ដោតលើលទ្ធផលសិក្សារបស់សិស្ស និងការពិភាក្សាឆ្លុះបញ្ចាំង។

- វប្បធម៌សហការ គឺសំដៅលើប្បធម៌មួយ ដែលមានការទុកចិត្តគ្នា និងពឹងផ្អែកគ្នាទៅវិញទៅមកគ្រប់សមាជិកទាំងអស់នៅក្នុងសហគមន៍ ដើម្បីផ្ដល់ឱកាសអំណាច និងសិទ្ធិសេរីភាពទៅគ្រូបង្រៀនដើម្បីធ្វើការសិក្សា និងរៀបចំផែនការរួមគ្នា ហើយជជែកដេញដោលគ្នាទៅវិញទៅមកអំពីការអនុវត្តការងារចំណេះដឹង និងផ្នត់គំនិតដែលទាក់ទង និងការបង្រៀន ហើយអ្វីសំខាន់ ដើម្បីសហការគ្នាបានល្អក្នុងការអភិវឌ្ឍសមត្ថភាព។
- ការផ្ដោតលើលទ្ធផលសិក្សារបស់សិស្ស និងសកម្មភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈត្រូវតែផ្ដោតលើការរីកចម្រើន និងការអភិវឌ្ឍរបស់សិស្សជាចម្បង ហើយក្នុងពេលនិយាយពីការអភិវឌ្ឍសាលារៀនគឺសំដៅលើលទ្ធផលសិក្សារបស់សិស្ស។
- ការពិភាក្សាឆ្លុះបញ្ចាំងសំដៅទៅលើការសន្ទនា ដែលផ្ដោតលើវិធីសាស្ត្របង្រៀនរបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្ស។ ការពិភាក្សានេះ លើកទឹកចិត្តគ្រូបង្រៀនឱ្យពិភាក្សាទៅលើការបង្រៀន និងសហការគ្នារិះរកវិធីសាស្ត្រដែលអាចធ្វើឱ្យការបង្រៀនមានភាពរីកចម្រើនបន្ថែម។ គ្រូបង្រៀនពិភាក្សាស៊ីជម្រៅលើកម្មវិធីសិក្សា ការបង្រៀន និងការរៀន ហើយត្រូវឆ្លុះបញ្ចាំងលើសំណួរគន្លឹះសំខាន់ធំៗក្នុងពេលបង្រៀន។

#### ៦.៥.១-សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់ឧទ្ទេស

គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនត្រូវរៀបចំសហកមន៍សិក្សាវិជ្ជាជីវៈ ដោយប្រើប្រាស់ក្រុមបច្ចេកទេសតាមមុខវិជ្ជាឯកទេសដូចគ្នាដែលមានស្រាប់។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវមាន

ប្រធានក្រុមម្នាក់ និងអ្នកសម្របសម្រួលម្នាក់ ដែលជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្របសម្រួល គឺជាអ្នកមានបទពិសោធការងារ បច្ចេកទេស កម្រិតវប្បធម៌ និងស្មារតីទទួលខុសត្រូវចំពោះសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ។ ចំពោះគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូត្រូវមានប្រធានក្រុម និងអ្នកសម្របសម្រួលអាចជាគ្រូឧទ្ទេសល្អ គ្រូឧទ្ទេសឈានមុខ ឬគ្រូឧទ្ទេសឆ្នើម ដែលទទួលបានពានរង្វាន់ស្នាដៃការងារក្នុងការសិក្សាស្រាវជ្រាវ និងការងារបង្រៀន និងរៀន។ បន្ថែមពីនេះប្រធានក្រុមក៏អាចជ្រើសរើសយកពីមន្ទីរ គ្រឹះស្ថានឧត្ដមសិក្សា និងនាយកដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ លើកលែងតែអ្នកសម្របសម្រួល គឺត្រូវតែជានាយកគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ។ ប្រធានក្រុម និងអ្នកសម្របសម្រួលត្រូវធ្វើការជ្រើសរើសដោយការតែងតាំងឬបោះឆ្នោត និងធ្វើការផ្លាស់ប្ដូរមុនឆ្នាំសិក្សានីមួយៗ។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗអាចប្រែប្រួលតាមការជាក់ស្ដែង។ ករណីមុខវិជ្ជាដែលមានគ្រូឧទ្ទេសតិចជាង០៥នាក់ នាយកអាចចាត់បញ្ចូលគ្នាជាមួយក្រុមបច្ចេកទេសផ្សេងទៀតជាមុខវិជ្ជាពាក់ព័ន្ធគ្នាតាមការជាក់ស្ដែង។

ឧទាហរណ៍៖

-ក្រុមបច្ចេកទេសភូមិវិទ្យា ប្រវត្តិវិទ្យា

-ក្រុមបច្ចេកទេសគីមីវិទ្យា ជីវវិទ្យា

-ក្រុមបច្ចេកទេសគណិតវិទ្យា រូបវិទ្យា

- ក្រុមបច្ចេកទេសភាសាខ្មែរ សីលធម៌-ពលរដ្ឋវិជ្ជា

ករណីគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូមានចំនួនគ្រូទ្ទេសតិច នាយកអាចចែកជាពីរក្រុមមុខវិជ្ជាគឺ៖

- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រពិត

- ក្រុមមុខវិជ្ជាវិទ្យាសាស្ត្រសង្គម

### ៦.៥.២.តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេសត្រូវមានផែនការគោលរួមមួយដោយមានកំណត់នូវចក្ខុវិស័យ បេសកកម្មច្បាស់លាស់ និងសកម្មភាពអាទិភាព ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍នេះ ត្រូវផ្ដោតលើការងារស្រាវជ្រាវប្រតិបត្តិ ការស្រាវជ្រាវគរុកោសល្យ ការស្រាវជ្រាវលើខ្លឹមសារមុខវិជ្ជាឯកទេស ការងារបង្រៀននិងរៀន ការអភិវឌ្ឍកម្មវិធីសិក្សា ការងារគ្រប់គ្រងថ្នាក់រៀន និងការវិភាគលទ្ធផលសិក្សារបស់សិស្ស ដើម្បីធ្វើឱ្យគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនដំណើរការប្រកបដោយប្រសិទ្ធភាព

ដូច្នេះ សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូត្រូវមានភារកិច្ចដូចជា៖

- សិក្សាស្រាវជ្រាវឯកសារ សៀវភៅទាក់ទងការបង្រៀន និងរៀន
- ធ្វើការស្រាវជ្រាវប្រតិបត្តិ ដើម្បីកែលម្អការបង្រៀន និងរៀន

- អនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងធ្វើថ្នាក់និទស្សន៍ ដើម្បីផ្លាស់ប្ដូរបទពិសោធ
- ចាត់តាំងសមាជិកឱ្យចូលស្ដាប់ការបង្រៀន និងការអប់រំគរុសិស្សរបស់គ្រូឧទ្ទេសណាម្នាក់ ហើយផ្លាស់ប្ដូរយោបល់ និងដកបទពិសោធ
- ចងក្រងវិធីបង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព
- ចែករំលែកបទពិសោធន៍ការស្រាវជ្រាវ ឬប្រសិទ្ធភាពរកបរបង្រៀន និងរៀនដល់សមាជិក
- ធ្វើបទបង្ហាញចំណេះដឹង ដែលសមាជិកទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា
- ដឹកនាំថតជាវីដេអូនៃការបង្រៀន និងរៀនថ្មីៗសម្រាប់ចែករំលែកដល់សាលារៀនដទៃ
- ជួយសមាជិករៀបការអភិវឌ្ឍវិជ្ជាជីវប្រចាំឆ្នាំ ព្រមទាំងតាមដាននូវការអនុវត្ត ដើម្បីធ្វើឱ្យសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈ
- ធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្ស និងរកវិធីកែលម្អលទ្ធផលសិក្សារបស់គរុសិស្ស និស្សិត

### ៦.៥.៣. របៀបរបបអនុវត្តការងារ

### ក.ការសិក្សាជាក្រុម

ការប្រជុំត្រូវដឹកនាំសម្របសម្រួលដោយប្រធានក្រុម និងអ្នកសម្របសម្រួល។រាល់ការប្រជុំត្រូវមានលិខិតប្រជុំអមដោយរបៀបវារៈប្រជុំជូនជាព័ត៌មាន ឬជាការអញ្ជើញគណៈគ្រប់គ្រងអង្គភាព និងនាយករងបច្ចេកទេស ដើម្បីជួយសម្របសម្រួល និងផ្តល់មតិកែលម្អរួម។ ចំពោះការបរិច្ឆេទនៃការជួបជុំគ្នាត្រូវតែមានការឯកភាពគ្នាតាមសហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗ ផ្អែកលើផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ណាមួយ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ដោយអនុវត្ត៤ដងក្នុងមួយខែ និងមានការឯកភាពយកថ្ងៃណាមួយតាមការជាក់ស្តែង។

ឧទាហរណ៍៖

ក្រុមមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា

- ព្រឹកថ្ងៃសុក្រពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី

ក្រុមមុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា

- រសៀលថ្ងៃពុធ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី

ការប្រជុំអាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិចដូចជា Zoom ឬ Google Meetជាដើម។ ចំពោះទីតាំងប្រជុំអាចកំណត់យកនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ឬធ្វើនៅទីតាំងខាងក្រៅដែលផ្តល់ផាសុខភាព និងមានភាពងាយស្រួលដល់សមាជិកទាំងអស់។ ប្រធានក្រុម និងអ្នកសម្របសម្រួលត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ និងជូនព័ត៌មានទៅគណៈគ្រប់គ្រងគ្រឹះស្ថានរបស់ខ្លួនដើម្បីជ្រាបជាព័ត៌មានផង និងអញ្ជើញឱ្យចូលរួមស្តាប់ និងផ្តល់យោបល់ឱ្យបានមុនមួយសប្តាហ៍។ ក្នុងករណីមានមេរៀន ឯកសារយោងត្រូវផ្ញើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួមការប្រជុំ។

រាល់ពេលប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បីរក្សាទុកជាឯកសារ ឬស្តុតាងក្នុងអង្គភាពហើយ សមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈស់ខ្លួន។

### ខ.ការសង្កេតថ្នាក់ និងប្រឹក្សា

ប្រធានក្រុមសហគមន៍ដែលត្រូវបានជ្រើសរើស ត្រូវមានតួនាទីបន្ថែមទៀត គឺជាគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សានីមួយៗ ហើយត្រូវសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដែលជាគ្រូប្រឹក្សាប្រចាំ គ្រឹះស្ថានបណ្តុះបណ្តាល ដើម្បីផ្តល់ដំបូន្មាន និងការគាំទ្រដល់គ្រូឧទ្ទេសធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវ ប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ ដោយផ្អែកវិធីកម្មវិធីបង្រៀនដាក់ស្តែង។ ការសង្កេតថ្នាក់ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ទី២ និងទី៣ ដោយជ្រើស រើសយកគ្រូឧទ្ទេសដែលទើបផ្ទេរចូលថ្មី ឬមានបទពិសោធន៍តិច ហើយធ្វើការបូកសរុបការងារ នៅរៀងរាល់ចុង សប្តាហ៍ទីបីនៃខែនីមួយៗ។ ព័ត៌មានដែលទទួលបានពីការសង្កេតថ្នាក់ គឺសម្រាប់ធ្វើការឆ្លុះបញ្ចាំងការត លើកក្រោយៗទៀត ហើយក៏អាចក្លាយជាប្រធានបទ សម្រាប់ដាក់ចូលក្នុងវារៈប្រជុំក្នុងខែនីមួយៗផងដែរ។ លើសពីនេះទៀត គ្រូប្រឹក្សាដែលជាប្រធានក្រុមសហគមន៍សិក្សា ត្រូវចាត់សមាជិករបស់ខ្លួនម្នាក់ៗ ឱ្យចូល សង្កេតការបង្រៀនរបស់គ្រូឧទ្ទេស ដែលមានបច្ចេកទេសខ្ពស់ ឱ្យបានពីរដងក្នុងមួយខែ ដើម្បីសិក្សាអំពីរបៀបច្នៃ ប្រឌិតវិធីសាស្រ្តសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពដាក់ស្តែងថ្នាក់នីមួយៗ។ រាល់ព្រឹត្តិបត្តិសង្កេត

## ៦.៦.សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូវិទ្យាល័យ និងអនុវិទ្យាល័យ

ជាទូទៅសាលាមធ្យមសិក្សាចំណេះទូទៅត្រូវរៀបចំសមាគមន៍សិក្សាវិជ្ជាជីវៈ ដោយប្រើប្រាស់ក្រុមបច្ចេកទេសតាមមុខវិជ្ជាឯកទេសដូចគ្នាដែលមានស្រាប់។ ប្រសិនបើសាលាមធ្យមសិក្សាចំណេះទូទៅមានចំនួនគ្រូបង្រៀនតិច នាយកសាលាអាចសហការជាមួយសាលាជិតខាងមានចម្ងាយមិនឱ្យលើស៣គ.ម.។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវមានប្រធានក្រុមម្នាក់ និងអ្នកសម្របសម្រួលម្នាក់ជ្រើសរើសក្នុងចំណោមសមាសភាពនៅក្នុងសហគមន៍សិក្សាផ្ទៃជីវៈនីមួយៗ។ ប្រធានក្រុម និងអ្នកសម្របសម្រួល គឺជាអ្នកមានបទពិសោធន៍ ការងារមានបច្ចេកទេស កម្រិតវប្បធម៌ខ្ពស់ និងមានស្មារតីទទួលខុសត្រូវលើសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួន។ ក្នុងអង្គភាពសាលារៀន ប្រធានក្រុម និងអ្នកសម្របសម្រួលអាចជាគ្រូបង្រៀនល្អ គ្រូបង្រៀនឈានមុន ឬគ្រូបង្រៀនឆ្នើម ដែលទទួលបានពានរង្វាន់ស្នាដៃការងារបង្រៀន និងរៀន។ ប្រធានក្រុម និងអ្នកសម្របសម្រួលត្រូវធ្វើការជ្រើសរើសដោយការតែងតាំង ឬបោះឆ្នោត និងធ្វើការផ្លាស់ប្តូរមុនឆ្នាំសិក្សានីមួយៗ។ ចំនួន និងសមាសភាពរបស់សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗអាចប្រែប្រួលតាមការដាក់ស្តែង។ ករណីមុខវិជ្ជាដែលមានគ្រូបង្រៀនតិចជាង០៥នាក់ នាយកសាលាអាចចាត់បញ្ចូលគ្នាជាមួយក្រុមបច្ចេកទេសផ្សេងទៀតតាមការដាក់ស្តែងៗ។

ឧទាហរណ៍៖

- ក្រុមបច្ចេកទេសភូមិវិទ្យា ប្រវត្តិវិទ្យា
- ក្រុមបច្ចេកទេសវិទ្យា ជីវវិទ្យា
- ក្រុមបច្ចេកទេសគណិតវិទ្យា រូបវិទ្យា
- ក្រុមបច្ចេកទេសភាសាខ្មែរ សីលធម៌-ពលរដ្ឋវិជ្ជា

ករណីសាលាមធ្យមសិក្សាមានគ្រូបង្រៀនតិច នាយកសាលាអាចចែកជាពីរក្រុមមុខវិជ្ជា គឺក្រុមមុខវិជ្ជាវិទ្យាសាស្ត្រពិត និងក្រុមមុខវិជ្ជាវិទ្យាសាស្ត្រសង្គម។ សាលារៀនមធ្យមសិក្សាចំណោះទូទៅក៏អាចបង្កើតជាសហគមន៍សិក្សាវិជ្ជាជីវៈជាកម្រិតថ្នាក់ផងដែរ ដោយយកការសិក្សារបស់សិស្សធ្វើជាប្រធានបទចម្បងក្នុងការពិភាក្សា និងចែករំលែក។

ឧទាហរណ៍៖ នៅក្នុងថ្នាក់ទី៧ គ្រូមុខវិជ្ជាផ្សេងៗអាចបង្កើតសហគមន៍ ដើម្បីពិភាក្សាពីកាសិក្សារបស់សិស្សណាម្នាក់ ក្រុមសិស្សណាមួយ ឬសិស្សទាំងអស់ក្នុងថ្នាក់។ ចំពោះសាលាសិក្សាចំណោះទូទៅដែលមានចាប់ពីថ្នាក់ទី៧ហូតដល់ថ្នាក់ទី១២ អាចបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈបញ្ចូលគ្នាក៏អាចធ្វើបានដែរ។

ឧទាហរណ៍៖ ក្រុមមុខវិជ្ជាគីមីវិទ្យានៅកម្រិតបឋមភូមិអាចចូលរួមបង្កើតសហគមន៍សិក្សាមុខវិជ្ជាគីមីវិទ្យាជាមួយគ្រូនៅកម្រិតទុតិយភូមិ។

### ៦.៦.១.តួនាទី និងភារកិច្ច

សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនអនុវិទ្យាល័យ ឬវិទ្យាល័យត្រូវមានផែនការគោលរួមមួយ ដែលមានកំណត់នូវចក្ខុវិស័យ បេសកកម្មច្បាស់លាស់ និងសកម្មភាពអាទិភាព ដើម្បីសម្រេចគោលដៅដែលខ្លួនចង់បាន។ សហគមន៍នេះ ត្រូវផ្តោតលើការងារស្រាវជ្រាវប្រតិបត្តិ ការស្រាវជ្រាវគរុកោសល្យ ការស្រាវជ្រាវលើខ្លឹមសារមុខវិជ្ជាឯកទេស ការងារបង្រៀន និងរៀន ការអភិវឌ្ឍកម្មវិធីសិក្សា និងការងារគ្រប់គ្រងថ្នាក់រៀនជាដើម ដើម្បីធ្វើឱ្យសាលារៀនមានដំណើរការប្រកបដោយប្រសិទ្ធភាព។

ដូច្នេះសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គូបង្រៀននៅវិទ្យាល័យ ឬអនុវិទ្យាល័យត្រូវមានភារកិច្ចមួយចំនួនដូចជា៖

- សិក្សាស្រាវជ្រាវទាក់ទងការបង្រៀន និងរៀន
- អនុវត្តការសិក្សាស្រាវជ្រាវមេរៀន និងធ្វើថ្នាក់និទស្សន៍ ដើម្បីចាប់យកនូវទេពកោសល្យទៅអនុវត្តក្នុងការងារបង្រៀន និងរៀនឱ្យមានការឯកភាពគ្នា
- ចាត់តាំងសមាជិកឱ្យចូលស្តាប់ការបង្រៀន និងការអប់រំសិស្សរបស់គ្រូណាម្នាក់ ហើយផ្លាស់ប្តូរយោបល់ និងដកបទពិសោធ ដើម្បីច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ

- ចងក្រងឯកសារវិធីបង្រៀន និងយុទ្ធសាស្ត្រថ្មីៗសម្រាប់ការងារបង្រៀននិងរៀនឱ្យមានប្រសិទ្ធភាព
- ចែករំលែកបទពិសោធន៍ការងារស្រាវជ្រាវ ឬប្រសិទ្ធភាពនៃការងារបង្រៀន និងរៀនដល់សមាជិក
- ធ្វើបទបង្ហាញចំណេះដឹងដែលសមាជិកទទួលបានតាមរយៈការចូលរួមវគ្គបំប៉ន ឬសិក្ខាសាលា
- ជួយសមាជិករៀបចំផែនការអភិវឌ្ឍន៍វិជ្ជាជីវៈប្រចាំឆ្នាំតាមដានការអនុវត្ត ដើម្បីធ្វើឱ្យសម្រេចបាននូវស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- ជួយបំប៉ន និងលើកកម្ពស់កម្រិតវប្បធម៌ បច្ចេកទេសដល់សមាជិករបស់ខ្លួន
- ជួយសមាជិកក្នុងការអនុវត្តផែនការបង្រៀនទៅតាមកាលកំណត់ឱ្យបានឯកភាពគ្នាទាំងវិធីសាស្ត្រ
- ទាំងខ្លឹមសារធ្វើការវិភាគលើលទ្ធផលសិក្សារបស់សិស្សនិងរកវិធីកែលម្អគុណភាពបង្រៀននិងរៀន
- កំណត់ឱ្យបានមុខសញ្ញាសិស្សរៀនយឺត និងជួយបង្រៀនបំប៉នឱ្យបានទាន់ពេលវេលា។

### ៦.៦.២.របៀបរបបអនុវត្តការងារ

### ក.ការសិក្សាជាក្រុម

ប្រធានក្រុម និងអ្នកសម្របសម្រួលត្រូវសហការជាមួយគណៈគ្រប់គ្រងសាលា និងនាយករងបច្ចេកទេស ដើម្បីដឹកនាំការសិក្សា។ រាល់ការប្រជុំត្រូវមានលិខិតប្រជុំអមដោយរបៀបវារៈប្រជុំជូនជាព័ត៌មាន ឬជាការអញ្ជើញថ្នាក់ដឹកនាំអប់រំថ្នាក់ស្រុក DTMT និងមន្ទីរ ដើម្បីជួយសម្របសម្រួល និងផ្តល់នូវមតិយោបល់កែលម្អបន្ថែម។ ចំពោះកាលបរិច្ឆេទនៃការជួបជុំគ្នាត្រូវតែមានការឯកភាពគ្នា។ សហគមន៍សិក្សាវិជ្ជាជីវៈនីមួយៗត្រូវតែមានផែនការសិក្សា និងកំណត់ពេលវេលាជាក់លាក់ណាមួយ ដែលសមាជិកទាំងអស់អាចចូលរួមបានទាំងអស់គ្នា។ ការជួបជុំគ្នាត្រូវធ្វើឡើងរៀងរាល់សប្តាហ៍ ហើយអនុវត្តបួនដងក្នុងមួយខែដោយឯកភាពយកថ្ងៃណាមួយ។ តាមការដាក់ស្តែងចំពោះអនុវិទ្យាល័យដែលមានបង្កើតជាកម្រងសាលារៀនការប្រជុំក្នុងសប្តាហ៍ទី៤ក្នុងខែនីមួយៗគួររៀបចំឡើងក្នុងកម្រិតកម្រង។

ឧទាហរណ៍៖

- ក្រុមមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា
- ព្រឹកថ្ងៃសុក្រពីម៉ោង ៧ និង៣០នាទី ដល់ម៉ោង១០ និង៣០នាទី
- ក្រុមមុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា
- រសៀលថ្ងៃពុធ ពីម៉ោង ១ និង៣០នាទី ដល់ម៉ោង៤ និង៣០នាទី

ការប្រជុំអាចធ្វើឡើងតាមរយៈការប្រជុំផ្ទាល់ឬតាមប្រព័ន្ធអេឡិចត្រូនិចដូចជា Zoom ឬ Google Meet ជាដើម។ ចំពោះទីតាំងប្រជុំអាចកំណត់យកនៅក្នុងសាលារៀន ឬធ្វើនៅទីតាំងក្រៅសាលាដែលផ្តល់ផាសុខភាព និងមានភាពងាយស្រួល។ ប្រធានក្រុម និងអ្នកសម្របសម្រួល ត្រូវជម្រាបជូនដល់សមាជិកខ្លួននូវរបៀបវារៈប្រជុំ ហើយក្នុងករណីមានមេរៀន ឯកសារយោងត្រូវធ្វើជូនដល់សមាជិកខ្លួនសម្រាប់អានមុនពេលចូលរួមឱ្យបានមួយសប្តាហ៍មុខការប្រជុំ។ រាល់ការប្រជុំត្រូវមានរបាយការណ៍ ឬកំណត់ហេតុ ដើម្បី

រក្សាទុកជាឯកសារ ឬភស្តុតាងក្នុងអង្គភាព ហើយសមាជិកម្នាក់ៗត្រូវចងក្រងខ្លឹមសារ និងរក្សាទុកក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន( Teacher Portfolio )។

ខ.ការសង្កេតថ្នាក់ និងប្រឹក្សា

ប្រធានក្រុមសហគមន៍សិក្សាវិជ្ជាជីវៈ ដែលបានជ្រើសរើសត្រូវមានតួនាទីបន្ថែមទៀត គឺជាគ្រូប្រឹក្សាសម្រាប់សហគមន៍សិក្សានីមួយៗ ហើយត្រូវសហការជាមួយនាយករងទទួលបន្ទុកបច្ចេកទេស ដែលជាគ្រូប្រឹក្សាប្រចាំសាលារៀន ដើម្បីផ្តល់ដំបូន្មាន និងការគាំទ្រដល់គ្រូបង្រៀនធ្វើការអភិវឌ្ឍវិជ្ជាជីវៈ និងធានាបាននូវប្រសិទ្ធភាពនៃការបង្រៀននិងរៀន។ ការចុះសង្កេតថ្នាក់ត្រូវមានឧបករណ៍សង្កេត និងមានផែនការច្បាស់លាស់ ដោយផ្អែកលើកាលវិភាគបង្រៀនជាក់ស្តែង។ ការសង្កេតថ្នាក់ត្រូវធ្វើឡើងក្នុងសប្តាហ៍ទី១ ទី២និងទី៣ ដោយចុះសង្កេតគ្រូបង្រៀនដែលទើបចេញថ្មីមានបទពិសោធន៍តិច ឬទទួលបានលទ្ធផលសិក្សាទាប ហើយធ្វើការបូកសរុបការងារនៅរៀងរាល់ចុងសប្តាហ៍ទីបីនៃខែនីមួយៗ។ ព័ត៌មានទទួលបានពីការសង្កេតថ្នាក់ គឺសម្រាប់ធ្វើការឆ្លុះបញ្ចាំងការសង្កេតលើកក្រោយៗទៀត ហើយក៏អាចក្លាយជាប្រធានបទសម្រាប់ដាក់ចូលក្នុងរបៀបវារៈប្រជុំក្នុងខែនីមួយៗផងដែរ។ លើសពីនេះទៀត គ្រូប្រឹក្សាដែលជាប្រធានក្រុមសហគមន៍សិក្សាត្រូវចាត់សមាជិករបស់ខ្លួនម្នាក់ៗ ឱ្យចូលសង្កេតការបង្រៀនរបស់គ្រូបង្រៀនដែលមានបច្ចេកទេសខ្ពស់ក្នុងសាលា ឬក្នុងកម្រងជាមួយគ្នាឱ្យបានពីរដងក្នុងមួយខែ ដើម្បីរៀនសូត្រ និងច្នៃប្រឌិតវិធីសាស្ត្រឱ្យសមស្របតាមមេរៀននីមួយៗ និងលទ្ធភាពជាក់ស្តែងនៃថ្នាក់នីមួយៗ។ រាល់ព្រឹត្តិបត្តិសង្កេតថ្នាក់ត្រូវមានការឯកភាពពីគ្រូបង្រៀនដែលត្រូវបានសង្កេត និងត្រូវរក្សាទុកដើម្បីជាភស្តុតាងក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់ខ្លួន។

## ៦-៧-ប្រព័ន្ធគាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ

ទោះបីជាការទទួលខុសត្រូវដ៏សំខាន់សម្រាប់ការផ្តួចផ្តើម និងការគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតលើនាយកសាលា និងគ្រូបង្រៀនក៏ដោយថ្នាក់ដឹកនាំ និងអង្គភាពពាក់ព័ន្ធក៏ត្រូវមានភារកិច្ចចូលរួមគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីឱ្យមានដំណើរការល្អ ដែលធានាបាននូវការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនឆ្លើយតប ទៅនឹងគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនិងផ្តល់ការអប់រំប្រកបដោយគុណភាព។ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ត្រូវដឹងអំពីតួនាទីរបស់ខ្លួន និងរៀបចំយន្តការគាំទ្រទាំងផ្នែកធនធានមនុស្សនិងបច្ចេកទេសថ្មីៗដល់អ្នកប្រតិបត្តិ ដើម្បីធានាបាននូវនិរន្តរភាពនៃការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមមូលដ្ឋានសាលារៀននីមួយៗ។ លើសពីនេះទៀត ការលើកទឹកចិត្តដល់អ្នកចូលរួមក៏ជាកត្តាជំរុញមួយដ៏មានប្រសិទ្ធភាព បន្ទាប់ពីពួកគេក្លាយជាសមាជិក និងបានចូលរួមសកម្មក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

សេចក្តីពណ៌នាខាងក្រោមនឹងរៀបរាប់អំពីតួនាទី ភារកិច្ចអ្នកពាក់ព័ន្ធ និងរបៀបលើកទឹកចិត្តដល់អ្នកចូលរួមនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

## ៦-៧-១.អ្នកពាក់ព័ន្ធសំខាន់ៗ

### ក.អង្គភាពថ្នាក់ក្រសួង

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសំដៅដល់នាយកដ្ឋានជំនាញដូចជា នាយកដ្ឋានគោលនយោបាយ នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ នាយកដ្ឋានធានាគុណភាពអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបឋមសិក្សា គណៈកម្មការអភិវឌ្ឍធនធានគ្រូបង្រៀន គ្រូឧទ្ទេសថ្នាក់ជាតិ និងអង្គភាពពាក់ព័ន្ធដទៃទៀត ដែលមានតួនាទី និងភារកិច្ចចូលរួមគាំទ្រដល់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមកម្រិតសាលារៀន។ អង្គភាពថ្នាក់ក្រសួងមានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- កំណត់វិធានការគោលនយោបាយ ឬការស្រាវជ្រាវនៅកម្រិតសាលារៀន
- ធានាបាននូវចក្ខុវិស័យរួមសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈ និងការអនុវត្តដែលមានសង្គតភាពនៅតាមអង្គភាពសាលារៀននីមួយៗ
- តម្រង់ទិសសហគមន៍សិក្សាវិជ្ជាជីវៈដល់អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ឱ្យយល់អំពីដំណើរការអនុវត្ត និងតួនាទីរបស់ខ្លួន
- បង្កើនឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់ដល់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈ
- ផ្តល់អ្នកជំនាញចូលរួមដោយឈរលើមូលដ្ឋានចំណេះដឹង និងតម្រូវការ ដើម្បីចែករំលែកឬផ្តល់ព័ត៌មានអំពីការអនុវត្តល្អទាំងក្នុងប្រទេស និងអន្តរជាតិ
- ជួយតាមដាន និងអភិវឌ្ឍន៍សកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីជំរុញការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈកាន់តែល្អប្រសើរ
- ធានាឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំទៅនឹងគន្លងអាជីពគ្រូបង្រៀន រៀបចំផ្តល់ការលើកទឹកចិត្តដល់អ្នកចូលរួមដោយទទួលបាននូវឱកាស ឬលាភសក្ការៈផ្សេងៗ
- បណ្តុះបណ្តាលបន្ថែមនូវចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងការលើកកម្ពស់ការងារបង្រៀន និងរៀន និងដំណើរការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ

### ខ.មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ

ការិយាល័យជំនាញរបស់មន្ទីរត្រូវសហការរៀបចំយន្តការជាមួយ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌនីមួយៗ ដើម្បីគាំទ្រដល់ការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈ។ មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌគួរមានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- ធានាបាននូវចក្ខុវិស័យរួមសម្រាប់សហគមន៍សិក្សាវិជ្ជាជីវៈនិងការអនុវត្តដែលមានសង្គតភាពនៅតាមអង្គភាពសាលារៀននីមួយៗ

- តម្រង់ទិសសហគមន៍សិក្សាវិជ្ជាជីវៈដល់អ្នកអនុវត្តគ្រប់លំដាប់ថ្នាក់ឱ្យយល់ពីដំណើរការអនុវត្ត និង តួនាទីរបស់ខ្លួន
- គាំទ្រផ្នែកធនធានមនុស្ស និងសម្ភារៈដល់សហគមន៍សិក្សាវិជ្ជាជីវៈ វាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនភ្ជាប់ទៅនឹងគន្លងអាជីព
- បង្កើតបណ្ដាញទំនាក់ទំនងរវាងសហគមន៍សិក្សាវិជ្ជាជីវៈ និងសហគមន៍មុខវិជ្ជាឯកទេស
- ចូលរួមពិនិត្យតាមដានការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមអង្គភាពសាលារៀនដោយមាន

**គ.គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន**

សំដៅដល់គ្រឹះស្ថានកំពុងបណ្ដុះបណ្ដាលគ្រូបង្រៀន ដែលមានភារកិច្ចបណ្ដុះបណ្ដាលដំបូងផង និងបណ្ដុះបណ្ដាលបន្តផង។ ក្រៅពីការរៀបចំឱ្យមានសហគមន៍សិក្សានៅក្នុងគ្រឹះស្ថានបណ្ដុះបណ្ដាលរបស់ខ្លួន គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនក៏ត្រូវរៀបចំឱ្យមានទំនាក់ទំនង និងយន្តការជួយដល់សហគមន៍សិក្សាតាមអង្គភាពសាលារៀនសាធារណៈផងដែរ។ គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនត្រូវមានតួនាទី និងទំនួលខុសត្រូវមួយចំនួនដូចជា៖

- រៀបចំអនុវត្តដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈរបស់ខ្លួនឱ្យមានប្រសិទ្ធភាព
- ពង្រឹងមូលដ្ឋានចំណេះដឹងស្ដីពីការអភិវឌ្ឍវិជ្ជាជីវៈតាមរយៈសហគមន៍សិក្សាវិជ្ជាជីវៈ និងផ្សព្វផ្សាយលទ្ធផលឱ្យបានទូលំទូលាយដល់សហគមន៍សិក្សាដទៃទៀតតាមអង្គភាពសាលារៀន
- សហគមន៍សិក្សាវិជ្ជាជីវៈនៅគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀនត្រូវមានទំនាក់ទំនង និងការគាំទ្រផ្នែកធនធានមនុស្សដល់សហគមន៍សិក្សាវិជ្ជាជីវៈនៅតាមអង្គភាពសាលារៀន
- ជួយគាំទ្រជំនាញផ្នែកខ្លឹមសារតាមកម្មវិធីបណ្ដុះបណ្ដាល និងធ្វើការណែនាំឱ្យបានជាប្រចាំ
- បញ្ចូលការអភិវឌ្ឍន៍វិជ្ជាជីវៈ ឬសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈទៅក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូ
- បង្កើនការយល់ដឹង និងជំនាញផ្សេងៗ ដើម្បីគាំទ្រដល់សហគមន៍សិក្សាវិជ្ជាជីវៈដូចជាជំនាញដឹកនាំ និងជំនាញសម្របសម្រួលជាដើម។
- បង្កើតឧបករណ៍វាយតម្លៃវិភាគតម្រូវការ ដែលនឹងជួយកំណត់បាននូវចំណុចកែលម្អសហគមន៍សិក្សាវិជ្ជាជីវៈ
- ដឹកនាំ និងលើកទឹកចិត្តដល់សិស្សនិស្សិតឱ្យចេះអនុវត្តនូវសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់យកទៅអនុវត្តនៅតាមសាលារៀនពេលចេញទៅបម្រើការងារ
- បង្កើតកម្រងស្នាដៃវិជ្ជាជីវៈសម្រាប់នាយកគ្រឹះស្ថាន និងគ្រូឧទ្ទេសឱ្យបានច្បាស់លាស់ និងជាគំរូសម្រាប់អង្គភាពសាលារៀនដទៃទៀត។

**ឃ-គ្រឹះស្ថានសិក្សាសាធារណៈ**

គ្រឹះស្ថានសិក្សាសាធារណៈរួមមាន វិទ្យាល័យ អនុវិទ្យាល័យ និងសាលាបឋមសិក្សា ដែលជាអង្គភាពមូលដ្ឋានដ៏សំខាន់ក្នុងការផលិតធនធានមនុស្ស។ ដើម្បីដឹកនាំអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំនៅនឹងកន្លែងអង្គភាពនីមួយៗត្រូវតែតាមដានឱ្យបានខ្ជាប់ខ្ជួននូវនិន្នាការអប់រំ និងគោលនយោបាយអប់រំទាក់ទងនឹងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកអប់រំ។ សាលារៀនត្រូវតែផ្តួចផ្តើមបង្កើតសម្របសម្រួលផ្តល់ទីកន្លែង និងធនធាន ដើម្បីដឹកនាំដំណើការសកម្មភាពសហគមន៍សិក្សាវិជ្ជាជីវៈតាមគោលការណ៍ណែនាំ។ ភាពជោគជ័យរបស់សហគមន៍សិក្សាវិជ្ជាជីវៈស្ថិតនៅលើគ្រូបង្រៀន និងនាយកសាលា ។

- **តួនាទីរបស់ប្រធានកម្រង និងគណៈគ្រប់គ្រងសាលាមានដូចខាងក្រោម៖**
  - ចូលរួមបង្កើតឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់នាយកសាលា ឬគណៈគ្រប់គ្រងសាលានៅមូលដ្ឋានរបស់ខ្លួន
  - ជំរុញគ្រូបង្រៀនឱ្យចូលរួមនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ និងកំណត់លក្ខខណ្ឌសហគមន៍សិក្សាវិជ្ជាជីវៈ
  - ដើម្បីដឹកនាំដំណើរការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅក្នុងអង្គភាពសាលារៀនត្រូវពន្យល់ឱ្យគ្រូបង្រៀនអំពីសារៈសំខាន់នៃសហគមន៍សិក្សាវិជ្ជាជីវៈ
  - ចូលរួមកំណត់ និងជ្រើសរើសតំណាងក្រុមបច្ចេកទេស និងគ្រូប្រឹក្សាដែលមានឆន្ទៈក្នុងការទទួលយកតួនាទីជាអ្នកសម្របសម្រួល និងដឹកនាំសហគមន៍សិក្សាវិជ្ជាជីវៈក្នុងឆ្នាំសិក្សានីមួយៗ
  - គាំទ្រសហគមន៍សិក្សាវិជ្ជាជីវៈ ដោយការបែងចែកធនធាន និងពេលវេលាឱ្យបានសមស្របតាមការជាក់ស្តែង
  - ដឹកនាំបង្កើតផែនការសិក្សាវិជ្ជាជីវៈ កម្រងស្នាដៃវិជ្ជាជីវៈសម្រាប់អង្គភាព និងគ្រូបង្រៀនម្នាក់ៗ
  - រៀបចំទីកន្លែងសម្រាប់គ្រូបង្រៀនធ្វើស្វ័យសិក្សា ក្នុងសាលារៀនដោយមានទីកន្លែងសមរម្យ និងឯកសារគ្រប់គ្រាន់។
- **តួនាទីរបស់គ្រូបង្រៀន**
  - ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដែលជាមធ្យោបាយមួយ ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន
  - អនុវត្តស្វ័យសិក្សា ដើម្បីពង្រីកចំណេះដឹងបន្ថែម និងសម្រាប់យកទៅចែករំលែកក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ
  - បើកទូលាយក្នុងការចែករំលែកចំណេះដឹង និងការសិក្សាបន្ថែមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ
  - ចូលរួមសកម្មនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីជួយដល់សមាជិកខ្លួន និងជួយលើកកម្ពស់ការងារបង្រៀន និងរៀន
  - ត្រូវទទួលយកតួនាទីបន្ថែមជាអ្នកដឹកនាំនៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីសម្របសម្រួលការ

- រៀបចំរបៀបវារៈនិងការកំណត់លទ្ធផលចុះសង្កេតការបង្រៀនសមាជិកសហគមន៍សិក្សាវិជ្ជាជីវៈ
- បង្កើតកម្រងស្នាដៃវិជ្ជាជីវៈក្នុងនោះមានផែនការសិក្សាវិជ្ជាជីវៈ និងសៀវភៅសិក្សាអាជីពជាដើម។

**៦-៧-២-ប្រព័ន្ធលើកទឹកចិត្តដល់សហគមន៍សិក្សាវិជ្ជាជីវៈ**

**ក.បញ្ញត្តិនៃការលើកទឹកចិត្ត**

ការលើកទឹកចិត្ត គឺជាកាតាលីករដ៏ចម្បងមួយ ដើម្បីធ្វើឱ្យការអនុវត្តសហគមន៍សិក្សាវិជ្ជាជីវៈទទួលបានជោគជ័យនៅតាមសាលារៀន។ ជាទូទៅគ្រូបង្រៀន និងនាយកសាលារំពឹងថា ទទួលបានអ្វីក្រោយពីកិច្ចប្រជុំក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ?។

ផ្អែកនាមទ្រឹស្តីរបស់លោក David McGiland ស្តីពីការទទួលបានតម្រូវការចាំបាច់ "The Acquired Needs Theory" បានកំណត់នូវតម្រូវការរបស់មនុស្ស។ ទ្រឹស្តីនេះបានបែងចែកតម្រូវការរបស់បុគ្គលិកបម្រើការងារជា៣ផ្នែកគឺ៖ ការទទួលបានស្នាដៃ ការទទួលបានសម្ព័ន្ធមិត្ត និងការទទួលបានអំណាច។

១-ការទទួលបានស្នាដៃ(Need for Achievement)៖

សំដៅដល់ការសម្រេចបាននូវភាពជោគជ័យអ្វីមួយដោយការខិតខំប្រឹងប្រែងរបស់បុគ្គលិក ឬចូលរួមក្នុងសកម្មភាពអ្វីមួយ។ ឧទាហរណ៍ ការទទួលបានស្នាដៃក្នុងអាជីពការងារអប់រំចំពោះគ្រូបង្រៀន និងនាយកសាលា គឺសំដៅដល់សម្រេចបាននូវលទ្ធផលសិក្សារបស់សិស្សដូចជា ការប្រឡងជាប់ជាសិស្សពូកែនិទ្ទេសល្អខ្ពស់ជាងគេ ឬមានចំនួនច្រើនជាងគេក្នុងការប្រឡងថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិណាមួយ។ ឧទាហរណ៍ផ្សេងទៀតជាបំណងប្រាថ្នារបស់គ្រូបង្រៀន និងនាយកសាលា គឺមានការទទួលស្គាល់ក្នុងសង្គមតាមរយៈការទទួលបាននូវពានរង្វាន់អាចជាថវិកា ឬពានរង្វាន់ជាប់ចំណាត់ថ្នាក់ទទួលស្គាល់ជាគ្រូល្អ នាយកល្អ ឬសាលាមានបរិស្ថានល្អប្រចាំក្រុង ស្រុក ខេត្ត ឬប្រទេស។

២-ការទទួលបានសម្ព័ន្ធមិត្ត(Need for Affiliation)៖

សំដៅដល់អ្នកអប់រំ ដែលបានលះបង់ពេលវេលាចូលរួមរាល់សកម្មភាពការងារ ដើម្បីបង្កើត និងថែរក្សាទំនាក់ទំនងជាមួយសហសេវិក ឬមនុស្សក្នុងអង្គភាព ឬសង្គម។

៣-ការទទួលបានអំណាច(Need for Power)៖

អំណាចក្នុងតម្រូវការនេះសំដៅដល់ឥទ្ធិពលរបស់ខ្លួនទៅលើមនុស្សជុំវិញ។ ដើម្បីឱ្យមានឥទ្ធិពលលើអ្នកដទៃក្នុងអាជីពជាអ្នកអប់រំ លុះត្រាបុគ្គលនោះបានបង្កើនសមត្ថភាពរបស់ខ្លួនឱ្យខ្ពស់ជាងគេ ដើម្បីជួយបង្រៀន ឬណែនាំដល់គេបាន ដោយបង្ហាញនូវស៊ីវិលធម៌វិជ្ជាជីវៈខ្ពង់ខ្ពស់មានភាពជាអ្នកដឹកនាំអាចធ្វើឱ្យការសិក្សាក្នុងក្រុមទទួលបានជោគជ័យ។ ដោយសារអំណាចនៃចំណេះដឹង និងភាពជាអ្នកដឹកនាំនេះនឹងធ្វើឱ្យអ្នកនៅជុំវិញកោតសរសើរលើកទឹកចិត្ត និងឈរឈ្មោះបោះឆ្នោតគាំទ្របុគ្គលក្លាយជាប្រធានក្រុម ឬអ្នកថ្នាក់ដឹកនាំទៅនាគត។

៤-ការបង្កើតឱកាស ដើម្បីលើកទឹកចិត្ត

ដើម្បីទទួលបានការលើកទឹកចិត្តដល់អ្នកចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ អង្គភាពពាក់ព័ន្ធនានាត្រូវបង្កើតឱកាស និងរៀបចំការលើកទឹកចិត្តដល់អ្នកចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ។

១-ថ្នាក់ជាតិ

- គួរមានការរៀបចំវេទិកាដូចជាសន្និសីទ និងសិក្ខាសាលាប្រចាំឆ្នាំតាមប្រធានបទ ឬកម្រិតថ្នាក់ ហើយសមាសភាពសហគមន៍សិក្សាវិជ្ជាជីវៈអាចចូលរួមជាវាគ្មិន ដើម្បីចែករំលែកនូវការអនុវត្តដែលរកឃើញដោយការសិក្សាស្រាវជ្រាវអប់រំ

- ជំរុញឱ្យមានការបោះពុម្ពផ្សាយឯកសារ សៀវភៅទាក់ទងទៅនឹងប្រសិទ្ធភាពនៃការប្រតិបត្តិ និងកិច្ចការស្រាវជ្រាវ

- ត្រូវមានយន្តការផ្តល់ផ្នែកបច្ចេកទេស និងថវិកាដូចជាលំហូរសម្រាប់ដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមមូលដ្ឋាន ប្រធានក្រុម និងអ្នកសម្របសម្រួលសហគមន៍សិក្សាវិជ្ជាជីវៈអាចចុះជួយដល់សហគមន៍សិក្សាវិជ្ជាជីវៈផ្សេងៗ

- រៀបចំគណៈវាយតម្លៃការចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ ជាក្រុមជាលក្ខខណ្ឌមួយសម្រាប់វាយតម្លៃការបង្រៀនដោយនាយកសាលារៀនបញ្ចូលក្នុងគន្លងអាជីព ផ្តល់ឱកាសឱ្យអ្នកដឹកនាំ ឬគ្រូបង្រៀនមានជំនាញល្អ រកឃើញចំណេះដឹងថ្មី បានចូលរួមក្នុងវគ្គបំប៉នកម្រិតជាតិ ឬអន្តរជាតិជាដើម។

២-ថ្នាក់ខេត្តស្រុក

- មានការរៀបចំដូចជាសន្និសីទ និងសិក្ខាសាលាជាត្រីមាស ឆមាសតាមប្រធានបទ ឬកម្រិតថ្នាក់ ហើយសមាសភាពសហគមន៍សិក្សាវិជ្ជាជីវៈអាចចូលរួមជាវាគ្មិន ដើម្បីចែករំលែកការអនុវត្ត ឬធនធផលនៃការសិក្សាស្រាវជ្រាវអប់រំ

- រៀបចំក្រុម និងយន្តការចុះជួយ និងពិនិត្យតាមដានការអនុវត្ត និងដំណើរការសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមមូលដ្ឋានជាច្រើន ដើម្បីធានាបាននូវប្រសិទ្ធភាព និងនិរន្តរភាពធ្វើបញ្ជីឈ្មោះ និងបញ្ជូនឈ្មោះគ្រូបង្រៀន និងនាយកសាលាដែលគ្រប់លក្ខខណ្ឌចូលក្នុងគន្លងអាជីពមកថ្នាក់ក្រសួង។

៣-អង្គភាពសាលារៀន

- រៀបចំឱ្យមានបរិស្ថានសិក្សាក្នុងអង្គភាពរបស់ខ្លួន ដោយមានទីកន្លែងសមរម្យសម្រាប់បុគ្គលិកអប់រំត្រៀមកិច្ចការបង្រៀនសិស្ស និងធ្វើស្វ័យសិក្សា ដើម្បីទទួលបានចំណេះដឹងថ្មីៗ យកទៅចែករំលែកក្នុងសហគមន៍សិក្សាវិជ្ជាជីវៈ

- បង្កើតគណៈកម្មការវាយតម្លៃលើភស្តុតាងបុគ្គលិកអប់រំ ដើម្បីចូលក្នុងគន្លងអាជីពគ្រូបង្រៀន ធ្វើវង្វាយតម្លៃតម្រូវការបុគ្គលិក និងរៀបចំកម្មវិធីសហគមន៍សិក្សាវិជ្ជាជីវៈឱ្យឆ្លើយតបទៅតម្រូវការជាក់ស្តែង

-រក្សាទុករាល់កម្រងស្នាដៃសាលារៀន និងគ្រូបង្រៀនសម្រាប់ជាភស្តុតាងក្នុងការវាយតម្លៃ។

ដូច្នេះ ក្រសួងអប់រំ គឺមានគោលបំណងកសាងសង្គមមួយផ្អែកលើចំណេះដឹង ឬហៅថាសង្គមពុទ្ធិ។ ក្នុងន័យនេះ វិស័យអប់រំត្រូវបានគេរំពឹងថា បណ្ដុះបណ្ដាលធនធានមនុស្ស និងមូលធនមនុស្ស ដើម្បីបម្រើការអភិវឌ្ឍជាតិបានយ៉ាងល្អ។ តាមរយៈការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈគ្រូបង្រៀន និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអាចរៀនសូត្របានពីគ្នាចែករំលែកបទពិសោធន៍ ស្វែងរកចំណេះដឹងថ្មី បង្កើតវប្បធម៌សិក្សាជាមួយគ្នានៅនឹងកន្លែង និងរួមគ្នាបង្កើនលទ្ធផលសិក្សារបស់សិស្ស ដើម្បីឱ្យគ្រឹះស្ថានសិក្សាមានសមត្ថភាពផ្ដល់សេវាអប់រំកាន់តែប្រសើរឡើង និងដើម្បីឱ្យសហគមន៍កាន់តែជឿជាក់លើសមត្ថភាពរបស់អ្នកផ្ដល់សេវាអប់រំ។ ដូចនេះ មេរៀននេះដើរតួនាទីជាផែនទីបង្ហាញផ្លូវសម្រាប់បុគ្គលិកអប់រំទាំងអស់ឱ្យបង្កើតវប្បធម៌រៀននៅនឹងកន្លែងតាមរយៈអនុវត្តជាក់ស្ដែង ដែលគ្រឹះស្ថានសិក្សាសាធារណៈនីមួយៗ ឬនៅជិតគ្នាត្រូវចេះមានភាពបត់បែង និងសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈទៅតាមបរិបទ និងស្ថានភាពរបស់ខ្លួន។

## សំណួរពិភាក្សា

១-ហេតុអ្វីបានក្រសួងអប់រំចាំបាច់មានការបណ្ដុះបណ្ដាលបន្តគ្រូបង្រៀនជាបន្តបន្ទាប់?

២-ចូរអ្នករៀបរាប់ខ្លះៗនូវកម្មវិធីដែលក្រសួងអប់រំបានរៀបចំបណ្ដុះបណ្ដាលបន្តដល់គ្រូបង្រៀន។

៣-ចំពោះមុខ។ តើក្រសួងអប់រំមានកម្មវិធីបណ្ដុះបណ្ដាលបន្តដល់គ្រូបង្រៀនមានអ្វីខ្លះ?

## មេរៀនទី៧៖ កិច្ចសហប្រតិបត្តិការរវាងសាលារៀន គ្រួសារ និងសហគមន៍

### ៧-១-វត្ថុបំណងមេរៀន

#### ក-វិជ្ជាសម្បទា

- កំណត់បានពីសារៈសំខាន់នៃទំនាក់ទំនងរវាងសាលារៀន គ្រួសារ និងសហគមន៍បានច្បាស់លាស់ក្នុងបរិបទឌីជីថល
- រៀបរាប់បានពីតួនាទីគ្រូបង្រៀន និងកិច្ចគាំទ្រការសិក្សាក្នុងសហគមន៍បានច្បាស់លាស់

#### ខ-បំណិនសម្បទា

- វិភាគបានពីសារៈសំខាន់នៃទំនាក់ទំនងរវាងសាលារៀន គ្រួសារ និងសហគមន៍តាមការពិភាក្សាក្រុម
- វាយតម្លៃបានពីការអនុវត្តតួនាទីគ្រូបង្រៀន និងកិច្ចគាំទ្រការសិក្សាក្នុងសហគមន៍តាមការពិភាក្សាក្រុម

#### គ-ចរិយាសម្បទា

- បណ្តុះស្មារតីស្រឡាញ់ និងចូលរួមក្នុងកិច្ចសហប្រតិបត្តិការរវាងសាលារៀន គ្រួសារ និងសហគមន៍ ដើម្បីរួមចំណែកអនុវត្តគោលនយោបាយសហគមន៍សាលារៀន។

### ៧-២-សេចក្តីផ្តើម

ស្តង់ដាសាលាគំរូ ដែលមាន៥ស្តង់ដាក្នុងនោះស្តង់ដាទី៣ បានកំណត់អំពីសហគមន៍សាលារៀនរួមមាន(១)ការបង្កើត និងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន(គ.គ.ស) និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀន(គ.គ.ថ)(២)ការចូលរួមរបស់សហគមន៍ និង(៣)ការគាំទ្ររបស់សហគមន៍។ ដូចនេះទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ទាមទារការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ប្រមូលផ្តុំរាល់កម្លាំងពាក់ព័ន្ធសំខាន់ៗមាននៅក្នុងសាលារៀន និងសហគមន៍ឱ្យអស់លទ្ធភាពរបស់មូលដ្ឋាននីមួយៗជាសម្ភារ និងស្មារតីបង្កើតបានជាអង្គឯកភាពមួយរឹងមាំសម្រាប់ធានាដល់ដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននិរន្តរភាព។ ដើម្បីធានានិរន្តភាព និងសម្រេចបានតាមគោលដៅអប់រំជាតិ អ្នកគ្រប់គ្រងអប់រំជាពិសេសនាយក លោកគ្រូ អ្នកគ្រូ គប្បីសិក្សាស៊ីជម្រៅអំពីទំនាក់ទំនងរវាងសហប្រតិបត្តិការសាលារៀន និងសហគមន៍ឱ្យបានច្បាស់លាស និងកំណត់បានគោលនយោបាយ និងបេសកកម្មសម្រាប់អភិវឌ្ឍសាលារៀន។

សាលារៀនមួយប្រកបដោយប្រសិទ្ធភាពផ្តោតបានលើ(១) សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍ និងសម្រេចបានស្តង់ដាសាលារៀន (២) សាលារៀនមានស្វ័យភាពក្នុងការងារផែនការកែលម្អសាលារៀន និងផ្តល់ការអភិវឌ្ឍជាប្រចាំដល់គណៈគ្រប់គ្រង និងគ្រូបង្រៀន (៣) សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាព និងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀន និងរៀន ការជួយ

សិស្សរៀនយឺត និងផ្ដល់ព័ត៌មានដល់មាតាបិតា និងសហគមន៍ (៤) គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្ត ដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវឌ្ឍិជាប្រចាំ និង(៥) មាតាបិតា និងសហគមន៍ចូលរួមគាំទ្រ និងអភិវឌ្ឍសាលារៀន។

## ៧.៣.ទំនាក់ទំនងរវាងសាលារៀន គ្រួសារ និងសហគមន៍

ការអភិវឌ្ឍសាលារៀនទាមទារចាំបាច់នូវធនធានមនុស្ស ធនធានសម្ភារ ថវិកាយន្តការចាត់តាំង គ្រប់គ្រង ទំនួលខុសត្រូវ សេវាកម្ម ព្រមទាំងទំនាក់ទំនងខាងក្នុង និងខាងក្រៅឱ្យមានលក្ខណៈស៊ីចង្វាក់គ្នា ប្រកបដោយតុល្យភាព។ ការសម្រេចលក្ខខណ្ឌនេះទាមទារការព្យាយាម ប្រមូលផ្ដុំរាល់កម្លាំងអប់រំ ដែលមាននៅក្នុងសាលារៀន និងសហគមន៍ព្រមទាំងទៅតាមលទ្ធភាពរបស់មូលដ្ឋាននីមួយៗ ដើម្បីប្រមូលផ្ដុំជាអង្គឯកភាពមួយរឹងមាំសម្រាប់ធានាដល់ដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននិរន្តរភាព។ នៅសង្គមណាក៏ដោយសាលារៀន និងសហគមន៍ត្រូវមានទំនាក់ទំនងគ្នាពុំអាចកាត់ផ្ដាច់បានឡើយ។ សាលារៀនពុំអាចអភិវឌ្ឍបាន បើខ្វះអ្នកចូលរួមពីសហគមន៍។ រីឯសហគមន៍វិញក៏ពុំអាចគង់វង្ស និងរីកចម្រើនបានបើខ្វះការផ្ដល់កម្លាំងចលករពីសាលារៀន។ អាស្រ័យហេតុនេះ ទើបទំនាក់ទំនង រវាងការអប់រំរបស់សាលារៀន ការអប់រំរបស់គ្រួសារ និងការអប់រំរបស់សង្គមចាំបាច់ត្រូវដំណើរការព្រមៗគ្នាឯកភាពគ្នាគ្រប់ផ្នែកនោះទើបសម្រេចនូវគោលដៅអប់រំជាតិ។ សាលារៀនចំណោះទូទៅត្រូវមានតួនាទី ជាអ្នកដឹកនាំមានគ្រូបង្រៀនជាកម្លាំងស្នូលក្នុងកិច្ចការទំនាក់ទំនងរវាងការអប់រំរបស់សាលារៀន ជាមួយការអប់រំរបស់គ្រួសារ និងការអប់រំរបស់សង្គម។ តាមការពិសោធកន្លងមកការងារបង្រៀន និងរៀនដែលទទួលបានលទ្ធផលល្អអាស្រ័យដោយគ្រូទទួលបន្ទុកថ្នាក់មានបទពិសោធន៍ និងមានការសហការល្អពីមជ្ឈដ្ឋានអប់រំទាំង៣(សាលា គ្រួសារ និងសហគមន៍)។

លោកគ្រូ អ្នកគ្រូ ទទួលបន្ទុកថ្នាក់ទាំងអស់ត្រូវចេះទាក់ទាញនូវសមានចិត្តរបស់ឪពុកម្ដាយ សិស្សានុសិស្ស និងកម្លាំងផ្សេងៗទៀតរបស់សង្គមឱ្យចូលរួមក្នុងការងារអប់រំរបស់សាលារៀនដូចជាការរកមូលហេតុនៃការរៀនខ្សោយ ការមិនគោរពវិន័យរបស់សិស្ស ការផ្ដល់ព័ត៌មានត្រឡប់ ដើម្បីរួមចំណែកធ្វើឱ្យសកម្មភាពនានាក្នុងសាលារៀនកាន់តែមានចរិតល្អវិសេសវិសាលថែមទៀត[82]។ គ្រួសារ(មាតាបិតា)ជាកោសិការបស់សង្គម ឬអាចនិយាយបានថា ជាកោសិការបស់សហគមន៍។ គណៈកម្មការទ្រទ្រង់សាលា ឬសហគមន៍អាចជួយគាំទ្រ ឬជួយបំពេញការអប់រំទាំងស្មារតី និងសម្ភារដូចជាការជួយកុមារឱ្យចូលរៀន ជួយកសាងសាលារៀន ជួយផ្ដល់សម្ភារចាំបាច់ ជួយការពារផលប្រយោជន៍របស់សាលារៀន ដើម្បីបុព្វហេតុអនាគតដ៏រុងរឿងរបស់សិស្សក៏ដូចជាគ្រួសារ។ សហគមន៍ត្រូវតែជួយរៀបចំ ជួយគាំទ្រជួយបំពេញ

---

[82] ក្រសួងអប់រំ, ការដឹកនាំ និងគ្រប់គ្រងអប់រំ, នាយកដ្ឋានបុគ្គលិក ឆ្នាំ២០១៦, ទំ១៦១។

ការអប់រំសាធារណៈ និងត្រូវតែចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យសម្រេចបានស្របតាមគោលដៅអប់រំជាតិ។

សារប្រយោជន៍នៃទំនាក់ទំនងរវាងសាលារៀន និងសហគមន៍ គឺជួយគ្នាទៅវិញទៅមកៈ

- សាលារៀនជួយដល់សហគមន៍
- បង្រៀន និងអប់រំកុមារឱ្យបានល្អ
- ផលិតពលករ ជំនាញផ្សេងៗ ដើម្បីបម្រើផលប្រយោជន៍សហគមន៍
- ថែរក្សាវប្បធម៌ ប្រពៃណីជាតិ ឱ្យស្ថិតស្ថេរគង់វង្ស
- ផ្តល់ឱ្យសហគមន៍នូវចំណេះដឹងថ្មីៗ និងបច្ចេកវិទ្យាទំនើប
- បង្កលក្ខណៈឱ្យសហគមន៍អាចធ្វើពិធីផ្សេងៗក្នុងសាលារៀន
- បង្កលក្ខណៈឱ្យសហគមន៍ចូលរួមគ្រប់សកម្មភាពរបស់សាលារៀន
- ផ្លាស់ប្តូរប្រពៃណីទំនៀមទម្លាប់អ្វីដែលអន់ថយដូចជា បំបាត់អបិយជំនឿផ្សេងៗជាដើម។
- សហគមន៍ជួយដល់សាលារៀន
- ជំរុញកូនចៅឱ្យទៅរៀនបានទៀងទាត់គ្រប់ភូមិសិក្សា
- តាមដាន ត្រួតពិនិត្យកិច្ចការកូនចៅនៅផ្ទះ និងផ្តល់ព័ត៌មានត្រឡប់
- ទំនាក់ទំនងជាមួយនាយកសាលា លោកគ្រូ អ្នកគ្រូ អំពីករណីសិស្សបោះបង់ការសិក្សា ឬខិលខូចជាដើម
- ចូលរួមធ្វើផែនការអភិវឌ្ឍសាលារៀន
- ចូលរួមការងារស្រង់ស្ថិតិកុមារ
- កែលម្អបរិស្ថានសាលារៀន
- ចូលរួមការពារ និងថែរក្សាទ្រព្យសម្បត្តិសាលារៀន
- ចូលរួមចំណាយកម្លាំងពលកម្មក្នុងការសាងសង់
- ចូលរួមដោះស្រាយ និងផ្តល់សម្ភារឧបទេសសម្រាប់ការបង្រៀន និងរៀន
- ចូលរួមគ្រប់សកម្មភាពបុណ្យទានផ្សេងៗ ដើម្បីប្រមូលថវិកាសាងសង់អគារសិក្សា
- ផ្តល់ទីកន្លែង និងសម្ភារដែលសាលាត្រូវការ( ទស្សនកិច្ចសិក្សា )
- ជួសជុលអគារសិក្សា និងសង្ហារិម
- ចូលរួមជាមួយសាលារៀនដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា
- ផ្តល់មតិយោបល់ដែលមានប្រយោជន៍ដល់សាលារៀន ពិសេសនាយកសាលា
- ចូលរួមរក្សាសុខភាព សុវត្ថិភាព និងកាត់បន្ថយភាពអនាធិបតេយ្យរបស់សិស្ស
- លុបបំបាត់ល្បែងស៊ីសងផ្សេងៗ

- ផ្តល់អ្នកឯកទេសជំនាញផ្សេងៗឱ្យមកធ្វើបទបង្ហាញដល់សិស្សានុសិស្ស អំពីបំណិនជីវិតងាយៗ

## ៧.៤.តួនាទីគ្រូបង្រៀន និងកិច្ចគាំទ្រការសិក្សាក្នុងសហគមន៍

ដើម្បីអភិវឌ្ឍសាលារៀនឱ្យសម្រេចបានតាមគោលដៅអប់រំជាតិនោះសហគមន៍មានតួនាទី និង ភារកិច្ចសំខាន់ៗដូចតទៅ ៖

១.ប្រមូលកុមារឱ្យចូលរៀន

- ជួយរំឭកគ្នាជាប្រចាំចំពោះគ្រួសារនីមួយៗឱ្យយកកូនចៅដែលដល់អាយុសិក្សាទៅសាលារៀនឱ្យទៀងទាត់( ថ្នាក់មត្តេយ្យ ឬថ្នាក់ដំបូងបឋមសិក្សា )
- ចូលរួមក្នុងយុទ្ធនាការប្រមូលកុមារចូលរៀន និងកិច្ចប្រជុំនានានៅក្នុងសាលារៀន
- ប្រមូលកុមារដែលនៅក្រៅសាលារៀន និងជួយទំនាក់ទំនងជាមួយឪពុកម្តាយដែលមិនបានឱ្យកូនចៅទៅរៀន ដើម្បីបានទៅរៀន
- ជួយប្រមូល និងជួយបង្កលក្ខណៈងាយស្រួល ដើម្បីឱ្យកុមារកំព្រាទីទ័លក្រ ពិការបានទៅរៀន ។

២.ស្វែងរក និងគ្រប់គ្រងចំណូល

សាលារៀនដំណើរការល្អគឺអាស្រ័យដោយមានថវិកាទ្រទ្រង់។ ដូចនេះសហគមន៍ត្រូវចូលរួម យ៉ាងសកម្មក្នុងការ ស្វែងរកថវិកាសម្រាប់កសាងជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងសម្រាប់ដំណើរការ ការងាររបស់សាលារៀន។ ការស្វែងរក និងគ្រប់គ្រងថវិកាអាចធ្វើទៅបានតាមរយៈច្រើនរូបភាពដូចជា៖

- សហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ អន្តរជាតិ ក្នុងការសាងសង់អគារ ផ្តល់អាហារូបករណ៍ អាហារពេលព្រឹក និងសម្ភារសិក្សាដល់សិស្សក្រីក្រ។ល។
- ធ្វើបុណ្យផ្សេងៗ(បុណ្យរស្មីសាមគ្គីជាតិ បុណ្យផ្កា បុណ្យកំសាន្តផ្សេងៗ បុណ្យអង្គាសបច្ច័យ បុណ្យកឋិនទាន។ល។
- សុំវិភាគទានជាប្រាក់ ស្រូវ សម្ភារៈផ្សេងៗ ការប្រើទុនបង្កើន ឬទុនបង្វិល ដោយទំនាក់ទំនងជាមួយសប្បុរសជន (គណៈកម្មការអាចារ្យវត្ត មាតាបិតាសិស្ស អតីតសិស្ស អ្នកមានទ្រព្យសម្បត្តិក្នុង និងក្រៅប្រទេស សហគមន៍ឯកជន ដូចជាក្រុមហ៊ុនផ្សេងៗ និងទំនាក់ទំនងជាមួយរដ្ឋអំណាចមូលដ្ឋាន) និងតាមរយៈសកម្មភាពផ្សេងៗទៀតដូចជា ការចូលរួមសាងសង់ និងជួសជុលសាលារៀន ធ្វើសិប្បកម្ម សកម្មភាពសិល្បៈ និងទំនាក់ទំនងជាមួយអង្គការជាតិ អន្តរជាតិ និងក្រៅរដ្ឋាភិបាល
- ថវិកាចំណូលត្រូវមានបញ្ជីកត់ត្រាច្បាស់លាស់ ដោយមានបញ្ជាក់នូវប្រភពចំណូល កាលបរិច្ឆេទទទួលនូវចំនួន ថវិកា ឈ្មោះអ្នកទទួល ឈ្មោះអ្នកដឹងឮ ។ល។
- បញ្ជីចំណាយត្រូវមានបញ្ជាក់នូវប្រភេទចំណាយ ចំនួនទឹកប្រាក់ កាលបរិច្ឆេទ និងភ្ជាប់ជាមួយនូវកំណត់ហេតុ ដែលអង្គប្រជុំបានសម្រេចឱ្យចំណាយ

- ថវិកាត្រូវថែរក្សា និងគ្រប់គ្រងដោយបុគ្គលស្មោះត្រង់ដែលជ្រើសរើសដោយសហគមន៍ ឬជាបុគ្គលមានមនសិការ និងស្មារតីស្រឡាញ់ដល់ការអប់រំ
- ចំណូល និងចំណាយត្រូវផ្សព្វផ្សាយឱ្យគណៈកម្មការ ឬសហគមន៍បានដឹង
- ចូលរួមគ្រប់គ្រងចាត់ចែងការប្រើប្រាស់ថវិកាសម្រាប់អភិវឌ្ឍសាលារៀនតាមតួនាទី ភារកិច្ច ដែលបានកំណត់នៅក្នុងសមាសភាពគណៈកម្មការ ដើម្បីធានាបាននូវតម្លាភាព និងគណនេយ្យភាព ដោយធ្វើការផ្សព្វផ្សាយថវិកាឱ្យគ្នាទៅវិញទៅមកលើចំណូល ចំណាយប្រចាំត្រីមាសជូនអ្នកពាក់ព័ន្ធ។ ចំពោះការគ្រប់គ្រង និងការប្រើប្រាស់សាច់ប្រាក់របស់គម្រោង ឬកម្មវិធីផ្សេងៗ ត្រូវអនុវត្តស្របទៅតាមការណែនាំរបស់គម្រោង ឬ កម្មវិធីនោះ។

៣.ថែរក្សាទ្រព្យសម្បត្តិសាលារៀន

-សហគមន៍ត្រូវចាត់ទុកសាលារៀនជាទ្រព្យសម្បត្តិរួម

-ចូលរួមក្នុងសកម្មភាពនានារបស់សាលារៀនដូចជាការសម្អាតបរិស្ថាន ការការពារសត្វពាហនៈកុំឱ្យចូលក្នុង សាលារៀន ការជួយយាមកាមថែរក្សា ការពារ និងជួសជុលទ្រព្យសម្បត្តិសាលារៀន

-តាមដានមើលជួយថែរក្សាសម្ភារសិក្សារបស់កូនចៅ ដែលសាលារៀនបានឱ្យខ្ចី សម្រាប់ការរៀនសូត្រ ដូចជា សៀវភៅសិក្សាជាដើម

-ថែរក្សាទ្រព្យសម្បត្តិដែលសាលារៀនបានឱ្យខ្ចីក្នុងពេលមានរវល់ដូចជា តុ កៅអី ពេលបុណ្យទាន

-ជួយថែរក្សា និងកែលម្អសម្ភារបរិក្ខារ សំណង់ ហេដ្ឋារចនាសម្ព័ន្ធ បរិស្ថានសាលារៀនឱ្យបានគង់វង្ស និងមានសុវត្ថិភាព ។

៤.បំផុសកូនចៅឱ្យទៅសាលារៀន

-ជួយផ្តល់ព័ត៌មានអំពីកុមារដែលត្រូវចូលសាលារៀន និងចំនួនកុមារដែលនៅក្រៅសាលារៀន ដោយជួយដោះស្រាយ តាមគ្រប់មធ្យោបាយ និងគ្រប់រូបភាពដើម្បីឱ្យបានទៅសាលារៀន

-សហគមន៍ត្រូវជួយផ្សព្វផ្សាយដល់ប្រជាជន ឱ្យនាំកូនចៅទៅសាលារៀនតាមរយៈមធ្យោបាយផ្សព្វផ្សាយផ្សេងៗដូចជាការប្រជុំផ្សេងៗ ការជួបជុំគ្នានៅវត្តរៀងរាល់ថ្ងៃសីល ថ្ងៃបុណ្យ ការសំដែងសិល្បៈ ការសម្តែងធម្មទេសនា ការបិទផ្សាយដំណឹង ប្រកាសតាមវិទ្យុ ទូរទស្សន៍ សារព័ត៌មាន និងការប្រកាសក្នុងពិធីបើកបវេសនកាលជាដើម

-ចូលរួមនៅក្នុងកម្មវិធីអាហារូបករណ៍ ឬ កម្មវិធីផ្តល់អាហារពេលព្រឹក ដើម្បីទាក់ទាញសិស្សឱ្យមកសាលារៀន

-ចូលរួមជ្រើសរើស និងតាមដាននិយតភាពសិក្សារបស់សិស្សទទួលអាហារូបករណ៍ដើម្បីបណ្តុះទំនុកចិត្ត ជឿជាក់ ពីគ្រប់មជ្ឈដ្ឋាន អំពីការយកចិត្តទុកដាក់របស់សំណាក់សហគមន៍ចំពោះសាលារៀន។

៥. តាមដានការសិក្សារៀនសូត្ររបស់សិស្ស

ការអប់រំមិនមែនជាបន្ទុករបស់សាលារៀនតែឯងទេ ប៉ុន្តែជាការចូលរួមចំណែករបស់សហគមន៍ផង ដែរ។ ដូចនេះ មាតាបិតា ឬអាណាព្យាបាលសិស្សត្រូវ៖

-ជួយអប់រំកូនបន្ថែម និងជំរុញឱ្យខំរៀនសូត្រ ដោយបង្កលក្ខណៈទាំងសម្ភារ និងពេលវេលា ពិសេសកូនស្រី

-ជួយតាមដាន និងជំរុញកូនឱ្យធ្វើកិច្ចការផ្ទះជាប្រចាំ

-ជួយតាមដាន និងផ្តល់ព័ត៌មានត្រឡប់ លើលទ្ធផលសិក្សាក្នុងសៀវភៅតាមដានការសិក្សា របស់កុមារដែលគ្រួសារសិស្សទទួលបាន ពីសាលារៀន ជារៀងរាល់ខែ

-ទំនាក់ទំនងជាមួយលោកគ្រូ អ្នកគ្រូ និងលោកនាយកសាលាឱ្យបានញឹកញាប់ដោយផ្ទាល់មាត់ ដើម្បីកាត់បន្ថយអត្រាត្រួតថ្នាក់ និងករណីសិស្សបោះបង់ការសិក្សា

-ចូលរួមប្រជុំ ដើម្បីទទួលព័ត៌មានពីការសិក្សារបស់កូនចៅ

-ផ្តល់មតិយោបល់មានប្រយោជន៍ដល់សាលារៀនជាពិសេសជាមួយគណៈគ្រប់គ្រងសាលារៀន

-ចូលរួមទស្សនកិច្ចសាលារៀននិងជួយផ្តល់បទពិសោធន៍ល្អៗយ៉ាងហោចណាស់មួយដងក្នុង មួយឆ្នាំ

-ជួយឧបត្ថម្ភដល់កុមារជួបការលំបាក

-ចូលរួមក្នុងពិធីចែករង្វាន់សិស្សពូកែ

-ជួយអប់រំផ្លូវចិត្ត អាកប្បកិរិយា និងសីលធម៌/សុជីវធម៌ដល់កុមារ

-ជួយផ្តល់ជំនាញបច្ចេកទេស ក្នុងការអប់រំវិជ្ជាជីវៈដល់កុមារ

-តាមដាន ត្រួតពិនិត្យការសិក្សារបស់កូន នៅសាលារៀន និងជួយបង្រៀនកូននៅផ្ទះ

-ជួយឧបត្ថម្ភ និងផ្តល់នូវមូលដ្ឋានសម្ភារ ដែលមាននៅក្នុងមូលដ្ឋាន ដើម្បីបម្រើដល់សកម្មភាព បង្រៀន និងរៀនដល់កុមារ (សម្ភារសម្រាប់ផលិតសម្ភារឧបទេស ... )។

៦-ចូលរួមកសាងផែនការ/អនុវត្តផែនការរបស់សាលារៀន និងការងារតាមដាន ត្រួតពិនិត្យ

ដើម្បីឱ្យសាលារៀនទទួលបាននូវការអភិវឌ្ឍទៅមុខជាលំដាប់ រាល់ផែនការការងាររបស់សាលា រៀនត្រូវតែមានការចូលរួមពីសហគមន៍ ដែលជាកម្លាំងមិនចេះរីងស្ងួតដូចជាការចូលរួមធ្វើផែនការអភិវឌ្ឍ សាលារៀនដោយកំណត់បញ្ហា កំណត់គោលបំណង កំណត់សកម្មភាព និងកំណត់កម្មវិធីផ្សេងៗ

-ចូលរួមកិច្ចប្រជុំប្រចាំត្រីមាស ដើម្បីពិភាក្សាពីការរីកចម្រើន និងលទ្ធផលការងារ

-ចូលរួមអនុវត្តផែនការអភិវឌ្ឍសាលារៀន តាមដានត្រួតពិនិត្យ និងវាយតម្លៃលើសកម្មភាពសាលារៀន

-ស្រង់ស្ថិតិកុមារពីអាយុ០ឆ្នាំដល់១៥ឆ្នាំ ពិសេសកុមារដល់វ័យសិក្សា អនក្ខរជន កំព្រា ទីទ័លក្រ និងកុមារពិការព្រោះស្ថិតិជាកត្តាមូលដ្ឋាននៃការអប់រំ និងជាមូលដ្ឋានក្នុងការធ្វើផែនការអប់រំក្នុងសហគមន៍

-ស្ថិតិធនធានសម្ភារដែលបម្រើឱ្យការអប់រំមានស្រាប់នៅក្នុងមូលដ្ឋានដូចជា ៖ កន្លែងពិសោធន៍កសិកម្ម សម្បត្តិ វប្បធម៌បុរាណ។ល។ កន្លែងទាំងអស់នេះសម្រាប់ឱ្យគ្រូនាំសិស្សទៅធ្វើទស្សនកិច្ចសិក្សា ពិនិត្យ និងចាប់យកចំណេះដឹង និងជំនាញវិជ្ជាជីវៈ

-ស្ថិតិកន្លែងរមណីយដ្ឋានសម្រាប់អ្នកទេសចរ( ជាកន្លែងទាក់ទាញភ្ញៀវឱ្យទៅទស្សនាដែលជាប្រភពចំណូលរបស់ សហគមន៍សម្រាប់ជួយជាវិភាគទានដល់ការអភិវឌ្ឍសាលារៀន )

-ស្ថិតិការដ្ឋានផ្សេងៗ ( ព្រោះការសិក្សារបស់សិស្សតម្រូវឱ្យសិស្សទៅពិនិត្យការអនុវត្ត

ជាក់ស្តែង ដូចជាការដ្ឋានវាយថ្ម ការដ្ឋានសំណង់ ...)

-ស្ថិតិសិប្បកម្មផ្សេងៗដូចជា តម្បាញ ធ្វើគុ ទូ ក្បាច់ចម្លាក់ គំនូរជាដើម (ដែលជាចំណេះដឹង និងជំនាញបម្រើដល់ សកម្មភាពរស់នៅប្រចាំថ្ងៃ )។

៧-ចែករំលែកបទពិសោធន៍ និងបំណិនជីវិត

-ណែនាំបង្រៀនពីរបៀបដាំដំណាំ ចិញ្ចឹមសត្វ និងជំនាញផ្សេងៗ ទាក់ទងនឹងបំណិនជីវិតមូលដ្ឋានដល់សិស្ស ដើម្បីឱ្យពួកគេមានបំណិនងាយៗសម្រាប់ជាមូលដ្ឋានក្នុងការប្រកបរបរចិញ្ចឹមជីវិតទៅអនាគត

-ជួយផ្សព្វផ្សាយបន្តដល់សហគមន៍នានា ដើម្បីចូលរួមក្នុងការរៀបចំការងារអប់រំ ផ្នែកបំណិនជីវិតមូលដ្ឋាន និង ជំនាញបច្ចេកទេសក្នុងសាលារៀន

-ចូលរួមចងក្រងបទពិសោធន៍ និងបំណិនជីវិតផ្សេងៗ ដែលមានក្នុងមូលដ្ឋានទុកជាឯកសារសម្រាប់បម្រើ ឱ្យការសិក្សារៀនសូត្របន្តទៀត។

៨-ទប់ស្កាត់បាតុភាពមិនប្រក្រតីក្នុង និងក្រៅសាលារៀន

-ចូលរួមទប់ស្កាត់រាល់សកម្មភាពទាំងឡាយណាប៉ះពាល់ដល់សាលារៀន ឬការសិក្សារបស់សិស្ស

-អប់រំណែនាំ សិស្សណា ដែលមិនស្តាប់ដំបូន្មានលោកគ្រូ អ្នកគ្រូ និងជួយផ្តល់ព័ត៌មានដល់ឪពុកម្តាយសិស្សនោះឱ្យណែនាំបន្ថែម

-ដោះស្រាយបញ្ហាផ្សេងៗ ដែលកើតឡើងនៅក្នុង និងក្រៅសាលារៀន ដូចជាសិស្សឈ្លោះគ្នា លេងល្បែងស៊ីសង សេពគ្រឿងញៀន បង្កអសន្តិសុខផ្សេងៗក្បែរសាលារៀន។ល។

៩-ពង្រឹង និងពង្រីកសមត្ថភាពយល់ដឹងអំពីការអភិវឌ្ឍសាលារៀន

ការអភិវឌ្ឍសហគមន៍ គឺការធ្វើឱ្យសហគមន៍រីកចម្រើនទាំងធនធានមនុស្ស និងធនធានសម្ភារ ។ កាលណាមនុស្ស ចូលរួមច្រើន សង្គមដែលគេរស់នៅនោះ នឹងសម្បូរទៅដោយអ្នកចេះដឹង ដែលអាចកែច្នៃមុខរបរឱ្យ ទទួលបានជីវភាពធូរធារ។ កាលណាជីវភាពរស់នៅបានធូរធារនោះសង្គមនឹងសម្បូរទៅដោយថវិកា និងសម្ភារប្រើប្រាស់ ពេលនោះសង្គមក្លាយទៅជាសង្គមរីកចម្រើន។ ការពង្រីកទំនាក់ទំនង រវាងសាលារៀន និងសហគមន៍ ពិសេសការយកចិត្តទុកដាក់លើការកាត់បន្ថយភាពអនាធិបតេយ្យរបស់សិស្សនឹងនាំឱ្យការអប់រំមានការរីកចម្រើនជាបន្តបន្ទាប់។

## ៧.៥.ការអប់រំតាមផ្ទះក្នុងយុគសម័យឌីជីថល

ការអប់រំបែបឌីជីថល គឺជាការប្រើប្រាស់ឧបករណ៍ និងបច្ចេកវិទ្យាឌីជីថល ក្នុងការរៀន និងការបង្រៀន ក៏ដូចជាការគ្រប់គ្រងដែរ។ គួរបញ្ជាក់ដែរថា សព្វថ្ងៃនេះគ្រឹះស្ថានសិក្សាមួយចំនួន ទាំងរដ្ឋ និងឯកជន បានប្រើប្រាស់នូវកម្មវិធីសិក្សាដែលមានដូចខាងក្រោម ៖

ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក (E-Learning) ជាប្រព័ន្ធនៃការអប់រំតាមបែបឌីជីថល ដែលមានមូលដ្ឋានចេញពីការអប់រំផ្លូវការ ប្រើប្រាស់ធនធានអេឡិចត្រូនិកជាជំនួយ។

ការអប់រំពីចម្ងាយ (Distance Learning) ជាវិធីសាស្ត្រមួយ ដែលសិស្សអាចទទួលបានការអប់រំសម្រាប់ការអភិវឌ្ឍសម្បទាទាំង៤ (ពុទ្ធិសម្បទា បំណិនសម្បទា កាយសម្បទា និងចរិយាសម្បទា) ដោយពុំចាំបាច់មានវត្តមាន ឬជួបគ្រូដោយផ្ទាល់។

គ្រឹះស្ថានសិក្សាមួយចំនួនក៏បានផ្សារភ្ជាប់កម្មវិធី ការអប់រំពីចម្ងាយ ជាមួយ ប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ(Blended Learning) ឬផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា(Learning Management System)។

ក្រសួងអប់រំ នឹងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអប់រំឌីជីថល និងការអប់រំពីចម្ងាយដោយមានសមាសភាគ ចំនួន៤ រួមមាន៖

១.ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងទិន្នន័យនៃការអប់រំឌីជីថល ដោយផ្តោយលើការរៀបចំបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Data Center)

២.សកម្មភាពផលិតវីដេអូនៃការបង្រៀន ដោយរួមបញ្ចូលនូវការបញ្ជ្រាបវិធីសាស្ត្របង្រៀនបែបថ្មី និងការឆ្លើយតបចំពោះការអប់រំពិសេស។

៣.ហេដ្ឋារចនាសម្ព័ន្ធនៃការផលិតវីដេអូនៃការបង្រៀន ដោយផ្តោតលើការបង្កើតស្ទូឌីយ៉ូសម្រាប់ផលិតវីដេអូ និងមាតិកាឌីជីថលដ៏ទៃ និងស្ទូឌីយ៉ូខ្នាតធំសម្រាប់ វេទិកាអប់រំ។

៤. វេទិកាឌីជីថលសម្រាប់ការអប់រំតាមប្រព័ន្ធអេឡិចត្រូនិក ដោយផ្តោតលើការរៀបចំបង្កើត App និង Website សម្រាប់ការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធគ្រប់គ្រងការសិក្សា ដោយផ្អែកលើបរិបទនៃការអប់រំនៅកម្ពុជា

## ៧.៦. ការសិក្សាតាមអនឡាញ និងអំណានតាមឌីជីថល

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡាបានលើកឡើងថា មាតាបិតា អាណាព្យាបាល និងគ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសុវត្ថិភាពសិស្សានុសិស្សលើប្រព័ន្ធអនឡាញ។ សូមយកចិត្តនៅពេលសិស្សានុសិស្សប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ មួយវិញទៀត បើយើងពិនិត្យទៅមើលអំពីការយកចិត្តទុកដាក់របស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា លោក ហង់ជួន ណារ៉ុន បានឱ្យដឹងថា ក្រសួងអប់រំ

នៅតែបន្តផលិតវីដេអូ សម្រាប់ការបង្រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក( E-Learning) សម្រាប់សិស្សរៀននៅតាមផ្ទះចាប់ពីមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាទុតិយភូមិ និងពង្រីកការផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយជាងមុន។ ក្នុងអំឡុងពេលមានជំងឺកូវីដ-១៩ បានរាតត្បាតពេញផ្ទៃប្រទេសកម្ពុជា ចំពោះអ្នកដែលពាក់ព័ន្ធនឹងការអប់រំពុំត្រឹមតែអ្នកសិក្សាប៉ុណ្ណោះទេគឺមានការចូលរួមពីសំណាក់អាណាព្យាបាល និងលោកគ្រូ អ្នកគ្រូផងជាតួអង្គដ៏សំខាន់ ដែលបង្កើតឱ្យមានការសិក្សាតាមប្រព័ន្ធអនឡាញទទួលបានលទ្ធផលល្អប្រសើរ។ សិស្សភាគច្រើនតែងតែទទួលបាននូវការព្រួយបារម្ភពីសំណាក់លោកគ្រូ អ្នកគ្រូ និងមាតាបិតាសិស្សក្នុងស្ថានភាពកូវីដកំពុងតែផ្ទុះឡើង។ ការសិក្សាតាមប្រព័ន្ធអនឡាញបានទាមទារឱ្យសិស្សានុសិស្ស មាតាបិតា អាណាព្យាបាល និងលោកគ្រូអ្នកគ្រូត្រូវការចូលរួមសហការគ្នាយ៉ាងពេញហឹង។ តាមពិត ការសិក្សាតាមអនឡាញនេះមានភាពអាក់រអួលបន្តិចបន្តួចនៅដំណាក់កាលដំបូង ដោយសារទាំងគ្រូ និងសិស្សសុទ្ធតែទើបចាប់ផ្ដើមទាំងអស់គ្នា ប៉ុន្តែដោយសារការព្យាយាម និងប្រឹងប្រែងគ្រប់ដំណាក់កាលបានជំរុញឱ្យការបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញមានលក្ខណៈរលូន និងមាននិរន្តភាពរហូតដល់សព្វថ្ងៃ។ បច្ចុប្បន្ននេះ ទោះបីជំងឺកូវីដ-១៩បានរលាយជាបន្តបន្ទាប់ក៏ពិតមែន ក៏ប៉ុន្តែដំណើរការនៃការបង្រៀន និងរៀនតាមអនឡាញនៅតែបន្ត ហើយក្រសួងអប់រំបានកំណត់ថា ការបង្រៀន និងរៀន គឺប្រព្រឹត្តទៅតាមបែបចម្រុះ( Bleded learning )មានន័យថា អាចបង្រៀនតាមបែបផ្ទាល់ និងអនឡាញ គឺធ្វើយ៉ាងណាឱ្យដំណើរការបង្រៀន និងរៀនបានដំណើរការដោយនិរន្តរភាព។

ដូច្នេះនិន្នាការនៃការអប់រំ និងពលរដ្ឋសកលនាពេលបច្ចុប្បន្ននេះបានផ្ដោតលើការអប់រំសតវត្សរ៍ទី ២១ ក្នុងនោះសំដៅដល់ការសិក្សាតាមបែបការត្រិះរិះពិចារណា ការបង្រៀន និងរៀនតាមបែបសហការ ការច្នៃប្រឌិតប្រកបដោយនុវានុវត្តន៍ជាពិសេសគឺអនុវត្តនូវបណ្ដាវិធីសាស្ត្របង្រៀនថ្មីៗ ផ្ដោតលើសកម្មភាពរៀនរបស់សិស្សជាមូលដ្ឋានតាមរយៈការសិក្សាប្រព័ន្ធឌីជីថលនិងបច្ចេកវិទ្យាជាប្រភពព័ត៌មានដ៏មានសារៈសំខាន់ក្នុងការសិក្សារៀនសូត្រ និងស្រាវជ្រាវ ដែលជាបច្ចុប្បន្នភាពនៃការអប់រំ។ មួយវិញទៀត មូលធនមនុស្សដែលសម្រេចក្នុងបរិបទថ្មីនេះ គឺជាពលរដ្ឋពេញលេញ និងមានលក្ខណៈសកលពោរពេញទៅដោយចំណេះដឹង ចំណេះធ្វើ និងសីលធម៌វិជ្ជាជីវៈ និងមានគុណតម្លៃដ៏មានសក្ដានុពលក្នុងសង្គម៕

# ឧស្សនៈសំខាន់ៗស្តីពីការអប់រំ

## ១-ឧស្សនៈសំខាន់ៗសម្តេចធិបតីហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីកម្ពុជា

-ការអប់រំប្រកបដោយគុណភាពខ្ពស់ គឺជាកូនសោដ៏សំខាន់មួយសម្រាប់ពង្រឹងសុខភាពសេដ្ឋកិច្ច និងភាពខ្លាំងរឹងមាំនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការដោះស្រាយបញ្ហាសង្គមតាមរយៈបង្កើនមូលធនមនុស្ស គំនិតច្នៃប្រតិដ្ឋ បច្ចេកវិទ្យា និងនវានុវត្តន៍ជាកត្តាដ៏សំខាន់មិនអាចខ្វះបានសម្រាប់ជំរុញបង្កើនភាពរឹងមាំនៃសេដ្ឋកិច្ចគ្រួសារ លើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន ភាពធន់ និងចីរភាព ដើម្បីសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០(៩ មករា ២០២៤)

-ក្មួយៗសិស្សានុសិស្សទាំងអស់កំពុងធ្វើការវិនិយោគរយៈពេលវែង និងសន្សំបាននូវ «ទ្រព្យសម្បត្តិជាចំណេះដឹងមិនចេះរីងស្ងួត»សម្រាប់មួយជីវិត ដែលទ្រព្យសម្បត្តិចំណេះដឹងទាំងនេះអាចលក់នៅក្នុងទីផ្សារការងារ និងទទួលបានផលជាបៀវត្សខ្ពស់ បង្កើនភាពងាយស្រួលក្នុងការទទួលបានការងារ មានផលិតភាពសេដ្ឋកិច្ចខ្ពស់ មានជោគជ័យនៃសហគ្រិនភាព មានចីរភាពនៃជីវភាពខ្ពស់ផ្ទាល់ខ្លួន និងមានភាពធន់នៅស្ទើរគ្រប់កាលៈទេសៈនៃស្ថានភាពសេដ្ឋកិច្ច និងសង្គម (៩ មករា ២០២៤)

-អត្ថន័យដ៏ធំធេងរបស់ទិវាគ្រូបង្រៀនគឺជាការបំផុសវប្បធម៌ដល់សិស្ស និស្សិត និងយុវជនក្នុងការបន្តដឹងគុណដល់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យពីព្រោះថា ពួកគាត់គឺជាឪពុកម្តាយទីពីរជាអ្នកផ្តល់បំណិនជីវិត និងសមត្ថភាពដល់សិស្ស និស្សិត គ្រប់ៗរូប (០៥ តុលា ២០២៣)

-ការបញ្ចូលផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទៅក្នុងកម្មវិធីសិក្សា ដែលជាសមិទ្ធផលនៃការធ្វើកំណែទម្រង់ និងបានបង្ហាញច្បាស់អំពីសមត្ថភាពនៃការស្រាវជ្រាវ និងការបង្កើតគំនិតថ្មី ដែលជាការវិវឌ្ឍជាវិជ្ជមាននៃវិស័យអប់រំកម្ពុជា (០៥ តុលា ២០២៣)

-ដើម្បីពង្រឹងការបណ្តុះបណ្តាលមូលដ្ឋានពីមត្តេយ្យសិក្សារហូតដល់ថ្នាក់ទី១២ ត្រូវមានវិធានគន្លឹះអាទិភាពចំនួន៤គឺ៖

១-ការពង្រឹងអភិបាលកិច្ច

២-ការពិនិត្យក សម្រួល និងការរៀបចំកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សាឱ្យស្របទៅតាមតម្រូវការ ក្នុងការពង្រឹងចំណេះដឹង, វិន័យ, សីលធម៌ និងឥរិយាបថរបស់សិស្ស,

៣-ការយកចិត្តទុកដាក់លើសុខភាពសិស្ស តាមរយៈកម្មវិធីអាហារូបត្ថម្ភដល់ កុមារ និងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន

៤-ការជំរុញ និងលើកទឹកចិត្តការចូលរួមរបស់ មាតាបិតា អាណាព្យាបាល និងសហគមន៍ក្នុងការអប់រំស្របតាមពាក្យស្លោក ភាពជាដៃគូរដ្ឋ និងសហគមន៍ ដើម្បីការអប់រំ។

-ដើម្បីសាលារៀនមានដំណើរការល្អ ត្រូវពឹងផ្អែកសំខាន់លើនាយកសាលា និងគ្រូបង្រៀន។ នាយកសាលាប្រៀបដូចជាម៉ែឪរបស់សាលារៀន (០៥ តុលា ២០២៣)

-ការបង្កើតឧបករណ៍បច្ចេកវិទ្យា និងចងក្រងសៀវភៅរបស់សិស្សមធ្យមសិក្សានេះ បង្ហាញឱ្យឃើញពីការវិវឌ្ឍន៍ប្រកបដោយវិជ្ជមានក្នុងវិស័យអប់រំនៅកម្ពុជា (០៥ តុលា ២០២៣)

-មហិច្ឆតារបស់សម្តេចធ្វើឱ្យសាលារដ្ឋទាំងអស់ផ្អែកចំណេះដឹងទូទៅទាំងអស់ត្រូវតែជាសាលាល្អ សាលារដ្ឋទំនើប និងវិន័យសិស្សកាន់តែល្អអាចទទួលយកបានក្នុងរយៈពេល១០ឆ្នាំខាងមុខ (០៥ តុលា ២០២៣)

-រាជរដ្ឋាភិបាលនឹងរៀបចំការចងក្រងឯកសារប្រវត្តិសាស្ត្រពីសតវត្សរ៍ទី១មក ដើម្បីឱ្យកូនខ្មែរសិក្សារៀនសូត្រ (០៥ តុលា ២០២៣)

-បើសាលារៀនមួយមានគុណភាពខ្ពស់ ទោះបីស្ថិតនៅឆ្ងាយប៉ុនណាក៏មានសិស្សរៀនសូត្រដែរ (០៥ តុលា ២០២៣) ។

## ៤-ឧស្សាហ៍ៈសំខាន់របស់សម្តេចតេជោហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីកម្ពុជា

-លទ្ធផលនៃការអប់រំនៅកម្ពុជានាពេលនេះ គឺជាលទ្ធផលប្រកបដោយអត្ថន័យបានមកដោយការប្រឹងប្រែងរបស់ពលរដ្ឋខ្មែរ (២៥ ខែមេសា ឆ្នាំ២០២៣)

-បើអ្នកជួយកសាងសាលា សូមបន្តជួយកសាងផ្ទះគ្រូនៅតាមសាលារៀននានាផងសម្រាប់គ្រូ និងសិស្សដែលមកពីឆ្ងាយបានស្នាក់នៅបន្តការសិក្សា និងលើកទឹកចិត្តឱ្យមេឃុំនៅតាមឃុំនានាជួយរៀបចំជាផ្ទះសម្បែងសម្រាប់គ្រូស្នាក់នៅផងដែរ បើសិនជាអាចធ្វើទៅបាន (២៥ ខែមេសា ឆ្នាំ២០២៣) ។

-បើដាំដើមឈើត្រឹម៥ឆ្នាំ អាចទទួលផល តែបើដាំដើមមនុស្សប្រើពេល១៦ឆ្នាំ ទើបបញ្ចប់ថ្នាក់បរិញ្ញាបត្រ១៨ឆ្នាំ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និង២០ឆ្នាំថ្នាក់បណ្ឌិត ហើយការដាំដើមមនុស្សត្រូវតែហ៊ានវិនិយោគ បើមិនហ៊ានវិនិយោគគឺមិនអាចទទួលបានប្រយោជន៍សម្រាប់សង្គមនោះឡើយ (២៥ ខែមេសា ឆ្នាំ២០២៣) ។

-ក្នុងយុគសម័យសេដ្ឋកិច្ចពុទ្ធិ និងបច្ចេកវិទ្យានេះ ឧត្តមភាពប្រកួតប្រជែងរបស់ប្រជាជាតិមួយនៅតែអាស្រ័យជាសំខាន់លើកត្តាធនធានមនុស្ស ដែលមានចំណេះដឹង ចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិត និងមានជំនាញច្បាស់លាស់ (០១ ខែវិច្ឆិកា ឆ្នាំ២០១៦)

-បទពិសោធរបស់ខ្ញុំនៅក្នុងការគ្រប់គ្រងកូន បណ្តុះបណ្តាលកូនចាត់ទុកថា ខ្ញុំទទួលបានជោគជ័យហើយតែខ្ញុំនៅតែមានកាតព្វកិច្ចរួមចំណែកជាមួយកូនខ្ញុំដើម្បីបណ្តុះបណ្តាលចៅរបស់ខ្ញុំ តំណមដែលខ្ញុំឱ្យកូនរបស់ខ្ញុំតម គឺដាច់ខាតកុំនិយាយថា ឯងមួយថ្ងៃមួយថ្ងៃគិតតែលេងហ្គេម ឯងមើលកូនគេនោះគេរៀនពូកែ កុំឱ្យសោះ (៤ ឧសភា ២០២២) ។

### ៣-ទស្សនៈសំខាន់របស់បណ្ឌិតសភាចារ្យហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ

-អ្នកនិពន្ធ និងអ្នកចងក្រងសៀវភៅ ឬឯកសារអប់រំ សូមបន្ត និងបង្កើនការបោះពុម្ពស្នាដៃបន្ថែមទៀត ដើម្បីធ្វើឱ្យធនធានសម្រាប់អំណានកាន់តែសម្បូរបែប ជាពិសេសធនធានអំណានជាភាសាខ្មែរ (១១ មីនា ២០២៤)

-គ្រឹះស្ថានសិក្សា មណ្ឌលសិក្សា ទីវត្តអារាមទាំងអស់ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបង្កើតបណ្ណាល័យ ឬជ្រុងអំណាន ដើម្បីឱ្យសិស្សានុសិស្ស និស្សិត សាមណសិស្ស សាមណនិស្សិត អាចទទួលបាន និងស្វែងរកប្រភពសម្រាប់អំណានកាន់តែសម្បូរបែប និងមានភាពបត់បែនឆ្លើយតបនឹងតម្រូវការអ្នកអាន (១១ មីនា ២០២៤)

យុវជនត្រូវតែមានគំនិតនាវានុវត្តន៍ និងការចេះច្នៃប្រតិដ្ឋ ហើយយុវជនក៏ត្រូវតែមានបំណិនខាងផ្នែកទំនាក់ទំនង ព្រោះទំនាក់ទំនងមានតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតជាបណ្តាញសង្គម ត្រង់ចំណុចនេះគេហៅបានថា មូលធនសង្គម ដែលជានាទៅការរួមរស់ជាមួយគ្នាដោយសុខសន្តិភាព(៣ តុលា ២០២២)។

# ឯកសារយោង


គួយ សុគាន, អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច, ឆ្នាំ២០១៥

គួយ សុគាន, វិធីសាស្ត្របង្រៀន និងរៀន, ឆ្នាំ២០១៦

ចាន់ វឌ្ឍសុផា, ចិត្តវិទ្យាអប់រំ, ឆ្នាំ២០០៥

ស៊ន សំណាង, «ការធ្វើខ្លួនជាពលរដ្ឋខ្មែរពិបាកជាងការធ្វើខ្លួនត្រឹមតែជាមនុស្សខ្មែរ, ឆ្នាំ២០១៨

ហង់ជួន ណារុន, កំណែទម្រង់កម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន, វិទ្យាស្ថានជាតិអប់រំ,២០២០

ហង់ ជួនណារ៉ុន កំណែទម្រង់សាលារៀន ឆ្នាំ២០២១

ហង់ជួន ណារ៉ុន, បរិវត្តកម្មឌីជីថលនៃការអប់រំបំណិនស.វទី២១,Sipar, ២០២១

រាជរដ្ឋាភិបាលកម្ពុជា,ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា,២០២១-២៣៥

អ.យ.ក, យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា,២០១៨-២០២៣

ក្រសួងអប់រំ ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេស ឆ្នាំ២០១៦

ក្រសួងអប់រំ, ផែនទីបង្ហាញផ្លូវការអប់រំនៅកម្ពុជាឆ្នាំ២០៣០

ក្រសួងអប់រំ, បំណិនផ្តល់ព័ត៌មានត្រឡប់,នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ឆ្នាំ២០១៦

ក្រសួងអប់រំ, ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០ ឆ្នាំ២០២១

ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ឆ្នាំ២០១០ ទំ៣។

ក្រសួងអប់រំ យុវជន និងកីឡា ស្តង់ដាវិជ្ជាជីវៈគ្រូឧទ្ទេស ឆ្នាំ២០២២ ទំ១១។

ក្រសួងអប់រំ សៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈនៅតាមគ្រឹះស្ថានសិក្សាសាធារណៈឆ្នាំ២០២១

ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា២០៣០,២០២១

កម្មវិធីសាលាជំនាន់ថ្មី, ការសិក្សាតាមបែបស្ថាបនានិយម, ឆ្នាំ២០២០

UNESCO, Global Citizenship Education: An Emerging Perspective, 2013.

UNESCO, Curriculum/IBE_GlossaryCurriculumTerminolog.2013

Southeast Asia Teachers Competency Framework,2018


សាលាឌីជីថល
វគ្គសិក្សាមេរៀនជំនាញទន់
១ ការគ្រប់គ្រងពេលវេលា
២ ការទំនាក់ទំនង
៣ ការងារជាក្រុម
៤ ភាពជាអ្នកដឹកនាំ
៥ ការច្នៃប្រឌិត
youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews